ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រមនីតិវិធីព្រហ្មទណ្ឌ
# នៃ
# ព្រះរាជាណាចក្រកម្ពុជា



ក្រសួងយុត្តិធម៌

មាតិកា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌

## ចំណាប់អារម្មណ៍របស់
## ឯកឧត្តម អង្គ វង្ស វឌ្ឍនា
## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ក្រមនីតិវិធីព្រហ្មទណ្ឌនេះ ជាលទ្ធផលនៃការងារអស់រយៈពេលជិត ១០ ឆ្នាំ របស់ក្រសួងយុត្តិធម៌ ដែលបានរៀបចំឡើង ដោយមានជំនួយនៃសហប្រតិបត្តិការបារាំង ។ ចាប់ពីឆ្នាំ ១៩៩៤ មក ក្រសួងយុត្តិធម៌ បានចាប់ផ្តើមរៀបចំកែសម្រួលនីតិវិធីព្រហ្មទណ្ឌ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រទេសកម្ពុជា ដែលចង់បានក្រមនីតិវិធីព្រហ្មទណ្ឌមួយច្បាស់លាស់ និងពេញលេញ ព្រោះថានីតិវិធីព្រហ្មទណ្ឌ ជាអត្ថបទច្បាប់ដ៏ចំបង និងជាមធ្យោបាយដ៏សំខាន់របស់តុលាការព្រហ្មទណ្ឌ ។

ក្នុងការរៀបចំក្រម ចាំបាច់ត្រូវប្រមូលផ្តុំនូវអត្ថបទទាំងឡាយដែលរាយប៉ាយ ដើម្បីធ្វើឱ្យមានភាពងាយស្រួលក្នុងស្វែងយល់ ដោយរៀបចំឱ្យមានលក្ខណៈឯកភាព និងស៊ីសង្វាក់គ្នា ។ ក្រសួងយុត្តិធម៌បានប្រកាន់យកគោលការណ៍នៃច្បាប់ចុះថ្ងៃទី ៨ មីនា ១៩៩៣ ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលមានគោលដៅធានានិរន្តភាពនៃស្ថាប័ន ស្របតាមប្រពៃណីច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា ហើយផ្តល់ទៅឱ្យចៅក្រមស៊ើបសួរ នូវតួនាទីដ៏ចំបងក្នុងដំណាក់កាលនៃការស៊ើបសួរ និងការស្វែងរកភស្តុតាង ។ ក្រមនេះបានបញ្ជាក់យ៉ាងច្បាស់លាស់ អំពីគោលការណ៍ដើម្បីធានាប្រសិទ្ធភាពក្នុងការស្វែងរកជនល្មើស ការចោទប្រកាន់ និងការជំនុំជំរះ ព្រមទាំងការគោរពនូវសេរីភាពបុគ្គល ស្របតាមគោលការណ៍ដែលបានកំណត់ដោយរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា និងអនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី មានជាអាទិ៍: សេចក្តីថ្លែងការណ៍សកលស្តីពីសិទ្ធិមនុស្ស ឆ្នាំ ១៩៤៨, កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ ១៩៦៦...) ។

ក្រមនីតិវិធីព្រហ្មទណ្ឌនេះ ត្រូវបានរដ្ឋសភាអនុម័តដោយសំលេង ៨៣/៨៣ នៅថ្ងៃទី ៧ ខែមិថុនា ឆ្នាំ ២០០៧ ហើយត្រូវបាន ព្រឹទ្ធសភាអនុម័ត ដោយសំលេង ៥១/៥១ នៅថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៧ ។ ការអនុម័តក្រមនេះ ជាសក្ខីភាពមួយនៃសមិទ្ធកម្មក្នុងការកសាងក្របខណ្ឌច្បាប់ ស្របតាមគោលនយោបាយកំណែទម្រង់ប្រព័ន្ធច្បាប់ និងតុលាការ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមកិច្ចដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន** ។

នៅក្នុងសង្គមខ្មែរយើងសព្វថ្ងៃ ប្រជាពលរដ្ឋស្ទើរគ្រប់រូប សុទ្ធតែយល់ថា ជាការចាំបាច់ណាស់ដែលត្រូវធ្វើឱ្យមានការយល់ដឹងអំពីវិធាននៃច្បាប់ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្ត ។ ព្រោះថាគ្រប់សង្គមក្នុងសម័យទំនើបទាំងអស់ សុទ្ធតែត្រូវប្រឈមមុខនឹងការយល់ដឹង និងការផ្សព្វផ្សាយច្បាប់ ដើម្បីដឹកនាំគ្រប់គ្រងធានាឱ្យមានសន្តិភាពសង្គម ធ្វើឱ្យមានសុវត្ថិភាពក្នុងប្រតិបត្តិការពាណិជ្ជកម្មជាលក្ខណៈជាតិ និងអន្តរជាតិ ។ ហើយនៅក្នុងឱកាសដែលរូបខ្ញុំ និងសហការីនៃក្រសួងយុត្តិធម៌តំណាងឱ្យរាជរដ្ឋាភិបាលដើម្បីការពារសេចក្តីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌ នៅរដ្ឋសភា នាសម័យប្រជុំលើកទី ៦ នីតិកាលទី ៣ ក៏មានតំណាងរាស្ត្រជាច្រើនបានលើកឡើងអំពីសារៈសំខាន់ និងភាពចាំបាច់ក្នុងការអប់រំ និងផ្សព្វផ្សាយច្បាប់ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្ត ដោយបានស្នើសុំឱ្យក្រសួងយុត្តិធម៌ធ្វើការអប់រំ និងផ្សព្វផ្សាយក្រមនេះ ដល់មន្ត្រីអនុវត្តច្បាប់ និងប្រជាពលរដ្ឋ ឱ្យបានទូលំទូលាយ ។

ជាការពិតណាស់ ការបោះពុម្ពផ្សព្វផ្សាយជាទៀងទាត់ នូវអត្ថបទគតិយុត្ត នៅគ្រប់ពេលដែលត្រូវបានអនុម័ត ជាតំណាក់កាលមួយដែលអនុញ្ញាតឱ្យស្ថាបនានូវប្រព័ន្ធប្រជាធិបតេយ្យ និងនីតិរដ្ឋមួយស្របតាមស្មារតីនៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។

ដោយយល់ឃើញអំពីភាពចាំបាច់ និងសារៈសំខាន់នៃការអប់រំផ្សព្វផ្សាយច្បាប់ ក្នុងការធានាប្រសិទ្ធភាពនៃការអនុវត្តច្បាប់ លើកកំពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋ ព្រមទាំងការពង្រឹងនីតិរដ្ឋផងក្រសួងយុត្តិធម៌ ដែលជាសេនាធិការឱ្យរាជរដ្ឋាភិបាលលើវិស័យនេះ បានរៀបចំធ្វើការបោះពុម្ពក្រមនីតិវិធីព្រហ្មទណ្ឌនេះ ដោយមានការជួយគាំទ្រពីសហប្រតិបត្តិការបារាំង ដើម្បីចែកជូនដល់អ្នកវិជ្ជា-ជីវៈច្បាប់ តុលាការ និងមន្ត្រីអនុវត្តច្បាប់ ឱ្យបានទូលំទូលាយ ។

ក្រសួងយុត្តិធម៌មានជំនឿយ៉ាងមុតមាំថា ក្រមនីតិវិធីព្រហ្មទណ្ឌនេះ នឹងក្លាយជាឧបករណ៍ដ៏សំខាន់មួយ សម្រាប់ការបណ្តុះបណ្តាល និងអប់រំផ្សព្វផ្សាយច្បាប់ ក៏ដូចជាការចូលរួមចំណែកលើកកំពស់នូវសិទ្ធិទទួលព័ត៌មានអំពីច្បាប់ និងសិទ្ធិទទួលបានយុត្តិធម៌ នៅព្រះរាជាណាចក្រកម្ពុជា ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៧

**អង្គ វង្ស វឌ្ឍនា**

នស/រកម/០៨០៧/០២៤

# ព្រះរាជក្រម

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមនីតិវិធីព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៣ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

34/2007

# ក្រមនីតិវិធីព្រហ្មទណ្ឌ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
35/240

# គន្ថីទី ១

# បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី

## មាតិកាទី ១

## គោលការណ៍ទូទៅ

### ជំពូកទោល

### គោលការណ៍ទូទៅ

**មាត្រា ១.–** គោលបំណងនៃក្រមនីតិវិធីព្រហ្មទណ្ឌ

ក្រមនីតិវិធីព្រហ្មទណ្ឌ មានគោលបំណងកំណត់អំពីវិធានទាំងឡាយដែលត្រូវគោរព និង ប្រព្រឹត្តតាម ដោយហ្មត់ចត់ ដើម្បីកំណត់ឱ្យច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយ ។

បទប្បញ្ញត្តិនៃក្រមនេះត្រូវយកទៅអនុវត្តចំពោះរឿងព្រហ្មទណ្ឌ កាលណាពុំមានវិធាន ដោយឡែកចែងដោយច្បាប់ពិសេសទេនោះ ។

**មាត្រា ២.–** បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី

បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណីគឺជាបណ្តឹងពីរផ្សេងគ្នា ។

បណ្តឹងអាជ្ញា មានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឱ្យឃើញពិរុទ្ធភាពនៃជន ល្មើស និងផ្តន្ទាទោសជននេះតាមច្បាប់កំណត់ ។

បណ្តឹងរដ្ឋប្បវេណី មានគោលបំណងធ្វើឱ្យបានជួសជុលការខូចខាត ដែលបណ្តាលមកពី អំពើល្មើសដល់ភាគីរងគ្រោះ ហើយក្នុងគោលបំណងនេះ ឱ្យអ្នករងគ្រោះបានទទួលសំណងជម្ងឺ ចិត្តធួនល្មមនឹងព្យសនកម្មដែលខ្លួនបានទទួល ។

## មាតិកាទី ២

## បណ្តឹងអាជ្ញា

### ជំពូកទោល

### បណ្តឹងអាជ្ញា

**មាត្រា ៣.–** កម្មវត្ថុនៃបណ្តឹងអាជ្ញា

បណ្តឹងអាជ្ញាអនុវត្តទៅលើបុគ្គលគ្រប់រូប ទាំងរូបវន្តបុគ្គល ទាំងនីតិបុគ្គល ដោយឥតប្រកាន់ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ឋានៈសង្គម ធនធាន ឬ ស្ថានភាពឯទៀតឡើយ ។

**មាត្រា ៤.–** ការចាប់ផ្តើមដំណើរការនៃបណ្តឹងអាជ្ញាដោយអយ្យការ

បណ្តឹងអាជ្ញាត្រូវអនុវត្តក្នុងនាមនៃផលប្រយោជន៍ទូទៅដោយអយ្យការ ។

អយ្យការធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិ-ការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ ។

**មាត្រា ៥.–** ការដាក់បណ្តឹងអាជ្ញាឱ្យមានចលនាដោយជនរងគ្រោះ

ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬ បទមជ្ឈិម អាចដាក់ពាក្យប្តឹងដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរ ។ ពាក្យប្តឹងដោយមានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្ប-វេណី មានអានុភាពប្តឹងដល់ចៅក្រមស៊ើបសួរ អំពីបណ្តឹងអាជ្ញានៅក្នុងលក្ខខណ្ឌដែលបញ្ញត្តិដោយមាត្រា ១៣៩ (ការបញ្ជូនបណ្តឹងទៅព្រះរាជអាជ្ញា) និងមាត្រា ១៤០ (ការបង់ប្រាក់តម្កល់ទុក) នៃក្រមនេះ ។

យុត្តាធិការព្រហ្មទណ្ឌក៏អាចទទួលបណ្តឹងពីមន្ត្រីរាជការ ឬ ភ្នាក់ងារសាធារណៈដទៃទៀតដែលច្បាប់ដោយឡែកបានប្រគល់អំណាចឱ្យផងដែរ ។

**មាត្រា ៦.–** ការដាក់ពាក្យប្តឹងទាមទារដោយជនរងគ្រោះ

បុគ្គលគ្រប់រូបដែលប្រកាសថា ខ្លួនជាអ្នករងគ្រោះនៃបទល្មើស អាចដាក់ពាក្យប្តឹងបាន ។ ពាក្យប្តឹងសាមញ្ញ គ្មានអានុភាពនាំឱ្យធ្វើការចោទប្រកាន់ជាបទព្រហ្មទណ្ឌទេ ។

នៅក្នុងករណីដែលពាក្យប្តឹងស្ថិតនៅដោយគ្មានចម្លើយ ឬ ត្រូវបានតម្កល់ទុកឥតចាត់ការដោយព្រះរាជអាជ្ញា ជនរងគ្រោះអាចប្តឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ទៅតាមរបៀបដូចដែលមានចែងទុកដោយមាត្រា ៤១ (ការតម្កល់រឿងទុកឥតចាត់ការ) នៃក្រមនេះ ។

**មាត្រា ៧.–** ការរលត់នៃបណ្តឹងអាជ្ញា

មូលហេតុនៃការរលត់បណ្តឹងអាជ្ញាមានដូចតទៅគឺ :

១-មរណភាពនៃជនល្មើស ។

២-ការផុតអាជ្ញាយុកាល ។

៣-ការលើកលែងទោសជាទូទៅ ។

៤-និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ ។

៥-អាជ្ញាអស់ជំនុំ ។

កាលណាបណ្តឹងអាជ្ញាត្រូវផុតរលត់ហើយ ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌមិនអាចចាប់ផ្តើមបានទៀតទេ ឬ ត្រូវតែបញ្ឈប់ ។

**មាត្រា ៨.–** មូលហេតុផ្សេងទៀតនៃការរលត់បណ្តឹងអាជ្ញា

កាលណាច្បាប់ដោយឡែកបានចែងដោយជាក់លាក់ នោះបណ្តឹងអាជ្ញាក៏អាចផុតរលត់បានដែរ :

១-ដោយការសម្រុះសម្រួលជាមួយរដ្ឋ ។

២-ដោយការដកពាក្យប្តឹង នៅក្នុងករណីដែលពាក្យប្តឹងនេះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ ។

៣-ដោយការបង់ប្រាក់ពិន័យសរុប ឬ ប្រាក់ពិន័យសម្រុះសម្រួល ។

**មាត្រា ៩.–** ឧក្រិដ្ឋកម្មដែលគ្មានអាជ្ញាយុកាលកំណត់

បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាមមិនអាចផុតអាជ្ញាយុកាលបានទេ ។

**មាត្រា ១០.–** អាជ្ញាយុកាលនៃបទល្មើស

លើកលែងតែបទប្បញ្ញត្តិនៃមាត្រា ៩ (ឧក្រិដ្ឋកម្មដែលគ្មានអាជ្ញាយុកាលកំណត់) នៃក្រមនេះចេញ ថិរវេលានៃអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាមានដូចតទៅគឺ :

-១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ

-៥ (ប្រាំ) ឆ្នាំ ចំពោះបទមជ្ឈិម

-១ (មួយ) ឆ្នាំ ចំពោះបទលហុ

**មាត្រា ១១.–** ការផ្តាច់រយៈពេលនៃអាជ្ញាយុកាល

ថិរវេលានៃអាជ្ញាយុកាល ត្រូវចាប់ផ្តើមគិតពីពេលប្រព្រឹត្តបទល្មើស ។ អាជ្ញាយុកាលត្រូវផ្តាច់ ដោយគ្រប់កិច្ចនៃការចោទប្រកាន់ ឬ កិច្ចស៊ើបសួរ ។ ការបញ្ចប់កិច្ចចោទប្រកាន់ ឬ កិច្ចស៊ើបសួរនីមួយៗ នាំឱ្យចាប់ផ្តើមគិតថិរវេលាថ្មីនៃអាជ្ញាយុកាល តាមការវែកញែកនៃមាត្រា ១០ (អាជ្ញាយុកាលនៃបទល្មើស) នៃក្រមនេះ ។ ថិរវេលាថ្មីអាចយកទៅជំទាស់បាន ចំពោះជនគ្រប់រូបដែលទាក់ទិននៅក្នុងរឿងនេះ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL



38/240

**មាត្រា ១២.–** អាជ្ញាអស់ជំនុំ

ដោយអនុវត្តតាមគោលការណ៍អាជ្ញាអស់ជំនុំ ជនណាដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេចំពោះអំពើដដែល ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ ។

## មាតិកាទី ៣

## បណ្តឹងរដ្ឋប្បវេណី

## ជំពូកទោល

## បណ្តឹងរដ្ឋប្បវេណី

**មាត្រា ១៣.–** បណ្តឹងរដ្ឋប្បវេណី និងព្យសនកម្ម

បណ្តឹងរដ្ឋប្បវេណីត្រូវអនុវត្តដោយជនរងគ្រោះនៃបទល្មើស ។

ដើម្បីទទួលការជួសជុលបាន ព្យសនកម្មត្រូវតែ :

- ជាផលវិបាកផ្ទាល់នៃបទល្មើស
- ជាព្យសនកម្មផ្ទាល់ខ្លួន
- បានកើតឡើង និងនៅក្នុងពេលបច្ចុប្បន្ន ។

ព្យសនកម្មអាចជាព្យសនកម្មខាងសម្ភារៈ ខាងរូបកាយ ឬ ខាងផ្លូវចិត្ត ។

**មាត្រា ១៤.–** ការជួសជុលព្យសនកម្ម

ព្យសនកម្មអាចត្រូវបានជួសជុល ដោយការបង់ជម្ងឺចិត្ត ដោយការសងទៅជនរងគ្រោះវិញនូវទ្រព្យសម្បត្តិដែលបានបាត់បង់ ឬ ដោយការធ្វើឱ្យដូចសភាពដើមវិញនូវទ្រព្យដែលគេបានបំផ្លិចបំផ្លាញ ឬ ធ្វើឱ្យខូចខាត ។

សំណងជម្ងឺចិត្តត្រូវតែមានលក្ខណៈធួនល្មមជាមួយនឹងព្យសនកម្មដែលទទួលរង ។

**មាត្រា ១៥.–** ដើមបណ្តឹងរដ្ឋប្បវេណី

បណ្តឹងរដ្ឋប្បវេណី អាចត្រូវធ្វើឡើងក្នុងនាមជនរងគ្រោះបាន ដោយអ្នកតំណាងស្របច្បាប់របស់ខ្លួន កាលណាជនរងគ្រោះនេះជាអនីតិជន ឬ ជានីតិជនស្ថិតនៅក្រោមរបបច្បាប់ការពារ ។

ROYAUME DU CAMBODGE MINISTERE DU PALAIS ROYAL



39/240

**មាត្រា ១៦.–** បណ្ដឹងរដ្ឋប្បវេណីរបស់សិទ្ធិវន្តនៃជនរងគ្រោះ

ក្នុងករណីមរណភាពនៃជនរងគ្រោះ បណ្ដឹងរដ្ឋប្បវេណីអាចត្រូវបានផ្ដើមធ្វើ ឬ បន្តបាន ដោយសិទ្ធិវន្ត ។

**មាត្រា ១៧.–** សមាគមប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាខាងផ្លូវភេទ អំពើហិង្សាក្នុងគ្រួសារ ឬ អំពើហិង្សាប្រឆាំងនឹងកុមារ

គ្រប់សមាគមដែលបានប្រកាសដោយត្រឹមត្រូវ យ៉ាងតិចបំផុតតាំងពី ៣ (បី) ឆ្នាំ មុនកាលបរិច្ឆេទនៃបទល្មើស ហើយដែលកម្មវត្ថុនៃលក្ខន្តិកៈរបស់ខ្លួនរួមមានការតស៊ូប្រឆាំងនឹងអំពើហិង្សាខាងផ្លូវភេទ ឬ អំពើហិង្សាក្នុងគ្រួសារ ឬ អំពើហិង្សាប្រឆាំងនឹងកុមារ នោះអាចប្រើប្រាស់សិទ្ធិដែលទទួលស្គាល់ដល់ដើមបណ្ដឹងរដ្ឋប្បវេណី ចំពោះប្រភេទបទល្មើសដូចតទៅ :

-ការបៀតបៀនដោយចេតនាដល់អាយុជីវិត

-ការបៀតបៀនដល់បូរណភាពនៃបុគ្គល

-ការបៀតបៀនខាងផ្លូវភេទ ។

**មាត្រា ១៨.–** សមាគមប្រយុទ្ធប្រឆាំងនឹងការចាប់ពង្រត់ ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ

គ្រប់សមាគមដែលបានប្រកាសដោយត្រឹមត្រូវ យ៉ាងតិចបំផុតតាំងពី ៣ (បី) ឆ្នាំ មុនកាលបរិច្ឆេទនៃបទល្មើស ហើយដែលកម្មវត្ថុនៃលក្ខន្តិកៈរួមមានការតស៊ូប្រឆាំងនឹងការចាប់ពង្រត់ ឬ ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មខាងផ្លូវភេទ អាចប្រើប្រាស់សិទ្ធិដែលទទួលស្គាល់ដល់ដើមបណ្ដឹងរដ្ឋប្បវេណី ចំពោះបទល្មើសដែលបានបញ្ញត្តិដោយច្បាប់ ដែលពាក់ព័ន្ធនឹងការប្រឆាំងការចាប់ពង្រត់ ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ។

**មាត្រា ១៩.–** សមាគមប្រយុទ្ធប្រឆាំងនឹងការប្រកាន់ពូជសាសន៍ និងការរើសអើង

គ្រប់សមាគមដែលបានប្រកាសដោយត្រឹមត្រូវ យ៉ាងតិចបំផុតតាំងពី ៣ (បី) ឆ្នាំ មុនកាលបរិច្ឆេទនៃបទល្មើស ហើយដែលកម្មវត្ថុនៃលក្ខន្តិកៈរួមមានការតស៊ូប្រឆាំងនឹងការប្រកាន់ពូជ-សាសន៍ និងការឧបត្ថម្ភដល់ជនរងគ្រោះនៃការរើសអើងស្ដីពីដើមកំណើតជាតិ ជាតិពន្ធុ ពូជសាសន៍



40/249

សាសនា អាចប្រើប្រាស់សិទ្ធិដែលទទួលស្គាល់ដល់ដើមបណ្ដឹងរដ្ឋប្បវេណី ចំពោះបទល្មើសដូចបានកំណត់ខាងក្រោម កាលណាបទល្មើសនោះ ត្រូវបានប្រព្រឹត្តដោយមូលហេតុដើមកំណើតជាតិនៃបុគ្គលណាម្នាក់ ឬ ដោយមូលហេតុថា បុគ្គលនោះជាសមាជិកពិតប្រាកដ ឬ ដោយស្មាននៃជាតិពន្ធុ ពូជសាសន៍ ឬ សាសនាណាមួយជាកំណត់ :

-ការរើសអើង

-ការបៀតបៀនដោយចេតនា ដល់អាយុជីវិត ឬ ដល់បូរណភាពបុគ្គល

-ការបំផ្លាញ និងការធ្វើឱ្យខូចខាត ។

**មាត្រា ២០.-** ភាពដែលអាចទទួលយកបាននូវបណ្ដឹងរបស់សមាគម

នៅក្នុងករណីដែលបានចែងក្នុងមាត្រា ១៧ (សមាគមប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាខាងផ្លូវភេទ អំពើហិង្សាក្នុងគ្រួសារ ឬ អំពើហិង្សាប្រឆាំងនឹងកុមារ) ដល់មាត្រា ១៩ (សមាគមប្រយុទ្ធប្រឆាំងនឹងការប្រកាន់ពូជសាសន៍ និងការរើសអើង) នៃក្រមនេះ បណ្ដឹងរបស់សមាគមអាចទទួលយកបាន លុះត្រាតែមានភស្តុតាងបញ្ជាក់ថា បានទទួលការយល់ព្រមអំពីសិទ្ធិពីជនរងគ្រោះ ឬ អ្នកតំណាងស្របច្បាប់នៃជននេះ ។ ក្នុងករណីបៀតបៀនដល់អាយុជីវិត បណ្ដឹងរបស់សមាគមអាចទទួលយកបាន លុះត្រាតែសមាគមបានបង្ហាញភស្តុតាងបញ្ជាក់ថា បានទទួលការយល់ព្រមអំពីសិទ្ធិពីសិទ្ធិវន្តនៃជនរងគ្រោះ ។

**មាត្រា ២១.-** ចុងចម្លើយនៃបណ្ដឹងរដ្ឋប្បវេណី

បណ្ដឹងរដ្ឋប្បវេណី អាចធ្វើឡើងប្រឆាំងនឹងជនទាំងអស់ដែលត្រូវជួសជុលព្យសនកម្មបណ្ដាលមកពីបទល្មើសរួមមាន :

-ចារី សហចារីនៃបទល្មើស

-អ្នកផ្ដើមគំនិត អ្នកសមគំនិត

-អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ។

**មាត្រា ២២.-** ទំនាក់ទំនងសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌ និងតុលាការរដ្ឋប្បវេណី

បណ្ដឹងរដ្ឋប្បវេណី អាចធ្វើឡើងក្នុងពេលជាមួយគ្នានឹងបណ្ដឹងអាជ្ញា នៅចំពោះមុខសាលាជម្រះក្ដីព្រហ្មទណ្ឌ ។

ROYAUME DU CAMBODGE MINISTÈRE DU PALAIS ROYAL



41/240

បណ្តឹងរដ្ឋប្បវេណីក៏អាចធ្វើបានផងដែរនៅចំពោះមុខសាលាជម្រះក្តីរដ្ឋប្បវេណី ។ ក្នុងករណីនេះ បណ្តឹងរដ្ឋប្បវេណីអាចត្រូវព្យួរសិន ដរាបណាមិនទាន់មានសេចក្តីសម្រេចជាស្ថាពរមួយ ត្រូវបានប្រកាសលើបណ្តឹងអាជ្ញា ។

**មាត្រា ២៣.-** ការប្រកាសជាមុនអំពីពិរុទ្ធភាព

តុលាការព្រហ្មទណ្ឌនឹងអាចសម្រេចការផ្តួសជុលព្យសនកម្មបាន លុះត្រាតែបានពិនិត្យជាមុនអំពីធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ ហើយបានប្រកាសថា ជនជាប់ចោទត្រូវមានពិរុទ្ធជាមុនសិន ។

**មាត្រា ២៤.-** មរណភាពរបស់ជនជាប់ចោទ

ដើមបណ្តឹងរដ្ឋប្បវេណី អាចសុំឱ្យមានការជួសជុលព្យសនកម្មពីសិទ្ធិវន្តនៃជនជាប់ចោទបាន ប្រសិនបើជនជាប់ចោទនេះ ទទួលមរណភាពនៅក្នុងពេលដំណើរការរឿងក្តីព្រហ្មទណ្ឌ ។ ថ្វីត្បិតតែបណ្តឹងអាជ្ញាត្រូវរលត់ តុលាការព្រហ្មទណ្ឌនៅតែមានសមត្ថកិច្ច ដើម្បីសម្រេចលើបណ្តឹងរដ្ឋប្បវេណីដែលធ្វើឡើងប្រឆាំងនឹងសិទ្ធិវន្តទាំងនោះ ។

**មាត្រា ២៥.-** ការលះបង់ និងការដកពាក្យប្តឹងរបស់ជនរងគ្រោះ

ជនរងគ្រោះអាចលះបង់មិនធ្វើបណ្តឹងសុំទាមទារសំណង ឬ ដកពាក្យប្តឹងរបស់ខ្លួន ។ ការលះបង់មិនប្តឹង និងដកពាក្យប្តឹងរបស់ជនរងគ្រោះ មិនអាចបញ្ឈប់ ឬព្យួរការអនុវត្តនៃបណ្តឹងអាជ្ញាបានទេ លើកលែងបញ្ញត្តិចំណុចទី ២ នៃមាត្រា ៨ (មូលហេតុផ្សេងទៀតនៃការរលត់បណ្តឹងអាជ្ញា) នៃក្រមនេះ ។

**មាត្រា ២៦.-** អាជ្ញាយុកាលនៃបណ្តឹងរដ្ឋប្បវេណី

បណ្តឹងរដ្ឋប្បវេណីត្រូវផុតអាជ្ញាយុកាលតាមវិធាននៃក្រមរដ្ឋប្បវេណី ។ ប៉ុន្តែបណ្តឹងរដ្ឋប្បវេណីនេះមិនអាចធ្វើបានទៀតទេនៅមុខតុលាការព្រហ្មទណ្ឌ ក្រោយការផុតថិរវេលានៃអាជ្ញាយុកាលរបស់បណ្តឹងអាជ្ញា ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL



42/240

# គន្ថីទី ២

# អាជ្ញាធរទទួលបន្ទុកចោទប្រកាន់ ស៊ើបសួរ និងស៊ើបអង្កេត

## មាតិកាទី ១

## អង្គការអយ្យការ

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ២៧.–** តួនាទីរបស់អង្គការអយ្យការ

អង្គការអយ្យការ ធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឱ្យតុលាការអនុវត្តច្បាប់ ។ អង្គការអយ្យការធានារ៉ាប់រងការអនុវត្តសេចក្តីសម្រេចខាងបទព្រហ្មទណ្ឌ ព្រមទាំងធានាយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួន ។

ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ចៅក្រមអយ្យការ មានសិទ្ធិកេណ្ឌកងកម្លាំងសាធារណៈដោយផ្ទាល់ជាជំនួយ ។

ចៅក្រមអយ្យការ ត្រូវតែមានវត្តមាននៅក្នុងពេលសវនាការរឿងព្រហ្មទណ្ឌ ។

**មាត្រា ២៨.–** ចៅក្រមអយ្យការ

ចៅក្រមអយ្យការមាន :

១-អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល ។

២-អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

៣-ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមសាលាដំបូង ។

**មាត្រា ២៩.–** ឋានានុក្រមនៃអង្គការអយ្យការ

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចប្តឹងបរិហារទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬ ព្រះរាជអាជ្ញាអមសាលាដំបូង អំពីបទល្មើសដែលខ្លួនបានដឹង អាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរដែលត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង ឱ្យអគ្គព្រះរាជអាជ្ញា ឬ ព្រះរាជអាជ្ញា ធ្វើការចោទប្រកាន់ ឬ ធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមការដែលរដ្ឋមន្ត្រីយល់ឃើញថាជាការគួរ ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មិនអាចធ្វើអធិបញ្ញាដល់អគ្គព្រះរាជអាជ្ញា ឬ ព្រះរាជអាជ្ញា ឱ្យធ្វើការតម្កល់ទុកឥតចាត់ការនូវរឿងក្តីព្រហ្មទណ្ឌណាមួយបានឡើយ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL



43/240

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានអំណាចលើចៅក្រមអយ្យការទាំងអស់ ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន ។ អគ្គព្រះរាជអាជ្ញាអាចធ្វើអធិបញ្ញាឱ្យចោទប្រកាន់ ឬ ក៏ចាត់ឱ្យចោទប្រកាន់ ឬ ក៏ធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាដែលខ្លួនយល់ឃើញថាជាការគួរ ។

ព្រះរាជអាជ្ញាមានអំណាចទៅលើចៅក្រមអយ្យការដែលនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន ។

ព្រះរាជអាជ្ញាអាចធ្វើអធិបញ្ញាឱ្យចៅក្រមអយ្យការធ្វើការចោទប្រកាន់ ឬ ក៏ចាត់ឱ្យចោទប្រកាន់ ឬ ក៏ធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមដែលខ្លួនយល់ឃើញថាជាការគួរ ។

**មាត្រា ៣០.-** បណ្តឹងដោយផ្ទាល់មាត់

ចៅក្រមអយ្យការគ្រប់រូបត្រូវគោរពតាមអធិបញ្ញាថ្នាក់លើរបស់ខ្លួនតាមឋានានុក្រម ។

ប៉ុន្តែ នៅពេលសវនាការ ចៅក្រមអយ្យការធ្វើការកត់សំគាល់ផ្ទាល់មាត់ដោយសេរីតាមការដែលខ្លួនយល់ឃើញថា ស្របទៅតាមសតិសម្បជញ្ញៈរបស់ខ្លួន ។ គ្មានការចោទប្រកាន់ខាងវិន័យណាមួយដែលអាចត្រូវធ្វើចំពោះចៅក្រមអយ្យការ ដោយសារតែវាចារបស់ខ្លួនដែលបានបញ្ចេញនៅពេលសវនាការនោះឡើយ ។

## ជំពូកទី ២
## មុខការរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

**មាត្រា ៣១.-** ការតំណាងនៃអង្គការអយ្យការអមតុលាការកំពូល

អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល គឺជាតំណាងនៃអង្គការអយ្យការអមតុលាការនេះ ។

**មាត្រា ៣២.-** តួនាទីរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ចូលរួមក្នុងការសុំឱ្យមានការគោរពច្បាប់ នៅក្នុងពេលដែលមានបណ្តឹងសាទុក្ខ បណ្តឹងសើរើ និងបណ្តឹងតវ៉ាផ្សេងៗទៀត ដែលដាក់ជូនតុលាការកំពូលពិនិត្យ ។



44/24

## ជំពូកទី ៣
## មុខការរបស់អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍

**មាត្រា ៣៣.-** ការតំណាងនៃអង្គការអយ្យការអមសាលាឧទ្ធរណ៍

អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ គឺជាតំណាងនៃអង្គការអយ្យការអមតុលាការនេះ ។

**មាត្រា ៣៤.-** តួនាទីរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឃ្លាំមើលការអនុវត្តច្បាប់ នៅក្នុងសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍ ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចធ្វើអធិការកិច្ចនៅអង្គការអយ្យការទាំងឡាយដែលនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន ។

ក្នុងករណីមានបទល្មើសធ្ងន់ធ្ងរ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៣៥.-** អំណាចរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ធ្វើការឃ្លាំមើល និងធ្វើការត្រួតពិនិត្យនគរបាលយុត្តិធម៌ ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចកោះអញ្ជើញអ្នកទទួលខុសត្រូវនៃអង្គភាពនគរ-បាលយុត្តិធម៌ ដើម្បីពិភាក្សាអំពីបញ្ហាដែលទាក់ទងនឹងការប្រព្រឹត្តិទៅរបស់អង្គភាពនគរបាលទាំងនេះ ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចប្រគល់ភារកិច្ចដល់មន្ត្រី ឬ ភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់ ឱ្យបំពេញកិច្ចទាំងឡាយដែលខ្លួនយល់ឃើញថា មានប្រយោជន៍ដល់ការគ្រប់គ្រង ឬ ដំណើរការដ៏ល្អនៃនគរបាលយុត្តិធម៌ ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចធ្វើអធិការកិច្ចគ្រប់ពេលវេលានៅអង្គភាពនគរ-បាលយុត្តិធម៌ ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចចូលរួមក្នុងការស្តាប់ចម្លើយ អាចត្រួតពិនិត្យ ការអនុវត្តវិធានការឃាត់ខ្លួន ជាពិសេសគឺការគោរពទម្រង់ការច្បាប់ និងការកាន់កាប់គ្រប់គ្រងកន្លែងឃាត់ខ្លួន ។



45/24

ប្រធានអង្គភាពនគរបាលយុត្តិធម៌ មន្ត្រីនគរបាលយុត្តិធម៌ ឬ ភ្នាក់ងារនគរបាលយុត្តិធម៌ គ្រប់រូបត្រូវគោរពតាមអធិបញ្ញារបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

## ជំពូកទី ៤
## មុខការរបស់ព្រះរាជអាជ្ញាអមសាលាដំបូង
## ផ្នែកទី ១
## អង្គការអយ្យការអមសាលាដំបូង

**មាត្រា ៣៦.–** ការតំណាងអង្គការអយ្យការអមសាលាដំបូង

ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមសាលាដំបូង ជាតំណាងអង្គការអយ្យការអមតុលាការនេះ ។

**មាត្រា ៣៧.–** អំណាចរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់ នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន ។ ប៉ុន្តែ កាលណាអនុវត្តដីកាសម្រេចចាត់ឱ្យ ស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ ។

ព្រះរាជអាជ្ញាប្រើប្រាស់អំណាចទាំងអស់ដែលក្រមនេះបានទទួលស្គាល់ ឱ្យដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត ។

ព្រះរាជអាជ្ញាអាចចុះទៅកាន់កន្លែងស៊ើបអង្កេត និងធ្វើគ្រប់ការណែនាំដែលមានប្រយោជន៍ ដល់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ ។ ក្នុងករណីចាំបាច់ពិសេស ព្រះរាជអាជ្ញាអាចដកសិទ្ធិស៊ើបអង្កេតពីមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ និងរៀបចំជំនួសមន្ត្រី និងភ្នាក់ងារនេះ ។

ព្រះរាជអាជ្ញាអាចធ្វើអធិការកិច្ចបានគ្រប់ពេលវេលា នៅអង្គភាពនគរបាលយុត្តិធម៌ ។ ព្រះរាជអាជ្ញាអាចចូលរួមក្នុងការស្តាប់ចម្លើយ អាចត្រួតពិនិត្យការអនុវត្តវិធានការឃាត់ខ្លួន ជាពិសេសគឺការគោរពទម្រង់ច្បាប់ និងការកាន់កាប់ទីកន្លែងឃាត់ខ្លួន ។

**មាត្រា ៣៨.–** អំណាចរបស់ព្រះរាជអាជ្ញារង

ព្រះរាជអាជ្ញារងដែលស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញា ប្រើប្រាស់អំណាចទាំងអស់ដែលព្រះរាជអាជ្ញាមាន ក្នុងការស្រាវជ្រាវ និងការចោទប្រកាន់បទល្មើស ។



46/240 R

**មាត្រា ៣៩.–** សមត្ថកិច្ចតាមដែនដីរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចគឺ :

-ព្រះរាជអាជ្ញានៃទីកន្លែងដែលមានការប្រព្រឹត្តិបទល្មើស

-ព្រះរាជអាជ្ញានៃទីលំនៅរបស់ជនដែលគេសង្ស័យថា បានប្រព្រឹត្តបទល្មើស

-ព្រះរាជអាជ្ញានៃទីកន្លែងចាប់ខ្លួនជនដែលត្រូវបានសង្ស័យថា បានប្រព្រឹត្តបទល្មើស ។

## ផ្នែកទី ២

## ការអនុវត្តបណ្តឹងអាជ្ញា

**មាត្រា ៤០.–** ជម្រើសនៃការចោទប្រកាន់

ព្រះរាជអាជ្ញាថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យប្តឹង និងពាក្យបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ ឬ ដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក ។

ព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬ ធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ។ មុននឹងសម្រេចព្រះរាជអាជ្ញាបើកការស៊ើបអង្កេតបឋម ឬ បង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែម ។

ក្នុងករណីមានបទល្មើសធ្ងន់ធ្ងរ ព្រះរាជអាជ្ញារាយការណ៍ជូនអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលត្រូវរាយការណ៍បន្តជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៤១.–** ការតម្កល់រឿងទុកឥតចាត់ការ

កាលណាបណ្តឹងណាមួយត្រូវបានតម្កល់ទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវឱ្យដំណឹងដល់អ្នកប្តឹងអំពីសេចក្តីសម្រេចរបស់ខ្លួន នៅក្នុងរយៈពេលយ៉ាងខ្លីបំផុត ហើយយ៉ាងយូរបំផុតរយៈពេល ២ (ពីរ) ខែ គិតពីថ្ងៃចុះពាក្យប្តឹងក្នុងបញ្ជីដែលមានចែងក្នុងមាត្រា ៥០(បញ្ជីនៃពាក្យប្តឹង) នៃក្រមនេះ ។

ការតម្កល់រឿងទុកឥតចាត់ការ ត្រូវតែមានសំអាងច្បាប់ និងសំអាងហេតុ ។ ការតម្កល់ទុកឥតចាត់ការនេះគ្មានអាជ្ញាអស់ជំនុំទេ ។

ព្រះរាជអាជ្ញាអាចសើរើកែប្រែសេចក្តីសម្រេចរបស់ខ្លួនវិញ ក្នុងខណៈដែលបណ្តឹងអាជ្ញាមិនទាន់ផុតរលត់នៅឡើយ ។

ប្រសិនបើអ្នកប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការទេ សាមីខ្លួនអាចធ្វើការតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បាន ។

ការតវ៉ានេះត្រូវធ្វើនៅក្នុងរយៈពេល ២ (ពីរ) ខែ គិតពីថ្ងៃទទួលដំណឹងអំពីសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ ។ ការតវ៉ានេះត្រូវធ្វើតាមបណ្តឹងសាមញ្ញ នៅអង្គការអយ្យការដែលពាក់ព័ន្ធ ។ បន្ទាប់មកសំណុំរឿងត្រូវបានបញ្ជូនភ្លាម ទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ដោយតំណាងអយ្យការអមសាលាដំបូង ។

ប្រសិនបើយល់ឃើញថា ការតវ៉ានេះមានមូលហេតុត្រឹមត្រូវ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ចេញអធិបញ្ញាដល់ព្រះរាជអាជ្ញាអមសាលាដំបូង ឱ្យធ្វើការចោទប្រកាន់ ។ អគ្គព្រះរាជ-អាជ្ញាធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរ ។ នៅក្នុងករណីផ្ទុយពីនេះ អគ្គព្រះរាជ-អាជ្ញាអមសាលាឧទ្ធរណ៍ តម្កល់សេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាអមសាលាដំបូងទុកជាបានការ ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវឱ្យដំណឹងអំពីសេចក្តីសម្រេចនេះ ដល់អ្នកប្តឹងតវ៉ា ។

**មាត្រា ៤២.–** កាតព្វកិច្ចធ្វើបណ្តឹងបរិហារចំពោះបទឧក្រិដ្ឋ ឬ បទមជ្ឈិម

អាជ្ញាធរសាធារណៈ ឬ មន្ត្រីគ្រប់រូបដែលនៅក្នុងការបំពេញមុខងាររបស់ខ្លួន បានដឹងអំពីបទឧក្រិដ្ឋ ឬ បទមជ្ឈិម ត្រូវតែជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា ឬ ដល់មន្ត្រីនគរបាលយុត្តិធម៌ ដោយត្រូវបញ្ជូននូវព័ត៌មាន កំណត់ហេតុ លិខិត និងវត្ថុតាងទាំងអស់ ដែលទាក់ទងនឹងបទល្មើសនោះភ្ជាប់ជាមួយផង ។

មិនអាចមានការលើកលែងដទៃណា ក្រៅពីការលើកលែងស្តីអំពីអាថ៌កំបាំងខាងវិជ្ជាជីវៈ ក្នុងករណីដែលច្បាប់បានចែងយ៉ាងជាក់លាក់នោះទេ ។

**មាត្រា ៤៣.–** ការចោទប្រកាន់

ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌអាចធ្វើតាម :

- ការបើកធ្វើការស៊ើបសួរ
- ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ
- តាមនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ។

**មាត្រា ៤៤.–** ការបើកការស៊ើបសួរ

ក្នុងករណីបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ការស៊ើបសួរត្រូវបានបើកតាមដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ដែលត្រូវប្ដឹងទៅចៅក្រមស៊ើបសួរ ។ ការស៊ើបសួរអាចបើកប្រឆាំងលើបុគ្គលម្នាក់ ឬ ច្រើននាក់ ដោយមានចង្អុលប្រាប់ឈ្មោះ ឬ ប្រឆាំងទៅលើអញ្ញាតជន ។

ដីកាបញ្ជូនរឿងឱ្យស៊ើបសួររួមមាន :

-សេចក្ដីសង្ខេបនៃអង្គហេតុ

-ការកំណត់ឈ្មោះបទល្មើស

-ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស និង

-ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន ។

ដីកាបញ្ជូនរឿងឱ្យស៊ើបសួរត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា ។

ទម្រង់ការនេះមានលក្ខណៈដាច់ខាតត្រូវតែគោរព បើពុំដូច្នេះទេ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរនេះត្រូវទុកជាមោឃៈ ។

**មាត្រា ៤៥.–** ការចោទប្រកាន់ក្នុងករណីបទមជ្ឈិម

ក្នុងករណីបទមជ្ឈិម ព្រះរាជអាជ្ញាអាច :

-បើកការស៊ើបសួរដោយធ្វើដូចដែលបានចែងដោយមាត្រា ៤៤ (ការបើកការស៊ើបសួរ) នៃក្រមនេះ

-បញ្ជូនជនជាប់ចោទទៅជំនុំជម្រះផ្ទាល់ នៅមុខតុលាការជាន់ដំបូង ដោយធ្វើដូចបានចែងនៅក្នុងមាត្រា ៤៦ (ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់) នៃក្រមនេះ ឬ

-បង្គាប់ឱ្យនាំជនជាប់ចោទចូលបង្ហាញខ្លួនភ្លាមនៅមុខតុលាការជាន់ដំបូង ដោយធ្វើដូចដែលបានចែងក្នុងមាត្រា ៤៧ (ការបង្ហាញខ្លួនភ្លាម) និងមាត្រា ៤៨ (នីតិវិធីនៃការបង្ហាញខ្លួនភ្លាម) នៃក្រមនេះ ។

**មាត្រា ៤៦.–** ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជាបញ្ជាឱ្យជនជាប់ចោទចូលទៅបង្ហាញខ្លួននៅមុខតុលាការជាន់ដំបូង ។ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់រួមមាន :

-អត្តសញ្ញាណនៃជនជាប់ចោទ

-សេចក្ដីសង្ខេបនៃអង្គហេតុ

-ឈ្មោះបទល្មើស

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL



៤១/២៥០

-អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស ។

ដីកានេះត្រូវចង្អុលប្រាប់ពីតុលាការ ព្រមទាំងទីកន្លែង កាលបរិច្ឆេទ និងម៉ោងពេលនៃសវនាការ ។ ដីកានេះត្រូវបញ្ជាក់ថា ជនជាប់ចោទអាចពឹងមេធាវីឱ្យអមខ្លួនបាន ។

**មាត្រា ៤៧.–** ការបង្ហាញខ្លួនភ្លាម

ព្រះរាជអាជ្ញាអាចបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទចូលបង្ហាញខ្លួនភ្លាម នៅមុខតុលាការជាន់ដំបូង ប្រសិនបើមានគ្រប់លក្ខខណ្ឌដូចតទៅ :

-បទល្មើសជាបទល្មើសជាក់ស្តែង តាមអត្ថន័យនៃមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង) និងមាត្រា ៨៨ (ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង) នៃក្រមនេះ

-បទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច១ (មួយ) ឆ្នាំ និងយ៉ាងច្រើន៥ (ប្រាំ)ឆ្នាំ

-ជនជាប់ចោទជានីតិជន

-រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន ។

**មាត្រា ៤៨.–** នីតិវិធីនៃការបង្ហាញខ្លួនភ្លាម

កាលណាសម្រេចថា ត្រូវប្រើនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ព្រះរាជអាជ្ញាត្រូវ :

-ពិនិត្យអត្តសញ្ញាណបុគ្គលដែលគេបញ្ជូនមកឱ្យខ្លួន

-ឱ្យដំណឹងដល់ជននោះ អំពីរឿងរ៉ាវដែលចោទប្រកាន់ និងឈ្មោះបទល្មើស

-ទទួលចម្លើយរបស់បុគ្គលនោះ ប្រសិនបើសាមីខ្លួនចង់និយាយ

-ធ្វើកំណត់ហេតុស្តីអំពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ។

ព្រះរាជអាជ្ញាប្រាប់ជនជាប់ចោទថា ខ្លួនមានសិទ្ធិសុំពឹងមេធាវីតាមការជ្រើសរើសរបស់ខ្លួន ឬ ចាត់តាំងឡើងដោយអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។

មេធាវីជ្រើសរើស ឬ ចាត់តាំង ត្រូវបានទទួលដំណឹងភ្លាម ។ មេធាវីអាចពិនិត្យសំណុំរឿង និងទាក់ទងជាមួយជនជាប់ចោទបាន ។

និទ្ទេសនៃទម្រង់ការទាំងនេះ ត្រូវចុះនៅក្នុងកំណត់ហេតុ បើពុំដូច្នោះទេ នីតិវិធីត្រូវទុកជាមោឃៈ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL



50/24

តុលាការជាន់ដំបូងត្រូវបានទទួលបណ្តឹងតាមកំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ។

ជនជាប់ចោទត្រូវបង្ខាំងទុកដោយមានកងកម្លាំងការពារ រហូតដល់ពេលសាមីខ្លួនចូលបង្ហាញខ្លួននៅចំពោះមុខតុលាការដែលត្រូវបើកសវនាការនៅក្នុងថ្ងៃនោះតែម្តង ។

នៅពេលបង្ហាញខ្លួននេះ តុលាការក្រោយពីបានផ្ទៀងផ្ទាត់មើលអត្តសញ្ញាណរបស់ជនជាប់ចោទ និងធ្វើរបាយការណ៍សង្ខេបរឿងរ៉ាវដែលបានចោទប្រកាន់ ត្រូវប្រាប់ដល់ជនជាប់ចោទថា សាមីខ្លួនអាចមានរយៈពេលដើម្បីរៀបចំការពារខ្លួន ។

ប្រសិនបើជនជាប់ចោទសុំរយៈពេល ឬ ប្រសិនបើតុលាការយល់ឃើញថា រឿងក្តីនោះមិនទាន់អាចជំនុំជម្រះភ្លាមៗបានទេនោះ សំណុំរឿងត្រូវលើកទៅពេលសវនាការក្រោយ ។

តុលាការអាចបង្គាប់ឱ្យឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្ន ដោយសាលក្រមដែលមានបញ្ជាក់ពីសំអាងហេតុ ។ នៅក្នុងសាលក្រមនោះ តុលាការត្រូវយោងតាមលក្ខខណ្ឌនៃមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន) នៃក្រមនេះ ។ តុលាការចេញដីកាសម្រេចបង្គាប់ឱ្យឃុំខ្លួន ។

សាលក្រមលើអង្គសេចក្តី ត្រូវតែប្រកាសក្នុងរយៈពេល ដែលមិនអាចលើសពី ២ (ពីរ) សប្តាហ៍ គិតពីថ្ងៃចូលទៅបង្ហាញខ្លួននៅមុខតុលាការ ។ ការឃុំខ្លួនបណ្តោះអាសន្នត្រូវតែបញ្ឈប់ដោយពេញច្បាប់ ក្រោយពីផុតរយៈពេល ២ (ពីរ) សប្តាហ៍ ។

ប្រសិនបើតុលាការដែលបានទទួលបណ្តឹងតាមនីតិវិធីបង្គាប់ឱ្យបង្ហាញខ្លួនភ្លាម យល់ឃើញថា លក្ខខណ្ឌនៃមាត្រា ៤៧ (ការបង្ហាញខ្លួនភ្លាម) នៃក្រមនេះ មិនបានបំពេញទេ ឬ ក៏ដោយភាពស្មុគស្មាញនៃសំណុំរឿង តម្រូវជាចាំបាច់ឱ្យធ្វើការស្រាវជ្រាវឱ្យបានជ្រាលជ្រៅបន្ថែម តុលាការត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ដើម្បីបើកការស៊ើបសួរ ។ ជនជាប់ចោទត្រូវតែនាំទៅបង្ហាញខ្លួននៅថ្ងៃនោះតែម្តងនៅចំពោះមុខចៅក្រមស៊ើបសួរ បើពុំដូច្នោះទេ ជនជាប់ចោទត្រូវតែដោះលែងឱ្យមានសេរីភាពវិញដោយឯកឯង ។

**មាត្រា ៤៩.-** ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ក្នុងករណីបទលហុ

ប្រសិនបើរឿងនោះជាបទលហុ ព្រះរាជអាជ្ញាត្រូវកោះជនជាប់ចោទឱ្យចូលខ្លួនទៅមុខតុលាការជំនុំជម្រះដោយផ្ទាល់ ដូចបានចែងនៅក្នុងមាត្រា ៤៦ (ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់) នៃក្រមនេះ ។



51/240

**មាត្រា ៥០.–** បញ្ជីនៃពាក្យប្ដឹង

នៅតាមតុលាការជាន់ដំបូងនីមួយៗ ត្រូវបង្កើតឱ្យមានបញ្ជីអយ្យការមួយសម្រាប់ចុះបណ្ដឹង ដែលប្ដឹងដោយផ្ទាល់ដល់ព្រះរាជអាជ្ញា ឬ ដែលបញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌ ។

គ្រប់បណ្ដឹងទាំងអស់ត្រូវតែចុះក្នុងបញ្ជីដោយមានខ្លឹមសារដូចតទៅ :

-អត្តសញ្ញាណរបស់អ្នកប្ដឹង

-កាលបរិច្ឆេទដែលអយ្យការ បានទទួលពាក្យប្ដឹង

-ប្រភពនៃបណ្ដឹង : បណ្ដឹងផ្ញើមកផ្ទាល់ចំពោះព្រះរាជអាជ្ញា ឬ ក៏បញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌

-ប្រភេទនៃរឿងហេតុដែលអ្នកប្ដឹងបានរាយការណ៍

-ចំណាត់ការលើពាក្យប្ដឹង : ការសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬ ការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ។

បញ្ជីនៃពាក្យប្ដឹងត្រូវកាន់កាប់ដោយលេខាធិការរបស់អយ្យការ ក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា ។ បញ្ជីអាចត្រូវបានបើកមើលដោយអាជ្ញាធរតុលាការទាំងអស់ ជាអាទិ៍ គឺអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

## មាតិកាទី ២
## ចៅក្រមស៊ើបសួរ
## ជំពូកទោល
## ចៅក្រមស៊ើបសួរ

**មាត្រា ៥១.–** ការចាត់តាំងដោយប្រធានតុលាការ

កាលណាចៅក្រមស៊ើបសួរណាម្នាក់ ពុំអាចបំពេញមុខងាររបស់ខ្លួនបានទេ ដោយសារការឈប់សម្រាក ដោយមានជម្ងឺឬដោយមានមូលហេតុដទៃផ្សេងទៀត ចៅក្រមស៊ើបសួរផ្សេងទៀតនៃតុលាការដដែលត្រូវបានចាត់តាំងជាបណ្ដោះអាសន្ន ដោយប្រធានតុលាការ ដើម្បីបំពេញមុខងារស៊ើបសួរ ។

ក្នុងករណីពុំមានចៅក្រមស៊ើបសួរទេ ចៅក្រមផ្សេងទៀតនៃតុលាការដដែល អាចត្រូវបានចាត់តាំងជាបណ្ដោះអាសន្ន ដោយប្រធានតុលាការដើម្បីបំពេញមុខងារស៊ើបសួរ ។



52/240

ប្រធានតុលាការចេញដីកាចាត់តាំងមួយដែលពុំបើកផ្លូវតវ៉ាឡើយ ។

លើសពីនេះ បទប្បញ្ញត្តិនៃមាត្រា ២៦ (ការបែងចែករឿងក្តី) នៃក្រមនីតិវិធីរដ្ឋប្បវេណីត្រូវតែគោរព ។

**មាត្រា ៥២.–** ការបែងចែកសំណុំរឿងដោយប្រធានតុលាការ

កាលណាមានចៅក្រមស៊ើបសួរច្រើនរូបនៅក្នុងតុលាការមួយ សំណុំរឿងទាំងឡាយត្រូវបែងចែកដោយប្រធានតុលាការ ។

**មាត្រា ៥៣.–** ការដកហូតសំណុំរឿងពីចៅក្រមស៊ើបសួរ

ការដកហូតសំណុំរឿងពីចៅក្រមស៊ើបសួរ ដើម្បីប្រគល់ជូនចៅក្រមស៊ើបសួរម្នាក់ទៀត អាចស្នើទៅពីប្រធានតុលាការ ដើម្បីជាប្រយោជន៍នៃរដ្ឋបាលដ៏ល្អនៃយុត្តិធម៌ ។ ការស្នើសុំនេះ អាចធ្វើឡើងដោយពាក្យសុំដែលមានសំអាងហេតុរបស់ព្រះរាជអាជ្ញា ដែលធ្វើឡើងដោយការផ្តើមគំនិតផ្ទាល់ខ្លួន ឬ តាមរយៈពាក្យប្តឹងរបស់ភាគី ។

មូលហេតុនៃការដកហូតសំណុំរឿងពីចៅក្រមស៊ើបសួរ ត្រូវយោងតាមបញ្ញត្តិនៃមាត្រា ៥៥៦ (មូលហេតុនៃការប្តឹងជំទាស់ចៅក្រមអាសនៈ) នៃក្រមនេះ ។

**មាត្រា ៥៤.–** ករណីមិនព្រមវៀរចាកដែលនាំឱ្យមោឃភាព

ចៅក្រមស៊ើបសួរមិនអាចចូលរួមក្នុងការជំនុំជម្រះរឿងព្រហ្មទណ្ឌ ដែលខ្លួនបានចាត់ការក្នុងឋានៈជាចៅក្រមស៊ើបសួរបានទេ បើពុំដូច្នេះទេ ការជំនុំជម្រះត្រូវចាត់ទុកជាមោឃៈ ។

ចៅក្រមស៊ើបសួរប្រើអំណាចដែលមានចែងនៅក្នុងក្រមនេះ ។

## មាតិកាទី ៣

## សភាស៊ើបសួរ

## ជំពូកទោល

## សភាស៊ើបសួរ

**មាត្រា ៥៥.–** សភាពិសេសនៃសាលាឧទ្ធរណ៍

នៅក្នុងសាលាឧទ្ធរណ៍មានសភាមួយដែលមានឈ្មោះថា សភាស៊ើបសួរ ។ សភាស៊ើបសួរមានសមត្ថកិច្ចជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ដែលធ្វើឡើងប្រឆាំងនឹងសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ ។

សមាជិកនៃសភាស៊ើបសួរពុំអាចចូលរួមក្នុងការជំនុំជម្រះរឿងក្ដីព្រហ្មទណ្ឌ ដែលខ្លួនបានបំពេញការក្នុងឋានៈជាចៅក្រមស៊ើបសួរបានទេ បើមិនដូច្នេះទេ សាលដីកានោះត្រូវចាត់ទុកជាមោឃៈ ។

## មាតិកាទី ៤

## នគរបាលយុត្តិធម៌

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ៥៦.-** បេសកកម្មរបស់នគរបាលយុត្តិធម៌

នគរបាលយុត្តិធម៌ គឺជាជំនួយរបស់អំណាចតុលាការ ។

នគរបាលយុត្តិធម៌មានភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ កំណត់អត្តសញ្ញាណ និងចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាង ។

**មាត្រា ៥៧.-** សមាសភាពរបស់នគរបាលយុត្តិធម៌

នគរបាលយុត្តិធម៌រួមមាន :

១-មន្ត្រីនគរបាលយុត្តិធម៌ ។

២-ភ្នាក់ងារនគរបាលយុត្តិធម៌ ។

៣-មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលច្បាប់បានប្រគល់អំណាចឱ្យធ្វើការពិនិត្យបទល្មើសខ្លះៗ ក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន ។

**មាត្រា ៥៨.-** ការសម្របសម្រួលសកម្មភាពការងាររបស់នគរបាលយុត្តិធម៌

ព្រះរាជអាជ្ញាដឹកនាំ និងសម្របសម្រួលសកម្មភាពការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន ។

ព្រះរាជអាជ្ញាមានអំណាចទៅលើមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលចែងនៅក្នុងមាត្រា ៨២ (ការផ្ដល់នីតិសម្បទាចំពោះមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត) នៃក្រមនេះ កាលណាមន្ត្រីនេះបំពេញមុខងាររបស់ខ្លួនជានគរបាលយុត្តិធម៌ ។

កាលណាអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ ។



54/240

**មាត្រា ៥៩.–** ការត្រួតពិនិត្យលើនគរបាលយុត្តិធម៌

នគរបាលយុត្តិធម៌ត្រូវស្ថិតនៅក្រោមការឃ្លាំមើល និងការត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អនុវត្តអំណាចខាងវិន័យទៅលើនគរបាលយុត្តិធម៌ ។

## ជំពូកទី ២
## មន្ត្រីនគរបាលយុត្តិធម៌
## ផ្នែកទី ១
## ការទទួលបាននូវគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌

**មាត្រា ៦០.–** មន្ត្រីនគរបាលយុត្តិធម៌

មានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ :

១-មន្ត្រីនគរបាលជាតិ មានឋានន្តរសក្តិចាប់ពីអនុសេនីយ៍ត្រីឡើងទៅ ដែលបានបំពើការងារយ៉ាងតិចបំផុត ២ (ពីរ) ឆ្នាំ ក្នុងនគរបាលជាតិរួចហើយ ហើយបន្ទាប់ពីបានទទួលសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ ។

២-នាយទាហាននៃកងរាជអាវុធហត្ថ ដែលបានបំពើការងារយ៉ាងតិចបំផុត ២ (ពីរ) ឆ្នាំ ក្នុងកងរាជអាវុធហត្ថរួចហើយ ហើយបន្ទាប់ពីបានទទួលសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ ។

៣-អ្នកមានឋានន្តរស័ក្តិ និងមុខងារដូចខាងក្រោម :

ក-អភិបាល និងអភិបាលរង ខេត្ត ក្រុង, អភិបាល និងអភិបាលរង ស្រុក ខណ្ឌ និង មេឃុំ ចៅសង្កាត់ ។

ខ-ប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ ប្រធាននិងអនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ និងប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈនៃអគ្គស្នងការដ្ឋាននគរបាលជាតិ ។

គ-ប្រធាន និងអនុប្រធាននាយកដ្ឋាន, ប្រធាន និងអនុប្រធានការិយាល័យ,

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

រ



55/240

ប្រធាន និងអនុប្រធានផ្នែក ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ និងស្ថិតក្រោមឱវាទរបស់នាយក-ដ្ឋានកណ្តាលនគរបាលយុត្តិធម៌ នាយកដ្ឋានកណ្តាលសន្តិសុខ និងនាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ ។

ឃ-ប្រធាន និងអនុប្រធាននាយកដ្ឋាន, ប្រធាន និងអនុប្រធានការិយាល័យ, ប្រធាន និងអនុប្រធានផ្នែកនៃ :

-នាយកដ្ឋាននគរបាលព្រំដែន "ចំពោះបទល្មើសឆ្លងដែន"

-មន្ទីរប្រឆាំងគ្រឿងញៀន

-នាយកដ្ឋាននគរបាលទេសចរណ៍

-ស្នងការពិសេសការពារបេតិកភ័ណ្ឌ ។

ង-ស្នងការ ស្នងការរងនគរបាលខេត្ត ក្រុង ។

ច-ប្រធាន និងអនុប្រធានការិយាល័យ, ប្រធាន និងអនុប្រធានផ្នែកដែលទទួលបន្ទុកការងារព្រហ្មទណ្ឌចំណុះស្នងការនគរបាលខេត្ត ក្រុងដូចជា :

-ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតធ្ងន់ និងការិយាល័យព្រហ្ម-ទណ្ឌកំរិតស្រាល

-ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន

-ការិយាល័យនគរបាលសេដ្ឋកិច្ច

-ការិយាល័យបច្ចេកទេសវិទ្យាសាស្ត្រព្រហ្មទណ្ឌ

-ការិយាល័យប្រឆាំងគ្រឿងញៀន

-ការិយាល័យប្រឆាំងភេរវកម្ម និង

-ការិយាល័យជនបរទេស ។

ឆ-អធិការ និងអធិការរង ប្រធាន និងអនុប្រធានផ្នែកព្រហ្មទណ្ឌនៃអធិការ-ដ្ឋាននគរបាល ស្រុក ខណ្ឌ ។

ជ-ប្រធាន និងអនុប្រធានការិយាល័យនគរបាលចរាចរ ប្រធាន និងអនុប្រធានផ្នែកនគរបាលចរាចរ "ចំពោះបទល្មើសចរាចរ" ។ ប្រធាន និងអនុប្រធានការិយាល័យគ្រប់គ្រងអាវុធជាតិផ្ទុះ និងប្រធាន និងអនុប្រធានផ្នែកនៃការិយាល័យគ្រប់គ្រងអាវុធជាតិផ្ទុះ "ចំពោះបទល្មើសអាវុធជាតិផ្ទុះ" ។ ប្រធាន និងអនុប្រធានអង្គភាព ប្រធាន និងអនុប្រធាន

ROYAUME DU CAMBODGE MINISTERE DU PALAIS ROYAL



56/240

ការិយាល័យនគរបាលទេសចរណ៍ និងប្រធាន និងអនុប្រធានផ្នែកនៃការិយាល័យនគរបាលទេសចរណ៍ ។

ឈ-ប្រធាន និងអនុប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំសង្កាត់ "ចំពោះបទល្មើសព្រហ្មទណ្ឌ" ។

ញ-មេបញ្ជាការ និងមេបញ្ជាការរងនៃកងរាជអាវុធហត្ថ ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ ។

ដ-មេបញ្ជាការ និងមេបញ្ជាការរងកងរាជអាវុធហត្ថប្រចាំខេត្ត ក្រុង ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ ។

ឋ-មេបញ្ជាការ និងមេបញ្ជាការរងកងរាជអាវុធហត្ថប្រចាំស្រុក ខណ្ឌ ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ ។

ឌ-ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកនៃកងរាជអាវុធហត្ថទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ ។

ឍ-ប្រធាន និងអនុប្រធានអង្គភាពផ្សេងទៀត ដែលទទួលបន្ទុកកិច្ចការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ ដែលត្រូវបានបង្កើតឡើងក្នុងករណីចាំបាច់ ។

រដ្ឋមន្ត្រីជាអាណាព្យាបាលនៃមន្ត្រីនគរបាល ឬ ជាអាណាព្យាបាលនៃនាយទាហានកងរាជអាវុធហត្ថទាំងឡាយ ដែលមានចែងនៅក្នុងចំណុចទី ១ ទី ២ និងទី ៣ នៃមាត្រានេះ មានភារកិច្ចតែងតាំងមន្ត្រីនគរបាល និងនាយទាហានកងរាជអាវុធហត្ថទាំងឡាយណាដែលត្រូវបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ ដោយប្រកាសរួមជាមួយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៦១.-** សញ្ញាប័ត្រជាន់ខ្ពស់របស់នគរបាលយុត្តិធម៌

សញ្ញាប័ត្រជាន់ខ្ពស់នៃនគរបាលយុត្តិធម៌ ត្រូវផ្តល់ជូន បន្ទាប់ពីឆ្លងកាត់ការប្រលងបែបវិជ្ជាជីវៈ ដែលរួមមានវិញ្ញាសាជាមូលដ្ឋានដូចខាងក្រោម :

១-វិញ្ញាសាស្តីពីនីតិព្រហ្មទណ្ឌ ។

២-វិញ្ញាសាស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

៣-វិញ្ញាសាស្តីពីករណីយកិច្ចសាស្ត្រ ដូចដែលមានចែងនៅក្នុងក្រមសីលធម៌ ដែលគាត់តែងដោយអង្គការសហប្រជាជាតិ ។

សញ្ញាប័ត្រនេះត្រូវចុះហត្ថលេខារួមដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីពាក់ព័ន្ធ និងមានបោះត្រាផង ។



53/240

**មាត្រា ៦២.–** គណៈមេប្រយោគ

គណៈមេប្រយោគនៃការប្រលង ស្ថិតក្រោមអធិបតីភាពរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ឬ ចៅក្រមអយ្យការអមតុលាការកំពូលដែលទទួលមុខងារនេះ ។

១-ទាក់ទងនឹងមន្ត្រីនៃនគរបាលជាតិ គណៈមេប្រយោគមានសមាសភាពដូចតទៅ :

-ចៅក្រមស៊ើបសួរម្នាក់ ដែលតែងតាំងដោយប្រធានតុលាការកំពូល

-ចៅក្រមអយ្យការម្នាក់ ដែលតែងតាំងដោយអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

-តំណាង ២ (ពីរ) រូប របស់ក្រសួងមហាផ្ទៃ ។

២-ទាក់ទងនឹងយោធិននៃកងរាជអាវុធហត្ថ គណៈមេប្រយោគមានសមាសភាពដូចតទៅ :

-ចៅក្រមស៊ើបសួរម្នាក់ ដែលតែងតាំងដោយប្រធានតុលាការកំពូល

-ចៅក្រមអយ្យការម្នាក់ ដែលតែងតាំងដោយអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

-តំណាង ២ (ពីរ) រូប មកពីក្រសួងការពារជាតិ ។

បែបបទនៃការចេញសញ្ញាប័ត្រ ត្រូវកំណត់ដោយប្រកាសរួមមួយ រវាងរដ្ឋមន្ត្រីពាក់ព័ន្ធ ។

**មាត្រា ៦៣.–** សម្បថនៃមន្ត្រីនគរបាលយុត្តិធម៌

មន្ត្រីនគរបាលយុត្តិធម៌ម្នាក់ៗ ត្រូវស្បថថា ខ្លួននឹងបំពេញដោយភក្ដីភាពនូវមុខងាររបស់ខ្លួន ។ សម្បថត្រូវធ្វើនៅមុខសាលាឧទ្ធរណ៍ ។ សម្បថមិនចាំបាច់ធ្វើជាថ្មីម្ដងទៀតឡើយ នៅពេលដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌នាពេលក្រោយទៀត ។ រូបមន្តនៃសម្បថត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

## ផ្នែកទី ២

## កំហុសប្រព្រឹត្តក្នុងពេលអនុវត្តមុខងារ

**មាត្រា ៦៤.–** នីតិវិធីខាងវិន័យ

រាល់កំហុសទាំងឡាយ ដែលប្រព្រឹត្តដោយមន្ត្រីនគរបាលយុត្តិធម៌ ក្នុងពេលអនុវត្តមុខងាររបស់ខ្លួន ត្រូវតែរាយការណ៍ដោយព្រះរាជអាជ្ញា ឬ ដោយចៅក្រមស៊ើបសួរ ដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ យោងតាមករណីនីមួយៗ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ប្រកាស

58/240

ជូនដំណឹងដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬ រដ្ឋមន្ត្រីក្រសួងការពារជាតិ ដើម្បីផ្ដើមដំណើរការនីតិ-វិធីវិន័យ ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវបានផ្ដល់ដំណឹងអំពីចំណាត់ការជាបន្តនៃនីតិវិធីវិន័យនេះ ។

**មាត្រា ៦៥.-** ទណ្ឌកម្មខាងវិន័យ

ទណ្ឌកម្មខាងវិន័យទាំងឡាយរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬ របស់រដ្ឋមន្ត្រីក្រសួងការពារជាតិ មិនមែនជាឧបសគ្គដល់ការធ្វើបណ្ដឹងអាជ្ញាទេ ប្រសិនបើមានបទល្មើសណាមួយត្រូវបានប្រព្រឹត្ត ។

កាលណាមន្ត្រីនគរបាលយុត្តិធម៌ប្រព្រឹត្តបទល្មើសក្នុងអំឡុងពេលបំពេញមុខងាររបស់ខ្លួន យុត្តាធិការស៊ើបសួរ ឬ ជំនុំជម្រះដែលទទួលបន្ទុករឿងនេះ ត្រូវផ្ទេរសំណុំរឿងតាមសេចក្ដីសម្រេចរបស់តុលាការកំពូលទៅឱ្យយុត្តាធិការផ្សេងចាត់ការវិញបាន ដើម្បីជាប្រយោជន៍ល្អដល់រដ្ឋ-បាល តុលាការ និងត្រូវជូនដំណឹងជាបន្ទាន់ដល់អង្គភាពសាមី ។

ពាក្យសុំដកសិទ្ធិនេះ ត្រូវបានធ្វើឡើងដោយព្រះរាជអាជ្ញា ។

**មាត្រា ៦៦.-** ការហាមឃាត់មិនឱ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌

នៅពេលដែលអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍យល់ឃើញថា សភាពធ្ងន់ធ្ងរនៃកំហុសដែលប្រព្រឹត្តដោយមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ មានវិសមិតភាពជាមួយនឹងការបំពេញមុខងារ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានសិទ្ធិប្រកាសចេញវិធានការដូចខាងក្រោម :

១-ហាមឃាត់មិនឱ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ជាបណ្ដោះអាសន្ន សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើនបំផុត ។

២-ហាមឃាត់មិនឱ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ជាស្ថាពរ ។

មុននឹងចេញសេចក្ដីសម្រេចរបស់ខ្លួន អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ កោះហៅមន្ត្រីនគរបាលយុត្តិធម៌ និងកត់ត្រាទុកនូវសេចក្ដីសង្កេតរបស់មន្ត្រីនោះ ។ សាមីជនអាចរកជំនួយពីមេធាវី ឬ ពីទីប្រឹក្សាម្នាក់ តាមការជ្រើសរើសរបស់ខ្លួន ។

សេចក្ដីសម្រេចពីការហាមឃាត់ ត្រូវតែបញ្ជាក់សំអាងហេតុ ។ សេចក្ដីសម្រេចនេះ ត្រូវផ្ដល់ជាដំណឹងដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬ រដ្ឋមន្ត្រីក្រសួងការពារជាតិ ទៅតាមករណីនីមួយៗ ។

សេចក្ដីសម្រេចនេះ អាចជាកម្មវត្ថុនៃបណ្ដឹងតវ៉ា ទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលអាចប្រកាសបដិសេធចោលការសម្រេចហាមឃាត់ ឬ បន្ថយរយៈពេលនៃការហាមឃាត់របស់អគ្គ-

ព្រះរាជអាជ្ញា ។ ក្រសួងសាមីនៃមន្ត្រីនគរបាលយុត្តិធម៌ដែលត្រូវបានអគ្គព្រះរាជអាជ្ញាសម្រេចហាមឃាត់នោះ អាចបញ្ជូនយោបល់របស់ខ្លួនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

មន្ត្រីនគរបាលយុត្តិធម៌ ដែលត្រូវបានអគ្គព្រះរាជអាជ្ញាសម្រេចហាមឃាត់ អាចដាក់ពាក្យប្តឹងតវ៉ាដោយមានសំអាងហេតុ ក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃ គិតពីថ្ងៃទទួលដំណឹងអំពីសេចក្តីសម្រេចហាមឃាត់នោះ ។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវសម្រេចសេចក្តីលើបណ្តឹងតវ៉ាខាងលើ ក្នុងអំឡុងពេលយ៉ាងយូរបំផុត ១ (មួយ) ខែ គិតពីថ្ងៃទទួលពាក្យប្តឹង ។ សេចក្តីសម្រេចនេះ មិនអាចប្តឹងតវ៉ាបានឡើយ ។

ក្នុងអំឡុងពេលដែលអាចធ្វើបណ្តឹងតវ៉ា និងអំឡុងពេលនៃការសម្រេចសេចក្តីលើបណ្តឹងតវ៉ា មន្ត្រីនគរបាលយុត្តិធម៌ ដែលត្រូវបានអគ្គព្រះរាជអាជ្ញាសម្រេចហាមឃាត់នោះ មិនអាចបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ឡើយ ។ មន្ត្រីនេះអាចបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌វិញបាន ប្រសិនបើរដ្ឋមន្ត្រីក្រសួងយុត្តិធម៌សម្រេចបដិសេធចោលការសម្រេចហាមឃាត់ ឬ បន្ថយរយៈពេលនៃការហាមឃាត់ ។

កិច្ចទាំងឡាយដែលមន្ត្រីនគរបាលយុត្តិធម៌បានបំពេញ ដោយបំពានសេចក្តីសម្រេចពីការហាមឃាត់របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍នេះ ត្រូវចាត់ទុកជាមោឃៈ ។

## ផ្នែកទី ៣

## សមត្ថកិច្ចដែនដីរបស់មន្ត្រីនគរបាលយុត្តិធម៌

**មាត្រា ៦៧.-** មណ្ឌលរដ្ឋបាលបំពេញការងារ

មន្ត្រីនគរបាលយុត្តិធម៌ម្នាក់ៗ មានសមត្ថកិច្ចនៅក្នុងព្រំប្រទល់ដែនដីនៃអង្គភាពដែលខ្លួនត្រូវបានចាត់តាំងឱ្យទៅបំពេញការងារ ។

នៅភ្នំពេញ មន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ចនៅលើវិសាលភាពនៃក្រុងទាំងមូល ទោះបីជាអង្គភាពដែលខ្លួនផ្លាស់ទៅកាន់នោះ នៅកន្លែងណាក៏ដោយ ។

សេចក្តីសម្រេចតែងតាំងមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែបញ្ជាក់មណ្ឌលរដ្ឋបាល ដែលមន្ត្រីនោះ ត្រូវចាត់តាំងឱ្យទៅបំពេញការ ។ សេចក្តីសម្រេចនេះ ត្រូវផ្តល់ដំណឹងដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ៦៨.–** ការពន្លាតសមត្ថកិច្ចដែនដី

ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងតាមអត្ថន័យនៃមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង) និងមាត្រា ៨៧ (ការចាប់ខ្លួនក្នុងករណីបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង) នៃក្រមនេះ ហើយប្រសិនបើមានការបន្ទាន់ ព្រះរាជអាជ្ញាអាចអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ធ្វើប្រតិបត្តិការនៅលើវិសាលភាពនៃដែនដីជាតិទាំងមូល ។ ការអនុញ្ញាតអាចធ្វើដោយផ្ទាល់មាត់ ប៉ុន្តែការអនុញ្ញាតនេះត្រូវតែចុះនិទ្ទេសនៅក្នុងលិខិតស៊ើបអង្កេត ។

ក្នុងក្របខ័ណ្ឌនៃការស៊ើបសួរ កាលណាចៅក្រមស៊ើបសួរចេញដីកាចាត់ឱ្យស៊ើបសួរជំនួស ក្នុងករណីបន្ទាន់ ចៅក្រមនេះអាចអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ធ្វើប្រតិបត្តិការនៅលើវិសាលភាពដែនដីជាតិទាំងមូល ។

កាលណាធ្វើប្រតិបត្តិការនៅក្រៅមណ្ឌលរបស់ខ្លួននោះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវសុំជំនួយពីមន្ត្រីនគរបាលយុត្តិធម៌ដែលមានសមត្ថកិច្ចខាងដែនដី ។

ចៅក្រមដែលបានអនុញ្ញាតឱ្យមានការពន្លាតសមត្ថកិច្ច ត្រូវជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ព្រះរាជអាជ្ញា ដែលមានសមត្ថកិច្ចខាងដែនដី ។

**មាត្រា ៦៩.–** កម្មវិបាកនៃការមិនគោរពវិធានសមត្ថកិច្ច

វិធាននៃសមត្ថកិច្ចខាងដែនដីដែលបានបញ្ញត្តនៅក្នុងមាត្រាមុនៗនេះ មានលក្ខណៈដាច់ខាត ។ បើមិនគោរពតាមទេនោះ កិច្ចទាំងឡាយដែលបំពេញដោយមន្ត្រីនគរបាលយុត្តិធម៌ត្រូវទុកជាមោឃៈ ។

**មាត្រា ៧០.–** សេចក្តីបង្គាប់បញ្ជារបស់អាជ្ញាធរតុលាការ

មន្ត្រីនគរបាលយុត្តិធម៌ ក្នុងការបំពេញបេសកកម្មរបស់ខ្លួន ទទួលបញ្ជា ឬ សុំបញ្ជាតែពីអាជ្ញាធរតុលាការ ។

## ផ្នែកទី ៤

## បេសកកម្មនៃមន្ត្រីនគរបាលយុត្តិធម៌

**មាត្រា ៧១.–** កំណត់ហេតុនៃបទល្មើស

មន្ត្រីនគរបាលយុត្តិធម៌ទទួលបណ្តឹងទាមទារ និងបណ្តឹងបរិហារ ។ មន្ត្រីនគរបាលយុត្តិធម៌កត់និទ្ទេសបទល្មើសទាំងឡាយ ។

មន្ត្រីនគរបាលយុត្តិធម៌ ធ្វើការស៊ើបអង្កេតបទល្មើសជាក់ស្តែង និងធ្វើការស៊ើបអង្កេតបឋម ក្នុងលក្ខខណ្ឌនៃមាត្រា ៨៤ (ភាពខុសគ្នានៃអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ទៅតាមការស៊ើបអង្កេត) ដល់មាត្រា ១១០ (អំណាចធ្វើមូលវិចារណីរបស់ចៅក្រម) នៃក្រមនេះ ។

កាលណាការស៊ើបសួរបានចាប់ផ្តើម មន្ត្រីនគរបាលយុត្តិធម៌ អនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួសពីចៅក្រមស៊ើបសួរ នៅក្នុងលក្ខខណ្ឌដែលបានចែងដោយមាត្រា ១៧៣ (ដីកាចាត់ឱ្យស៊ើបសួរជំនួស) ដល់មាត្រា ១៨៤ (កំណត់ហេតុកសាងដោយមន្ត្រីនគរបាលយុត្តិធម៌) នៃក្រមនេះ ។

**មាត្រា ៧២.–** កំណត់ហេតុ

គ្រប់បណ្តឹងដែលទទួលដោយមន្ត្រីនគរបាលយុត្តិធម៌នោះ តម្រូវឱ្យមានធ្វើកំណត់ហេតុ ។

កំណត់ហេតុត្រូវស្រង់ដោយត្រឹមត្រូវនូវសេចក្តីរាយការណ៍របស់អ្នកប្តឹង ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ អាចហៅរកអ្នកបកប្រែភាសាម្នាក់ដែលត្រូវស្បថតាមជំនឿ ឬ សាសនាថា ខ្លួននឹងបកប្រែភាសាឱ្យបានត្រឹមត្រូវតាមសេចក្តីរាយការណ៍ ។ នៅក្នុងករណីណាក៏ដោយ អ្នកបកប្រែភាសាមិនអាចត្រូវបានជ្រើសរើសក្នុងចំណោមនគរបាល ឬ កងរាជអាវុធហត្ថដែលជាកងកម្លាំងរួមប្រតិបត្តិការបានឡើយ ។

កំណត់ហេតុស្តីអំពីការដាក់ពាក្យប្តឹងត្រូវមានចុះសេចក្តីដូចតទៅ :

-ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌

-អង្គភាពរបស់មន្ត្រីនគរបាលយុត្តិធម៌នេះ

-កាលបរិច្ឆេទ ។

ទំព័រនីមួយៗ ត្រូវចុះហត្ថលេខាដោយមន្ត្រីនគរបាលយុត្តិធម៌ និងដោយអ្នកប្តឹង ។

ការឆូត ការថែម និងការយោង ត្រូវតែមានបញ្ជាក់ដោយមានចុះហត្ថលេខារបស់មន្ត្រីនគរបាលយុត្តិធម៌ និងអ្នកប្តឹង នៅរឹមទំព័រ ។

មុននឹងចុះហត្ថលេខា ឬ ផ្តិតស្រាមដៃ អ្នកប្តឹងត្រូវអានកំណត់ហេតុឡើងវិញ ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវអានខ្លឹមសារកំណត់ហេតុដោយសំឡេងខ្លាំងៗ ។

**មាត្រា ៧៣.–** បញ្ជីបណ្តឹង

នៅគ្រប់អង្គភាពនគរបាលយុត្តិធម៌ ត្រូវតែមានបញ្ជីបណ្តឹងមួយ ។ នៅគ្រប់ពេលដែលមានការដាក់ពាក្យប្តឹង មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះក្នុងបញ្ជីនូវនិទ្ទេសដូចតទៅ :

-អត្តសញ្ញាណរបស់អ្នកប្តឹង

-កាលបរិច្ឆេទនៃការដាក់ពាក្យប្តឹង

-ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលធ្វើកំណត់ហេតុស្តីពីការដាក់ពាក្យប្តឹង

-ប្រភេទនៃអំពើដែលប្តឹង

-ចំណាត់ការលើបណ្តឹងដូចជាបញ្ជូនទៅព្រះរាជអាជ្ញា ឬ ក៏ផ្តើមធ្វើការស៊ើបអង្កេត ។

បញ្ជីបណ្តឹងត្រូវតែកាន់កាប់ជាអចិន្ត្រៃយ៍សម្រាប់ជូនអាជ្ញាធរតុលាការតាមត្រូវការ ។

**មាត្រា ៧៤.-** ចំណាត់ការបន្តពីការដាក់ពាក្យប្តឹង

មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបណ្តឹងនោះ ត្រូវតែចាប់ផ្តើមភ្លាមៗ ធ្វើការស៊ើបអង្កេត ឬ ក៏បញ្ជូនកំណត់ហេតុស្តីពីការដាក់ពាក្យប្តឹងនោះ ទៅព្រះរាជអាជ្ញាដើម្បីចាត់ការតទៅ ។

មន្ត្រីនគរបាលយុត្តិធម៌ មុនធ្វើការស៊ើបអង្កេត អាចសុំសេចក្តីណែនាំពីព្រះរាជអាជ្ញា ។

កាលណាទទួលពាក្យប្តឹងបរិហារ ដែលមានបង្ហាញមូលហេតុជាក់ច្បាស់សមហេតុផល មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញា និងសុំការណែនាំ ។

**មាត្រា ៧៥.-** ការបំពានលើសកម្មភាពតុលាការ

ក្នុងករណីណាក៏ដោយ មន្ត្រីនគរបាលយុត្តិធម៌ មិនអាចតម្កល់រឿងព្រហ្មទណ្ឌណាមួយទុកឥតចាត់ការបានទេ ទោះបីជាក្រោយពីមានការសម្រុះសម្រួលគ្នារវាងជនល្មើស និងជនរងគ្រោះ ឬ ក៏មានការដកពាក្យប្តឹងក៏ដោយ ។

មន្ត្រីនគរបាលយុត្តិធម៌ដែលរក្សាទុកកំណត់ហេតុ ឬ វត្ថុតាងដោយចេតនា ឬ ក៏លាក់បំបាំងដល់អាជ្ញាធរតុលាការ អំពីអត្ថិភាពនៃកំណត់ហេតុ ឬ វត្ថុតាង ត្រូវចាត់ទុកថា មន្ត្រីនគរបាលនោះបានប្រព្រឹត្តបទល្មើស ដែលត្រូវផ្តន្ទាទោសតាមក្រមព្រហ្មទណ្ឌពាក់ព័ន្ធនឹងជំពូកស្តីពីការស្រាវជ្រាវរកភស្តុតាង ។

## ជំពូកទី ៣

## ភ្នាក់ងារនគរបាលយុត្តិធម៌

**មាត្រា ៧៦.-** ការទទួលបាននូវគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌

មានគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌ :

១-នាយនគរបាល និងនាយនគរបាលរង ដែលមិនមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ ។

២-ភ្នាក់ងារនគរបាលជាតិផ្សេងទៀត ។

៣-នាយទាហាននៃកងរាជអាវុធហត្ថ ដែលមិនមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ ។

៤-យោធិនផ្សេងទៀតនៃកងរាជអាវុធហត្ថ ។

**មាត្រា ៧៧.–** សម្បថរបស់ភ្នាក់ងារនគរបាលយុត្តិធម៌

ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវស្បថថា បំពេញមុខងាររបស់ខ្លួនដោយស្មោះត្រង់ ។ សម្បថនេះត្រូវធ្វើឡើងនៅចំពោះមុខសាលាដំបូង ។ សម្បថនេះពុំចាំបាច់ធ្វើឡើងវិញឡើយ នៅពេលដែលបានទទួលនូវគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌ នាពេលក្រោយទៀត ។ រូបមន្តសម្បថត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៧៨.–** បេសកកម្មរបស់ភ្នាក់ងារនគរបាលយុត្តិធម៌

ភ្នាក់ងារនគរបាលយុត្តិធម៌ មានបេសកកម្ម :

១-ពិនិត្យបទល្មើស ជាអាទិ៍ បទលហុ ។

២-ជួយដល់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងការបំពេញមុខងាររបស់គេ ។

ចំពោះការពិនិត្យបទល្មើស ភ្នាក់ងារនគរបាលយុត្តិធម៌ធ្វើរបាយការណ៍ ។ របាយការណ៍នេះ មានតំលៃត្រឹមតែព័ត៌មានធម្មតា ។

ក្នុងករណីណាក៏ដោយ ភ្នាក់ងារនគរបាលយុត្តិធម៌ពុំអាចបំពេញកិច្ចទាំងឡាយ ដែលត្រូវរក្សាទុកជូនតែមន្ត្រីនគរបាលយុត្តិធម៌ ។ កិច្ចទាំងឡាយណាដែលត្រូវបានបំពេញដោយបំពានលើការហាមឃាត់នេះ ត្រូវចាត់ទុកជាមោឃៈ ។

**មាត្រា ៧៩.–** កំហុសដែលត្រូវបានប្រព្រឹត្តនៅក្នុងពេលបំពេញមុខងារ

រាល់កំហុសទាំងឡាយ ដែលប្រព្រឹត្តដោយភ្នាក់ងារនគរបាលយុត្តិធម៌ នៅក្នុងពេលបំពេញមុខងាររបស់ខ្លួន ត្រូវតែឱ្យដំណឹងដោយព្រះរាជអាជ្ញា ឬ ដោយចៅក្រមស៊ើបសួរ ជូនចំពោះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ យោងតាមករណីនីមួយៗ អគ្គព្រះរាជអាជ្ញាប្រកាសប្រាប់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬ រដ្ឋមន្ត្រីក្រសួងការពារជាតិ ដើម្បីចាប់ផ្តើមនីតិវិធីខាងវិន័យ ។ អគ្គព្រះរាជអាជ្ញាត្រូវបានផ្តល់ដំណឹងអំពីចំណាត់ការបន្តនៃនីតិវិធីវិន័យ ។

**មាត្រា ៨០.-** ទណ្ឌកម្មខាងវិន័យ

ទណ្ឌកម្មខាងវិន័យរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិ មិនមែនជាឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេ ប្រសិនបើមានបទល្មើសណាមួយត្រូវបានប្រព្រឹត្ត ។

កាលណាភ្នាក់ងារនគរបាលយុត្តិធម៌ប្រព្រឹត្តបទល្មើស នៅក្នុងការបំពេញមុខងាររបស់ខ្លួន តុលាការកំពូលអាចផ្ទេរអំណាចឱ្យទៅយុត្តាធិការផ្សេងចាត់ការវិញបាន ដើម្បីជាប្រយោជន៍ល្អដល់រដ្ឋបាលតុលាការ ។

ពាក្យសុំដកសិទ្ធិនេះ ត្រូវបានធ្វើឡើងដោយព្រះរាជអាជ្ញា ។

## ជំពូកទី ៤

## ការកំណត់សមត្ថកិច្ចរបស់នគរបាលជាតិ និងកងរាជអាវុធហត្ថ

**មាត្រា ៨១.-** ការកំណត់សមត្ថកិច្ច

ក្នុងវិស័យនគរបាលយុត្តិធម៌ នគរបាលជាតិ និងកងរាជអាវុធហត្ថ ត្រូវមានសមត្ថកិច្ចដូចមានចែងក្នុងមាត្រា ៥៦ (បេសកកម្មរបស់នគរបាលយុត្តិធម៌) នៃក្រមនេះ ។

លើសពីនេះទៅទៀត ចំពោះបទល្មើសយោធា មានតែកងរាជអាវុធហត្ថទេ ដែលមានគុណសម្បត្តិជានគរបាលយុត្តិធម៌ ។

កិច្ចប្រតិបត្តិការ និងកិច្ចសហប្រតិបត្តិការរវាងនាយនគរបាលជាតិ និងនាយទាហាននៃកងរាជអាវុធហត្ថ ក្នុងពេលបំពេញមុខងារជានគរបាលយុត្តិធម៌ ត្រូវកំណត់ដោយអនុក្រឹត្យ ។

អង្គភាពនគរបាលយុត្តិធម៌ ដែលមានសមត្ថកិច្ចថ្នាក់ជាតិ អាចត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ ។

## ជំពូកទី ៥

## មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលមាននីតិសម្បទាពិសេស សម្រាប់ពិនិត្យបទល្មើសមួយចំនួន

**មាត្រា ៨២.-** ការផ្តល់នីតិសម្បទាចំពោះមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត

មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលច្បាប់ដោយឡែកប្រគល់អំណាចឱ្យពិនិត្យបទល្មើស ត្រូវដាក់ឱ្យស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញាក្នុងពេលបំពេញមុខងារនេះ ។

បែបបទ និងនីតិវិធីនៃការផ្តល់នីតិសម្បទា ត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងយុត្តិ-ធម៌ និងក្រសួងពាក់ព័ន្ធ ។

មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតត្រូវស្បថថា បំពេញមុខងាររបស់ខ្លួនដោយស្មោះត្រង់ ។ សម្បថត្រូវធ្វើនៅចំពោះមុខសាលាដំបូង ។ រូបមន្តនៃពាក្យសម្បថ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងយុត្តិធម៌ ។

ចំពោះការពិនិត្យបទល្មើស មន្ត្រីរាជការ និងភ្នាក់ងារទាំងនេះធ្វើរបាយការណ៍ ។ របាយ-ការណ៍នេះមានតំលៃត្រឹមតែព័ត៌មានធម្មតាប៉ុណ្ណោះ ។

រាល់កំហុសទាំងឡាយដែលប្រព្រឹត្តដោយមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតនៅក្នុងពេលបំពេញមុខងាររបស់ខ្លួន ត្រូវតែឱ្យដឹងលឺងដោយព្រះរាជអាជ្ញា ឬ ដោយចៅក្រមស៊ើបសួរជូនចំពោះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ អគ្គព្រះរាជអាជ្ញា ប្រកាសប្រាប់រដ្ឋមន្ត្រីដែលមន្ត្រី ឬ ភ្នាក់ងារនោះនៅក្រោមឱវាទ ដើម្បីចាប់ផ្តើមនីតិវិធីខាងវិន័យ ។ អគ្គព្រះរាជអាជ្ញាត្រូវបានផ្តល់ដំណឹងអំពីចំណាត់ការបន្តនៃនីតិវិធីវិន័យ ។ ទណ្ឌកម្មខាងវិន័យមិនមែនជាឧបសគ្គដល់ការផ្ទើបណ្តឹងអាជ្ញាទេ ប្រសិនបើមានបទល្មើសត្រូវបានប្រព្រឹត្ត ។

## គន្ថីទី ៣
## ការស៊ើបអង្កេត
## មាតិកាទី ១
## បទប្បញ្ញត្តិទូទៅ
## ជំពូកតោល
## បទប្បញ្ញត្តិទូទៅ

**មាត្រា ៨៣.-** ការសម្ងាត់នៃការស៊ើបអង្កេត

ការស៊ើបអង្កេត ត្រូវតែជាការសម្ងាត់ ។ បុគ្គលទាំងឡាយ ដែលចូលរួមក្នុងការស៊ើបអង្កេតជាពិសេសចៅក្រមខាងអយ្យការ មេធាវី ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ មន្ត្រីរាជការអ្នកជំនាញ អ្នកបកប្រែ គ្រូពេទ្យ និង បុគ្គលដែលមានសមត្ថកិច្ចដូចមានចែងក្នុងមាត្រា ៩៥(ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ) នៃក្រមនេះ ត្រូវរក្សាការសម្ងាត់នៃវិជ្ជាជីវៈ ។

ប៉ុន្តែ ការគោរពនូវការសម្ងាត់វិជ្ជាជីវៈ មិនមែនជាឧបសគ្គដល់ការប្រើសិទ្ធិនៃការការពារខ្លួនឡើយ ។

ម្យ៉ាងទៀត ព្រះរាជអាជ្ញាត្រូវបានអនុញ្ញាតឱ្យធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ កាលណាខ្លួនយល់ឃើញថាព័ត៌មាន ដែលផ្សព្វផ្សាយពីរឿងណាមួយនោះ ជាព័ត៌មានមិនពិត ។

ការបំពានលើការសម្ងាត់នៃការស៊ើបអង្កេត គឺជាបទល្មើស ដែលត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ៨៤.–** ភាពខុសគ្នានៃអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ទៅតាមការស៊ើបអង្កេត

អំណាចទាំងឡាយ ដែលផ្តល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌ ខុសគ្នាទៅតាមពេលដែលមន្ត្រីនោះ បំរើការក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតករណីជាក់ស្តែង ឬ ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតជាបឋម ។

## មាតិកាទី ២

## ការស៊ើបអង្កេតករណីជាក់ស្តែង

### ជំពូកទី ១

### បទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង

**មាត្រា ៨៥.–** អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ នៅក្នុងករណីស៊ើបអង្កេតបទល្មើសជាក់ស្តែង

ក្នុងករណីមានបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ ត្រូវតែគោរពតាមបទប្បញ្ញត្តិនៃមាតិកានេះ ។

**មាត្រា ៨៦.–** និយមន័យបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង

បទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែងគឺ :

-បទល្មើសដែលកំពុងប្រព្រឹត្ត

-បទល្មើសដែលទើបប្រព្រឹត្តរួចភ្លាម ។

ត្រូវចាត់ទុកថាជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែងដែរ កាលណានៅក្រោយពេលមានបទល្មើសរួចបន្តិចមក :

-ជនដែលគេសង្ស័យ ត្រូវបានសាធារណជនស្រែកដេញប្រផាប់ចាប់ប្រកីង

-បុគ្គលដែលត្រូវគេរកឃើញមានវត្ថុ ឬ មានស្នាកស្នាម ឬ តម្រុយច្បាស់លាស់ ហើយ

ស៊ើសង្វាក់ផ្សេងទៀត ដែលនាំឱ្យគេសន្និដ្ឋានបានថា បុគ្គលនោះ បានប្រព្រឹត្ត ឬ បានចូលរួមប្រព្រឹត្តបទល្មើស ។

**មាត្រា ៨៧.-** ការចាប់ខ្លួនក្នុងករណីបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង

ក្នុងករណីបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង គ្រប់បុគ្គលទាំងអស់អាចចាប់ខ្លួនជនល្មើស ហើយនាំខ្លួនជននោះទៅប្រគល់ជូនមន្ត្រីនគរបាលយុត្តិធម៌ដែលនៅជិតបំផុត ។

**មាត្រា ៨៨.-** ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង

ត្រូវបានចាត់ទុកដូចជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែងផងដែរ បើទោះបីជាស្ថិតនៅក្រៅពីករណីដែលមានចែងក្នុងមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង) ខាងលើនេះក៏ដោយ គ្រប់បទឧក្រិដ្ឋ ឬ បទមជ្ឈិមទាំងឡាយណាដែលត្រូវបានប្រព្រឹត្តនៅក្នុងទីកន្លែងដែលអ្នកកាន់កាប់នៅទីនោះ សុំឱ្យព្រះរាជអាជ្ញា ឬ មន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬ ភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងករណីដែលគ្មានមន្ត្រីនគរបាលយុត្តិធម៌នៅទីកន្លែងនោះ ។ ក្នុងករណីចុងក្រោយនេះ ភ្នាក់ងារនគរបាលយុត្តិធម៌ ត្រូវរាយការណ៍ជាបន្ទាន់ជូនដល់មន្ត្រីនគរបាលយុត្តិធម៌ ។

## ជំពូកទី ២
## វិធានការស្រាវជ្រាវ

**មាត្រា ៨៩.-** វិធានការដំបូងក្នុងករណីបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង

ក្នុងករណីបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា ។

មន្ត្រីនគរបាលយុត្តិធម៌ចុះទៅកាន់ទីកន្លែងកើតហេតុ ដើម្បីធ្វើការពិនិត្យបទល្មើស ។ មន្ត្រីនគរបាលយុត្តិធម៌ធានារ៉ាប់រងរក្សាទុកនូវតម្រុយនៃភស្តុតាងទាំងឡាយណាដែលអាចបាត់បង់ ។ មន្ត្រីនគរបាលយុត្តិធម៌អាចហាមឃាត់បុគ្គលគ្រប់រូបកុំឱ្យទៅទីណាឆ្ងាយពីកន្លែងបទល្មើស រហូតដល់ពេលបញ្ចប់កិច្ចប្រតិបត្តិការរបស់ខ្លួន ។

ប្រសិនបើយល់ឃើញថា មានប្រយោជន៍ ព្រះរាជអាជ្ញាចុះទៅកាន់កន្លែងកើតហេតុ និងដឹកនាំការស៊ើបអង្កេត ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ប្រសិនបើមានការបន្ទាន់ ព្រះរាជអាជ្ញាអាចអនុញ្ញាតឱ្យ មន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ធ្វើប្រតិបត្តិការលើវិសាលភាពទាំងមូលនៃដែនដីជាតិ ដោយគោរពតាមលក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងមាត្រា ៦៨ (ការពន្លាតសមត្ថកិច្ចដែនដី) នៃក្រមនេះ ។

**មាត្រា ៩០.-** កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យ

មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួន ។

**មាត្រា ៩១.-** ការឆែកឆេរ

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបាន ។ ក្នុងករណីនេះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវទទួលជាបឋមនូវការអនុញ្ញាតពីព្រះរាជអាជ្ញា ទោះបីជាការអនុញ្ញាតដោយផ្ទាល់មាត់ក៏ដោយ ។

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើការឆែកឆេរនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬ បើគ្មានអ្នកកាន់កាប់ទេត្រូវធ្វើនៅចំពោះមុខសាក្សីពីរនាក់ ។ សាក្សីត្រូវចាត់តាំងដោយមន្ត្រីនគរបាលយុត្តិធម៌ ។ សាក្សីមិនអាចជានគរបាល ឬ ក៏ជាកងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រតិបត្តិ-ការក្នុងការឆែកឆេរនោះបានឡើយ ។

មន្ត្រីនគរបាលយុត្តិធម៌ មិនអាចផ្តើមធ្វើការឆែកឆេរមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចឡើយ លើកលែងតែ :

-ក្នុងករណីដែលមានចែងដោយមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង) នៃក្រមនេះ

-ក្នុងករណីដែលចែងដោយមាត្រា ៨៨(ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង) នៃក្រមនេះ

-ក្នុងករណីមានសំរែកស្រែកឱ្យគេជួយពីក្នុងទីកន្លែង

-ក្នុងករណីឆែកឆេរនៅទីកន្លែងក្នុងពេលម៉ោងដែលបើកចំហដល់សាធារណជន

-ក្នុងករណីឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ប្រើប្រាស់គ្រឿងញៀន ។

មន្ត្រីនគរបាលយុត្តិធម៌ធ្វើកំណត់ហេតុស្តីពីការឆែកឆេរ ដែលនៅក្នុងនោះមានចុះ :

-ការអនុញ្ញាតរបស់ព្រះរាជអាជ្ញាដោយប្រាប់ថ្ងៃ និងម៉ោងនៃការអនុញ្ញាតនេះ

-អត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬ របស់សាក្សីនីមួយៗ ។

ROYAUME DU CAMBODGE LE MINISTERE DU PALAIS ROYAL

មន្ត្រីនគរបាលយុត្តិធម៌ មិនអាចធ្វើការឆែកឆេរនៅក្នុងការិយាល័យមេធាវីបានទេ ។ មានតែព្រះរាជអាជ្ញា ឬ ចៅក្រមស៊ើបសួរតែប៉ុណ្ណោះ ដែលអាចធ្វើការឆែកឆេរនេះបាន នៅចំពោះមុខប្រធានគណៈមេធាវី ឬ ប្រតិភូរបស់ប្រធានគណៈមេធាវី ឬ មេធាវីសាមី ។

មន្ត្រីនគរបាលយុត្តិធម៌ អាចធ្វើការឆែកឆេរនៅក្នុងអគារសារព័ត៌មាន សហគ្រាសនៃសារព័ត៌មានសរសេរ ឬ សហគ្រាសសារព័ត៌មានសោតទស្សន៍បាន តែចំពោះមុខព្រះរាជអាជ្ញា ឬ ចៅក្រមស៊ើបសួរម្នាក់ ដែលធានាការពារកុំឱ្យការឆែកឆេរនេះ ប៉ះពាល់ដល់ការប្រកបដោយសេរីនូវមុខរបរអ្នកសារព័ត៌មាន និងធ្វើឱ្យយឺតយ៉ាវដល់ការផ្សព្វផ្សាយព័ត៌មាននេះដោយមិនត្រឹមត្រូវ ។

**មាត្រា ៩២.–** ការបិទស្លាកបោះត្រាលើវត្ថុតាង

មន្ត្រីនគរបាលយុត្តិធម៌ អាចចាប់យកវត្ថុតាង ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបិទស្លាកបោះត្រានៅលើវត្ថុតាងនោះ ។

ក្រោយពីបានបង្ហាញវត្ថុដែលចាប់បានដល់អ្នកកាន់កាប់ទីកន្លែង ឬ ដល់សាក្សីពីរនាក់មើលរួច មន្ត្រីនគរបាលយុត្តិធម៌ ធ្វើកំណត់ហេតុស្តីពីការចាប់យកដែលរួមមានបញ្ជីសារពើភ័ណ្ឌនៃវត្ថុដែលចាប់ ។ កំណត់ហេតុស្តីពីការចាប់យក ត្រូវចុះហត្ថលេខា ឬ ផ្តិតស្រាមមេដៃដោយអ្នកកាន់កាប់ទីកន្លែង ឬ ដោយសាក្សីពីរនាក់ ។

**មាត្រា ៩៣.–** កំណត់ហេតុលើការស្តាប់ចម្លើយ

មន្ត្រីនគរបាលយុត្តិធម៌អាចហៅ និងនាំមកកាន់អង្គភាពរបស់ខ្លួននូវបុគ្គលគ្រប់រូប ដែលសង្ស័យថា បានចូលរួមក្នុងបទល្មើស ។ មន្ត្រីនគរបាលយុត្តិធម៌ធ្វើការស្តាប់ចម្លើយជនទាំងនោះ ។

ការស្តាប់ចម្លើយនីមួយៗ ត្រូវមានធ្វើកំណត់ហេតុ ។

កំណត់ហេតុត្រូវដកស្រង់តាមដោយត្រឹមត្រូវ នូវសេចក្តីរាយការណ៍របស់បុគ្គលដែលផ្តល់ចម្លើយ ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ អាចរកអ្នកបកប្រែដែលស្បថថា និយាយការពិតស្របតាមជំនឿ ឬ សាសនារបស់ខ្លួន ។ អ្នកបកប្រែមិនអាចជ្រើសរើសយកពីក្នុងចំណោមនគរបាល កងរាជអាវុធហត្ថ ឬ បុគ្គលដែលទាក់ទិនក្នុងរឿងជាមួយគ្នា បានទេ ។

ទំព័រនីមួយៗនៃកំណត់ហេតុ ត្រូវចុះហត្ថលេខា ឬ ផ្តិតស្រាមមេដៃដោយបុគ្គលដែលបានឆ្លើយ ។ មុននឹងចុះហត្ថលេខា ឬ ផ្តិតស្រាមមេដៃ បុគ្គលនោះត្រូវអានកំណត់ហេតុឡើងវិញ ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ត្រូវអានដោយសំឡេងខ្លាំងៗ នូវខ្លឹមសារកំណត់ហេតុ ។ មន្ត្រី

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

នគរបាលយុត្តិធម៌អាចហៅរកអ្នកបកប្រែបាន ។ កាលណាបុគ្គលនោះមិនព្រមចុះហត្ថលេខា ឬ មិនព្រមផ្តិតម្រាមដៃទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ ។

**មាត្រា ៩៤.-** បទបញ្ជាឱ្យចូលខ្លួនក្នុងករណីការស៊ើបអង្កេតបទល្មើសជាក់ស្តែង

មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលគ្រប់រូប ដែលអាចផ្តល់ព័ត៌មានស្តីអំពីរឿងហេតុបាន ។

បុគ្គលដែលកោះហៅនោះ ត្រូវចូលបង្ហាញខ្លួន ។ ក្នុងករណីរឹងទទឹង មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា ដែលអាចចេញបញ្ជាឱ្យចូលខ្លួនបាន ។ បញ្ជាឱ្យចូលខ្លួននេះត្រូវមានអត្តសញ្ញាណរបស់បុគ្គលដែលពាក់ព័ន្ធ មានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា និងមានបោះត្រាផង ។ បញ្ជាឱ្យចូលខ្លួន អនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះ ឱ្យចូលបង្ហាញខ្លួន ។ កថាខណ្ឌទី ២ ដល់ទី ៥ នៃមាត្រា ៩៣(កំណត់ហេតុលើការស្តាប់ចម្លើយ) នៃក្រមនេះ ត្រូវយកមកអនុវត្ត ។

**មាត្រា ៩៥.-** ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ

ប្រសិនបើត្រូវធ្វើការពិនិត្យបច្ចេកទេស ឬវិទ្យាសាស្ត្រដែលមិនអាចបង្អង់បាន មន្ត្រីនគរបាលយុត្តិធម៌អាចពឹងដល់បុគ្គលគ្រប់រូបដែលមានមុខជំនាញ ។ ប្រសិនបើបុគ្គលនោះមិនទាន់បានចុះឈ្មោះនៅក្នុងបញ្ជីអ្នកជំនាញដូចចែងនៅមាត្រា ១៦៣ (បញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ) នៃក្រមនេះទេ បុគ្គលនេះត្រូវស្បថតាមសាសនា ឬ ជំនឿរបស់ខ្លួនថា នឹងជួយដោយភក្តីភាពដល់តុលាការ ។

## ជំពូកទី ៣

## ការឃាត់ខ្លួន

**មាត្រា ៩៦.-** ការឃាត់ខ្លួន

ដើម្បីឆ្លើយតបនឹងតម្រូវការចាំបាច់នៃការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួន បុគ្គលដែលសង្ស័យថា បានចូលរួមក្នុងបទល្មើស ។ មន្ត្រីនគរបាលយុត្តិធម៌ក៏អាចឃាត់ខ្លួនបុគ្គលដែលអាចផ្តល់ព័ត៌មានស្តីអំពីរឿងហេតុបានដែរ ប្រសិនបើលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ ៖

-បុគ្គលដែលអាចផ្តល់ព័ត៌មានប្រកែកមិនព្រមផ្តល់ព័ត៌មាន

-មានការយល់ព្រមជាលាយលក្ខណ៍អក្សរឱ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា ។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា ព្រមទាំងត្រូវបញ្ជូនគ្រប់ភស្តុតាងទាំងអស់ដែលតម្រូវឱ្យមានការឃាត់ខ្លួននេះ ។ ការឃាត់ខ្លួនមានថិរវេលា ៤៨ (សែសិបប្រាំបី) ម៉ោង ។ ថិរវេលាត្រូវចាប់គិតពីម៉ោងដែលសាមីខ្លួនមកដល់អង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ ។

ចំពោះបទឧក្រិដ្ឋ កាលណាមានតម្រុយដែលបង្ហាញឱ្យឃើញថា មានពិរុទ្ធភាពលើបុគ្គលដែលឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌អាចពន្យារពេលឃាត់ខ្លួនបាន ប្រសិនបើវិធានការនេះជាការចាំបាច់ ដើម្បីឱ្យការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ ។ ការពន្យារពេលនេះត្រូវសុំទៅព្រះរាជអាជ្ញា ដែលត្រូវផ្ទៀងផ្ទាត់មើលមូលកភាព ។ ការអនុញ្ញាតឱ្យពន្យារពេលឃាត់ខ្លួនដែលធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ ត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង ។ ការពន្យារគឺជាវិធានការពិសេស ។ ការពន្យារនេះមិនអាចឱ្យលើសពី ២៤ (ម្ភៃបួន) ម៉ោង ឡើយ ដោយមិនគិតពីថិរវេលាចាំបាច់ក្នុងការដឹកជញ្ជូន ។

ការពន្យារមិនអាចត្រូវយល់ព្រមបានទេ ប្រសិនបើបុគ្គលដែលឃាត់ខ្លួននោះ ជាអនីតិជន ។

ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៣៦ ម៉ោងឡើយ ។

ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ២៤ ម៉ោងឡើយ ។

ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៤៨ ម៉ោងឡើយ ។

ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៣៦ ម៉ោងឡើយ ។

អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ ពុំអាចត្រូវគេឃាត់ខ្លួនបានឡើយ ។

**មាត្រា ៩៧.-** កំណត់ហេតុស្តីពីការឃាត់ខ្លួន

កាលណាមានការឃាត់ខ្លួនបុគ្គលណាមួយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវឱ្យដំណឹងជាបន្ទាន់អំពីសេចក្តីសម្រេចរបស់ខ្លួនដល់បុគ្គលនោះ ដោយប្រាប់ឱ្យបានដឹងអំពីមូលហេតុនៃសេចក្តីសម្រេចឃាត់ខ្លួននេះ ។ មន្ត្រីនគរបាលយុត្តិធម៌ប្រាប់ដល់សាមីខ្លួនឱ្យបានដឹងផងដែរ អំពីសិទ្ធិដែលបានចែងនៅមាត្រា ៩៨ (សិទ្ធិរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន) នៃក្រមនេះ ។ ក្នុងករណីចាំបាច់

មន្ត្រីនគរបាលយុត្តិធម៌អាចហៅអ្នកបកប្រែ ។ មន្ត្រីនគរបាលយុត្តិធម៌ធ្វើកំណត់ហេតុស្ដីពីការឃាត់ខ្លួនជាបន្ទាន់ដោយមានចុះសេចក្ដីដូចតទៅ :

-ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឱ្យឃាត់ខ្លួន

-អត្តសញ្ញាណនៃបុគ្គលដែលត្រូវឃាត់ខ្លួន

-មូលហេតុនៃការឃាត់ខ្លួន

-ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលផ្ដើមឃាត់ខ្លួន

-ការឱ្យដំណឹងអំពីសិទ្ធិដែលបានបញ្ញត្តិនៃមាត្រា ៩៨ (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន) នៃក្រមនេះ

-ជាយថាហេតុ ឈ្មោះអ្នកបកប្រែ ។

កំណត់ហេតុនេះត្រូវមានចុះហត្ថលេខា ឬ ផ្ដិតស្រាមដៃរបស់ជនឃាត់ខ្លួន ក្រោយពីបានអានកំណត់ហេតុរួច ឬ បើសាមីខ្លួនមិនចេះអក្សរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវអានកំណត់ហេតុឱ្យស្ដាប់ ។ ប្រសិនបើជននេះប្រកែកមិនព្រមចុះហត្ថលេខា ឬ ផ្ដិតស្រាមដៃទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេស ។ កំណត់ហេតុត្រូវភ្ជាប់ជាមួយសំណុំរឿង ។

**មាត្រា ៩៨.–** ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន

ក្នុងរយៈពេល២៤ ម៉ោងបានកន្លងផុតទៅ តាំងពីពេលផ្ដើមនៃការឃាត់ខ្លួនមកនោះ បុគ្គលដែលឃាត់ខ្លួនអាចសុំសន្ទនាជាមួយមេធាវី ឬ ជាមួយជនណាម្នាក់ដែលខ្លួនជ្រើសរើស កុំឱ្យតែជននេះមានការទាក់ទិននៅក្នុងរឿងជាមួយ ។ ជននេះត្រូវបានទទួលដំណឹងពីការស្នើសុំជ្រើសរើសនេះ តាមគ្រប់មធ្យោបាយ និងជាបន្ទាន់ ។ ជននេះអាចចូលទៅកាន់កន្លែងឃាត់ខ្លួន និងទាក់ទងជាមួយបុគ្គលសាមីខ្លួនបាន ៣០ (សាមសិប)នាទី ក្នុងលក្ខខណ្ឌធានាការសម្ងាត់នៃការសន្ទនានេះ ។ ក្រោយការសន្ទនា ជននេះអាចធ្វើកំណត់សម្គាល់ជាលាយលក្ខណ៍អក្សរដែលត្រូវភ្ជាប់ជាមួយសំណុំរឿង ។

**មាត្រា ៩៩.–** ជំនួយរបស់គ្រូពេទ្យនៅក្នុងពេលឃាត់ខ្លួន

ព្រះរាជអាជ្ញា ឬ មន្ត្រីនគរបាលយុត្តិធម៌ សុំឱ្យគ្រូពេទ្យមកពិនិត្យបុគ្គលដែលឃាត់ខ្លួនបានគ្រប់ពេលវេលា ។ គ្រូពេទ្យផ្ទៀងផ្ទាត់មើលថា តើស្ថានភាពសុខភាពនៃបុគ្គលឃាត់ខ្លួននេះសមស្របនឹងការឃាត់ខ្លួនដែរឬទេ ។

ប្រសិនបើគ្រូពេទ្យយល់ឃើញថា ស្ថានភាពសុខភាពរបស់បុគ្គលនោះ ពុំសមស្របជាមួយនឹងការឃាត់ខ្លួនទេនោះ មន្ត្រីនគរបាលយុត្តិធម៌រាយការណ៍ជាបន្ទាន់ដល់ព្រះរាជអាជ្ញា ។ គ្រូពេទ្យចេញវិញ្ញាបនប័ត្របញ្ជាក់សុខភាពដែលត្រូវភ្ជាប់ជាមួយសំណុំរឿង ។ មន្ត្រីនគរបាលយុត្តិធម៌ចុះនិទ្ទេសនៅលើកំណត់ហេតុអំពីឈ្មោះរបស់គ្រូពេទ្យ ព្រមទាំងថ្ងៃ ខែ ឆ្នាំ និងម៉ោងនៃការពិនិត្យសុខភាព ។

ព្រះរាជអាជ្ញាអាចចុះទៅកាន់ទីកន្លែងផ្ទាល់ ដើម្បីផ្ទៀងផ្ទាត់លក្ខខណ្ឌនៃការឃាត់ខ្លួន ។

**មាត្រា ១០០.-** អនីតិជនដែលត្រូវបានឃាត់ខ្លួន

កាលណាបុគ្គលដែលត្រូវបានឃាត់ខ្លួនជាអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ឪពុក ម្ដាយ ដល់អ្នកតំណាងស្របច្បាប់ ឬ ដល់អ្នកទទួលភារកិច្ចលើអនីតិជននេះ ។

**មាត្រា ១០១.-** បញ្ជីនៃការឃាត់ខ្លួន

នៅក្នុងកន្លែងនីមួយៗ របស់នគរបាល ឬ កងរាជអាវុធហត្ថ ដែលសម្រាប់ទទួលជនដែលត្រូវឃាត់ខ្លួន ត្រូវមានបញ្ជីស្ដីពីការឃាត់ខ្លួនមួយ ។

គ្រប់ការឃាត់ខ្លួនត្រូវមានចុះនៅក្នុងបញ្ជីដោយមានសេចក្ដីដូចតទៅនេះ :

-ឈ្មោះ និងឋានៈមន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឱ្យធ្វើការឃាត់ខ្លួន

-អត្តសញ្ញាណរបស់បុគ្គលដែលឃាត់ខ្លួន

-ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលចាប់ផ្ដើមឃាត់ខ្លួន និងបញ្ចប់ការឃាត់ខ្លួន

-ឈ្មោះ និងឋានៈរបស់ចៅក្រមដែលបានអនុញ្ញាតឱ្យបន្តការឃាត់ខ្លួន ជាយថាហេតុ

-ឈ្មោះរបស់គ្រូពេទ្យដែលបានពិនិត្យបុគ្គលឃាត់ខ្លួន ជាយថាហេតុ

-ប្រភេទនៃសេចក្ដីសម្រេចរបស់អាជ្ញាធរតុលាការនៅពេលផុតកំណត់ការឃាត់ខ្លួន ។

បញ្ជីនេះត្រូវកាន់កាប់ជាប្រចាំសម្រាប់ជូនអាជ្ញាធរតុលាការតាមត្រូវការ ។

**មាត្រា ១០២.-** កំណត់ហេតុសរុបនៃការឃាត់ខ្លួន

គ្រប់ការឃាត់ខ្លួនត្រូវតែមានធ្វើកំណត់ហេតុសរុបនៃការឃាត់ខ្លួន ។

កំណត់ហេតុសរុបនេះត្រូវមានចុះនិទ្ទេសដូចតទៅ :

-ឈ្មោះ និងឋានៈមន្ត្រីនគរបាលយុត្តិធម៌ដែលបង្គាប់ឱ្យឃាត់ខ្លួន

-អត្តសញ្ញាណរបស់បុគ្គលដែលត្រូវឃាត់ខ្លួន

-មូលហេតុនៃការឃាត់ខ្លួន

-ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលផ្ដើមការឃាត់ខ្លួន

-បែបបទនៃការជូនដំណឹងដល់ព្រះរាជអាជ្ញា

-បែបបទនៃការជូនដំណឹងដោយអនុវត្តតាមមាត្រា ១០០(អនីតិជនដែលត្រូវបានឃាត់ខ្លួន) នៃក្រមនេះ

-ឈ្មោះគ្រូពេទ្យដែលបានពិនិត្យបុគ្គលឃាត់ខ្លួន

-អត្តសញ្ញាណរបស់ជនដែលបានសន្ទនាជាមួយបុគ្គលឃាត់ខ្លួនស្របតាមមាត្រា ៩៨ (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន) នៃក្រមនេះ

-ឈ្មោះ និងឋានៈរបស់ចៅក្រមដែលជាយថាហេតុបានអនុញ្ញាតឱ្យបន្តការឃាត់ខ្លួន

-ថិរវេលានៃការស្តាប់ចម្លើយនីមួយៗ និងថិរវេលានៃការសម្រាកដែលនៅចន្លោះការស្តាប់ចម្លើយនីមួយៗ

-ថ្ងៃ ខែ ឆ្នាំ និងម៉ោងនៃការឃាត់ខ្លួន

-ប្រភេទនៃសេចក្តីសម្រេចរបស់អាជ្ញាធរតុលាការនៅពេលបញ្ចប់ការឃាត់ខ្លួន

-លក្ខខណ្ឌនៃការប្រព្រឹត្តិទៅនៃការឃាត់ខ្លួន ព្រមទាំងឧប្បត្តិហេតុជាយថាហេតុ ។

កំណត់ហេតុសរុបនៃការឃាត់ខ្លួនត្រូវភ្ជាប់ជាមួយសំណុំរឿង ។

## ជំពូកទី ៤

## ការបញ្ជូនខ្លួន

**មាត្រា ១០៣.–** ការបញ្ជូនខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន

នៅពេលផុតកំណត់នៃរយៈពេលឃាត់ខ្លួន បុគ្គលដែលត្រូវបានឃាត់ខ្លួននោះត្រូវ :

-បញ្ជូនខ្លួនទៅព្រះរាជអាជ្ញា ឬ

-ដោះលែងឱ្យមានសេរីភាពឡើងវិញ ។

សេចក្តីសម្រេចនេះធ្វើឡើងដោយព្រះរាជអាជ្ញា ។

**មាត្រា ១០៤.–** រយៈពេលនៃការបញ្ជូនខ្លួន

កាលណាបុគ្គលដែលត្រូវឃាត់ខ្លួន ត្រូវបញ្ជូនខ្លួនទៅព្រះរាជអាជ្ញានោះ បុគ្គលនេះត្រូវបានគេនាំខ្លួនភ្លាមយកទៅចំពោះមុខព្រះរាជអាជ្ញា ។

ប្រសិនបើការបង្ហាញខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន ពុំអាចធ្វើឡើងនៅថ្ងៃតែមួយបាន ដោយសារមានមូលហេតុពិសេសដែលបណ្តាលមកពីការលំបាកក្នុងការដឹកជញ្ជូន ឬ ចម្ងាយផ្លូវនៃការដឹកជញ្ជូននោះ រយៈពេលបន្ថែមអាចផ្តល់ឱ្យដោយព្រះរាជអាជ្ញា បាន ។

នៅក្នុងគ្រប់ករណីទាំងអស់ ការបង្ហាញខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន ត្រូវធ្វើឡើងនៅក្នុងរយៈពេលដ៏ឆាប់បំផុតតាមការដែលអាចធ្វើទៅបាន ។

មូលហេតុនៃការឃឹតឃាំងត្រូវចុះក្នុងកំណត់ហេតុ ដែលត្រូវប្រគល់ជូនព្រះរាជអាជ្ញាដោយមន្ត្រីនគរបាលយុត្តិធម៌ ។

## ជំពូកទី ៥
## វិធាននានាអំពីការស៊ើបអង្កេតករណីជាក់ស្តែង

**មាត្រា ១០៥.–** ការហាមឃាត់មិនឱ្យស្តាប់ដោយឯកឯង ជាអាទិ៍

មន្ត្រីនគរបាលយុត្តិធម៌ ពុំមានអំណាចបង្គាប់ឱ្យស្តាប់ និងថតសំឡេងការសន្ទនាតាមទូរស័ព្ទឡើយ ។ មន្ត្រីនគរបាលយុត្តិធម៌ ពុំមានអំណាចបង្គាប់ឱ្យចាប់ និងថតការឆ្លើយឆ្លងដែលចេញតាមមធ្យោបាយទូរគមនាគមន៍ ជាអាទិ៍ សារតាមទូរសារ ឬ សារតាមអ៊ិនធើណែត ។

**មាត្រា ១០៦.–** ចិរវេលានៃការស៊ើបអង្កេតករណីជាក់ស្តែង

ចិរវេលានៃការស៊ើបអង្កេតបទល្មើសជាក់ស្តែង មិនអាចលើសពី ៧ (ប្រាំពីរ) ថ្ងៃ គិតពីថ្ងៃប្រព្រឹត្តបទល្មើស ។ កិច្ចស៊ើបអង្កេតត្រូវប្រព្រឹត្តទៅជាប់ជានិច្ចនៅក្នុងចិរវេលានេះ ។ ប្រសិនបើការស៊ើបអង្កេតមិនបានបញ្ចប់ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃនោះទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្នើសុំយោបល់ទៅព្រះរាជអាជ្ញា ។

**មាត្រា ១០៧.–** ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា

ក្រោយបញ្ចប់ការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនកំណត់ហេតុ និងវត្ថុតាងទាំងអស់ទៅព្រះរាជអាជ្ញា ។

កាលណាបុគ្គលណាមួយត្រូវបញ្ជូនទៅព្រះរាជអាជ្ញា នោះការបញ្ជូនកំណត់ហេតុ និងវត្ថុតាង ត្រូវធ្វើជាមួយការបញ្ជូនខ្លួនបុគ្គលនោះដែរ ។

**មាត្រា ១០៨.–** ទិន្នន័យដែលត្រូវចុះនៅក្នុងកំណត់ហេតុ

កំណត់ហេតុដែលធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះ :



70/240

-ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌

-អង្គភាពរបស់មន្ត្រីនោះ

-កាលបរិច្ឆេទ ។

ទំព័រនីមួយៗ ត្រូវចុះហត្ថលេខាដោយមន្ត្រីនគរបាលយុត្តិធម៌ ។

ពាក្យឆូតលុប និងការយោងត្រូវមានបញ្ជាក់យល់ព្រម ដោយមានចុះហត្ថលេខារបស់មន្ត្រីនគរបាលយុត្តិធម៌នៅរឹមទំព័រ ។

កំណត់ហេតុស្តីពីការស្តាប់ចម្លើយ ឬ ស្តីពីការឃាត់ខ្លួន ត្រូវមានចុះអត្តសញ្ញាណរបស់បុគ្គលដែលពាក់ព័ន្ធ ។

**មាត្រា ១០៩.-** មោឃភាពនៃការមិនគោរពវិធានបញ្ញត្តិ

វិធាន និងទម្រង់ការដែលបានបញ្ញត្តនៅមាត្រា :

-មាត្រា ៩០ (កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យ)

-មាត្រា ៩១ (ការឆែកឆេរ)

-មាត្រា ៩២ (ការបិទស្លាកបោះត្រាលើវត្ថុតាង)

-មាត្រា ៩៣ (កំណត់ហេតុលើការស្តាប់ចម្លើយ)

-មាត្រា ៩៤ (បទបញ្ជាឱ្យចូលខ្លួនក្នុងករណីការស៊ើបអង្កេតបទល្មើសជាក់ស្តែង)

-មាត្រា ៩៥ ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ)

-មាត្រា ៩៦ (ការឃាត់ខ្លួន)

-មាត្រា ៩៧ (កំណត់ហេតុស្តីពីការឃាត់ខ្លួន)

-មាត្រា ៩៨ (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន)

-មាត្រា ៩៩ (ជំនួយរបស់គ្រូពេទ្យនៅក្នុងពេលឃាត់ខ្លួន)

-មាត្រា ១០០ (អនីតិជនដែលត្រូវបានឃាត់ខ្លួន)

-មាត្រា ១០៥ (ការហាមឃាត់មិនឱ្យស្តាប់ដោយឯកឯង ជាអាទិ៍)

-មាត្រា ១០៦ (ថិរវេលានៃការស៊ើបអង្កេតករណីជាក់ស្តែង) និង

-មាត្រា ១០៨ (និទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ) នៃក្រមនេះ ។

មានលក្ខណៈដាច់ខាតត្រូវតែគោរព បើមិនដូច្នេះទេនឹងនាំឱ្យមានមោឃភាពនៃនីតិវិធី ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



47/249

**មាត្រា ១១០.–** អំណាចធ្វើមូលវិចារណ៍របស់ចៅក្រម

តាមគោលការណ៍ កំណត់ហេតុមានតម្លៃគ្រាន់តែជាព័ត៌មានប៉ុណ្ណោះ ។ ប៉ុន្តែ កំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវទុកជាបន្ទាល់ "ឯកសារដើម" មានន័យថា ត្រូវទុកជាឯកសារដែលត្រូវជៀរហូតដល់មានភស្តុតាងផ្ទុយ ។ ភស្តុតាងផ្ទុយអាចជូនមកចៅក្រមបានដោយសេរីតាមគ្រប់មធ្យោបាយត្រឹមត្រូវតាមច្បាប់ ។

ចៅក្រមធ្វើមូលវិចារណ៍ដោយសេរី លើកំណត់ហេតុដែលធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌ ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតបទល្មើសជាក់ស្តែង ។

## មាតិកាទី ៣
## ការស៊ើបអង្កេតបឋម
## ជំពូកទោល
## ការស៊ើបអង្កេតបឋម

**មាត្រា ១១១.–** ការបើកការស៊ើបអង្កេតបឋម

កាលណាបានដឹងពីអំពើដែលអាចជាបទឧក្រិដ្ឋ ឬ បទមជ្ឈិម ឬ បទលហុ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតបឋមដោយឯកឯង ឬ តាមការសុំរបស់ព្រះរាជអាជ្ញា ។

**មាត្រា ១១២.–** វិធានដែលអនុវត្តចំពោះការស៊ើបអង្កេតបឋម

បទប្បញ្ញត្តិនៃមាត្រា :

- មាត្រា ៩០ (កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យ)
- មាត្រា ៩៥ (ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ)
- មាត្រា ១០៥ (ការហាមឃាត់មិនឱ្យស្លាប់ដោយឯកឯង ជាអាទិ៍)
- មាត្រា ១០៧ (ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា)
- មាត្រា ១០៨ (និទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ) នៃក្រមនេះ

ត្រូវយកមកអនុវត្តនៅក្នុងការស៊ើបអង្កេតបឋម ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL



78/240/2

**មាត្រា ១១៣.–** ការឆែកឆេរ

កាលណាការស៊ើបអង្កេតជាបឋមនោះ ទាក់ទងនឹងបទឧក្រិដ្ឋ ឬ បទមជ្ឈិម មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរ និងចាប់យកវត្ថុតាង ។

មន្ត្រីនគរបាលយុត្តិធម៌ ជាបឋមត្រូវទទួលការយល់ព្រមច្បាស់លាស់ និងពិតប្រាកដពីអ្នកកាន់កាប់ទីកន្លែង ។

ការយល់ព្រមនេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ សរសេរដោយផ្ទាល់ដៃរបស់អ្នកកាន់កាប់ទីកន្លែង ។ ប្រសិនបើអ្នកកាន់កាប់ទីកន្លែងមិនចេះអក្សរ នោះត្រូវសរសេរឱ្យបានច្បាស់លាស់ក្នុងកំណត់ហេតុថា អ្នកកាន់កាប់ទីកន្លែងនោះមិនចេះអក្សរ ហើយយល់ព្រមឱ្យឆែកឆេរ ។

ក្នុងករណីដែលអ្នកកាន់កាប់ទីកន្លែងអវត្តមាន ឬ បដិសេធការឆែកឆេរ ប្រធានសាលាដំបូងដែលមានសមត្ថកិច្ចដែនដី អាចចេញដីកាអនុញ្ញាតឱ្យឆែកឆេរ តាមការសុំរបស់ព្រះរាជអាជ្ញា ។ ព្រះរាជអាជ្ញា ត្រូវដឹកនាំដោយផ្ទាល់នូវការឆែកឆេរនេះ ។ ការឆែកឆេរ ត្រូវធ្វើនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬ បើគ្មានអ្នកកាន់កាប់ទេត្រូវធ្វើនៅចំពោះមុខសាក្សីពីរនាក់ ។ សាក្សីត្រូវចាត់តាំងដោយព្រះរាជអាជ្ញា ។ សាក្សីមិនអាចជានគរបាល ឬ ជាកងរាជអាវុធហត្ថដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះឡើយ ។ ការឆែកឆេរ មិនអាចផ្តើមមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចឡើយ ។

បទប្បញ្ញត្តិនៃមាត្រា ៩២ (ការបិទស្លាកបោះត្រាលើវត្ថុតាង) នៃក្រមនេះ ត្រូវយកមកអនុវត្តក្នុងការចាប់យកវត្ថុតាង ។

**មាត្រា ១១៤.–** ការបញ្ជាឱ្យចូលខ្លួន ការស៊ើបអង្កេតបឋម

មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលគ្រប់រូបដែលត្រូវបានសង្ស័យថាបានចូលរួមក្នុងបទល្មើស ឬ ដែលអាចផ្តល់ព័ត៌មានស្តីពីរឿងហេតុ ។

បុគ្គលដែលកោះហៅត្រូវតែចូលមកបង្ហាញខ្លួន ។ ក្នុងករណីរឹងទទឹង មន្ត្រីនគរបាលយុត្តិ-ធម៌ជូនដំណឹងដល់ព្រះរាជអាជ្ញាដែលអាចចេញបញ្ជាឱ្យចូលខ្លួន ។ បញ្ជាឱ្យចូលខ្លួននេះ ត្រូវមានចុះអត្តសញ្ញាណបុគ្គលពាក់ព័ន្ធ កាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា និងមានបោះត្រា ។

បញ្ជាឱ្យចូលខ្លួន អនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ ប្រើប្រាស់កងកម្លាំងសាធារណៈ ដើម្បីបង្ខំបុគ្គលនោះឱ្យចូលបង្ហាញខ្លួន ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



79/240/2

**មាត្រា ១១៥.-** កំណត់ហេតុស្រង់ចម្លើយ ការស៊ើបអង្កេតបឋម

ការស្តាប់ចម្លើយនីមួយៗ ត្រូវមានធ្វើកំណត់ហេតុ ។

កំណត់ហេតុត្រូវដកស្រង់ដោយត្រឹមត្រូវតាមចម្លើយរបស់បុគ្គលពាក់ព័ន្ធ ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌អាចហៅរកអ្នកបកប្រែដែលបានស្បថស្របតាមសាសនា ឬ ជំនឿរបស់ខ្លួនថា ខ្លួននឹងបកប្រែឱ្យ បានត្រឹមត្រូវ ។ អ្នកបកប្រែមិនអាចត្រូវបានជ្រើសរើសក្នុងចំណោមនគរបាល កងរាជអាវុធហត្ថ ឬ បុគ្គលដែលពាក់ព័ន្ធនៅក្នុងរឿងជាមួយទេ ។

**មាត្រា ១១៦.-** ការឃាត់ខ្លួនជនជាប់សង្ស័យ

កាលណាការស៊ើបអង្កេតបឋមទាក់ទងនឹងបទឧក្រិដ្ឋ ឬ បទមជ្ឈិម នោះបទប្បញ្ញត្តិនៃជំពូកទី ៣ ស្តីពីការឃាត់ខ្លួន និងជំពូកទី ៤ ស្តីពីការបញ្ជូនខ្លួននៃមាតិកាទី ២ ស្តីពីការស៊ើបអង្កេតករណីជាក់ស្តែងក្នុងគន្ថីនេះ ត្រូវយកមកអនុវត្ត ។

**មាត្រា ១១៧.-** មោឃភាពនៃការមិនគោរពវិធានបញ្ញត្តិ

ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតបឋមវិធាន និងទម្រង់ការដែលចែងនៅក្នុងមាត្រា :

- មាត្រា ៩៦ (ការឃាត់ខ្លួន)
- មាត្រា ៩៧ (កំណត់ហេតុស្តីពីការឃាត់ខ្លួន)
- មាត្រា ១០០ (អនីតិជនដែលត្រូវបានឃាត់ខ្លួន)
- មាត្រា ១០៥ (ការហាមឃាត់មិនឱ្យស្តាប់ដោយឯកឯង ជាអាទិ៍)
- មាត្រា ១០៧ (ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា)
- មាត្រា ១១៣ (ការឆែកឆេរ)
- មាត្រា ១១៤ (ការបញ្ជាឱ្យចូលខ្លួន ការស៊ើបអង្កេតបឋម) នៃក្រមនេះ

មានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើពុំដូច្នេះទេនាំឱ្យមានមោឃភាពនៃនីតិវិធី ។

**មាត្រា ១១៨.-** អំណាចធ្វើមូលវិចារណ៍របស់ចៅក្រម

តាមគោលការណ៍ កំណត់ហេតុមានតម្លៃគ្រាន់តែជាព័ត៌មានប៉ុណ្ណោះ ។ ប៉ុន្តែ កំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវទុកជាបន្ទាល់ "ឯកសារដើម" មានន័យថា ត្រូវទុកជាឯកសារដែលបានត្រូវជឿរហូតដល់មានភស្តុតាងផ្ទុយ ។ ភស្តុតាងផ្ទុយអាចជូនមកចៅក្រមបានដោយសេរីតាមគ្រប់មធ្យោបាយត្រឹមត្រូវតាមច្បាប់ ។

ចៅក្រមធ្វើមូលវិចារណ៍ដោយសេរី លើកំណត់ហេតុដែលធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតបឋម ។

## មាតិកាទី ៤

## ការប្រគល់ឱ្យម្ចាស់ដើមវិញនូវវត្ថុដែលចាប់យកក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេត

## ជំពូកតោល

## ការប្រគល់ឱ្យម្ចាស់ដើមវិញនូវវត្ថុដែលចាប់យកក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេត

**មាត្រា ១១៩.–** អាជ្ញាធរមានសមត្ថកិច្ចបង្គាប់ឱ្យប្រគល់វត្ថុជូនម្ចាស់ដើមវិញ

ព្រះរាជអាជ្ញាមានសមត្ថកិច្ចបង្គាប់ឱ្យប្រគល់វត្ថុដែលចាប់បាននៅក្នុងពេលស៊ើបអង្កេតទៅម្ចាស់ដើមវិញ ប្រសិនបើវត្ថុទាំងនោះពុំមានប្រយោជន៍សម្រាប់ការសំដែងការពិតទេនោះ ហើយប្រសិនបើកម្មសិទ្ធិលើវត្ថុនោះ គ្មានការជំទាស់អ្វីប្រាកដប្រជាទេ ។

ប៉ុន្តែ វត្ថុដែលមានគ្រោះថ្នាក់ចំពោះមនុស្ស ឬ ចំពោះទ្រព្យសម្បត្តិ ដូចជាអាវុធ ឬ ជាតិផ្ទុះព្រមទាំងវត្ថុដែលត្រូវបានកាន់កាប់ដោយខុសច្បាប់ មិនអាចប្រគល់ឱ្យវិញបានទេ ។ វត្ថុទាំងនោះត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ឬ ត្រូវបំផ្លាញចោល ។

ក្នុងករណីមិនព្រមប្រគល់ឱ្យវិញទេ អ្នកប្តឹងអាចប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាបាន ។

ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញា គ្មានសមត្ថកិច្ចក្នុងការប្រគល់ទេ កាលណាមានការចោទប្រកាន់ធ្វើឡើងនៅចំពោះមុខយុត្តាធិការស៊ើបសួរ ឬ យុត្តាធិការជំនុំជម្រះ ។ ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញានៅតែមានសមត្ថកិច្ច កាលណាការស៊ើបសួរត្រូវបានបញ្ចប់ដោយសេចក្តីសម្រេចលើកលែងចោទប្រកាន់ជាស្ថាពរ ។

**មាត្រា ១២០.–** ការប្រគល់វត្ថុដែលរឹបអូសជូនម្ចាស់ដើមវិញ

កាលបើតុលាការដែលទទួលពាក្យប្តឹងបានចេញសេចក្តីសម្រេចមួយជាស្ថាពរ ហើយពុំបានសម្រេចសេចក្តីលើការប្រគល់វត្ថុដល់ម្ចាស់ដើមវិញទេ នោះព្រះរាជអាជ្ញា ឬ អគ្គព្រះរាជអាជ្ញាមានសមត្ថកិច្ចទៅតាមករណីនីមួយៗ ដើម្បីសម្រេចដោយឯកឯង លើពាក្យសុំឱ្យមានការប្រគល់វត្ថុដល់ម្ចាស់ដើមវិញនេះ នៅពេលដែលកម្មសិទ្ធិនៃវត្ថុនោះពុំមានការជំទាស់អ្វីជាប្រាកដប្រជាទេ ។

# គន្ថីទី ៤
# ការស៊ើបសួរ
## មាតិកាទី ១
## ចៅក្រមស៊ើបសួរ
### ជំពូកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១២១.–** ការសម្ងាត់នៃការស៊ើបសួរ

ការស៊ើបសួរត្រូវតែជាការសម្ងាត់ ។

បុគ្គលទាំងឡាយដែលចូលរួមក្នុងការស៊ើបសួរ ជាពិសេសចៅក្រម មេធាវី ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ មន្ត្រីរាជការ អ្នកជំនាញ អ្នកបកប្រែ គ្រូពេទ្យ និងបុគ្គលដែលមានសមត្ថកិច្ចដូចចែងក្នុងមាត្រា ៩៥ (ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ) នៃក្រមនេះ ត្រូវរក្សាការសម្ងាត់នៃវិជ្ជាជីវៈ ។

ប៉ុន្តែ ការគោរពនូវការសម្ងាត់វិជ្ជាជីវៈ មិនអាចជាឧបសគ្គដល់ការប្រើសិទ្ធិនៃការការពារខ្លួនឡើយ ។

ម្យ៉ាងទៀត ព្រះរាជអាជ្ញាអាចធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ កាលណាខ្លួនយល់ឃើញថា ព័ត៌មានដែលផ្សព្វផ្សាយពីរឿងណាមួយនោះ ជាព័ត៌មានមិនពិត ។

ការបំពានលើការសម្ងាត់នៃការស៊ើបសួរ គឺជាបទល្មើសដែលត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ១២២.–** ការបើកការស៊ើបសួរ

ការស៊ើបសួរត្រូវតែធ្វើដោយខានមិនបានចំពោះបទឧក្រិដ្ឋ ។ ចំពោះបទមជ្ឈិម ការស៊ើបសួរអាចធ្វើក៏បាន ឬ មិនធ្វើក៏បាន ។

**មាត្រា ១២៣.–** សមត្ថកិច្ចដែនដី

ចៅក្រមដែលមានសមត្ថកិច្ចគឺ :

- ចៅក្រមស៊ើបសួរនាទីកន្លែងបទល្មើស
- ចៅក្រមស៊ើបសួរនាទីលំនៅឋាន ឬ ទីសំណាក់របស់បុគ្គលដែលសង្ស័យថាបាន

ROYAUME DU CAMBODGE · LE MINISTÈRE DU PALAIS ROYAL



82/249

ប្រព្រឹត្តបទល្មើស

-ចៅក្រមស៊ើបសួរនាទីកន្លែងចាប់ខ្លួនបុគ្គលដែលសង្ស័យថា បានប្រព្រឹត្តបទល្មើស ។

ក្នុងករណីដែលមានទំនាស់រវាងចៅក្រមស៊ើបសួរច្រើនរូប នៅសាលាដំបូងខុសៗគ្នា ហើយទទួលបណ្តឹងទាំងអស់គ្នា អំពីរឿងព្រហ្មទណ្ឌតែមួយដូចគ្នា ទំនាស់នេះត្រូវបញ្ជូនទៅប្រធានសភាស៊ើបសួរដើម្បីសម្រេច ។

វិវាទសមត្ថកិច្ចដែនដី រវាងសភាស៊ើបសួរច្រើន ត្រូវសម្រេចដោយប្រធានតុលាការកំពូល ។

ការសម្រេចនេះបិទផ្លូវតវ៉ា ។

**មាត្រា ១២៤.-** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

ការស៊ើបសួរត្រូវបានបើកដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ដោយអនុលោមតាមមាត្រា ៤៤(ការបើកការស៊ើបសួរ) នៃក្រមនេះ ។

ការស៊ើបសួរអាចបើកប្រឆាំងនឹងបុគ្គលម្នាក់ ឬ ច្រើននាក់ ដោយមានចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ប្រឆាំងនឹងអញ្ញាតជន ដោយអនុលោមតាមវាក្យ-ខ័ណ្ឌទី ២ នៃមាត្រា ៤៤(ការបើកការស៊ើបសួរ) នៃក្រមនេះ ។

ចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរណាមួយបាន ដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាទេ ។

កាលបើចៅក្រមស៊ើបសួរទទួលពាក្យប្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្ប-វេណី ចៅក្រមស៊ើបសួរត្រូវធ្វើតាមនីតិវិធីដូចដែលមានចែងនៅមាត្រា ១៣៩ (ការបញ្ជូនបណ្តឹងទៅព្រះរាជអាជ្ញា) និងមាត្រា ១៤០ (ការបង់ប្រាក់តម្កល់ទុក) នៃក្រមនេះ ។

កាលណាទទួលពាក្យប្តឹងសាមញ្ញ ចៅក្រមស៊ើបសួរត្រូវបញ្ជូនពាក្យប្តឹងនោះទៅព្រះរាជ-អាជ្ញា ។

**មាត្រា ១២៥.-** វិសាលភាពនៃការប្តឹង

ចៅក្រមស៊ើបសួរទទួលបណ្តឹងអំពីអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ។ ចៅក្រមស៊ើបសួរត្រូវស៊ើបសួរតែអំពីអង្គហេតុនោះប៉ុណ្ណោះ ។

ប្រសិនបើមានលេចអង្គហេតុថ្មី ដែលអាចជាបទល្មើសព្រហ្មទណ្ឌ នៅក្នុងពេលស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានអំពីអង្គហេតុនេះទៅព្រះរាជអាជ្ញា ។ ព្រះរាជអាជ្ញាអាចប្តឹងសុំឱ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនេះ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ



83/240

បន្ថែម ។ បើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ ចៅក្រមស៊ើបសួរគ្មានអំណាចស៊ើបសួរអំពីអង្គហេតុថ្មីនោះឡើយ ។

ប៉ុន្តែ ចៅក្រមស៊ើបសួរមិនចាំបាច់សុំដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ ប្រសិនបើអង្គហេតុថ្មីនោះ ជាស្ថានទម្ងន់ទោសទៅលើអង្គហេតុ ដែលចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដំបូង ។

**មាត្រា ១២៦.–** ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ

ចៅក្រមស៊ើបសួរត្រូវតែដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យនូវបុគ្គលដែលមានចង្អុលប្រាប់ឈ្មោះ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ។

ចៅក្រមស៊ើបសួរមានអំណាចដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យនូវបុគ្គលគ្រប់រូប ដែលមានតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់គ្នាយ៉ាងខ្លាំងថា បានចូលរួមប្រព្រឹត្តបទល្មើស ទោះបីជាគ្មានការចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក៏ដោយ ។

ចៅក្រមស៊ើបសួរអាចដាក់បុគ្គលនោះឱ្យស្ថិតនៅក្រោមការពិនិត្យក្នុងឋានៈ ជាចារី ជាអ្នកផ្តើមគំនិត ឬ ជាអ្នកសមគំនិត ។

**មាត្រា ១២៧.–** ការស៊ើបសួរដាក់បន្ទុក និងដោះបន្ទុក

ចៅក្រមស៊ើបសួរបំពេញកិច្ចស៊ើបសួរទាំងអស់ដែលខ្លួនយល់ឃើញថា មានប្រយោជន៍សម្រាប់បង្ហាញឱ្យឃើញការពិតដោយអនុលោមតាមច្បាប់ ។

ចៅក្រមស៊ើបសួរមានករណីយកិច្ចស៊ើបសួរទាំងដាក់បន្ទុក និងដោះបន្ទុក ។

**មាត្រា ១២៨.–** ជំនួយរបស់ក្រឡាបញ្ជី

ចៅក្រមស៊ើបសួរត្រូវមានក្រឡាបញ្ជីម្នាក់អមជានិច្ច ។ ក្នុងករណីណាក៏ដោយ ក្រឡាបញ្ជីមិនអាចបំពេញកិច្ចដែលជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរបានទេ ។

**មាត្រា ១២៩.–** មុខងាររបស់ក្រឡាបញ្ជី

សំណុំរឿងស៊ើបសួរត្រូវរក្សាទុកដោយក្រឡាបញ្ជី ។ ក្រឡាបញ្ជីចម្លងលិខិតនីមួយៗនៃសំណុំរឿងតាមលទ្ធភាពដែលអាចធ្វើបាន ។ លិខិតចម្លងនេះត្រូវតែបញ្ជាក់ថា ត្រឹមត្រូវតាមលិខិតដើមដោយក្រឡាបញ្ជី ។ សេចក្តីចម្លងត្រូវរៀបចំទុកនៅក្នុងសំណុំរឿងបង្ការទុក ។

គ្រប់លិខិតនៃសំណុំរឿង ត្រូវតែបង់លេខដោយក្រឡាបញ្ជីតាមលំដាប់នៃកាលប្បវត្តិ ។



84/249

សំណុំរឿង និងសំណុំលិខិតដែលបង្ការទុកត្រូវតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីនៅមន្ទីរ ចៅក្រមស៊ើបសួរឬ នៅក្នុងបន្ទប់ណាមួយនៃតុលាការដែលមានលក្ខខណ្ឌសន្តិសុខគ្រប់គ្រាន់ ។

មេធាវី ឬ លេខាធិការរបស់មេធាវី ត្រូវបានអនុញ្ញាតដោយចៅក្រមស៊ើបសួរឱ្យធ្វើការថតចម្លងដោយខ្លួនជាអ្នកចេញសោហ៊ុយ និងក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី ។

**មាត្រា ១៣០.-** ការចុះដល់ទីកន្លែងដោយចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី

ចៅក្រមស៊ើបសួរអាចចុះដល់ទីកន្លែងជាមួយក្រឡាបញ្ជីរបស់ខ្លួន នៅលើវិសាលភាពនៃសមត្ថកិច្ចដែនដីនៃតុលាការជាន់ដំបូង ដើម្បីបំពេញកិច្ចស៊ើបសួរដែលខ្លួនយល់ឃើញថា មានប្រយោជន៍ជាអាទិ៍ ការពិនិត្យសម្ភារៈ ការឆែកឆេរ និងការចាប់យកវត្ថុតាង ។

ចៅក្រមស៊ើបសួរត្រូវជូនដំណឹងទៅព្រះរាជអាជ្ញាអំពីការចុះទៅពិនិត្យនេះ ។ ក្នុងករណីនេះ ព្រះរាជអាជ្ញាអាចរួមដំណើរជាមួយចៅក្រមស៊ើបសួរនេះ ។

ប្រសិនបើការចាំបាច់នៃការស៊ើបសួរតម្រូវ នោះចៅក្រមស៊ើបសួរអាចចុះទៅកាន់ទីកន្លែងជាមួយក្រឡាបញ្ជី នៅលើវិសាលភាពដែនដីជាតិទាំងមូល ។ ប៉ុន្តែ ចៅក្រមត្រូវជូនដំណឹងជាមុនដល់ព្រះរាជអាជ្ញាអមតុលាការជាន់ដំបូង នៅក្នុងដែនដីដែលខ្លួនធ្វើដំណើរទៅកាន់នោះ ។

ចៅក្រមស៊ើបសួរ ត្រូវធ្វើកំណត់ហេតុស្តីពីប្រតិបត្តិការរបស់ខ្លួននេះ ។

**មាត្រា ១៣១.-** ដីកាចាត់ឱ្យស៊ើបសួរជំនួស

ចៅក្រមស៊ើបសួរអាចសុំឱ្យចៅក្រមផ្សេង ឬ មន្ត្រីនគរបាលយុត្តិធម៌ ឬ អង្គភាពនគរបាលយុត្តិធម៌ បំពេញកិច្ចខ្លះតាមដីកាចាត់ឱ្យស៊ើបសួរជំនួស នៅក្នុងលក្ខខណ្ឌដែលមានចែងនៅមាត្រា ១៧៣ (ដីកាចាត់ឱ្យស៊ើបសួរជំនួស) ដល់មាត្រា ១៨៤ (កំណត់ហេតុកសាងដោយមន្ត្រីនគរបាលយុត្តិធម៌) នៃក្រមនេះ ។

**មាត្រា ១៣២.-** ការស្នើសុំឱ្យបំពេញកិច្ចដោយព្រះរាជអាជ្ញា

នៅគ្រប់ពេលវេលានៃការស៊ើបសួរ ព្រះរាជអាជ្ញាអាចសុំឱ្យចៅក្រមស៊ើបសួរធ្វើកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍ ។

ប្រសិនបើចៅក្រមស៊ើបសួរ មិនព្រមធ្វើតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាទេនោះ ចៅក្រមរូបនេះត្រូវចេញដីកាបដិសេធនៅក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ។ ដីកានេះត្រូវមានសំអាងហេតុ ហើយត្រូវតែជូនដំណឹងដល់ព្រះរាជអាជ្ញាក្នុងថិរវេលាយ៉ាងឆាប់បំផុត ។

ROYAUME DU CAMBODGE MINISTERE DU PALAIS ROYAL



85/240

ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្តឹងដោយផ្ទាល់តាមរយៈពាក្យសុំ ទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ ។

**មាត្រា ១៣៣.–** ការស្នើសុំឱ្យបំពេញកិច្ចដោយជនត្រូវចោទ

នៅគ្រប់ពេលវេលានៃការស៊ើបសួរ ជនត្រូវចោទអាចសុំឱ្យចៅក្រមស៊ើបសួរធ្វើការសួរចម្លើយខ្លួន ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឬ សាក្សី សួរតទល់គ្នា ឬ ចុះទៅដល់ទីកន្លែង ។ ពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវមានសំអាងហេតុ ។

ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំនេះទេ ចៅក្រមរូបនេះត្រូវចេញដីកាបដិសេធនៅក្នុងថិរវេលា ១ (មួយ) ខែ បន្ទាប់ពីពេលទទួលពាក្យសុំ ។ ដីកានេះត្រូវតែមានសំអាងហេតុ និងត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ ។

ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងថិរវេលា ១ (មួយ) ខែទេ ជនត្រូវចោទអាចប្តឹងដោយផ្ទាល់ តាមរយៈពាក្យសុំដល់សភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ ។

**មាត្រា ១៣៤.–** ការស្នើសុំឱ្យបំពេញកិច្ចដោយដើមបណ្តឹងរដ្ឋប្បវេណី

នៅគ្រប់ពេលវេលានៃការស៊ើបសួរ ដើមបណ្តឹងរដ្ឋប្បវេណីអាចសុំដល់ចៅក្រមស៊ើបសួរឱ្យស្តាប់ចម្លើយខ្លួន ស្តាប់ចម្លើយសាក្សី សួរចម្លើយជនត្រូវចោទសួរតទល់គ្នា ឬ ចុះទៅដល់ទីកន្លែង ។ ពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ ។

ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំនេះទេ ចៅក្រមរូបនេះ ត្រូវចេញដីកាបដិសេធក្នុងថិរវេលា ១ (មួយ) ខែ ក្រោយពេលទទួលពាក្យសុំ ។ ដីកានេះត្រូវតែមានសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា និងដល់ដើមបណ្តឹងរដ្ឋប្បវេណី ។

ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងថិរវេលា ១(មួយ) ខែទេ ដើមបណ្តឹងរដ្ឋប្បវេណី អាចប្តឹងដោយផ្ទាល់តាមរយៈពាក្យសុំដល់សភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ ។

**មាត្រា ១៣៥.–** ការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា

នៅគ្រប់ពេលវេលា ព្រះរាជអាជ្ញាអាចពិនិត្យមើលសំណុំរឿងស៊ើបសួរ ឬ ស្នើសុំឱ្យបញ្ជូនសំណុំរឿងមកពិនិត្យ ប៉ុន្តែត្រូវមានភារកិច្ចបង្វិលសំណុំរឿងនេះទៅវិញ នៅក្នុងថិរវេលា ២៤ (ម្ភៃបួន) ម៉ោង ។

**មាត្រា ១៣៦.–** វត្តមានរបស់ព្រះរាជអាជ្ញា ចំពោះកិច្ចស៊ើបសួរ

ព្រះរាជអាជ្ញាអាចមានវត្តមាននៅក្នុងគ្រប់កិច្ចស៊ើបសួរ ជាពិសេសក្នុងការសួរចម្លើយជនត្រូវចោទក្នុងការសួរតទល់ និងក្នុងការស្ដាប់ចម្លើយ ។

**មាត្រា ១៣៧.–** ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍

កាលណាការស៊ើបសួរត្រូវបានបើក បុគ្គលគ្រប់រូបដែលបានប្រកាសខ្លួនថាជាជនរងគ្រោះ អាចតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរបានគ្រប់ពេលវេលា ។

ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍ ធ្វើឡើងដោយគ្មានតម្រូវតាមទម្រង់ណាមួយឡើយ ។

កាលណាការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានធ្វើឡើងតាមលិខិត លិខិតនេះត្រូវដាក់បញ្ចូលក្នុងសំណុំរឿង ។ កាលណាការតាំងខ្លួនត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុ ។

ចៅក្រមស៊ើបសួរត្រូវជូនដំណឹង អំពីការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនេះ ដល់ព្រះរាជ-អាជ្ញា និងដល់ជនត្រូវចោទ ។

**មាត្រា ១៣៨.–** បណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី

ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬ បទមជ្ឈិម អាចដាក់ពាក្យប្ដឹងជូនចៅក្រមស៊ើបសួរមានសមត្ថ-កិច្ច ដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ។ ពាក្យប្ដឹងអាចដាក់ក្នុងនាមជនរងគ្រោះដោយមេធាវី ។

**មាត្រា ១៣៩.–** ការបញ្ជូនបណ្ដឹងទៅព្រះរាជអាជ្ញា

ចៅក្រមស៊ើបសួរធ្វើការកត់សំគាល់នូវការដាក់ពាក្យប្ដឹង ដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីតាមដីកា ។ ចៅក្រមស៊ើបសួរបញ្ជូនបណ្ដឹងនេះទៅព្រះរាជអាជ្ញា ។

ក្រោយពីបានឃើញពាក្យប្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ព្រះរាជអាជ្ញាត្រូវប្ដឹងទៅចៅក្រមស៊ើបសួរ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះ អាចធ្វើប្រឆាំងនឹងអញ្ញាតជន ទោះបីជាបណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចោទទៅលើឈ្មោះបុគ្គលម្នាក់ ឬ ច្រើននាក់ក៏ដោយ ។

ព្រះរាជអាជ្ញាអាចសុំដល់ចៅក្រមស៊ើបសួរកុំឱ្យស៊ើបសួរ ប្រសិនបើបណ្ដឹងអាជ្ញាត្រូវបានផុតរលត់ ឬ ប្រសិនបើអំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌទេ ។



87/240

ក្នុងករណីដែលចៅក្រមស៊ើបសួរសម្រេចមិនស៊ើបសួរ ចៅក្រមរូបនេះត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ដែលត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី ។

ក្នុងករណីដែលចៅក្រមស៊ើបសួរនៅតែសម្រេចស៊ើបសួរ ចៅក្រមរូបនេះត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា ។

**មាត្រា ១៤០.–** ការបង់ប្រាក់តម្កល់ទុក

ដោយផ្អែកទៅលើធនធាននៃដើមបណ្តឹងរដ្ឋប្បវេណី និងទៅលើការលំបាកនៃរឿងដែលអាចមើលឃើញជាមុន ចៅក្រមស៊ើបសួរកំណត់តាមដីកាសម្រេចនូវចំនួនទឹកប្រាក់ដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវបង់ ព្រមទាំងរយៈពេលដែលត្រូវបង់ប្រាក់នេះផង ។

ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីពុំមានលទ្ធភាពអាចបង់ប្រាក់តម្កល់ទុកបានទេ ចៅក្រមស៊ើបសួរអាចលើកលែងមិនឱ្យបង់ប្រាក់នេះបាន ។ ដីកានេះត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី ។

ក្នុងករណីដែលមានការបង់ប្រាក់តម្កល់ទុក ដើមបណ្តឹងរដ្ឋប្បវេណីទទួលបង្កាន់ដៃដែលមានចុះហត្ថលេខាដោយប្រធានតុលាការ ព្រះរាជអាជ្ញា និងក្រឡាបញ្ជី ។

ប្រសិនបើប្រាក់តម្កល់ទុក មិនត្រូវបានបង់នៅក្នុងរយៈពេល ដែលកំណត់ដោយចៅក្រមស៊ើបសួរទេ ពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវប្រកាសថាមិនអាចទទួលបានដោយចៅក្រមស៊ើបសួរ ។ ចៅក្រមស៊ើបសួរនេះ សម្រេចតាមដីកាដែលត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី ។

ប្រាក់តម្កល់ទុកត្រូវបង្វិលទៅសាមីខ្លួននៅពេលបញ្ចប់នីតិវិធី លើកលែងតែត្រូវអនុវត្តបទ-ប្បញ្ញត្តិនៃមាត្រា ១៤១ (បណ្តឹងដោយបំពាន ឬ បណ្តឹងដោយអូសបន្លាយពេលវេលា)នៃក្រមនេះ ។

ប្រាក់តម្កល់ទុក ត្រូវតម្កល់ទុកនៅក្នុងគណនីពិសេស ដែលបើកនៅក្នុងធនាគារ ឬរក្សាទុកនៅក្នុងទីកន្លែងដែលមានការធានាសន្តិសុខយ៉ាងរឹងមាំ ។ ទីកន្លែងនេះត្រូវបានជ្រើសរើសតាមការព្រមព្រៀងគ្នារបស់ប្រធានតុលាការ និងព្រះរាជអាជ្ញា ។

**មាត្រា ១៤១.–** បណ្តឹងដោយបំពាន ឬ បណ្តឹងដោយអូសបន្លាយពេលវេលា

ប្រសិនបើការស៊ើបសួរដែលបានបើកបន្ទាប់ពីមានពាក្យប្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបិទតាមដីកាលើកលែងចោទប្រកាន់ ហើយប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថា នីតិវិធីធ្វើឡើងដោយរំលោភ ឬ ដោយអូសបន្លាយពេលវេលា នោះចៅក្រម

ROYAUME DU CAMBODGE
MINISTERE DU PALAIS



85/240

ស៊ើបសួរ អាចសម្រេចតាមដីកាសម្រេចឱ្យដើមបណ្ដឹងបង់ប្រាក់ពិន័យរដ្ឋប្បវេណី ។ ចំនួនប្រាក់ពិន័យមិនអាចលើសចំនួនទឹកប្រាក់តម្កល់ទុកឡើយ ។ ដីកាសម្រេចឱ្យបង់ប្រាក់ពិន័យនេះ ត្រូវឱ្យដំណឹងដល់សាមីខ្លួនជាបន្ទាន់ ។

**មាត្រា ១៤២.–** បណ្ដឹងឱ្យជួសជុលការខូចខាត

កាលណាការស៊ើបសួរដែលបើកបន្ទាប់ពីមានពាក្យប្ដឹង ដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានបិទតាមដីកាលើកលែងចោទប្រកាន់ចូលជាស្ថាពរ បុគ្គលដែលមានឈ្មោះនៅក្នុងពាក្យប្ដឹង អាចប្ដឹងសុំការជួសជុលសំណងពីអ្នកដែលប្ដឹងពីខ្លួន ប្រសិនបើនីតិវិធីផ្ដើមឡើង ដោយរំលោភ ឬ ដោយអួសបន្ទាយពេលវេលា ។

ពាក្យប្ដឹងសុំការជួសជុលនេះ ត្រូវដាក់ជូនដល់តុលាការជាន់ដំបូងដែលរឿងត្រូវបានស៊ើបសួរ ។ តុលាការអាចសុំឱ្យគេបញ្ជូនសំណុំរឿងមកពិនិត្យ ។

## ជំពូកទី ២
## ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ
### ផ្នែកទី ១
### ការជូនដំណឹងអំពីការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ

**មាត្រា ១៤៣.–** ការជូនដំណឹងអំពីការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ

នៅពេលចូលបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរពិនិត្យអត្តសញ្ញាណជនត្រូវចោទ ប្រាប់ជននេះឱ្យបានដឹងរឿងរ៉ាវដែលចោទប្រកាន់ និងប្រាប់អំពីឈ្មោះបទល្មើសដែលកំណត់ដោយច្បាប់ ។ ចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទថា ខ្លួនអាចឆ្លើយ ឬមិនឆ្លើយបានដោយសេរី ។ និទ្ទេសស្ដីពីការប្រាប់នេះត្រូវចុះនៅក្នុងកំណត់ហេតុនៅពេលចូលបង្ហាញខ្លួនលើកដំបូង ។

ប្រសិនបើជនត្រូវចោទចង់ឆ្លើយនោះ ចៅក្រមស៊ើបសួរត្រូវទទួលចម្លើយនោះភ្លាម ។

ចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទ ឱ្យបានដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការជ្រើសរើសមេធាវី ឬ ក្នុងការសុំឱ្យចាត់តាំងមេធាវីឱ្យខ្លួន ដោយអនុវត្តតាមច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី ។

ជនត្រូវចោទជាអនីតិជនត្រូវតែមានមេធាវីអមជានិច្ច ។ បើគ្មានការជ្រើសរើសដោយជនត្រូវចោទនេះ មេធាវីត្រូវបានចាត់តាំងនៅក្នុងលក្ខខណ្ឌដែលចែងដោយច្បាប់ស្ដីអំពីលក្ខន្តិកៈមេធាវី ។



59/240

ក្រោយពីការចូលបង្ហាញខ្លួនលើកទីមួយ ជនត្រូវចោទដែលនៅក្រៅឃុំ ត្រូវប្រកាសប្រាប់ដល់ចៅក្រមស៊ើបសួរអំពីអាសយដ្ឋានរបស់ខ្លួន ។ ជនត្រូវចោទនេះត្រូវបានទទួលដំណឹងថា :

-ខ្លួនត្រូវតែជូនព័ត៌មាន ដល់ចៅក្រមស៊ើបសួរ នៅពេលណាដែលខ្លួនផ្លាស់ប្ដូរអាសយដ្ឋាន

-គ្រប់ការឱ្យដំណឹងដែលបានធ្វើឡើងតាមអាសយដ្ឋានចុងក្រោយ ដែលប្រកាសឡើងដោយជនត្រូវចោទនោះ ត្រូវចាត់ទុកថាបានធ្វើឡើងដល់សាមីខ្លួនផ្ទាល់ ។

ការឱ្យដំណឹងព្រមទាំងការប្រកាសស្ដីអំពីការផ្លាស់ប្ដូរអាសយដ្ឋាននោះ ត្រូវចុះក្នុងកំណត់ហេតុនៅពេលចូលបង្ហាញខ្លួនលើកដំបូង ។

**មាត្រា ១៤៤.-** ជំនួយរបស់អ្នកបកប្រែ

ក្នុងករណីចាំបាច់ចៅក្រមស៊ើបសួរត្រូវហៅរកអ្នកបកប្រែ ។ អ្នកបកប្រែត្រូវស្បថស្របតាមសាសនា ឬ ជំនឿរបស់ខ្លួនថាខ្លួននឹងជួយដល់តុលាការ និងបកប្រែឱ្យបានត្រឹមត្រូវតាមចម្លើយទាំងឡាយ ។ ក្នុងករណីណាក៏ដោយ អ្នកបកប្រែមិនអាចត្រូវជ្រើសរើសក្នុងចំណោមចៅក្រម ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ ភាគី ឬ សាក្សីទេ ។

## ផ្នែកទី ២
## ការសួរចម្លើយជនត្រូវចោទ

**មាត្រា ១៤៥.-** វត្តមានរបស់មេធាវីក្នុងពេលសួរចម្លើយ

កាលណាជនត្រូវចោទមានមេធាវីអម ចៅក្រមស៊ើបសួរ ត្រូវកោះហៅមេធាវីយ៉ាងតិចបំផុត ៥ (ប្រាំ) ថ្ងៃ មុនការសួរចម្លើយ ។ ក្នុងចិរវេលានេះ មេធាវីអាចពិនិត្យមើលសំណុំរឿងនៃនីតិវិធី ។

ជនត្រូវចោទអាចត្រូវសួរចម្លើយបានតែនៅចំពោះមុខមេធាវីរបស់ខ្លួនប៉ុណ្ណោះ ។ ប៉ុន្តែប្រសិនបើមេធាវីដែលត្រូវបានកោះហៅយ៉ាងត្រឹមត្រូវហើយ មិនចូលបង្ហាញខ្លួននៅថ្ងៃ និងម៉ោងកំណត់ទេ ចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទ ដោយគ្មានវត្តមានរបស់មេធាវី ។ និទ្ទេសស្ដីអំពីអវត្តមាននេះត្រូវចុះនៅក្នុងកំណត់ហេតុសួរចម្លើយជនត្រូវចោទ ។

ក្នុងករណីពិសេស ចៅក្រមស៊ើបសួរ អាចសួរចម្លើយជនត្រូវចោទ ដោយមិនចាំបាច់កោះហៅមេធាវី ប្រសិនបើជនត្រូវចោទបោះបង់ចោលយ៉ាងជាក់លាក់នូវវត្តមានរបស់មេធាវីខ្លួន ។ ការ

បោះបង់ចោលនេះត្រូវចុះនៅក្នុងកំណត់ហេតុមួយផ្សេងពីកំណត់ហេតុសួរចម្លើយ និងត្រូវចុះហត្ថលេខាដោយជនត្រូវចោទ ។

ក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរក៏អាចធ្វើការសួរចម្លើយដោយមិនបាច់កោះហៅមេធាវីបានដែរ ។ ភាពបន្ទាន់នេះត្រូវតែបណ្ដាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬ បណ្ដាលមកពីការភ័យខ្លាចបាត់បង់តម្រុយនៃភស្តុតាង ។ ប្រភេទនៃភាពបន្ទាន់ ត្រូវតែចុះនិទ្ទេសនៅក្នុងកំណត់ហេតុ ។

ចៅក្រមស៊ើបសួរ អាចហៅរកអ្នកបកប្រែដូចបានចែងនៅក្នុងមាត្រា ១៤៤(ជំនួយរបស់អ្នកបកប្រែ) នៃក្រមនេះ ។

**មាត្រា ១៤៦.–** សំណួរដោយមានការអនុញ្ញាតរបស់ចៅក្រមស៊ើបសួរ

នៅពេលសួរចម្លើយជនត្រូវចោទ ព្រះរាជអាជ្ញា និងមេធាវីក៏អាចលើកសំណួរបានដែរដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ ។

ក្នុងករណីមិនអនុញ្ញាត ករណីនោះត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ ។

**មាត្រា ១៤៧.–** ការពិភាក្សាដេញដោល

បទប្បញ្ញត្តិនៃមាត្រា ១៤៥ (វត្តមានរបស់មេធាវីក្នុងពេលសួរចម្លើយ) និងមាត្រា ១៤៦ (សំណួរដោយមានការអនុញ្ញាតរបស់ចៅក្រមស៊ើបសួរ) នៃក្រមនេះ ត្រូវយកមកអនុវត្តក្នុងករណីសួរចម្លើយតទល់ជនត្រូវចោទ ។

**មាត្រា ១៤៨.–** រយៈពេលអប្បបរមាសម្រាប់ការសួរចម្លើយ

កាលណាថិរវេលា ៤ (បួន) ខែ បានកន្លងផុតទៅ ចាប់ពីពេលសួរចម្លើយនៅពេលបង្ហាញខ្លួនលើកដំបូង ជនត្រូវចោទមិនត្រូវបានសួរចម្លើយ ឬ សួរតទល់ទេ ចៅក្រមស៊ើបសួរត្រូវតែទទួលចម្លើយ ប្រសិនបើជនត្រូវចោទបានស្នើសុំ ។ បើចៅក្រមស៊ើបសួរមិនព្រមកោះហៅជនត្រូវចោទក្នុងថិរវេលា ១ (មួយ) ខែ បន្ទាប់ពីការសុំទេ នោះជនត្រូវចោទអាចប្ដឹងផ្ទាល់ទៅសភាស៊ើបសួរដែលទទួលចម្លើយនេះដោយខ្លួនឯង ។ បន្ទាប់មកកំណត់ហេតុត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ ។

**មាត្រា ១៤៩.–** សិទ្ធិការពារខ្លួនរបស់ជនត្រូវចោទ

មេធាវីរបស់ជនត្រូវចោទដែលជាប់ឃុំ អាចប្រាស្រ័យទាក់ទងដោយសេរីជាមួយកូនក្ដីរបស់ខ្លួននៅក្នុងពន្ធនាគារ ឬ នៅក្នុងមណ្ឌលឃុំខ្លួន ។ ការសន្ទនារវាងមេធាវី និងជនត្រូវចោទមិនអាចត្រូវគេស្ដាប់ ឬ ថតបានទេ ។ មេធាវីអាចអានលិខិតនៃសំណុំរឿងឱ្យកូនក្ដីខ្លួនស្ដាប់ ។ ផ្ទុយទៅវិញមេធាវីមិនអាចឱ្យលិខិតថតចម្លងពីលិខិតនៃសំណុំរឿង ដល់កូនក្ដីរបស់ខ្លួនបានឡើយ ។



91/250

# ផ្នែកទី ៣
# ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

**មាត្រា ១៥០.–** ការស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានអមដោយមេធាវី ។

ក្នុងករណីនេះ ចៅក្រមស៊ើបសួរត្រូវកោះហៅមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងតិចបំផុត ៥ (ប្រាំ) ថ្ងៃ មុនការស្តាប់ចម្លើយ ។ នៅក្នុងចិរវេលានេះ មេធាវីអាចពិនិត្យសំណុំរឿងនៃនីតិវិធីបាន ។

ដើមបណ្តឹងរដ្ឋប្បវេណី អាចត្រូវបានគេស្តាប់ចម្លើយតែនៅចំពោះមុខមេធាវីរបស់ខ្លួនប៉ុណ្ណោះ ។ ប៉ុន្តែ ប្រសិនបើមេធាវីដែលត្រូវបានកោះហៅយ៉ាងត្រឹមត្រូវ ហើយមិនចូលមកបង្ហាញខ្លួននៅថ្ងៃ និង ម៉ោងតាមកំណត់ទេ ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីដោយគ្មានវត្តមានរបស់មេធាវី ។ និទ្ទេសស្តីពីអវត្តមាន ត្រូវចុះនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ ។

ក្នុងករណីពិសេស ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីបាន ដោយមិនចាំបាច់កោះហៅមេធាវី ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីបោះបង់ចោលយ៉ាងជាក់លាក់នូវវត្តមានមេធាវីរបស់ខ្លួន ។ ការបោះបង់ចោលនេះ ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុមួយដោយឡែកពីកំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងត្រូវចុះហត្ថលេខាដោយដើមបណ្តឹងរដ្ឋប្បវេណី ។

ក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរក៏អាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ដោយមិនចាំបាច់កោះហៅមេធាវីបានដែរ ។ ភាពបន្ទាន់នេះ ត្រូវបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬ បណ្តាលមកពីភ័យខ្លាចបាត់បង់តម្រុយភស្តុតាង ។ ប្រភេទនៃភាពបន្ទាន់ត្រូវតែចុះនិទ្ទេសនៅក្នុងកំណត់ហេតុ ។

ចៅក្រមស៊ើបសួរអាចហៅរកអ្នកបកប្រែបាន ដូចបានចែងនៅមាត្រា ១៤៤ (ជំនួយរបស់អ្នកបកប្រែ) នៃក្រមនេះ ។

**មាត្រា ១៥១.–** សំណួរដោយមានការអនុញ្ញាតរបស់ចៅក្រមស៊ើបសួរ

នៅក្នុងពេលស្តាប់ចម្លើយ ព្រះរាជអាជ្ញា និងមេធាវីអាចលើកសំណួរមកសួរបាន ដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ ។ ក្នុងករណីមិនអនុញ្ញាត ករណីនោះត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ ។

ROYAUME DU CAMBODGE MINISTÈRE DU PALAIS ROYAL



98/250

**មាត្រា ១៥២.-** ការពិភាក្សាដេញដោល ឬ ការសួរតទល់

បទប្បញ្ញត្តិនៃមាត្រា ១៥០ (ការស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី) និងមាត្រា ១៥១ (សំណួរដោយមានការអនុញ្ញាតរបស់ចៅក្រមស៊ើបសួរ) នៃក្រមនេះ ត្រូវយកមកអនុវត្តនៅក្នុងករណីសួរតទល់ដើមបណ្តឹងរដ្ឋប្បវេណី ។

## ផ្នែកទី ៤

## ការស្តាប់ចម្លើយសាក្សី

**មាត្រា ១៥៣.-** ការស្តាប់ចម្លើយសាក្សី

ចៅក្រមស៊ើបសួរ អាចស្តាប់ចម្លើយបុគ្គលគ្រប់រូប ដែលចម្លើយនោះអាចមានប្រយោជន៍នៅក្នុងការសំដែងឱ្យឃើញការពិត ។

ចៅក្រមស៊ើបសួរស្តាប់ចម្លើយសាក្សីដាច់ពីគ្នា ដោយគ្មានវត្តមានជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ។ ចៅក្រមស៊ើបសួរក៏អាចសួរតទល់គ្នារវាងជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និង សាក្សីផងបានដែរ ។

បុគ្គលគ្រប់រូប ដែលត្រូវបានចៅក្រមស៊ើបសួរកោះហៅក្នុងឋានៈជាសាក្សី ត្រូវតែមកបង្ហាញខ្លួន ។

ក្នុងករណីរឹងទទឹង ចៅក្រមស៊ើបសួរអាចសុំឱ្យកងកម្លាំងសាធារណៈបង្ខំសាក្សីនេះឱ្យចូលមកបង្ហាញខ្លួនបាន ។ ចៅក្រមស៊ើបសួរចេញបញ្ជាឱ្យចូលមកបង្ហាញខ្លួន ។ បញ្ជានេះត្រូវមានអត្តសញ្ញាណរបស់សាក្សី ហើយត្រូវចុះកាលបរិច្ឆេទ និង ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និង មានបោះត្រាផង ។

**មាត្រា ១៥៤.-** សម្បថរបស់សាក្សី

មុននឹងឆ្លើយទៅនឹងសំណួរ សាក្សីម្នាក់ៗ ត្រូវស្បថស្របតាមសាសនា ឬ ជំនឿរបស់ខ្លួនថានិយាយតែការពិត ។ ទម្រង់នៃសម្បថ ត្រូវធ្វើដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃក្រមនេះ ។

**មាត្រា ១៥៥.-** ជំនួយរបស់អ្នកបកប្រែ

ចៅក្រមស៊ើបសួរអាចហៅរកអ្នកបកប្រែ ដើម្បីស្តាប់ចម្លើយសាក្សីដូចបានចែងនៅមាត្រា ១៤៤ (ជំនួយរបស់អ្នកបកប្រែ) នៃក្រមនេះ ។

ROYAUME DU CAMBODGE MINISTERE DU PALAIS ROYAL



93/249

**មាត្រា ១៥៦.-** សាក្សីដែលអនុញ្ញាតឱ្យរួចពីសម្បថ

ត្រូវបានស្ដាប់ចម្លើយដោយមិនចាំបាច់ធ្វើសម្បថ ចំពោះសាក្សីដូចតទៅនេះ :

១-ឪពុក ម្ដាយ និងបុព្វជនគ្រប់រូបរបស់ជនត្រូវចោទ ។

២-កូនប្រុស កូនស្រី និងបច្ឆាជនគ្រប់រូបផ្សេងទៀតរបស់ជនត្រូវចោទ ។

៣-បង ប្អូនប្រុស ស្រីរបស់ជនត្រូវចោទ ។

៤-បង ប្អូនថ្លៃប្រុស ស្រីរបស់ជនត្រូវចោទ ។

៥-ប្ដី ឬ ប្រពន្ធរបស់ជនត្រូវចោទ ទោះបីបានលែងលះគ្នាហើយក៏ដោយ ។

៦-កុមារអាយុតិចជាង ១៤ ឆ្នាំ ។

**មាត្រា ១៥៧.-** ភាពគ្មានលទ្ធភាពស្ដាប់ចម្លើយរបស់សាក្សីមួយចំនួន

ដើម្បីគោរពសិទ្ធិការពារខ្លួន ចៅក្រមស៊ើបសួរមិនអាចស្ដាប់ចម្លើយក្នុងឋានៈជាសាក្សីនូវបុគ្គលណាមួយដែលមានតម្រុយពិរុទ្ធភាពថាបានប្រព្រឹត្តបទល្មើសនោះទេ ។ ក្នុងករណីនេះ ចៅក្រមត្រូវយកនីតិវិធីនៃមាត្រា ១៤៣ (ការជូនដំណឹងអំពីការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ) នៃក្រមនេះមកអនុវត្ត ។

**មាត្រា ១៥៨.-** ការចុះទៅដល់លំនៅឋានរបស់សាក្សី

ប្រសិនបើសាក្សីឈឺ ឬ មិនអាចធ្វើដំណើរបាន ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី អាចចុះទៅកាន់លំនៅឋាន ឬ ទីកន្លែងដែលសាក្សីនោះនៅ ដើម្បីទទួលចម្លើយ ។

## ផ្នែកទី ៥

## ការឆែកឆេរ និងការចាប់យកវត្ថុតាង

**មាត្រា ១៥៩.-** វិធានអនុវត្តចំពោះការឆែកឆេរ

ចៅក្រមស៊ើបសួរអាចធ្វើការឆែកឆេរបាន ។

ចៅក្រមស៊ើបសួរត្រូវឆែកឆេរនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬ បើគ្មានអ្នកកាន់កាប់ទេ ត្រូវធ្វើនៅចំពោះមុខសាក្សី ២ (ពីរ) នាក់ ដែលខ្លួនចាត់តាំង ។ សាក្សីមិនអាចជានគរបាល ឬ ជាកងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ ។

ចៅក្រមស៊ើបសួរមិនអាចផ្ដើមឆែកឆេរមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចបានទេ លើកលែងតែ :



94/240

-ក្នុងករណីឆែកឆេរនៅទីកន្លែងដែលបើកចំហដល់សាធារណជន

-ក្នុងករណីឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ដឹកជញ្ជូន ចែកចាយ ឬ ប្រើប្រាស់គ្រឿងញៀន ។

ការឆែកឆេរនៅក្នុងការិយាល័យមេធាវី ត្រូវធ្វើនៅចំពោះមុខប្រធានគណៈមេធាវី ឬ ប្រតិភូរបស់ប្រធានគណៈមេធាវីនោះ ។

ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុ ស្ដីពីការឆែកឆេរដោយមានចុះហត្ថលេខារបស់ខ្លួន និង ក្រឡាបញ្ជី រួមជាមួយអ្នកកាន់កាប់ទីកន្លែង ឬ សាក្សី២ (ពីរ) នាក់ ។

កំណត់ហេតុត្រូវចុះនិទ្ទេស អំពីអត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬ សាក្សីនីមួយៗ ។ កាលបើការឆែកឆេរប្រព្រឹត្តទៅនៅក្នុងការិយាល័យមេធាវី កំណត់ហេតុត្រូវចុះនិទ្ទេសអំពីវត្តមានរបស់ប្រធានគណៈមេធាវី ឬ របស់ប្រតិភូនៃប្រធានគណៈមេធាវីនេះ ។

**មាត្រា ១៦០.–** ការបិទស្លាកបោះត្រាលើវត្ថុតាង

ចៅក្រមស៊ើបសួរអាចចាប់យកវត្ថុតាង ។ ចៅក្រមស៊ើបសួរត្រូវតែបិទស្លាកបោះត្រាលើវត្ថុ-តាង ។

ក្រោយពីបានបង្ហាញវត្ថុដែលចាប់ដល់អ្នកកាន់កាប់ទីកន្លែង ឬ ដល់សាក្សីទាំង ២ (ពីរ) នាក់រួចមក ចៅក្រមស៊ើបសួរធ្វើកំណត់ហេតុស្ដីពីការចាប់ ដែលរួមមានបញ្ជីសារពើភ័ណ្ឌនៃវត្ថុដែលចាប់យក ។ កំណត់ហេតុស្ដីពីការចាប់នេះ ត្រូវមានចុះហត្ថលេខារបស់ចៅក្រមស៊ើបសួរ និង ក្រឡាបញ្ជី រួមជាមួយអ្នកកាន់កាប់ទីកន្លែង ឬ សាក្សី២ (ពីរ) នាក់ ។ កំណត់ហេតុត្រូវមានចុះនិទ្ទេសអំពីអត្តសញ្ញាណនៃអ្នកកាន់កាប់ទីកន្លែង ឬ សាក្សីនីមួយៗ ។

**មាត្រា ១៦១.–** ការប្រគល់វត្ថុដែលចាប់យកឱ្យទៅម្ចាស់ដើមវិញដោយចៅក្រមស៊ើបសួរ

នៅពេលដែលមិនទាន់ចេញដីកាដំណោះស្រាយរឿងនៅឡើយទេ ចៅក្រមស៊ើបសួរមានសមត្ថកិច្ចប្រគល់សងទៅម្ចាស់ដើមវិញនូវវត្ថុដែលចាប់បាន កាលណាកម្មសិទ្ធិនេះគ្មានការជំទាស់អ្វីប្រាកដប្រជាទេ ។ ចៅក្រមស៊ើបសួរសម្រេចតាមដីកាដែលមានសំអាងហេតុ ក្រោយពីបានទទួលមតិពីព្រះរាជអាជ្ញា ។ ដីកាសម្រេច ត្រូវឱ្យដំណឹងជាបន្ទាន់ដល់អ្នកប្ដឹង និងមេធាវីនៃអ្នកប្ដឹងប្រសិនបើមាន ។

មិនត្រូវប្រគល់សងទៅឱ្យអ្នកប្ដឹងសុំទេ កាលណាវិធានការនេះ អាចបង្កជាឧបសគ្គដល់ការសំដែងឱ្យឃើញការពិត ។



05/240

វត្ថុដែលមានគ្រោះថ្នាក់ដល់បុគ្គល ឬ ទ្រព្យសម្បត្តិដូចជាអាវុធ ឬ ជាតិផ្ទុះ ព្រមទាំងវត្ថុដែលការកាន់កាប់មិនស្របច្បាប់ មិនអាចត្រូវប្រគល់សងទៅឱ្យសាមីខ្លួនបានទេ ។ វត្ថុទាំងនេះត្រូវរឹបអូសជាកម្មសិទ្ធិរបស់រដ្ឋ ។

## ផ្នែកទី ៦

## កោសលវិច័យ

**មាត្រា ១៦២.–** ភាពចាំបាច់នៃការធ្វើកោសលវិច័យ

នៅក្នុងករណីដែលមានបញ្ហាបច្ចេកទេសចោទឡើង ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យធ្វើកោសលវិច័យដោយឯកឯង ឬ តាមពាក្យសុំរបស់ព្រះរាជអាជ្ញារបស់ជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី ។

កាលណាចៅក្រមស៊ើបសួរបដិសេធមិនព្រមធ្វើតាមពាក្យសុំធ្វើកោសលវិច័យទេ ចៅក្រមស៊ើបសួរត្រូវសម្រេចតាមដីកាដោយមានសំអាងហេតុ ។ ដីកាត្រូវសម្រេចក្នុងរយៈពេល ៥(ប្រាំ) ថ្ងៃ ប្រសិនបើពាក្យសុំនោះចេញមកពីព្រះរាជអាជ្ញា និង ១ (មួយ) ខែ ប្រសិនបើពាក្យនោះចេញមកពីជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី ។ ដីកាសម្រេចនេះត្រូវជូនដំណឹងឱ្យដល់អ្នកប្តឹងសុំជាបន្ទាន់ ។

**មាត្រា ១៦៣.–** បញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ

ត្រូវបានបង្កើតឱ្យមានបញ្ជីថ្នាក់ជាតិមួយនៃអ្នកជំនាញ ។ បញ្ជីនេះត្រូវរៀបចំឡើងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ បែបបទនៃការចុះឈ្មោះ ឬ លុបឈ្មោះចេញពីបញ្ជីត្រូវកំណត់ដោយប្រកាស ។

អ្នកជំនាញដែលត្រូវបានចុះឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិ ត្រូវស្បថនៅមុខសាលាឧទ្ធរណ៍ភ្នំពេញ ស្របតាមសាសនា ឬ ជំនឿរបស់ខ្លួនថានឹងផ្តល់ជំនួយដោយស្មោះត្រង់ ដល់ការស្វែងរកយុត្តិធម៌ ។ អ្នកជំនាញដែលត្រូវបានចុះឈ្មោះក្នុងបញ្ជីមិនចាំបាច់ស្បថសាជាថ្មីទៀតទេ នៅពេលណាខ្លួនត្រូវបានគេចាត់តាំងឱ្យធ្វើកោសលវិច័យ ។

**មាត្រា ១៦៤.–** ការចាត់តាំងអ្នកជំនាញដែលមិនស្ថិតក្នុងបញ្ជីថ្នាក់ជាតិ

ចៅក្រមស៊ើបសួរ តាមធម្មតាត្រូវជ្រើសរើសអ្នកជំនាញដែលត្រូវបានចុះឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ ។

96/240

ចៅក្រមស៊ើបសួរ តាមដីកាដោយមានសំអាងហេតុជាពិសេស អាចចាត់តាំងអ្នកជំនាញដែលគ្មានឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិបាន ។ ក្នុងករណីនេះអ្នកជំនាញត្រូវស្បថតាមសាសនា ឬជំនឿរបស់ខ្លួនថា ខ្លួននឹងផ្តល់ជំនួយដោយស្មោះត្រង់ដល់ការស្វែងរកយុត្តិធម៌ ។

**មាត្រា ១៦៥.-** ដីកាចាត់តាំងអ្នកជំនាញ

អ្នកជំនាញត្រូវបានចាត់តាំងតាមដីការបស់ចៅក្រមស៊ើបសួរ ។ ដីកាត្រូវបញ្ជាក់អំពីបេសកកម្មរបស់អ្នកជំនាញព្រមទាំងរយៈពេលដែលត្រូវបំពេញបេសកកម្មនេះ ។

បេសកកម្មអាចទាក់ទងទៅនឹងបញ្ហាដែលមានលក្ខណៈបច្ចេកទេសតែប៉ុណ្ណោះ ។

ប្រសិនបើជាការគួរ ចៅក្រមស៊ើបសួរប្រគល់វត្ថុដែលចាប់បានមួយផ្នែក ឬ ទាំងអស់នោះជូនអ្នកជំនាញ ។ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុស្តីពីការប្រគល់វត្ថុដែលចាប់បាន ។ អ្នកជំនាញអាចបំបែកស្លាកដែលបិទដើម្បីធ្វើកោសល្យវិច័យបាន ។ ប្រសិនបើកោសល្យវិច័យនេះ អាចធ្វើឱ្យខូចខាត ឬវិនាសដល់វត្ថុដែលចាប់បាននោះ អ្នកជំនាញត្រូវជូនព័ត៌មានដល់ចៅក្រមស៊ើបសួរ និងសុំការអនុញ្ញាតពីចៅក្រមនេះ មុននឹងផ្តើមប្រតិបត្តិការរបស់ខ្លួន ។

**មាត្រា ១៦៦.-** ការត្រួតពិនិត្យបេសកកម្មរបស់អ្នកជំនាញដោយចៅក្រមស៊ើបសួរ

អ្នកជំនាញបំពេញបេសកកម្មរបស់ខ្លួន ក្រោមការពិនិត្យរបស់ចៅក្រមស៊ើបសួរ ។ អ្នកជំនាញត្រូវជូនព័ត៌មានដល់ចៅក្រមស៊ើបសួរ អំពីការប្រព្រឹត្តទៅនៃបេសកកម្មរបស់ខ្លួនជាអាទិ៍ ការលំបាកដែលខ្លួនអាចជួបប្រទះ ។

ប្រសិនបើអ្នកជំនាញមិនគោរពរយៈពេលដែលកំណត់ដោយចៅក្រមស៊ើបសួរទេ ចៅក្រមស៊ើបសួរចាត់អ្នកជំនាញផ្សេងទៀតជំនួសអ្នកជំនាញនោះ ។ ប៉ុន្តែ ប្រសិនបើកាលៈទេសៈតម្រូវនោះ ចៅក្រមស៊ើបសួរអាចអនុញ្ញាតតាមដីកាសម្រេចឱ្យធ្វើការពន្យារពេលបាន ។

**មាត្រា ១៦៧.-** កិច្ចដែលចាំបាច់សម្រាប់ការបំពេញបេសកកម្មរបស់អ្នកជំនាញ

ដើម្បីបំពេញបេសកកម្មរបស់ខ្លួន អ្នកជំនាញអាចស្តាប់ចម្លើយបុគ្គលគ្រប់រូបក្រៅពីជនត្រូវចោទ ។ ចម្លើយដែលអ្នកជំនាញបានទទួលនោះ មានតម្លៃត្រឹមតែជាព័ត៌មានធម្មតា ។ បុគ្គលដែលអ្នកជំនាញស្តាប់ចម្លើយនោះ មិនបាច់ស្បថទេ ។

ប្រសិនបើខ្លួនយល់ឃើញថា ចាំបាច់ត្រូវស្តាប់ចម្លើយជនត្រូវចោទ អ្នកជំនាញត្រូវសុំការអនុញ្ញាតពីចៅក្រមស៊ើបសួរ ។ ជនត្រូវចោទអាចសុំឱ្យអ្នកជំនាញស្តាប់ចម្លើយរបស់ខ្លួននៅចំពោះមុខមេធាវី ។

ប៉ុន្តែ កាលណាចៅក្រមស៊ើបសួរចាត់តាំងគ្រូពេទ្យ ឬ អ្នកចិត្តសាស្ត្រដើម្បីពិនិត្យជនត្រូវចោទនោះការពិនិត្យវេជ្ជសាស្ត្រ ឬ ចិត្តសាស្ត្រ ត្រូវធ្វើដោយគ្មានវត្តមានមេធាវី ។

**មាត្រា ១៦៨.–** របាយការណ៍របស់អ្នកជំនាញ

កាលណាប្រតិបត្តិការកោសល្យវិច័យបានបញ្ចប់ អ្នកជំនាញធ្វើរបាយការណ៍ដែលនៅក្នុងនោះ ត្រូវពណ៌នាយ៉ាងច្បាស់លាស់អំពីប្រតិបត្តិការរបស់ខ្លួន ហើយនិងធ្វើសេចក្ដីសន្និដ្ឋាន ។ អ្នកជំនាញត្រូវបញ្ជាក់ថាបានធ្វើដោយផ្ទាល់ខ្លួន នូវប្រតិបត្តិការដែលពណ៌នានៅក្នុងរបាយការណ៍ ។ របាយការណ៍ត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា ។

កាលណាអ្នកជំនាញបានបំបែកស្លាកដើម្បីពិនិត្យវត្ថុដែលចាប់យក អ្នកជំនាញត្រូវចុះនិទ្ទេសអំពីបញ្ហានេះនៅក្នុងរបាយការណ៍របស់ខ្លួន ។

កាលណាអ្នកជំនាញប្រគល់របាយការណ៍របស់ខ្លួននោះ អ្នកជំនាញត្រូវប្រគល់ជូនចៅក្រមស៊ើបសួរវិញនូវវត្ថុដែលចាប់យក ។ ប្រសិនបើស្លាកត្រូវបានបំបែក ចៅក្រមស៊ើបសួរត្រូវបិទស្លាកជាថ្មីនៅលើវត្ថុនោះ ។ កំណត់ហេតុស្ដីពីការប្រគល់សងនូវវត្ថុ និងជាយថាហេតុ ការបិទស្លាកជាថ្មីលើវត្ថុនោះត្រូវតែធ្វើឡើង ។

កាលណាកោសល្យវិច័យធ្វើឱ្យខូចខាត ឬ វិនាសនូវវត្ថុដែលចាប់យក អ្នកជំនាញត្រូវចុះនិទ្ទេសនៅក្នុងរបាយការណ៍របស់ខ្លួនអំពីការអនុញ្ញាតរបស់ចៅក្រមស៊ើបសួរ ដូចមានចែងនៅវាក្យខណ្ឌទី ៣ កថាខណ្ឌទី ៣ មាត្រា ១៦៥ (ដីកាចាត់តាំងអ្នកជំនាញ) នៃក្រមនេះ ។

ក្នុងករណីដែលអាចធ្វើបាននោះ អ្នកជំនាញត្រូវធ្វើសេចក្ដីចម្លងរបាយការណ៍ ហើយផ្ញើនៅចៅក្រមស៊ើបសួរ ។

**មាត្រា ១៦៩.–** ការចាត់តាំងអ្នកជំនាញច្រើនរូប

ប្រសិនបើកាលៈទេសៈតម្រូវ ចៅក្រមស៊ើបសួរអាចចាត់តាំងអ្នកជំនាញច្រើននាក់ ។

នៅក្នុងករណីនេះ ប្រសិនបើអ្នកជំនាញនេះមានយោបល់ខុសគ្នានោះ ម្នាក់ៗត្រូវសរសេរអំពីយោបល់របស់ខ្លួនផ្ទាល់ ឬ ការមិនយល់ព្រមរបស់ខ្លួន ។

**មាត្រា ១៧០.–** ការជូនដំណឹងអំពីសេចក្ដីសន្និដ្ឋាននៃកោសល្យវិច័យ

កាលណារបាយការណ៍កោសល្យវិច័យត្រូវបានធ្វើរួចហើយ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញា ។

របាយការណ៍កោសល្យវិច័យត្រូវដាក់ចូលក្នុងសំណុំរឿងស៊ើបសួរ ។

ចៅក្រមស៊ើបសួរកោះហៅជនត្រូវចោទ និងមេធាវី ដើម្បីប្រាប់ឱ្យដឹងពីសេចក្ដីសន្និដ្ឋាននៃកោសលវិច័យនេះ ។

ចៅក្រមស៊ើបសួរអាចកោះហៅដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវីផងដែរ ដើម្បីប្រាប់ឱ្យដឹងពីសេចក្ដីសន្និដ្ឋាននៃកោសលវិច័យ ។

ចៅក្រមស៊ើបសួរកំណត់រយៈពេលដែលអនុញ្ញាតឱ្យព្រះរាជអាជ្ញា ជនត្រូវចោទ ឬ ដើមបណ្ដឹងរដ្ឋប្បវេណីដាក់ពាក្យសុំធ្វើកោសលវិច័យបន្ថែម ឬ ប្រតិកោសលវិច័យ ។ រយៈពេលនេះមិនអាចតិចជាង ១០ (ដប់) ថ្ងៃទេ ។ ក្នុងរយៈពេលនេះ សំណុំរឿងដែលរួមមានរបាយការណ៍កោសលវិច័យ អាចត្រូវបានពិនិត្យមើលដោយមេធាវី ។

គ្រប់ពាក្យសំដីកោសលវិច័យបន្ថែម ឬ ប្រតិកោសលវិច័យ ត្រូវតែមានសំអាងហេតុនិងធ្វើឡើងជាលាយលក្ខណ៍អក្សរ ។

កាលណាចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំធ្វើកោសលវិច័យបន្ថែម ឬ ប្រតិកោ-សលវិច័យទេ ចៅក្រមស៊ើបសួរត្រូវសម្រេចតាមដីកាដោយមានសំអាងហេតុ ។ ដីកាត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ប្រសិនបើពាក្យសុំចេញមកពីព្រះរាជអាជ្ញា និង ១ (មួយ) ខែ ប្រសិនបើពាក្យនេះចេញពីជនត្រូវចោទ ឬ ដើមបណ្ដឹងរដ្ឋប្បវេណី ។ ដីកា ត្រូវឱ្យដំណឹងជាបន្ទាន់ដល់អ្នកប្ដឹងសុំ ។

គ្រប់ពាក្យសុំធ្វើកោសលវិច័យបន្ថែម ឬ ប្រតិកោសលវិច័យដែលធ្វើឡើងក្រោយផុតរយៈពេលដែលកំណត់ដោយចៅក្រមស៊ើបសួរ ត្រូវដាក់បញ្ចូលក្នុងសំណុំរឿង ។

ប្រសិនបើចៅក្រមស៊ើបសួរដែលបានទទួលពាក្យសុំឱ្យធ្វើកោសលវិច័យ ធ្វើកោសលវិច័យបន្ថែម ឬ ប្រតិកោសលវិច័យ មិនព្រមសម្រេចក្នុងរយៈពេលដែលបានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រា ១៦២ (ភាពចាំបាច់នៃការធ្វើកោសលវិច័យ) នៃក្រមនេះ ឬ ចែងក្នុងមាត្រានេះ អ្នកសុំអាចធ្វើពាក្យប្ដឹងដោយផ្ទាល់តាមរយៈពាក្យសុំដល់សភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ ។

**មាត្រា ១៧១.–** សោហ៊ុយសម្រាប់ធ្វើកោសលវិច័យ

សោហ៊ុយក្នុងការធ្វើកោសលវិច័យជាបន្ទុករបស់អ្នកស្នើសុំ ។

កាលណាចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញា ឬ មន្ត្រីនគរបាលយុត្តិធម៌ ស្នើសុំឱ្យធ្វើកោសល-វិច័យ កោសលវិច័យបន្ថែម ឬ ធ្វើប្រតិកោសលវិច័យ សោហ៊ុយទាំងនេះជាបន្ទុករបស់រដ្ឋ ។

ROYAUME DU CAMBODGE MINISTÈRE DU PALAIS ROYAL



99/240

## ផ្នែកទី ៧
## ការស្ដាប់ទូរស័ព្ទ

**មាត្រា ១៧២.–** ការស្ដាប់ទូរស័ព្ទ ជាអាទិ៍ ដែលបង្គាប់ដោយចៅក្រមស៊ើបសួរ

តាមតម្រូវការចាំបាច់ដើម្បីសំដែងឱ្យឃើញនូវការពិត ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យស្ដាប់ និងថតការសន្ទនាតាមទូរស័ព្ទ ។ ចៅក្រមស៊ើបសួរក៏អាចបង្គាប់ឱ្យចាប់ និងថតគ្រប់ការឆ្លើយឆ្លងគ្នា តាមមធ្យោបាយទូរគមនាគមន៍ផងដែរដូចជា សារតាមទូរសារ ឬ សារតាមអិនធើណែត ។

ចៅក្រមស៊ើបសួរអាចសុំឱ្យគ្រប់អង្គភាពសាធារណៈ ឬ គ្រប់មន្ត្រីរាជការជំនាញតាំងឧបករណ៍បច្ចេកទេស និងធ្វើការថត ។ ចៅក្រមស៊ើបសួរបញ្ជាក់នៅក្នុងដីកាសម្រេចរបស់ខ្លួន អំពីប្រភេទនៃទំនាក់ទំនងដែលត្រូវចាប់ ព្រមទាំងអំពីរយៈពេលនៃបេសកកម្ម ។

អង្គភាពសាធារណៈ មន្ត្រីរាជការដែលចាត់តាំង ត្រូវបំពេញតាមពាក្យសុំរបស់ចៅក្រមស៊ើបសួរ ។ នៅក្នុងពេលអនុវត្តបេសកកម្ម អង្គភាពសាធារណៈ ឬ គ្រប់មន្ត្រីរាជការដែលចាត់តាំងត្រូវជូនព័ត៌មានដល់ចៅក្រមស៊ើបសួរអំពីការប្រព្រឹត្តិទៅនៃបេសកកម្ម ជាអាទិ៍ អំពីការលំបាកជាយថាហេតុ ។ កាលណាបេសកកម្មត្រូវបានបំពេញរួចហើយ អង្គភាពសាធារណៈ ឬ គ្រប់មន្ត្រីរាជការនោះត្រូវចម្លងជាលាយលក្ខណ៍អក្សរនូវសំឡេងដែលថតបាន ។ ការធ្វើឱ្យទៅជាលាយលក្ខណ៍អក្សរនេះ ត្រូវឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនូវខ្លឹមសារនៃសំឡេងដែលថតបាន ។ សំឡេងដែលថតបាននេះត្រូវប្រគល់ជូនចៅក្រមស៊ើបសួរ និងបិទស្លាក ។

គ្រប់ពេលវេលា ចៅក្រមស៊ើបសួរអាចចុះទៅកាន់ទីកន្លែងដែលធ្វើការចាប់ និងថតនោះ ។ ការចូលទៅក្នុងទីកន្លែងទាំងនេះ មិនអាចត្រូវបានហាមឃាត់ដល់ចៅក្រមស៊ើបសួរដោយសំអាងលើមូលហេតុអ្វីបានទេ ទោះបីជាទីកន្លែងយោធាក៏ដោយ ។

ចៅក្រមស៊ើបសួរក៏អាចធ្វើកិច្ចការនេះតាមដីកាចាត់ឱ្យស៊ើបសួរជំនួសបានដែរ ។

## ផ្នែកទី ៨
## ដីកាចាត់ឱ្យស៊ើបសួរជំនួស

**មាត្រា ១៧៣.–** ដីកាចាត់ឱ្យស៊ើបសួរជំនួស

តាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស ចៅក្រមស៊ើបសួរអាចប្រគល់សិទ្ធិឱ្យចៅក្រមនៃតុលាការរបស់ខ្លួន ឬ តុលាការផ្សេងទៀត មន្ត្រីនគរបាលយុត្តិធម៌ ឬ ដល់អង្គភាពនគរបាលយុត្តិធម៌ដើម្បីបំពេញកិច្ចស៊ើបសួរ ។

**មាត្រា ១៧៤.–** អត្ថន័យនៃដីកាចាត់ឱ្យស៊ើបសួរជំនួស

ដីកាចាត់ឱ្យស៊ើបសួរជំនួសបញ្ជាក់អំពីប្រភេទនៃកិច្ចដែលត្រូវធ្វើ ។ កិច្ចនោះត្រូវតែមានទំនាក់ទំនងដោយផ្ទាល់ជាមួយបទល្មើសដែលចោទប្រកាន់ ។ ដីកាចាត់ឱ្យស៊ើបសួរជំនួសមិនអាចមានលក្ខណៈជាទូទៅទេ ត្រូវណែនាំឱ្យបានច្បាស់លាស់ ។

ចៅក្រមស៊ើបសួរកំណត់ថិរវេលាដែលត្រូវអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ។

ដីកាចាត់ឱ្យស៊ើបសួរជំនួសត្រូវមានចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង ។

ចៅក្រមស៊ើបសួរអាចដកហូតដីកាចាត់ឱ្យស៊ើបសួរជំនួសបានគ្រប់ពេលវេលា ។

**មាត្រា ១៧៥.–** ដីកាចាត់ឱ្យស៊ើបសួរជំនួសដែលចេញឱ្យចៅក្រមម្នាក់ទៀត

កាលណាដីកាចាត់ឱ្យស៊ើបសួរជំនួសត្រូវបានចេញឱ្យដល់ចៅក្រមណាម្នាក់ ចៅក្រមរូបនេះប្រើប្រាស់អំណាចទាំងអស់របស់ចៅក្រមស៊ើបសួរ ។

**មាត្រា ១៧៦.–** ដីកាចាត់ឱ្យស៊ើបសួរជំនួសចេញឱ្យមន្ត្រីនគរបាលយុត្តិធម៌

កាលណាដីកាចាត់ឱ្យស៊ើបសួរជំនួសត្រូវបានប្រគល់ឱ្យដល់មន្ត្រីនគរបាលយុត្តិធម៌ នោះមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់អំណាចដែលមានចែងនៅក្នុងមាត្រា ១៧៨ (កំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យ) ដល់មាត្រា ១៨៤ (កំណត់ហេតុកសាងដោយមន្ត្រីនគរបាលយុត្តិធម៌) នៃក្រមនេះ ។

ចំពោះការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ស្ថិតនៅក្រោមអំណាចចៅក្រមស៊ើបសួរ ហើយត្រូវរាយការណ៍ជូនចៅក្រមនេះតែប៉ុណ្ណោះ ។

**មាត្រា ១៧៧.–** ការប្រតិបត្តិដីកាចាត់ឱ្យស៊ើបសួរជំនួសដោយមន្ត្រីនគរបាលយុត្តិធម៌

មន្ត្រីនគរបាលយុត្តិធម៌បំពេញកិច្ចដែលមានចែងនៅក្នុងដីកាចាត់ឱ្យស៊ើបសួរជំនួស នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន លើកលែងតែបទប្បញ្ញត្តិនៃកថាខណ្ឌទី ២ និងទី ៣ មាត្រា ៦៨ (ការពន្លាតសមត្ថកិច្ចដែនដី) នៃក្រមនេះ ។

**មាត្រា ១៧៨.–** កំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យ

មន្ត្រីនគរបាលយុត្តិធម៌ធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួន ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



101/240

**មាត្រា ១៧៩.-** វិធានទាក់ទងនឹងការស្តាប់ចម្លើយដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌

មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយសាក្សី ។

មុននឹងឆ្លើយចំពោះសំណួរ សាក្សីម្នាក់ៗត្រូវស្បថតាមសាសនា ឬ ជំនឿរបស់ខ្លួនថា និយាយតែការពិត ។ ប៉ុន្តែ សាក្សីដែលមានរៀបរាប់នៅមាត្រា ១៥៦ (សាក្សីដែលអនុញ្ញាតឱ្យរួចពីសម្បថ) ត្រូវបានលើកលែងមិនបាច់ធ្វើសម្បថ ។ ដើម្បីគោរពសិទ្ធិការពារខ្លួន មន្ត្រីនគរបាលយុត្តិធម៌មិនអាចស្តាប់ចម្លើយក្នុងឋានៈជាសាក្សី នូវបុគ្គលណាមួយដែលមានតម្រុយនៃពិរុទ្ធភាពលើបុគ្គលនោះទេ ។ កាលណាការស្តាប់ចម្លើយសាក្សីណាម្នាក់ បានធ្វើឱ្យលេចតម្រុយនៃពិរុទ្ធភាពលើសាក្សីនោះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ឈប់ការស្តាប់ ហើយត្រូវរាយការណ៍ជូនចៅក្រមស៊ើបសួរ ។ មន្ត្រីនគរបាលយុត្តិធម៌ អាចហៅអ្នកបកប្រែដែលបានស្បថស្របតាមសាសនា ឬ ជំនឿរបស់ខ្លួនថា ខ្លួននឹងជួយបកប្រែជូនតុលាការឱ្យបានត្រឹមត្រូវ ។

បុគ្គលដែលបានកោះហៅក្នុងឋានៈជាសាក្សី ត្រូវតែចូលបង្ហាញខ្លួន ។ ក្នុងករណីរឹងទទឹង មន្ត្រីនគរបាលយុត្តិធម៌រាយការណ៍ជូនចៅក្រមស៊ើបសួរ ដែលអាចចេញបញ្ជាឱ្យចូលខ្លួន ដោយមានចុះអត្តសញ្ញាណនៃសាក្សី ។ បញ្ជានេះត្រូវមានចុះកាលបរិច្ឆេទ និងហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង ។ បញ្ជាឱ្យចូលបង្ហាញខ្លួន អនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កម្លាំងសាធារណៈ ដើម្បីបង្ខំឱ្យសាក្សីចូលបង្ហាញខ្លួនចំពោះមុខខ្លួន ។

កថាខណ្ឌទី ២ ដល់ទី ៥ នៃមាត្រា ៩៣ (កំណត់ហេតុលើការស្តាប់ចម្លើយ) នៃក្រមនេះ ត្រូវយកមកអនុវត្តលើកំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី ។

**មាត្រា ១៨០.-** ការស្តាប់ចម្លើយដែលពុំអាចធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌

មន្ត្រីនគរបាលយុត្តិធម៌មិនអាចសួរចម្លើយជនត្រូវចោទ ឬ ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីបានទេ ។

**មាត្រា ១៨១.-** ការឆែកឆេរ និងការចាប់យក ដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរ និងចាប់យកវត្ថុតាងនៅក្នុងលក្ខខណ្ឌដែលចែងនៅក្នុងមាត្រា ៩១ (ការឆែកឆេរ) និងមាត្រា ៩២ (ការបិទស្លាកបោះត្រាលើវត្ថុតាង) នៃក្រមនេះ ។ ប៉ុន្តែ ការអនុញ្ញាតដែលមានចែងនៅក្នុងវាក្យខណ្ឌទី ២ កថាខណ្ឌទី ១ មាត្រា ៩១ (ការឆែកឆេរ) នៃក្រមនេះ ត្រូវតែផ្តល់ឱ្យដោយចៅក្រមស៊ើបសួរ ។

**មាត្រា ១៨២.-** ការឃាត់ខ្លួននៅក្នុងក្របខ័ណ្ឌនៃដីកាចាត់ឱ្យស៊ើបសួរជំនួស

បទប្បញ្ញត្តិនៃមាត្រា ៩៦ (ការឃាត់ខ្លួន) ដល់មាត្រា ១០២ (កំណត់ហេតុសរុបនៃការឃាត់ខ្លួន) ស្ដីអំពីការឃាត់ខ្លួន ត្រូវយកមកអនុវត្តនៅក្នុងក្របខ័ណ្ឌនៃការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ។ ប៉ុន្តែ អំណាចដែលប្រគល់ដោយមាត្រាទាំងនេះដល់ព្រះរាជអាជ្ញា ត្រូវបានប្រើប្រាស់ដោយចៅក្រមស៊ើបសួរ ។ សម្រាប់ការអនុវត្តមាត្រា ១០៣ (ការបញ្ជូនខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន) និងមាត្រា ១០៤ (រយៈពេលនៃការបញ្ជូនខ្លួន) នៃក្រមនេះ នៅពេលផុតកំណត់នៃការឃាត់ខ្លួន ជនដែលត្រូវបានឃាត់ខ្លួន ត្រូវតែនាំទៅបង្ហាញខ្លួន នៅចំពោះមុខចៅក្រមស៊ើបសួរ ។

**មាត្រា ១៨៣.-** ការស្ដាប់ទូរស័ព្ទ ជាអាទិ៍នៅក្នុងក្របខ័ណ្ឌនៃដីកាចាត់ឱ្យស៊ើបសួរជំនួស

កាលណាដីកាចាត់ឱ្យស៊ើបសួរជំនួសបានចែងអំពីការស្ដាប់ និងការថតការសន្ទនាតាមទូរស័ព្ទ ឬ ការចាប់ និងការថតគ្រប់ការឆ្លើយឆ្លងតាមមធ្យោបាយទូរគមនាគមន៍ ដូចជាសារតាមទូរសារ ឬ សារតាមអ៊ិនធើណែត មន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់អំណាចដែលប្រគល់ឱ្យចៅក្រមស៊ើបសួរដោយវាក្យខណ្ឌទី ២ កថាខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃមាត្រា ១៧២ (ការស្ដាប់ទូរស័ព្ទ ជាអាទិ៍ ដែលបង្គាប់ដោយចៅក្រមស៊ើបសួរ) នៃក្រមនេះ ។

**មាត្រា ១៨៤.-** កំណត់ហេតុកសាងដោយមន្ត្រីនគរបាលយុត្តិធម៌

កំណត់ហេតុដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ នៅក្នុងក្របខ័ណ្ឌនៃការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃមាត្រា ១០៨ (និទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ) នៃក្រមនេះ ។

## ជំពូកទី ៣

## វិធានការនិរន្តរាយ

### ផ្នែកទី ១

### ដីកា

**មាត្រា ១៨៥.-** ការចេញដីកា

ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យចូលខ្លួន ដីកាបង្គាប់ឱ្យនាំខ្លួន ដីកាបង្គាប់ឱ្យចាប់ខ្លួន និងដីកាបង្គាប់ឱ្យឃុំខ្លួន ។



103/290

## ផ្នែកទី ២

## ដីកាបង្គាប់ឱ្យចូលខ្លួន

**មាត្រា ១៨៦.–** ដីកាបង្គាប់ឱ្យចូលខ្លួន

ចៅក្រមស៊ើបសួរ អាចចេញដីកាបង្គាប់ឱ្យចូលខ្លួន ។

ដីកាបង្គាប់ឱ្យចូលខ្លួន គឺជាបញ្ជាដល់បុគ្គលណាម្នាក់ឱ្យចូលទៅបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ ។

ដីកាបង្គាប់ឱ្យចូលខ្លួន អាចចេញទៅលើជនត្រូវចោទ ឬ ទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព ។

**មាត្រា ១៨៧.–** និទ្ទេសដែលត្រូវចុះលើដីកាបង្គាប់ឱ្យចូលខ្លួន

ដីកាបង្គាប់ឱ្យចូលខ្លួន មាននិទ្ទេសដូចតទៅ :

-អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ

-បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ

-ថ្ងៃ ខែ ឆ្នាំ ម៉ោង និងទីកន្លែងដែលត្រូវចូលបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ

-ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា ។

ដីកាបង្គាប់ឱ្យចូលខ្លួនត្រូវមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និង មានបោះត្រាផង ។

**មាត្រា ១៨៨.–** ការជូនដំណឹងអំពីដីកាបង្គាប់ឱ្យចូលខ្លួន

ដីកាបង្គាប់ឱ្យចូលខ្លួន ត្រូវឱ្យដំណឹងដល់បុគ្គលដែលពាក់ព័ន្ធ ដោយមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬ ដោយអាជ្ញាសាលា ។

បុគ្គលដែលពាក់ព័ន្ធទទួលចុងដីកា ហើយត្រូវចុះហត្ថលេខានៅលើដើមដីកា ដែលត្រូវបង្វិលជូនចៅក្រមស៊ើបសួរវិញ ។

មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬ អាជ្ញាសាលាត្រូវជូនដំណឹងដល់ចៅក្រមស៊ើបសួរអំពីគ្រប់ការលំបាកក្នុងការអនុវត្តបេសកកម្មរបស់ខ្លួន ។

## ផ្នែកទី ៣

## ដីកាបង្គាប់ឱ្យនាំខ្លួន

**មាត្រា ១៨៩.–** ការចេញដីកាបង្គាប់ឱ្យនាំខ្លួនដោយចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យនាំខ្លួន ។

**មាត្រា ១៩០.–** ដីកាបង្គាប់ឱ្យនាំខ្លួន

ដីកាបង្គាប់ឱ្យនាំខ្លួន គឺជាបញ្ជាដល់កងកម្លាំងសាធារណៈឱ្យចាប់ និងនាំខ្លួនបុគ្គលណាម្នាក់ទៅចំពោះមុខចៅក្រមស៊ើបសួរ ។

ដីកាបង្គាប់ឱ្យនាំខ្លួន អាចត្រូវចេញទៅលើជនត្រូវចោទ ឬ ទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព ។

**មាត្រា ១៩១.–** និទ្ទេសដែលត្រូវចុះលើដីកាបង្គាប់ឱ្យនាំខ្លួន

ដីកាបង្គាប់ឱ្យនាំខ្លួន មាននិទ្ទេសដូចតទៅ :

-អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ

-បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ

-ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា ។

ដីកាបង្គាប់ឱ្យនាំខ្លួន ត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង ។

**មាត្រា ១៩២.–** ការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន

ការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ត្រូវប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌ ។

ក្នុងករណីបន្ទាន់ ដីកាបង្គាប់ឱ្យនាំខ្លួន ត្រូវផ្សព្វផ្សាយដល់អង្គភាពនគរបាល ឬ កងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយ ។ ដើមដីកានេះ ត្រូវប្រគល់ជូនជាបន្ទាន់ដល់មន្ត្រីនគរបាលយុត្តិធម៌ ដែលទទួលបន្ទុកអនុវត្តដីកានោះ ។ មន្ត្រីនគរបាលយុត្តិធម៌មិនអាចចូលទៅក្នុងលំនៅឋានរបស់បុគ្គលដែលពាក់ព័ន្ធមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចបានទេ ។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងដល់ចៅក្រមស៊ើបសួរអំពីការលំបាកក្នុងការអនុវត្តបេសកកម្មរបស់ខ្លួន ។

**មាត្រា ១៩៣.–** ការបង្ហាញខ្លួនតាមដីកាបង្គាប់ឱ្យនាំខ្លួន

ប្រសិនបើដោយមូលហេតុនៃកាលៈទេសៈ បុគ្គលដែលពាក់ព័ន្ធមិនអាចត្រូវនាំទៅបង្ហាញខ្លួនដល់ចៅក្រមស៊ើបសួរក្រោយពេលចាប់ខ្លួនបានទេ បុគ្គលនេះត្រូវតែនាំខ្លួនទៅក្នុងអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ ក្នុងមណ្ឌលឃុំខ្លួន ឬ ទៅក្នុងពន្ធនាគារ ។ បុគ្គលនេះ ត្រូវតែនាំខ្លួនទៅបង្ហាញខ្លួនយ៉ាងយូរបំផុតថ្ងៃបន្ទាប់ដល់ចៅក្រមស៊ើបសួរ ឬ ដល់អ្នកជំនួស ។ ប្រសិនបើការបង្ហាញខ្លួនមិនបានប្រព្រឹត្តទៅនៅថ្ងៃបន្ទាប់ទេ បុគ្គលពាក់ព័ន្ធត្រូវបានដោះលែងឱ្យមានសេរីភាពវិញ ។

**មាត្រា ១៩៤.–** ការគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន

កាលណាបុគ្គលណាម្នាក់ ដែលត្រូវបានចាប់ខ្លួនដោយអនុវត្តតាមដីកាបង្គាប់ឱ្យនាំខ្លួនត្រូវបានឃុំខ្លួននោះ ថិរវេលានៃការឃុំខ្លួននេះត្រូវរាប់បញ្ចូលទៅក្នុងថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ប្រសិនបើមាន ។

## ផ្នែកទី ៤
## ដីកាបង្គាប់ឱ្យចាប់ខ្លួន

**មាត្រា ១៩៥.–** ការចេញដីកាបង្គាប់ឱ្យចាប់ខ្លួនដោយចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យចាប់ខ្លួន ។

**មាត្រា ១៩៦.–** ដីកាបង្គាប់ឱ្យចាប់ខ្លួន

ដីកាបង្គាប់ឱ្យចាប់ខ្លួនអាចត្រូវចេញទៅលើជនត្រូវចោទ ឬ បុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព ។

ចៅក្រមស៊ើបសួរ នឹងអាចចេញដីកាបង្គាប់ឱ្យចាប់ខ្លួនបាន លុះត្រាតែ :

១-បទល្មើសដែលចោទប្រកាន់ ជាបទឧក្រិដ្ឋ ឬ បទមជ្ឈិម ដែលត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ ។

២-បុគ្គលដែលពាក់ព័ន្ធ បានគេចខ្លួនមិនដឹងជាស្ថិតនៅទីកន្លែងណា ឬ ស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

ដីកាបង្គាប់ឱ្យចាប់ខ្លួន គឺជាបញ្ជា :

-ដល់កងកម្លាំងសាធារណៈឱ្យស្រាវជ្រាវរកចាប់ និងឱ្យនាំខ្លួនបុគ្គលនោះ ទៅក្នុង



106/240

ពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន

-ដល់ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនឱ្យទទួល និងឃុំខ្លួនបុគ្គលនោះ ។

**មាត្រា ១៩៧.-** ដីកាបង្គាប់ឱ្យចាប់ខ្លួន និងយោបល់របស់ព្រះរាជអាជ្ញា

មុននឹងចេញដីកាបង្គាប់ឱ្យចាប់ខ្លួន ចៅក្រមស៊ើបសួរត្រូវតែទទួលយោបល់ព្រះរាជអាជ្ញា ។ ចៅក្រមស៊ើបសួរត្រូវចេញដីកានេះដោយមានចែងមូលហេតុ ក្រោយពីបានទទួលយោបល់ពីព្រះរាជអាជ្ញា ។

ព្រះរាជអាជ្ញា ធានារ៉ាប់រងផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួន ។

**មាត្រា ១៩៨.-** និទ្ទេសដែលត្រូវចុះលើដីកាបង្គាប់ឱ្យចាប់ខ្លួន

ដីកាបង្គាប់ឱ្យចាប់ខ្លួនមាននិទ្ទេសដូចតទៅ :

-អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ

-បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់បង្ក្រាបបទល្មើសនេះ

-ឈ្មោះ និងឋានៈចៅក្រមដែលចេញដីកា ។

ដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និង ត្រូវមានបោះត្រាផង ។

**មាត្រា ១៩៩.-** ការអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួន

ការអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌ ។

ក្នុងករណីបន្ទាន់ ដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវផ្សព្វផ្សាយទៅតាមអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ តាមគ្រប់មធ្យោបាយ ។ ដើមដីកា ត្រូវប្រគល់ក្នុងរយៈពេលយ៉ាងខ្លីបំផុតឱ្យដល់មន្ត្រីនគរបាលយុត្តិធម៌ ដែលទទួលបន្ទុកអនុវត្តដីកានោះ ។

មន្ត្រីនគរបាលយុត្តិធម៌ មិនអាចចូលទៅក្នុងលំនៅឋានរបស់បុគ្គលដែលពាក់ព័ន្ធមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចបានទេ ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវឱ្យដំណឹងដល់ចៅក្រមស៊ើបសួរអំពីការលំបាកទាំងអស់ក្នុងពេលអនុវត្តបេសកកម្មរបស់ខ្លួន ។

**មាត្រា ២០០.-** ការផ្សព្វផ្សាយជាអន្តរជាតិនូវដីកាបង្គាប់ឱ្យចាប់ខ្លួន

ក្នុងករណីចាំបាច់ ដីកាបង្គាប់ឱ្យចាប់ខ្លួន អាចផ្សព្វផ្សាយជាអន្តរជាតិតាមរយៈក្រសួងយុត្តិធម៌ ដោយប្រើមធ្យោបាយនានាដែលមានប្រសិទ្ធភាព ។

**មាត្រា ២០១.-** ការបង្ហាញខ្លួនតាមដីកាបង្គាប់ឱ្យចាប់ខ្លួន

ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ត្រូវតែទទួល និងឃុំខ្លួនជនត្រូវចោទដែលជាកម្មវត្ថុនៃដីកាបង្គាប់ឱ្យចាប់ខ្លួន ។ ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនរក្សាទុកដើមដីកា ឬ ចុងដីកា ដែលមានបញ្ជាក់ថា ត្រឹមត្រូវតាមច្បាប់ដើម ។

បុគ្គលដែលពាក់ព័ន្ធត្រូវតែបានគេនាំទៅបង្ហាញដល់ចៅក្រមស៊ើបសួរ ឬ អ្នកជំនួសចៅក្រមស៊ើបសួរក្នុងរយៈពេលយ៉ាងខ្លីបំផុត ប្រសិនបើស្ថិតក្នុងដំណាក់កាលស៊ើបសួរនៅឡើយ ។

ប្រសិនបើការនាំខ្លួនទៅបង្ហាញនេះ តម្រូវឱ្យមានការផ្ទេរបុគ្គលពាក់ព័ន្ធទៅពន្ធនាគារ ឬ ទៅមណ្ឌលឃុំខ្លួនមួយផ្សេងទៀត ការផ្ទេរនេះត្រូវចាត់ចែងដោយអយ្យការ ។

ប្រសិនបើបុគ្គលពាក់ព័ន្ធមិនត្រូវបានគេនាំខ្លួនទៅបង្ហាញដល់ចៅក្រមស៊ើបសួរ ឬ អ្នកជំនួសចៅក្រមស៊ើបសួរ នៅថ្ងៃបន្ទាប់ពីការចាប់ខ្លួន បុគ្គលនេះត្រូវតែបានព្រះរាជអាជ្ញានាំទីកន្លែងឃុំខ្លួនស្ដាប់ចម្លើយ ។ ព្រះរាជអាជ្ញានេះធ្វើកំណត់ហេតុស្ដីពីការស្ដាប់ចម្លើយ ដែលត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ ។

**មាត្រា ២០២.-** ការគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន

កាលណាបុគ្គលណាម្នាក់ដែលត្រូវបានចាប់ខ្លួន ដោយអនុវត្តតាមដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវបានឃុំខ្លួន នោះថិរវេលានៃការឃុំខ្លួននេះត្រូវរាប់បញ្ចូលទៅក្នុងថិរវេលានៃការឃុំខ្លួនបណ្ដោះ-អាសន្ន ប្រសិនបើមាន ។

## ផ្នែកទី ៥

## ការឃុំខ្លួនបណ្ដោះអាសន្ន

**មាត្រា ២០៣.-** គោលការណ៍នៃការឃុំខ្លួនបណ្ដោះអាសន្ន

ជាគោលការណ៍ ជនត្រូវចោទត្រូវតែមានសេរីភាព ។ ក្នុងករណីពិសេស ជនត្រូវចោទអាចត្រូវឃុំខ្លួនបណ្ដោះអាសន្ន នៅក្នុងលក្ខខណ្ឌដែលបានចែងនៅក្នុងផ្នែកនេះ ។

**មាត្រា ២០៤.-** ករណីនៃការឃុំខ្លួនបណ្ដោះអាសន្ន

ការឃុំខ្លួនបណ្ដោះអាសន្ន អាចអនុវត្តបានតែក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬ បទមជ្ឈិម ដែលច្បាប់កំណត់ផ្ដន្ទាទោសដាក់ពន្ធនាគារស្មើ ឬ លើសពី ១ (មួយ) ឆ្នាំ ។

**មាត្រា ២០៥.–** មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន

ការឃុំខ្លួនបណ្តោះអាសន្នអាចត្រូវបានបង្គាប់ កាលណាការឃុំខ្លួនបណ្តោះអាសន្ននេះជាការចាំបាច់ :

១-ដើម្បីបញ្ចប់បទល្មើស ឬ បង្ការបទល្មើសកុំឱ្យកើតជាថ្មី ។

២-ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬ ជនរងគ្រោះ ឬ ដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត ។

៣-ដើម្បីរក្សាភស្តុតាង ឬ តម្រុយជាសម្ភារៈ ។

៤-ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី ។

៥-ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ ។

៦-ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឱ្យមានការច្របូកច្របល់ ដែលបណ្តាលមកពីបទល្មើស ។

**មាត្រា ២០៦.–** កំណត់សម្គាល់របស់ជនត្រូវចោទ និងការប្រាប់ហេតុផលនៃដីកា

ចៅក្រមស៊ើបសួរដែលសម្រេចថានឹងត្រូវឃុំខ្លួនបណ្តោះអាសន្ន ដោយគំនិតផ្តើមរបស់ខ្លួនផ្ទាល់ ឬ តាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ត្រូវឱ្យដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សម្គាល់របស់ជនត្រូវចោទនេះ ។ កាលណាជនត្រូវចោទមានមេធាវីអមផងនោះ មេធាវីត្រូវបង្ហាញមធ្យោបាយការពារខ្លួន ។

ចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ន តាមដីកាដោយមានសំអាងហេតុ ។ នៅក្នុងដីកានេះ ចៅក្រមស៊ើបសួរត្រូវយោងតាមបញ្ញត្តិនៃមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន) នៃក្រមនេះ ។ ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន ត្រូវបានជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ ។

ចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឱ្យឃុំខ្លួន ដូចបានចែងនៅក្នុងមាត្រា ២២០ (និយមន័យដីកាបង្គាប់ឱ្យឃុំខ្លួន) មាត្រា ២២១ (និទ្ទេសដែលត្រូវចុះលើដីកាបង្គាប់ឱ្យឃុំខ្លួន) និងមាត្រា ២២២ (ការអនុវត្តដីកាបង្គាប់ឱ្យឃុំខ្លួន).នៃក្រមនេះ ។

**មាត្រា ២០៧.–** ដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន

កាលណាចៅក្រមស៊ើបសួរ ដែលទទួលបណ្តឹងតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាដែលសុំឱ្យឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ននោះ មិនព្រមធ្វើតាមការសុំឱ្យឃុំខ្លួននោះទេ ចៅក្រម



109/240

ស៊ើបសួរ ត្រូវចេញក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ នូវដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន ដោយមិនចាំបាច់មានសំអាងហេតុទេ ។ ដីកានេះត្រូវជូនដំណឹងជាបន្ទាន់ដល់អ្នកប្ដឹងសុំ ។

ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចនៅក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ព្រះរាជអាជ្ញាអាចធ្វើពាក្យប្ដឹងទៅសភាស៊ើបសួរ ដែលនឹងសម្រេចជំនួសចៅក្រមស៊ើបសួរ ។

**មាត្រា ២០៨.–** ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋ

ចំពោះនីតិជនដែលត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ ការឃុំខ្លួនបណ្ដោះអាសន្ន មិនអាចលើសពី ៦ (ប្រាំមួយ) ខែ បានទេ ។ ប៉ុន្តែ នៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួនបណ្ដោះអាសន្នម្ដងបាន ៦ (ប្រាំមួយ) ខែ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់ ។

ចៅក្រមស៊ើបសួរអាចសម្រេចពន្យារការឃុំខ្លួនបណ្ដោះអាសន្នបានតែ ២ (ពីរ) ដងគត់ ។

**មាត្រា ២០៩.–** ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទមជ្ឈិម

ចំពោះនីតិជនដែលត្រូវចោទប្រកាន់ពីបទមជ្ឈិម ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ (បួន) ខែ បានទេ ។ ប៉ុន្តែ នៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួនបណ្ដោះអាសន្នបានតែម្ដងគត់មិនឱ្យលើសពី ២ (ពីរ) ខែ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់ ។

ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នខាងលើនេះ មិនត្រូវលើសពីពាក់កណ្ដាលនៃអប្ប-បរមានៃទោសដែលច្បាប់បានកំណត់ឡើយ ។

**មាត្រា ២១០.–** ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ននៅក្នុងករណីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ជាអាទិ៍

ក្នុងករណីដែលមានការចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋប្រល័យពូជសាសន៍ ឬ បទឧក្រិដ្ឋសង្គ្រាម ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ១ (មួយ) ឆ្នាំបានទេ ចំពោះបទល្មើសនីមួយៗ ។ ប៉ុន្តែ នៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួនបណ្ដោះអាសន្នម្ដងបាន ១ (មួយ) ឆ្នាំ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់ ។

ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យពន្យារការឃុំខ្លួនបណ្ដោះអាសន្ននេះបានតែ ២ (ពីរ) ដងគត់ ។

110/240

**មាត្រា ២១១.-** ការពន្យារពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន

កាលណាចៅក្រមស៊ើបសួរសម្រេចថាពន្យារពេលឃុំខ្លួនជាបណ្ដោះអាសន្ន ចៅក្រមស៊ើបសួរត្រូវឱ្យដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សំគាល់របស់ជននេះ ។ កាលណាជនត្រូវចោទមានមេធាវីអម នោះមេធាវីត្រូវបង្ហាញមធ្យោបាយការពារខ្លួនក្តីរបស់ខ្លួន ។

ចៅក្រមស៊ើបសួរពន្យារការឃុំខ្លួនបណ្ដោះអាសន្ន តាមដីកាដោយមានសំអាងហេតុ ។ នៅក្នុងដីកានេះ ចៅក្រមស៊ើបសួរត្រូវយោងទៅតាមបទប្បញ្ញត្តិនៃមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន) នៃក្រមនេះ ។ ដីកានេះត្រូវឱ្យដំណឹងជាបន្ទាន់ដល់ជនត្រូវចោទ ។

**មាត្រា ២១២.-** សេចក្តីសម្រេចទាក់ទងនឹងអនីតិជនមានអាយុតិចជាង ១៤ (ដប់បួន) ឆ្នាំ

អនីតិជនអាយុតិចជាង ១៤ (ដប់បួន) ឆ្នាំ មិនអាចត្រូវឃុំខ្លួនបណ្ដោះអាសន្នទេ ។ ចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អនីតិជននេះឱ្យឪពុកម្ដាយ អ្នកអាណាព្យាបាល ឬ ក្នុងករណីគ្មានអ្នកអាណាព្យាបាល ត្រូវប្រគល់ទៅមជ្ឈមណ្ឌលអប់រំថែរក្សាបណ្ដោះអាសន្ន រង់ចាំសេចក្តីសម្រេចរបស់តុលាការ ។

**មាត្រា ២១៣.-** ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋទាក់ទងនឹងអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ

ចំពោះអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ និងត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ ថិរវេលាឃុំខ្លួនបណ្ដោះអាសន្ន មានដូចតទៅ :

១-ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ (បួន) ខែ បានទេ កាលណាអនីតិជននេះ មានអាយុតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ ។

២-ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៦ (ប្រាំមួយ) ខែ បានទេ កាលណាអនីតិជននេះ មានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។

**មាត្រា ២១៤.-** ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទមជ្ឈិមទាក់ទងនឹងអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ

ចំពោះអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ និងត្រូវចោទប្រកាន់ពីបទមជ្ឈិម ថិរវេលាឃុំខ្លួនបណ្ដោះអាសន្ន មានដូចតទៅ :

១-ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ២ (ពីរ) ខែ បានទេ កាលណាអនីតិជននេះ មានអាយុតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

២-ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ (បួន) ខែ បានទេ កាលណាអនីតិជននេះ មានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។

ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នតាមចំណុចទី ១ និងចំណុចទី ២ ខាងលើនេះ មិនត្រូវលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់សម្រាប់អនីតិជននោះឡើយ ។

**មាត្រា ២១៥.–** ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំដោយចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យដោះលែងជនត្រូវចោទ ឱ្យនៅក្រៅឃុំវិញបានគ្រប់ពេលវេលា ។

កាលណាចៅក្រមស៊ើបសួរមានបំណងដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំនោះ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញា ដើម្បីសុំយោបល់ហើយបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ ។ ព្រះរាជអាជ្ញាត្រូវផ្ដល់យោបល់របស់ខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុត ។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ។

ក្នុងករណីបន្ទាន់ចៅក្រមស៊ើបសួរ អាចបង្គាប់ឱ្យដោះលែងជនត្រូវចោទភ្លាម ដោយមិនរង់ចាំយោបល់របស់ព្រះរាជអាជ្ញា ។ ចៅក្រមស៊ើបសួរត្រូវចង្អុលប្រាប់មូលហេតុនៃការបន្ទាន់នេះនៅក្នុងដីកាសម្រេចរបស់ខ្លួន ។

**មាត្រា ២១៦.–** ការដោះលែងឱ្យនៅក្រៅឃុំ តាមបណ្ដឹងរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាអាចសុំឱ្យដោះលែងជនត្រូវចោទបានគ្រប់ពេលវេលា ។ ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ។

ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្ដឹងសុំតាមរយៈពាក្យសុំទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ ។

ដីកាដែលសម្រេចមិនព្រមដោះលែងត្រូវមានសំអាងហេតុ ។

**មាត្រា ២១៧.–** ការដោះលែងឱ្យនៅក្រៅឃុំ តាមបណ្ដឹងរបស់ជនត្រូវចោទ

ជនត្រូវចោទអាចដាក់ពាក្យសុំឱ្យដោះលែងនៅក្រៅឃុំបានគ្រប់ពេលវេលា ។ ចៅក្រមស៊ើបសួរបញ្ជូនពាក្យនោះភ្លាមទៅព្រះរាជអាជ្ញា ដើម្បីផ្ដល់យោបល់ និងបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ ។ ព្រះរាជអាជ្ញាត្រូវផ្ដល់យោបល់ក្នុងរយៈពេលខ្លីបំផុត ។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីពេលបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ។

ជនត្រូវចោទអាចដាក់ពាក្យសុំនៅក្រៅឃុំសាជាថ្មីម្តងទៀត ទៅចៅក្រមស៊ើបសួរ ឬ ទៅសភាស៊ើបសួរក្នុងរយៈពេល ១ (មួយ) ខែ បន្ទាប់ពីមានសេចក្តីសម្រេចបដិសេធពាក្យសុំលើកមុន ។ ចៅក្រមស៊ើបសួរ ឬ សភាស៊ើបសួរ ត្រូវសម្រេចលើពាក្យនេះក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំ ។

ដីកាដែលមិនព្រមដោះលែងឱ្យនៅក្រៅឃុំត្រូវតែមានសំអាងហេតុ ។

ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេ ជនត្រូវចោទអាចធ្វើពាក្យប្តឹងផ្ទាល់ទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ ។

**មាត្រា ២១៨.-** ការជូនដំណឹងអំពីដីកាដោះលែងឱ្យនៅក្រៅឃុំ

ដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំត្រូវតែជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងដល់ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ។ បទប្បញ្ញត្តិនៃមាត្រា ២៧៦ (ការដោះលែងជនត្រូវចោទដែលជាប់ឃុំឱ្យមានសេរីភាព) នៃក្រមនេះ ត្រូវយកមកអនុវត្ត ។

ដីកាមិនព្រមដោះលែងឱ្យនៅក្រៅឃុំ ត្រូវតែជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ ។

កាលណាចៅក្រមស៊ើបសួរសម្រេចឱ្យដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ ចៅក្រមនេះអាចដាក់ជននោះឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ក្នុងលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ២២៣ (កាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ) ដល់មាត្រា ២៣០ (ការគេចវេះរបស់ជនត្រូវចោទពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ) នៃក្រមនេះ ។

## ផ្នែកទី ៦

## ដីកាបង្គាប់ឱ្យឃុំខ្លួន

**មាត្រា ២១៩.-** ការចេញដីកាបង្គាប់ឱ្យឃុំខ្លួនដោយចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យឃុំខ្លួន ។

**មាត្រា ២២០.-** និយមន័យដីកាបង្គាប់ឱ្យឃុំខ្លួន

ដីកាបង្គាប់ឱ្យឃុំខ្លួន គឺជាបញ្ជាដល់ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនឱ្យទទួល និងឱ្យឃុំខ្លួនជនត្រូវចោទ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ចៅក្រមស៊ើបសួរអាចនឹងចេញដីកាបង្គាប់ឱ្យឃុំខ្លួនបាន លុះត្រាតែជនត្រូវចោទជាកម្មវត្ថុនៃដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន ។

**មាត្រា ២២១.-** និទ្ទេសដែលត្រូវចុះលើដីកាបង្គាប់ឱ្យឃុំខ្លួន

ដីកាបង្គាប់ឱ្យឃុំខ្លួនមានចុះនិទ្ទេសដូចតទៅ :

-អត្តសញ្ញាណរបស់ជនត្រូវចោទ

-ប្រភេទនៃបទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ

-ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា ។

ដីកាបង្គាប់ឱ្យឃុំខ្លួនត្រូវមានចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រា ។

**មាត្រា ២២២.-** ការអនុវត្តដីកាបង្គាប់ឱ្យឃុំខ្លួន

ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនត្រូវតែទទួល និងឃុំខ្លួនបុគ្គលដែលមានដីកាបង្គាប់ឱ្យឃុំខ្លួនរហូតទាល់តែបានទទួលការឱ្យដំណឹងអំពីការដោះលែងឱ្យមានសេរីភាពវិញ ។ ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន រក្សាទុកដើមដីកាបង្គាប់ឱ្យឃុំខ្លួន ឬ ចុងដីកានេះ ដែលបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម ។

## ផ្នែកទី ៧
## ការត្រួតពិនិត្យតាមផ្លូវតុលាការ

**មាត្រា ២២៣.-** កាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ

ចៅក្រមស៊ើបសួរអាចដាក់ជនត្រូវចោទ ឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា ប្រសិនបើជនត្រូវចោទនេះត្រូវបានចោទប្រកាន់អំពីបទល្មើស ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ។

ការត្រួតពិនិត្យតាមផ្លូវតុលាការ មានអានុភាពបង្គាប់ជនត្រូវចោទដែលនៅក្រៅឃុំឱ្យគោរពកាតព្វកិច្ចមួយ ឬ ច្រើនដូចតទៅ :

១-មិនត្រូវចេញក្រៅព្រំប្រទល់ដែនដីកំណត់ដោយចៅក្រមស៊ើបសួរ ។

២-មិនត្រូវផ្លាស់ប្តូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ ។



114/249

៣-មិនត្រូវទៅកាន់ទីកន្លែងខ្លះដែលកំណត់ដោយចៅក្រមស៊ើបសួរ ។

៤-ត្រូវចូលបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ ដែលចាត់តាំងដោយចៅក្រមស៊ើបសួរ ។

៥-ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។

៦-ប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីគ្រប់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ ។

៧-មិនត្រូវបើកបររថយន្ត ។

៨-មិនត្រូវទទួល ឬ ជួបបុគ្គលមួយចំនួន ដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ ។

៩-ដាក់ប្រាក់ធានាដែលចំនួនប្រាក់ធានា និងថិរវេលាបង់ប្រាក់នេះ ត្រូវបានកំណត់ ដោយចៅក្រមស៊ើបសួរដោយផ្អែកទៅលើធនធានរបស់ជនត្រូវចោទ ។

១០-មិនត្រូវកាន់កាប់ ឬ យកតាមខ្លួននូវអាវុធ ។ ត្រូវប្រគល់ជូនដល់ការិយាល័យ ក្រឡាបញ្ជីនូវអាវុធដែលជនត្រូវចោទកាន់កាប់ ។

១១-ត្រូវប្រគល់ខ្លួនឱ្យពេទ្យពិនិត្យព្យាបាល និងជាយថាហេតុ ដាក់ឱ្យស្ថិតនៅក្រោម របបព្យាបាលរោគក្នុងមន្ទីរពេទ្យ ។

១២-មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះ ។

ដើម្បីអនុវត្តចំណុចទី ១២ ខាងលើ ចៅក្រមស៊ើបសួរមិនអាចហាមឃាត់ការអនុវត្តនូវ អាណត្តិបោះឆ្នោត ឬ សកម្មភាពខាងសហជីពបានទេ ។

**មាត្រា ២២៤.-** ការមិនអនុវត្តការត្រួតពិនិត្យតាមផ្លូវតុលាការ ចំពោះអនីតិជនមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ

អនីតិជនអាយុតិចជាង ១៤ (ដប់បួន) ឆ្នាំ មិនអាចត្រូវដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ តាមផ្លូវតុលាការបានទេ ។

**មាត្រា ២២៥.-** ការប្រគល់បង្កាន់ដៃ

នៅក្នុងករណីដែលមានចែងត្រង់ចំណុចទី ៦ ទី ៩ និងចំណុចទី ១០ នៃមាត្រា ២២៣ (កាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ) ខាងលើនេះ ជនត្រូវចោទទទួលបង្កាន់ដៃស្តីពីការប្រគល់ ឯកសារអត្តសញ្ញាណ ប្រាក់ធានា ឬ អាវុធ ។ បង្កាន់ដៃប្រគល់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ ត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី ។

បង្កាន់ដៃប្រគល់ប្រាក់ធានា ឬ អាវុធ ត្រូវចុះហត្ថលេខារួមដោយប្រធានតុលាការ ព្រះរាជអាជ្ញា និងក្រឡាបញ្ជី ។

ប្រាក់ធានាត្រូវតម្កល់ទុកនៅគណនីពិសេសដែលបើកនៅធនាគារ ឬ ត្រូវរក្សាទុកនៅទីកន្លែងមួយដែលមានការធានាសន្តិសុខរឹងមាំ ។ ទីកន្លែងនេះត្រូវជ្រើសរើសតាមការឯកភាពគ្នាដោយប្រធានតុលាការ និងព្រះរាជអាជ្ញា ។

អាវុធត្រូវរក្សាទុកនៅទីកន្លែងដូចបានពោលខាងលើ ។

**មាត្រា ២២៦.-** ដីកាបង្គាប់ឱ្យដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ចៅក្រមស៊ើបសួរដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ តាមគំនិតផ្ដើមផ្ទាល់របស់ខ្លួន ឬ តាមសេចក្ដីសន្និដ្ឋានសរុបរបស់ព្រះរាជអាជ្ញា ។ ចៅក្រមស៊ើបសួរបញ្ជាក់នៅក្នុងដីកាសម្រេចរបស់ខ្លួន អំពីកាតព្វកិច្ចដែលតម្រូវទៅលើជនត្រូវចោទ ។

ដីកាសម្រេចដាក់ខ្លួនឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ ។

កាលណាចៅក្រមស៊ើបសួរ ដែលទទួលបណ្ដឹងតាមសេចក្ដីសន្និដ្ឋានពីព្រះរាជអាជ្ញា សុំឱ្យដាក់ខ្លួនជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ មិនព្រមសម្រេចតាមការសុំទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធការសុំនេះក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ។

ដីកាសម្រេចនេះត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា ។

ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញាអាចធ្វើពាក្យប្ដឹងទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ ។

**មាត្រា ២២៧.-** ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយឯកឯង ដោយចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរ អាចកែប្រែខ្លឹមសារនៃកាតព្វកិច្ច អាចលុបចោល ឬ បញ្ចូលកាតព្វកិច្ចថ្មីបានគ្រប់ពេលវេលា ។

ចៅក្រមស៊ើបសួរក៏អាចបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការបានដែរ ។

ចៅក្រមស៊ើបសួរសម្រេចតាមដីកា ដែលត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ ។

**មាត្រា ២២៨.-** បណ្ដឹងសុំកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយព្រះរាជអាជ្ញា

ROYAUME DU CAMBODGE MINISTERE DU PALAIS ROYAL

NC/240

ព្រះរាជអាជ្ញាអាចសុំឱ្យលើកលែង ឬ កែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា ។ ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ។ ដីកាសម្រេចនេះត្រូវផ្ដល់ដំណឹងក្នុងរយៈពេលខ្លីបំផុតដល់ព្រះរាជអាជ្ញា ។

ប្រសិនបើចៅក្រមស៊ើបសួរ មិនបានសម្រេចក្នុងរយៈពេលនេះទេ ព្រះរាជអាជ្ញាអាចធ្វើពាក្យសុំទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ ។

ដីកាដែលសម្រេចមិនព្រមធ្វើតាមបណ្ដឹងសុំរបស់ព្រះរាជអាជ្ញា ត្រូវតែមានសំអាងហេតុ ។

**មាត្រា ២២៩.-** បណ្ដឹងសុំកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយជនត្រូវចោទ

ជនត្រូវចោទអាចធ្វើពាក្យសុំឱ្យលើកលែង ឬ កែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា ។ ចៅក្រមស៊ើបសួរបញ្ជូនពាក្យសុំនេះភ្លាមទៅព្រះរាជអាជ្ញា ដើម្បីសុំយោបល់ និងផ្ញើសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ ។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ គិតពីថ្ងៃបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ។ ដីកាសម្រេចនេះត្រូវផ្ដល់ដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ ។

កាលណាមានពាក្យសុំឱ្យលើកលែង ឬ ឱ្យកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបានធ្វើជាថ្មី មុនពេលចៅក្រមស៊ើបសួរ ឬ សភាស៊ើបសួរសម្រេចលើពាក្យសុំពីមុននោះ រយៈពេល ៥ (ប្រាំ) ថ្ងៃនេះ ត្រូវចាប់ផ្ដើមគិតពីពេលចេញសេចក្ដីសម្រេចលើពាក្យសុំពីមុន ។ ដីកាដែលសម្រេចមិនព្រមធ្វើតាមពាក្យសុំ ត្រូវតែមានសំអាងហេតុ ។

ប្រសិនបើចៅក្រមស៊ើបសួរមិនសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ នេះទេ ជនត្រូវចោទអាចធ្វើពាក្យប្ដឹងទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ ។

**មាត្រា ២៣០.-** ការគេចវេះរបស់ជនត្រូវចោទពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ

ប្រសិនបើជនត្រូវចោទគេចវេះដោយចេតនា ពីកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរអាចសម្រេចឱ្យឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្នបាន ទោះបីទោសជាប់ពន្ធនាគារដែលត្រូវរងនោះមានថិរវេលាប៉ុន្មានក៏ដោយ ហើយទោះជាជនត្រូវចោទត្រូវបានឃុំខ្លួនបណ្ដោះអាសន្នអស់រយៈពេលអតិបរមាដែលមានចែងដោយមាត្រា ២០៨ (ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋ) ដល់មាត្រា ២១០ (ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ននៅក្នុងករណីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ជាអាទិ៍) មាត្រា ២១៣ (ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋទាក់ទងនឹងអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី)



17/240

ឆ្នាំ) និងមាត្រា ២១៤ (ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងបទមជ្ឈិមទាក់ទងនឹងអនីតិជន មានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ) នៃក្រមនេះក៏ដោយ ។

កាលណាចៅក្រមស៊ើបសួរ សម្រេចថានឹងឃុំខ្លួនបណ្តោះអាសន្នដោយមូលហេតុខាងលើនេះ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សំគាល់របស់ជននេះ ។ ប្រសិនបើជនត្រូវចោទមានមេធាវីអមនោះ មេធាវីត្រូវជូនមតិយោបល់ការពារកូនក្តីរបស់ខ្លួន ។

ចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនជនត្រូវចោទ តាមដីកាដែលមានសំអាងហេតុ ។ ដីកាសម្រេចនេះ ត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ ។

ការឃុំខ្លួនបណ្តោះអាសន្នដែលសម្រេចតាមមាត្រានេះ មិនអាចឱ្យលើសពី ៤ (បួន) ខែ ចំពោះនីតិជន និង ២ (ពីរ) ខែ ចំពោះអនីតិជន ។

## ជំពូកទី ៤
## ការកោះហៅ និងការជូនដំណឹង
### ផ្នែកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ២៣១.-** រយៈពេលរួម

គ្រប់ថិរវេលាដែលចែងដោយគន្ថីនេះ ដើម្បីបំពេញកិច្ច ឬ ទម្រង់ការណាមួយនោះ ត្រូវផុតរលត់នៅថ្ងៃចុងក្រោយវេលាម៉ោង ២៤ (ម្ភៃបួន) ។ រយៈពេលដែលផុតតាមធម្មតានៅថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬ ថ្ងៃបុណ្យ ត្រូវអូសបន្ទាយរហូតដល់ថ្ងៃទីមួយ ដែលបើកធ្វើការវិញ ។

នៅក្នុងគ្រប់ករណីដែលទាមទារហត្ថលេខា របស់បុគ្គលណាម្នាក់នៅលើកិច្ចណាមួយនោះ ហត្ថលេខានេះ អាចជំនួសដោយស្នាមម្រាមដៃ កាលណាបុគ្គលនោះមិនចេះចុះហត្ថលេខាទេ ។

**មាត្រា ២៣២.-** របៀបកោះហៅ

ជនត្រូវចោទនៅក្រៅឃុំ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ត្រូវបានកោះហៅតាមផ្លូវប្រៃសណីយ៍ តាមផ្លូវរដ្ឋបាល ឬ តាមរយៈអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ ។

ការកោះហៅជនត្រូវចោទ ត្រូវធ្វើទៅតាមអាសយដ្ឋានចុងក្រោយបង្អស់ ដែលបានប្រកាសដូចដែលចែងនៅមាត្រា ១៤៣ (ការជូនដំណឹងអំពីការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ) នៃក្រមនេះ ។

ROYAUME DU CAMBODGE MINISTERE DU PALAIS ROYAL



118/249

ក្នុងករណីចាំបាច់ ការកោះហៅអាចធ្វើតាមគ្រប់មធ្យោបាយ ។

**មាត្រា ២៣៣.-** ការកោះហៅជនត្រូវចោទ ដែលត្រូវបានឃុំខ្លួន

ជនត្រូវចោទដែលត្រូវបានឃុំខ្លួន ត្រូវកោះហៅតាមរយៈប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ។

**មាត្រា ២៣៤.-** ការកោះហៅមេធាវី

មេធាវីត្រូវកោះហៅតាមផ្លូវប្រៃសណីយ៍ ឬ តាមផ្លូវរដ្ឋបាល ។

ក្នុងករណីចាំបាច់ ការកោះហៅអាចធ្វើបានតាមគ្រប់មធ្យោបាយ ។

**មាត្រា ២៣៥.-** និទ្ទេសនៃការកោះហៅនៅក្នុងសំណុំរឿង

វិធីកោះហៅ និងកាលបរិច្ឆេទនៃការកោះហៅ ត្រូវចុះនិទ្ទេសដោយកំណត់ហេតុក្រឡាបញ្ជីនៅក្នុងសំណុំរឿង ។

**មាត្រា ២៣៦.-** ការជូនដំណឹងអំពីដីកាសម្រេចដល់មេធាវី

នៅរាល់ពេលដែលដីកាត្រូវជូនដំណឹងដល់ជនត្រូវចោទនោះ ចៅក្រមស៊ើបសួរក៏ត្រូវជូនដំណឹងដល់មេធាវីផងដែរ ប្រសិនបើជនត្រូវចោទមានមេធាវីអម ។

នៅរាល់ពេលដែលដីកាត្រូវឱ្យដំណឹងដល់ដើមបណ្តឹងរដ្ឋប្បវេណីនោះ ចៅក្រមស៊ើបសួរក៏ត្រូវជូនដំណឹងដល់មេធាវីផងដែរ ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីមានមេធាវីអម ។

**មាត្រា ២៣៧.-** ការជូនដំណឹងអំពីដីកាសម្រេចដល់ព្រះរាជអាជ្ញា

ដីការបស់ចៅក្រមស៊ើបសួរ ត្រូវជូនដំណឹងដោយផ្ទាល់មាត់ដល់ព្រះរាជអាជ្ញា ។

ក្រឡាបញ្ជីចុះនិទ្ទេស អំពីកាលបរិច្ឆេទនៃការជូនដំណឹងនេះ នៅរឹមដីកា ។ ព្រះរាជអាជ្ញាចុះហត្ថលេខា ។

អគ្គព្រះរាជអាជ្ញាត្រូវបានជូនដំណឹងអំពីដីការបស់ចៅក្រមស៊ើបសួរ ដោយព្រះរាជអាជ្ញាតាមបែបបទដែលអគ្គព្រះរាជអាជ្ញាបានកំណត់ ។

**មាត្រា ២៣៨.-** ការជូនដំណឹងអំពីដីកាសម្រេចដល់ជនត្រូវចោទ

ដីការបស់ចៅក្រមស៊ើបសួរ ដែលត្រូវជូនដំណឹងដល់ជនត្រូវចោទ ដែលត្រូវបានឃុំខ្លួនតាមរបៀបដូចតទៅ :

-ដោយផ្ទាល់មាត់ ឬ

-តាមរយៈប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ។

ដីការបស់ចៅក្រមស៊ើបសួរ ដែលត្រូវជូនដំណឹងដល់ជនត្រូវចោទនៅក្រៅឃុំ ដល់ដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវីតាមរបៀបដូចតទៅនេះ :

-ដោយផ្ទាល់មាត់

-តាមផ្លូវរដ្ឋបាល ឬ

-តាមរយៈអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ ។

កាលណាការជូនដំណឹងត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ នោះក្រឡាបញ្ជីចុះនិទ្ទេសអំពីការជូនដំណឹងនៅរឹមដីកា ។ ជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវចុះហត្ថលេខារបស់ខ្លួន ។

នៅក្នុងករណីដទៃទៀត ការជូនដំណឹងត្រូវធ្វើដោយការប្រគល់សេចក្ដីចម្លងដីកា ដោយមានចំណាររបស់អ្នកទទួលថាបានទទួលទុកជាសម្គាល់ ។

**មាត្រា ២៣៩.-** ការប្រគល់ដីកាកោះហៅ ឬ ដីកាផ្សេងៗទៀត

គ្រប់មន្ត្រីរាជការ គ្រប់អាជ្ញាធររដ្ឋបាល គ្រប់នគរបាល ឬ កងរាជអាវុធហត្ថ ដែលចៅក្រមស៊ើបសួរសុំឱ្យប្រគល់ដីកាកោះហៅ ឬ ដីកាផ្សេងៗទៀត ត្រូវតែអនុវត្តតាមបញ្ជារបស់ចៅក្រមនេះ ។

បុគ្គល អង្គភាព ឬ អាជ្ញាធរដែលចៅក្រមស៊ើបសួរចាត់តាំងនោះ ត្រូវតែប្រគល់ដីកាកោះ ឬ ដីកាដល់សាមីខ្លួន ដោយមានចំណាររបស់អ្នកទទួលបញ្ជាក់ថាបានទទួលទុកជាសម្គាល់ ។ ដីកាដែលមានចំណារទទួលនេះ ត្រូវបង្វិលជូនទៅចៅក្រមស៊ើបសួរក្នុងរយៈពេលយ៉ាងខ្លីបំផុត ។

## ផ្នែកទី ២

## វិធានរដោយឡែក

**មាត្រា ២៤០.-** និទ្ទេសដែលត្រូវចុះជាកាតព្វកិច្ចនៅក្នុងកំណត់ហេតុរបស់ចៅក្រមស៊ើបសួរ

គ្រប់កំណត់ហេតុរបស់ចៅក្រមស៊ើបសួរ ត្រូវតែមានចុះសេចក្ដីដូចតទៅ :

-ឈ្មោះរបស់ចៅក្រមស៊ើបសួរ

-ឈ្មោះក្រឡាបញ្ជី

-លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង

-កាលបរិច្ឆេទនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

-ប្រភេទនៃបទល្មើស ដែលចង្អុលប្រាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS

120/240

-កាលបរិច្ឆេទនៃការធ្វើកំណត់ហេតុ ។

ទំព័រនីមួយៗនៃកំណត់ហេតុ ត្រូវតែចុះហត្ថលេខាដោយចៅក្រមស៊ើបសួរនិងដោយក្រឡាបញ្ជី ។

កំណត់ហេតុមិនត្រូវឱ្យមានចន្លោះបន្ទាត់ទេ ។ ការឆូតលុប ឬ ការយោងត្រូវតែបញ្ជាក់ដោយហត្ថលេខារបស់ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី នៅរឹមទំព័រ ។

**មាត្រា ២៤១.-** ហត្ថលេខាលើកំណត់ហេតុនៃការចូលខ្លួនជាលើកដំបូង

ទំព័រនីមួយៗនៃកំណត់ហេតុស្តីពីការចូលបង្ហាញខ្លួនលើកដំបូង ដូចមានចែងនៅមាត្រា ១៤៣ (ការជូនដំណឹងអំពីការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ) នៃក្រមនេះ ត្រូវចុះហត្ថលេខារបស់ចៅក្រមស៊ើបសួរ ក្រឡាបញ្ជី និងសាមីខ្លួន នៅរឹមទំព័រ ។

កាលណាជនត្រូវចោទបានឆ្លើយ ចម្លើយទាំងនេះត្រូវកត់ត្រាជាលាយលក្ខណ៍អក្សរឱ្យបានត្រឹមត្រូវនៅក្នុងកំណត់ហេតុ ។

**មាត្រា ២៤២.-** វិធានសម្រាប់សរសេរកំណត់ហេតុ

ការសួរចម្លើយ ការស្តាប់ចម្លើយ ឬ ការសួរតទល់នីមួយៗ ត្រូវតែមានធ្វើកំណត់ហេតុ ។

កំណត់ហេតុស្រង់យ៉ាងត្រឹមត្រូវនូវសំណួរ ចម្លើយ និងចម្លើយដែលឆ្លើយដោយឯកឯង ។

ទំព័រនីមួយៗនៃកំណត់ហេតុសួរចម្លើយជនត្រូវចោទ ត្រូវចុះហត្ថលេខាដោយជនត្រូវចោទ និងជាយថាហេតុ ដោយអ្នកបកប្រែ ។

ទំព័រនីមួយៗនៃកំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ត្រូវចុះហត្ថលេខាដោយដើមបណ្តឹងរដ្ឋប្បវេណី និងជាយថាហេតុ ដោយអ្នកបកប្រែ ។

ទំព័រនីមួយៗនៃកំណត់ហេតុស្តាប់ចម្លើយសាក្សី ត្រូវចុះហត្ថលេខាដោយសាក្សី និងជាយ-ថាហេតុ ដោយអ្នកបកប្រែ ។

ទំព័រនីមួយៗនៃកំណត់ហេតុសួរតទល់ ត្រូវចុះហត្ថលេខាដោយគ្រប់បុគ្គលទាំងអស់ដែលតទល់គ្នា និងជាយថាហេតុ ដោយអ្នកបកប្រែ ។

មុននឹងចុះហត្ថលេខា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី ឬ សាក្សី អានកំណត់ហេតុឡើងវិញ ។ ប្រសិនបើបុគ្គលណាមួយមិនចេះអានទេ ក្រឡាបញ្ជីអានកំណត់ហេតុដោយសំឡេងខ្លាំងៗ ។ អ្នកបកប្រែធ្វើការបកប្រែ ។ ប្រសិនបើបុគ្គលណាមួយមិនព្រមចុះហត្ថលេខាទេ ចៅក្រមស៊ើបសួរ ត្រូវចុះនិទ្ទេស នៅលើកំណត់ហេតុនោះ ។

**មាត្រា ២៤៣.-** និទ្ទេសដែលត្រូវចុះជាកាតព្វកិច្ចលើដីការបស់ចៅក្រមស៊ើបសួរ

គ្រប់ដីការបស់ចៅក្រមស៊ើបសួរ ត្រូវមានចុះសេចក្តីដូចតទៅ :

-ឈ្មោះចៅក្រមស៊ើបសួរ

-ឈ្មោះក្រឡាបញ្ជី

-លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង

-កាលបរិច្ឆេទនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

-ប្រភេទនៃបទល្មើស ដែលចង្អុលនៅក្នុងដីកាសន្និដ្ឋានចោទប្រកាន់

-អត្តសញ្ញាណនៃជនត្រូវចោទ ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត លំនៅឋានរបស់ជនត្រូវចោទ ប្រសិនបើពិរុទ្ធកម្មត្រូវបានប្រកាស

-លេខ និងកាលបរិច្ឆេទនៃការធ្វើដីកា ។

ទំព័រនីមួយៗនៃដីកា ត្រូវតែចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី ។

ដីកាមិនត្រូវឱ្យមានការចន្លោះបន្ទាត់ឡើយ ។ ការឆូត ឬ ការយោង ត្រូវតែមានបញ្ជាក់ដោយហត្ថលេខារបស់ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី នៅលើរឹមទំព័រ ។

**មាត្រា ២៤៤.-** ដីកាបញ្ជូនលិខិត

កាលណាចៅក្រមស៊ើបសួរបញ្ជូនលិខិតណាមួយនៃសំណុំរឿងទៅព្រះរាជអាជ្ញាពិនិត្យ ចៅក្រមស៊ើបសួរត្រូវចេញដីកាបញ្ជូនលិខិតនោះ ។

កាលណាចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាពិនិត្យ ចៅក្រមស៊ើបសួរត្រូវចេញដីកាបញ្ជូនសំណុំរឿងនោះ ។

បទប្បញ្ញត្តិនៃមាត្រា ២៤៣ (និទ្ទេសដែលត្រូវចុះជាកាតព្វកិច្ចលើដីការបស់ចៅក្រមស៊ើបសួរ) នៃក្រមនេះ ត្រូវយកមកអនុវត្តចំពោះដីកាបញ្ជូន ។

**មាត្រា ២៤៥.-** បណ្តឹងធ្វើឡើងដោយមេធាវី

គ្រប់ពេលដែលក្រមនេះអនុញ្ញាតឱ្យជនត្រូវចោទជូនពាក្យសុំដល់ចៅក្រមស៊ើបសួរ ពាក្យសុំនេះអាចធ្វើបានដោយមេធាវីរបស់ជនត្រូវចោទ ។

គ្រប់ពេលដែលក្រមនេះអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីជូនពាក្យសុំដល់ចៅក្រមស៊ើបសួរ ពាក្យសុំនេះ អាចធ្វើបានដោយមេធាវីនៃដើមបណ្តឹងរដ្ឋប្បវេណី ។

រាល់ពាក្យសុំដោយបុគ្គលដែលស្ថិតនៅក្រៅនីតិវិធីស៊ើបសួរ ឱ្យប្រគល់សងវត្ថុដែលចាប់យកអាចធ្វើបានដោយមេធាវី ។

## ជំពូកទី ៥
## ការបិទការស៊ើបសួរ

**មាត្រា ២៤៦.-** ដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា

កាលណាចៅក្រមស៊ើបសួរយល់ឃើញថា ការស៊ើបសួរបានបញ្ចប់ ចៅក្រមស៊ើបសួរជូនព័ត៌មាននេះដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី ។

២ (ពីរ) ថ្ងៃ ក្រោយមក ចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ ។

ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាចាំបាច់ត្រូវធ្វើកិច្ចស៊ើបសួរថ្មីទៀតនោះ ព្រះរាជអាជ្ញាត្រូវធ្វើតាមមាត្រា ១៣២ (ការស្នើសុំឱ្យបំពេញកិច្ចដោយព្រះរាជអាជ្ញា) នៃក្រមនេះ ។

ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ប្រសិនបើជនត្រូវចោទត្រូវឃុំខ្លួន និង ១ (មួយ) ខែ ក្នុងករណីដែលជនត្រូវចោទនៅក្រៅឃុំ ព្រះរាជអាជ្ញាបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញដោយមានដីកាសន្និដ្ឋានស្ថាពរភ្ជាប់ជាមួយផង ។ ថិរវេលានេះត្រូវគិតពីថ្ងៃដែលព្រះរាជអាជ្ញាបានទទួលសំណុំរឿង ។

ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញដូចចៅក្រមស៊ើបសួរដែរថា ការស៊ើបសួរត្រូវបញ្ចប់នោះ ព្រះរាជអាជ្ញាធ្វើដីកាសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ ។ ព្រះរាជអាជ្ញា អាចប្តឹងសុំឱ្យចៅក្រមស៊ើបសួរសម្រេចបញ្ជូនខ្លួនជនត្រូវចោទ ទៅកាន់តុលាការជំនុំជម្រះ ឬ ក៏លើកលែងចោទប្រកាន់ ។

មាត្រា២៤៧នេះត្រូវបានធ្វើវិសោធនកម្មដោយព្រះរាជក្រម នស/រកម/០៦១៣/០០៩ សូមចុចទីនេះដើម្បីមើលមាត្រា២៤៧ថ្មី នៅទំព័រ២០៨

~~**មាត្រា ២៤៧.-** ដីកាដំណោះស្រាយ~~

~~ចៅក្រមស៊ើបសួរបិទការស៊ើបសួរតាមដីកាដំណោះស្រាយ ។ ដីកានេះ អាចជាដីកាបញ្ជូនទៅជំនុំជម្រះ ឬ ដីកាលើកលែងចោទប្រកាន់ ។~~

~~ប្រសិនបើយល់ឃើញថាអំពើនោះ ជាបទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុ ចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនត្រូវចោទទៅមុខតុលាការជំនុំជម្រះ ។ ដីកាត្រូវរៀបរាប់អំពើដែលត្រូវចោទប្រកាន់ និងរឿងបទល្មើសតាមច្បាប់ ។~~

~~ចៅក្រមស៊ើបសួរចេញដីកាលើកលែងចោទប្រកាន់នៅក្នុងករណីដូចតទៅ :~~



123/240

~~១-អំពើប្រព្រឹត្ត មិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុ ។~~

~~២-ជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់ ។~~

~~៣-គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ ។~~

~~ដីកាដំណោះស្រាយជានិច្ចកាលត្រូវតែមានសំអាងហេតុ ។ ចៅក្រមស៊ើបសួរមិនត្រូវជាប់កាតព្វកិច្ចគោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាទេ ។ ដីកាអាចជាដីកាបញ្ជូនទៅតុលាការជំនុំជម្រះ ចំពោះអំពើមួយចំនួន និងជាដីការលើកលែងចោទប្រកាន់ចំពោះអំពើដទៃទៀត ។~~

~~ដីកាដំណោះស្រាយត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុត ដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ។~~

**មាត្រា ២៤៨.–** ការប្រគល់វត្ថុដែលចាប់យកឱ្យទៅម្ចាស់ដើមវិញ

នៅក្នុងដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរសម្រេចអំពីការប្រគល់សងទៅឱ្យម្ចាស់ដើមវិញនូវវត្ថុដែលចាប់យក ។ បទប្បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ១១៩(អាជ្ញាធរមានសមត្ថកិច្ចបង្គាប់ឱ្យប្រគល់វត្ថុជូនម្ចាស់ដើមវិញ) នៃក្រមនេះ ក៏ត្រូវយកមកអនុវត្តដែរ ។

**មាត្រា ២៤៩.–** សេចក្តីសម្រេចនៃដីកាដំណោះស្រាយទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ

ដីកាដំណោះស្រាយបញ្ចប់ការឃុំខ្លួនបណ្តោះអាសន្ន ។ ក្នុងករណីនេះបទប្បញ្ញត្តិនៃមាត្រា ២៧៦ (ការដោះលែងជនត្រូវចោទដែលជាប់ឃុំឱ្យមានសេរីភាព) នៃក្រមនេះ ត្រូវយកមកអនុវត្ត ។

ប៉ុន្តែ តាមសេចក្តីសម្រេចដោយឡែកនៃដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរអាចរក្សាជនត្រូវចោទឱ្យនៅជាប់ឃុំបណ្តោះអាសន្ន រហូតដល់ពេលចូលបង្ហាញខ្លួននៅមុខតុលាការ ។ នៅក្នុងដីកានេះ ចៅក្រមស៊ើបសួរត្រូវយោងតាមលក្ខខណ្ឌនៃមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន) នៃក្រមនេះ ។

សេចក្តីសម្រេចរក្សាទុកជនត្រូវចោទក្នុងឃុំជាបណ្តោះអាសន្ន លែងមានអានុភាពក្នុងរយៈពេល ៤ (បួន) ខែ ។ ប្រសិនបើជនត្រូវចោទមិនបានចូលទៅបង្ហាញខ្លួននៅមុខតុលាការក្នុងរយៈពេល ៤ (បួន) ខែនោះទេ ជនត្រូវចោទនេះត្រូវបានដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្នដោយឯកឯង ។

ដីកាដំណោះស្រាយបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL



R4/240

កាលណាចៅក្រមស៊ើបសួរបានដាក់កំហិតដល់ជនត្រូវចោទ ឱ្យបង់ប្រាក់ធានា ឱ្យប្រគល់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ ឬ ឱ្យប្រគល់អាវុធដែលមិនទាក់ទងនឹងបទល្មើស ប្រាក់ធានា ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ ឬ អាវុធនោះ ត្រូវប្រគល់សងសាមីខ្លួនវិញដោយក្រឡាបញ្ជី ដោយមានបង្កាន់ដៃទទួលដែលចុះហត្ថលេខាដោយជនត្រូវចោទទុកជាសម្គាល់ ។

ប៉ុន្តែ តាមសេចក្តីសម្រេចដោយឡែកនៃដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរអាចរក្សាទុកជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ រហូតដល់ពេលចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ ។

**មាត្រា ២៥០.–** ការបញ្ជូនដើម្បីបើកសវនាការជំនុំជម្រះ

ប្រសិនបើចៅក្រមស៊ើបសួរសម្រេចចេញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងជាបន្ទាន់ទៅប្រធានតុលាការ ដើម្បីកំណត់ពេលសវនាការជំនុំជម្រះ ។

**មាត្រា ២៥១.–** ការបើកការស៊ើបសួរជាថ្មីលើបន្ទុកថ្មីទៀត

ក្រោយពេលដែលដីកាលើកលែងចោទប្រកាន់របស់ចៅក្រមស៊ើបសួរ ឬ សាលដីកាលើកលែងចោទប្រកាន់របស់សភាស៊ើបសួរបានចូលជាស្ថាពរ ប្រសិនមានលេចឡើងបន្ទុកថ្មី ការស៊ើបសួរអាចបើកឡើងវិញ តាមការផ្តើមគំនិតរបស់ព្រះរាជអាជ្ញា ។

## ជំពូកទី ៦

## មោឃភាពនៃការស៊ើបសួរ

**មាត្រា ២៥២.–** មោឃភាពនៃការមិនគោរពវិធានបញ្ញត្តិ

វិធាន និងទម្រង់ការដែលចែងដោយមាត្រាខាងក្រោម ស្តីអំពីបទប្បញ្ញត្តិទូទៅនៃនីតិវិធីស៊ើបសួរមានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើពុំដូច្នោះទេនាំឱ្យមានមោឃភាពនៃនីតិវិធី :

- មាត្រា ១២២ (ការបើកការស៊ើបសួរ)
- មាត្រា ១២៣ (សមត្ថកិច្ចដែនដី)
- កថាខណ្ឌទី ៣ នៃមាត្រា ១២៤ (ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ)
- កថាខណ្ឌទី ១ និងទី ២ នៃមាត្រា ១២៥ (វិសាលភាពនៃការប្តឹង) និង
- មាត្រា ១២៨ (ជំនួយរបស់ក្រឡាបញ្ជី) នៃក្រមនេះ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL



125/240

នាំឱ្យមានមោឃភាពផងដែរ កាលណាការបំពានវិធាន ឬទម្រង់ការសំខាន់ណាមួយដែលចែងដោយក្រមនេះ ឬបទប្បញ្ញត្តិទាំងឡាយស្ដីពីនីតិវិធីព្រហ្មទណ្ឌធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីដែលទទួលរងការបំពាននេះ ។ វិធាន និងទម្រង់ការដែលមានលក្ខណៈសំខាន់នោះមានជាអាទិ៍ គឺវិធាន ទម្រង់ការដែលមានបំណងធានាការគោរពសិទ្ធិការពារខ្លួន ។

**មាត្រា ២៥៣.–** ការប្ដឹងទៅសភាស៊ើបសួរ

មានតែសភាស៊ើបសួរប៉ុណ្ណោះ ដែលមានសមត្ថកិច្ច ដើម្បីពិនិត្យមោឃភាពនៃលិខិតនៃនីតិវិធី ។

ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថា លិខិតណាមួយនៃនីតិវិធីមានមោឃភាព ចៅក្រមស៊ើបសួរនេះ ប្ដឹងទៅសភាស៊ើបសួរ តាមដីកាដោយមានសំអាងហេតុ និងជូនព័ត៌មានដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី ។

ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាលិខិតណាមួយនៃនីតិវិធីមានមោឃភាព ព្រះរាជអាជ្ញាធ្វើពាក្យសុំដោយមានសំអាងហេតុ បញ្ជូនទៅសភាស៊ើបសួរ និងជូនព័ត៌មានដល់ចៅក្រមស៊ើបសួរ ។

ប្រសិនបើជនត្រូវចោទ ឬដើមបណ្ដឹងរដ្ឋប្បវេណីយល់ឃើញថា លិខិតណាមួយនៃនីតិវិធីមានមោឃភាព សាមីជនធ្វើពាក្យសុំដោយមានសំអាងហេតុ ជូនទៅសភាស៊ើបសួរ និងជូនដំណឹងដល់ចៅក្រមស៊ើបសួរ ។ ពាក្យសុំអាចធ្វើដោយមេធាវីរបស់ជនត្រូវចោទ ឬរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ។

ពាក្យសុំដែលចែងនៅក្នុងមាត្រានេះ ត្រូវចុះបញ្ជីនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ ។ ភ្លាមនោះ ក្រឡាបញ្ជីសុំឱ្យចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងនៃនីតិវិធីមកឱ្យខ្លួនភ្លាម ។

ដីកាដែលអាចត្រូវប្ដឹងឧទ្ធរណ៍បាន មិនអាចធ្វើជាកម្មវត្ថុនៃបណ្ដឹងសុំមោឃភាពបានឡើយ ។

**មាត្រា ២៥៤.–** ការលះបង់ដោយភាគីណាមួយក្នុងការទាមទារមោឃភាព

កាលណាការបំពានវិធាន ឬទម្រង់ការសំខាន់ណាមួយបានធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍នៃភាគីណាមួយ ភាគីនេះអាចបោះបង់មិនលើកយកមោឃភាពមកសំអាង ហើយកែប្រែនីតិវិធីនេះឱ្យមានភាពប្រក្រតីឡើងវិញ ។ ការបោះបង់នេះ ត្រូវតែពិនិត្យដោយចៅក្រមស៊ើបសួរនៅក្នុងកំណត់ហេតុ ។ កាលណាភាគីមានអមដោយមេធាវី ចៅក្រមស៊ើបសួរត្រូវកោះហៅមេធាវីយ៉ាង

តិច ៩ (ប្រាំ) ថ្ងៃ មុនកាលបរិច្ឆេទនៃការធ្វើកំណត់ហេតុ ។ នៅក្នុងរយៈពេលនេះ មេធាវីអាច ពិនិត្យសំណុំរឿងនៃនីតិវិធីបាន ។

**មាត្រា ២៥៥.-** ការបន្តការស៊ើបសួរក្នុងករណីមានបណ្តឹងមកសភាស៊ើបសួរ

កាលណាសភាស៊ើបសួរ បានទទួលពាក្យប្តឹងសុំមោឃកម្ម ចៅក្រមស៊ើបសួរអាចបន្តការ ស៊ើបសួររបស់ខ្លួនបាន លើកលែងតែមានសេចក្តីសម្រេចផ្ទុយពីនេះរបស់ប្រធានសភាស៊ើបសួរ ។ សេចក្តីសម្រេចនេះ ពុំអាចប្តឹងតវ៉ាបានឡើយ ។

**មាត្រា ២៥៦.-** ការលុបលាងមោឃភាពដោយដីកាដំណោះស្រាយ

ដីកាដំណោះស្រាយដែលចូលជាស្ថាពរ លុបលាងមោឃភាពនៃនីតិវិធីមុន ប្រសិនបើមាន ។ គ្មានមោឃភាពណាមួយនៃនីតិវិធីមុន អាចត្រូវបានលើកឡើងនៅចំពោះមុខតុលាការជំនុំជម្រះ បានទៀតឡើយ ។

# មាតិកាទី ២
# សភាស៊ើបសួរ
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ២៥៧.-** បញ្ជីបណ្តឹងឧទ្ធរណ៍ និងពាក្យសុំ

ត្រូវបើកឱ្យមានកាន់បញ្ជីបណ្តឹងឧទ្ធរណ៍ និងពាក្យសុំមួយនៅការិយាល័យក្រឡាបញ្ជីនៃ សភាស៊ើបសួរ ។ បន្ទាប់ពីបានទទួលពាក្យប្តឹង ក្រឡាបញ្ជីនៃសភាស៊ើបសួរត្រូវតែឱ្យដំណឹងភ្លាម ទៅចៅក្រមស៊ើបសួរ ។

កាលណាសភាស៊ើបសួរត្រូវបានប្តឹងដោយផ្ទាល់តាមរយៈពាក្យសុំ ក្រឡាបញ្ជីនៃសភាស៊ើប សួរ សុំឱ្យក្រឡាបញ្ជីនៃចៅក្រមស៊ើបសួរ ផ្ញើមកឱ្យខ្លួននូវសំណុំរឿងនៃនីតិវិធី ឬ សំណុំរឿងបង្ការ ទុក ។

**មាត្រា ២៥៨.-** ការជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការ

ប្រធានសភាស៊ើបសួរពិនិត្យផ្ទៀងផ្ទាត់មើលថា តើសំណុំរឿងមានលក្ខណៈគ្រប់គ្រាន់ល្មម ជំនុំជម្រះបានឬទេ រួចហើយកំណត់កាលបរិច្ឆេទបើកសវនាការ ។ ប្រធានសភាស៊ើបសួរជូន ដំណឹងដោយផ្ទាល់មាត់អំពីកាលបរិច្ឆេទនៃការបើកសវនាការ ដល់អគ្គព្រះរាជអាជ្ញាអមសាលា



ROYAUME DU CAMBODGE LE MINISTERE DU PALAIS

123/240

ឧទ្ធរណ៍ ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការនេះ ដល់គូភាគី និង ដល់មេធាវី ។

ការជូនដំណឹងដល់ជនត្រូវចោទដែលត្រូវបានឃុំខ្លួន ត្រូវធ្វើដូចតទៅនេះ :

-ដោយផ្ទាល់មាត់ ឬ

-តាមរយៈប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ។

ការជូនដំណឹងដល់ជនត្រូវចោទនៅក្រៅឃុំ ដល់ដើមបណ្ដឹងរដ្ឋប្បវេណី និងដល់មេធាវី ត្រូវធ្វើដូចតទៅ :

-ដោយផ្ទាល់មាត់

-តាមផ្លូវរដ្ឋបាល ឬ

-តាមរយៈអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ ។

កាលណាការជូនដំណឹងធ្វើដោយផ្ទាល់មាត់ ក្រឡាបញ្ជីចុះនិទ្ទេសអំពីកាលបរិច្ឆេទនៃការជូនដំណឹងនៅរឹមទំព័រនៃដីកា ។ ជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី ឬ មេធាវីចុះហត្ថលេខារបស់ខ្លួន ។

ក្នុងករណីដទៃទៀត ការជូនដំណឹងត្រូវធ្វើដោយការប្រគល់សេចក្ដីចម្លងដីកាដោយមានបំណាវទទួល ។

**មាត្រា ២៥៩.-** ការពិគ្រោះសំណុំរឿង និងសារណា

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងមេធាវី អាចពិនិត្យមើលសំណុំរឿងរហូតដល់ពេលបើកសវនាការ ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវប្រគល់សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរដល់ក្រឡាបញ្ជីយ៉ាងយូរបំផុត ១ (មួយ) ថ្ងៃ មុនពេលសវនាការ ។

គូភាគី និងមេធាវីអាចប្រគល់សារណាដល់ក្រឡាបញ្ជី ។

សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងសារណាត្រូវចុះទិដ្ឋាការដោយក្រឡាបញ្ជី ដោយមានចុះកាលបរិច្ឆេទ និងត្រូវបញ្ចូលក្នុងសំណុំរឿងភ្លាម ។

គូភាគី និងមេធាវីត្រូវបានអនុញ្ញាតឱ្យជូនសារណារហូតដល់ពេលចាប់ផ្ដើមបើកសវនាការ ។

**មាត្រា ២៦០.-** ដំណើរការនៃកិច្ចពិភាក្សាដេញដោល

ការពិភាក្សាដេញដោលត្រូវប្រព្រឹត្តទៅក្នុងបន្ទប់ពិភាក្សា ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



128/240

ក្រោយពីរបាយការណ៍របស់ប្រធានសភាស៊ើបសួរ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងមេធាវីរបស់គូភាគី ធ្វើការកត់សម្គាល់របស់ខ្លួនដោយសង្ខេប ។

សភាស៊ើបសួរអាចបង្គាប់ឱ្យគូភាគី ព្រមទាំងជនត្រូវចោទជាប់ឃុំ ចូលមកបង្ហាញខ្លួនដោយផ្ទាល់ហើយនិងផ្តល់វត្ថុតាង ។

កាលណាការពិភាក្សាដេញដោលបានបញ្ចប់ សភាស៊ើបសួរធ្វើការពិគ្រោះសម្រេចដោយគ្មានវត្តមានរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ គូភាគី និងមេធាវីឡើយ ។

សាលដីកាត្រូវប្រកាសនៅពេលសវនាការអសាធារណៈនៅថ្ងៃនោះ ឬ ក៏នៅពេលសវនាការលើកក្រោយ ។ សាលដីកាត្រូវតែមានសំអាងហេតុ ហើយត្រូវតែមានធាតុដែលចាំបាច់ដល់ការត្រួតពិនិត្យរបស់តុលាការកំពូល ។ សាលដីកាត្រូវចុះហត្ថលេខាដោយប្រធានសភាស៊ើបសួរ ។

សាលដីកាត្រូវជូនដំណឹងដោយផ្ទាល់មាត់ក្នុងរយៈពេលខ្លីបំផុត ដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ ក្រឡាបញ្ជីចុះនិទ្ទេសអំពីកាលបរិច្ឆេទនៃការជូនដំណឹងនៅរឹមទំព័រនៃសាលដីកា ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ចុះហត្ថលេខាថាបានទទួល ។

សាលដីកាត្រូវជូនដំណឹងដល់គូភាគី និងមេធាវី ដូចដែលមានចែងនៅក្នុងមាត្រា ២៣៨ (ការជូនដំណឹងអំពីដីកាសម្រេចដល់ជនត្រូវចោទ) នៃក្រមនេះ ។

**មាត្រា ២៦១.–** ការពិនិត្យលើនិយ័តភាពនៃនីតិវិធី

នៅរាល់ពេលដែលបានទទួលបណ្តឹង សភាស៊ើបសួរពិនិត្យមើលពីនិយ័តភាពនៃនីតិវិធី និងការប្រព្រឹត្តទៅដ៏ល្អនៃនីតិវិធីនេះ ។

កាលណាពិនិត្យឃើញមូលហេតុនៃមោឃភាព សភាស៊ើបសួរអាចចាត់ទុកជាមោឃៈ ដោយឯកឯងនូវនីតិវិធីទាំងមូល ឬ ផ្នែកណាមួយ ។ សភាស៊ើបសួរត្រូវធ្វើដូចដែលមានចែងនៅក្នុងមាត្រា ២៨០ (អានុភាពនៃមោឃកម្ម) នៃក្រមនេះ ។

**មាត្រា ២៦២.–** កិច្ចនៃការស៊ើបសួរបន្ថែម

សភាស៊ើបសួរអាចបង្គាប់ឱ្យធ្វើកិច្ចស៊ើបសួរបំពេញបន្ថែម តាមដែលខ្លួនយល់ឃើញថាមានប្រយោជន៍ ។

ដើម្បីបំពេញកិច្ចនេះ សភាស៊ើបសួរត្រូវចាត់តាំងសមាជិកម្នាក់របស់សភា ឬ ក៏ចៅក្រមស៊ើបសួរណាម្នាក់ដែលខ្លួនប្រគល់អំណាចឱ្យ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

129/240

ចៅក្រមដែលទទួលភារកិច្ចស៊ើបសួរបំពេញនោះ ប្រើប្រាស់អំណាចរបស់ចៅក្រមស៊ើបសួរនៅក្នុងព្រំដែនកំណត់ដោយសភាស៊ើបសួរ ។

កាលណាកិច្ចស៊ើបសួរត្រូវបានបំពេញរួចហើយ សំណុំរឿងនៃនីតិវិធីត្រូវយកមកតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ ។ ប្រធានសភាស៊ើបសួរកំណត់កាលបរិច្ឆេទនៃសវនាការថ្មី ។ បទប្បញ្ញត្តិនៃមាត្រា ២៥៩ (ការពិគ្រោះសំណុំរឿង និងសារណា) នៃក្រមនេះ ត្រូវយកមកអនុវត្ត ។

**មាត្រា ២៦៣.–** ការពន្យាតការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យដល់បទល្មើសដែលទាក់ទងគ្នា

សភាស៊ើបសួរដោយឯកឯង ឬ តាមសេចក្តីសន្និដ្ឋានរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចបង្គាប់ឱ្យពន្យាតការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យដល់បទល្មើសដែលទាក់ទងគ្នានឹងបទល្មើស ដែលចង្អុលដោយចៅក្រមស៊ើបសួរ កាលណាបទល្មើសនោះលេចចេញពីសំណុំរឿងនៃនីតិវិធី ។

បទល្មើសដែលទាក់ទងគ្នាគឺ :

-កាលណាបទល្មើសបានប្រព្រឹត្តក្នុងពេលជាមួយគ្នា ដោយបុគ្គលច្រើនរួមគ្នា

-កាលណាបទល្មើសបានប្រព្រឹត្តដោយបុគ្គលផ្សេងគ្នា បន្ទាប់ពីមានការព្រមព្រៀងគ្នា ទោះបីជាការប្រព្រឹត្តិនៅក្នុងពេល ឬ នៅទីកន្លែងផ្សេងក៏ដោយ ឬ

-កាលណាវត្ថុដែលលួច កែបំបាត់ ឬ បានមកពីបទល្មើសណាមួយនោះ ត្រូវបានលាក់បំបាត់ដោយបុគ្គលផ្សេងទៀត ។

**មាត្រា ២៦៤.–** ការពន្យាតការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យរហូតដល់បុគ្គលផ្សេងទៀត

សភាស៊ើបសួរអាចបង្គាប់ឱ្យចោទប្រកាន់បុគ្គលផ្សេងក្រៅពីបុគ្គល ដែលចែងដោយចៅក្រមស៊ើបសួរ លើកលែងតែបទប្បញ្ញត្តិនៅមាត្រា ១២ (អាជ្ញាអស់ជំនុំ) នៃក្រមនេះ ។

**មាត្រា ២៦៥.–** ការបើកជាថ្មីនូវការស៊ើបសួរលើបន្ទុកថ្មីទៀត

ក្រោយពេលដែលដីការបស់ចៅក្រមស៊ើបសួរ ឬ សាលដីការបស់សភាស៊ើបសួរដែលលើកលែងចោទប្រកាន់បានចូលជាស្ថាពរ ហើយមានលេចឡើងនូវបន្ទុកថ្មី ការស៊ើបសួរអាចត្រូវបានបើកឡើងវិញ តាមគំនិតផ្តើមរបស់ព្រះរាជអាជ្ញា ។

# ជំពូកទី ២
# បណ្តឹងឧទ្ធរណ៍ចំពោះដីការបស់ចៅក្រមស៊ើបសួរ

**មាត្រា ២៦៦.–** បណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញា

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញាអាចប្តឹងឧទ្ធរណ៍ចំពោះគ្រប់ដីកាសម្រេចទាំងអស់របស់ចៅក្រមស៊ើបសួរបាន ។

**មាត្រា ២៦៧.–** បណ្តឹងឧទ្ធរណ៍ចំពោះដីការបស់ចៅក្រមស៊ើបសួរដោយជនត្រូវចោទ

ជនត្រូវចោទអាចប្តឹងឧទ្ធរណ៍ចំពោះដីកាដូចតទៅ :

-ដីកាបដិសេធពាក្យសុំឱ្យធ្វើកិច្ចស៊ើបសួរ ដូចដែលមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រា ១៣៣ (ការស្នើសុំឱ្យបំពេញកិច្ចដោយជនត្រូវចោទ)

-ដីកាមិនព្រមប្រគល់វត្ថុដែលចាប់ឱ្យទៅម្ចាស់ដើមវិញ ដូចដែលមានចែងក្នុងមាត្រា ១៦១ (ការប្រគល់វត្ថុដែលចាប់យកឱ្យទៅម្ចាស់ដើមវិញដោយចៅក្រមស៊ើបសួរ) និងមាត្រា ២៤៨ (ការប្រគល់វត្ថុដែលចាប់យកឱ្យទៅម្ចាស់ដើមវិញ)

-ដីកាបដិសេធពាក្យសុំឱ្យធ្វើកោសលវិច័យ ដូចដែលមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រា ១៦២ (ភាពចាំបាច់នៃការធ្វើកោសលវិច័យ)

-ដីកាបដិសេធពាក្យសុំឱ្យធ្វើកោសលវិច័យបន្ថែម ឬ សុំឱ្យធ្វើប្រតិកោសលវិច័យដូចដែលមានចែងក្នុងកថាខណ្ឌទី ៧ នៃមាត្រា ១៧០(ការជូនដំណឹងអំពីសេចក្តីសន្និដ្ឋាននៃកោសលវិច័យ) និង

-ដីកាស្តីពីរឿងឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ ដូចដែលមានចែងក្នុងផ្នែកទី ៥ ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន និងផ្នែកទី ៧ ស្តីពីការត្រួតពិនិត្យតាមផ្លូវតុលាការនៃជំពូកទី ៣ ស្តីពីវិធានការនិរន្តរាយ ក្នុងមាតិកាទី ១ នៃគន្ថីនេះ និង មាត្រា ២៤៩ (សេចក្តីសម្រេចនៃដីកាដំណោះស្រាយទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ) នៃក្រមនេះ ។

**មាត្រា ២៦៨.–** បណ្តឹងឧទ្ធរណ៍ចំពោះដីការបស់ចៅក្រមស៊ើបសួរ ដោយដើមបណ្តឹងរដ្ឋប្បវេណី

ដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងឧទ្ធរណ៍ចំពោះដីកាដូចតទៅ :

-ដីកាបដិសេធពាក្យសុំឱ្យធ្វើកិច្ចស៊ើបសួរ ដូចដែលមានចែងក្នុងកថាខណ្ឌទី ២ នៃ

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL



134/240

មាត្រា ១៣៤ (ការស្នើសុំឱ្យបំពេញកិច្ចដោយដើមបណ្តឹងរដ្ឋប្បវេណី)

-ដីកាមិនព្រមស៊ើបសួរដូចដែលមានចែងក្នុងកថាខណ្ឌទី ៤ នៃមាត្រា ១៣៩ (ការបញ្ជូនបណ្តឹងទៅព្រះរាជអាជ្ញា)

-ដីកាកំណត់ចំនួនប្រាក់កក់ ដូចដែលមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រា ១៤០ (ការបង់ប្រាក់តម្កល់ទុក)

-ដីកាប្រកាសមិនទទួលពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដូចដែលមានចែងក្នុងកថាខណ្ឌទី ៤ នៃមាត្រា ១៤០ (ការបង់ប្រាក់តម្កល់ទុក) នៃក្រមនេះ

-ដីកាផ្តន្ទាទោសដើមបណ្តឹងរដ្ឋប្បវេណី ដូចដែលមានចែងក្នុងមាត្រា ១៤១ (បណ្តឹងដោយបំពាន ឬ បណ្តឹងដោយអូសបន្លាយពេលវេលា)

-ដីកាមិនព្រមប្រគល់សងវត្ថុដែលចាប់យក ទៅម្ចាស់ដើមវិញ ដូចដែលមានចែងក្នុងមាត្រា ១៦១ (ការប្រគល់វត្ថុដែលចាប់យកឱ្យទៅម្ចាស់ដើមវិញដោយចៅក្រមស៊ើបសួរ) និងមាត្រា ២៤៨ (ការប្រគល់វត្ថុដែលចាប់យកឱ្យទៅម្ចាស់ដើមវិញ)

-ដីកាបដិសេធពាក្យសុំឱ្យធ្វើកោសលវិច័យ ដូចដែលមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រា ១៦២ (ភាពចាំបាច់នៃការធ្វើកោសលវិច័យ)

-ដីកាបដិសេធពាក្យសុំឱ្យធ្វើកោសលវិច័យបន្ថែម ឬ សុំឱ្យធ្វើប្រតិកោសលវិច័យ ដូចដែលមានចែងក្នុងកថាខណ្ឌទី ៧ នៃមាត្រា ១៧០ (ការជូនដំណឹងអំពីសេចក្តីសន្និដ្ឋាននៃកោសលវិច័យ)

-ដីកាដំណោះស្រាយដូចដែលមានចែងក្នុងមាត្រា ២៤៧ (ដីកាដំណោះស្រាយ)នៃក្រមនេះ ។

**មាត្រា ២៦៩.–** បណ្តឹងឧទ្ធរណ៍ចំពោះដីកាបដិសេធមិនប្រគល់វត្ថុដែលរឹបអូសទៅម្ចាស់ដើមវិញ

គ្រប់បុគ្គលនៅក្រៅនីតិវិធីស៊ើបសួរដែលអនុលោមតាមមាត្រា ១៦១ (ការប្រគល់វត្ថុដែលចាប់យកឱ្យទៅម្ចាស់ដើមវិញដោយចៅក្រមស៊ើបសួរ) នៃក្រមនេះ ដែលសុំឱ្យប្រគល់សងមកខ្លួនវិញនូវវត្ថុដែលចាប់យក អាចប្តឹងឧទ្ធរណ៍ចំពោះដីការបស់ចៅក្រមស៊ើបសួរដែលបដិសេធពាក្យសុំនេះ ។



132/240

**មាត្រា ២៧០.-** រយៈពេលប្តឹងឧទ្ធរណ៍

បណ្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវធ្វើក្នុងរយៈពេល ១ (មួយ) ខែ យ៉ាងយូរគិតពីពេលប្រកាសដីកា ។

បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ត្រូវធ្វើក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងអំពីដីកានេះ ។

បណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងរបស់បុគ្គលដែលមានចែងនៅក្នុងមាត្រា ២៦៩ (បណ្តឹងឧទ្ធរណ៍ចំពោះដីកាបដិសេធមិនប្រគល់វត្ថុដែលរឹបអូសទៅម្ចាស់ដើមវិញ) នៃក្រមនេះ ត្រូវធ្វើក្នុងរយៈវេលា ៥ (ប្រាំ) ថ្ងៃ គិតពីការជូនដំណឹងពីដីកា ។

ប្រសិនបើការជូនដំណឹងធ្វើឡើងដោយការប្រគល់សេចក្តីចម្លងនៃដីកាដោយមានចំណារទទួល នោះរយៈពេលបណ្តឹងឧទ្ធរណ៍ ផ្តើមគិតចាប់ពីកាលបរិច្ឆេទនៃចំណារទទួលនោះ ។

**មាត្រា ២៧១.-** សមត្ថកិច្ចរបស់សភាស៊ើបសួរ

បណ្តឹងឧទ្ធរណ៍ត្រូវបញ្ជូនទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ។

**មាត្រា ២៧២.-** ទម្រង់នៃការប្រកាសប្តឹងឧទ្ធរណ៍

បណ្តឹងឧទ្ធរណ៍ត្រូវធ្វើតាមការប្រកាសប្តឹង នៅក្រឡាបញ្ជីនៃតុលាការជាន់ដំបូង ។ បណ្តឹងឧទ្ធរណ៍ត្រូវចុះក្នុងបញ្ជីនៃបណ្តឹងឧទ្ធរណ៍របស់តុលាការ ។

បណ្តឹងឧទ្ធរណ៍អាចត្រូវធ្វើដោយមេធាវីរបស់ជនត្រូវចោទ របស់ដើមបណ្តឹងរដ្ឋប្បវេណី ឬ របស់បុគ្គលដែលមានចែងនៅមាត្រា ២៦៩ (បណ្តឹងឧទ្ធរណ៍ចំពោះដីកាបដិសេធមិនប្រគល់វត្ថុដែលរឹបអូសទៅម្ចាស់ដើមវិញ) នៃក្រមនេះ ។

បណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទដែលត្រូវបានឃុំខ្លួន ត្រូវធ្វើតាមការប្រកាសប្តឹងនៅមុខប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ។ ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ត្រូវប្រគល់ភ្លាមនូវលិខិតប្តឹងឧទ្ធរណ៍មួយច្បាប់ ជូនទៅក្រឡាបញ្ជីនៃតុលាការជាន់ដំបូង ។ លិខិតនេះត្រូវបញ្ចូលទៅក្នុងបញ្ជីបណ្តឹងឧទ្ធរណ៍ ។

**មាត្រា ២៧៣.-** ការបញ្ជូនសំណុំរឿងទៅសភាស៊ើបសួរ

កាលណាបានទទួលបណ្តឹងឧទ្ធរណ៍ ក្រឡាបញ្ជីនៅតុលាការជាន់ដំបូងជូនដំណឹងភ្លាមដល់ចៅក្រមស៊ើបសួរ ។

ក្រឡាបញ្ជីនៃចៅក្រមស៊ើបសួររៀបចំ និងបញ្ជូនសំណុំរឿងទៅសភាស៊ើបសួរ ដោយមានសេចក្តីចម្លងនៃលិខិតប្តឹងឧទ្ធរណ៍ភ្ជាប់ជាមួយផង ។ សេចក្តីចម្លងនេះ ត្រូវធ្វើឡើងដោយក្រឡាបញ្ជីនៃតុលាការជាន់ដំបូងក្រោយពីបានឃើញនិទ្ទេសដែលចុះក្នុងបញ្ជីបណ្តឹងឧទ្ធរណ៍ ។

សំណុំរឿងនេះត្រូវបញ្ជូនទៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ នៅក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីមានបណ្តឹងឧទ្ធរណ៍ លើកលែងតែក្នុងកាលៈទេសៈដែលមិនអាចជំនះបាន ។

**មាត្រា ២៧៤.–** សំណុំរឿងបង្ការការពារ

កាលណាសំណុំរឿងបង្ការទុក ត្រូវបានធ្វើឡើងស្របតាមមាត្រា ១២៩ (មុខងាររបស់ក្រឡាបញ្ជី) នៃក្រមនេះ នោះចៅក្រមស៊ើបសួររក្សាទុកសំណុំរឿងដើម ។ សំណុំរឿងបង្ការទុកត្រូវបញ្ជូនទៅសភាស៊ើបសួរ ។

**មាត្រា ២៧៥.–** ការបន្តការស៊ើបសួរក្នុងករណីមានបណ្តឹងឧទ្ធរណ៍

ក្នុងករណីមានបណ្តឹងឧទ្ធរណ៍ចំពោះដីកាណាមួយក្រៅពីដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរ អាចបន្តការស៊ើបសួររបស់ខ្លួនបាន លើកលែងតែមានសេចក្តីសម្រេចផ្ទុយរបស់ប្រធានសភាស៊ើបសួរ ។

សេចក្តីសម្រេចនេះមិនអាចតវ៉ាបានឡើយ ។

**មាត្រា ២៧៦.–** ការដោះលែងជនត្រូវចោទដែលជាប់ឃុំឱ្យមានសេរីភាព

កាលណាចៅក្រមស៊ើបសួរសម្រេចឱ្យដោះលែងជនត្រូវចោទ ដែលជាប់ឃុំបណ្តោះអាសន្ន ជនត្រូវចោទនោះ ត្រូវបានរក្សាទុកនៅក្នុងពន្ធនាគារ រហូតដល់ផុតរយៈពេលសម្រាប់បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា លើកលែងតែព្រះរាជអាជ្ញាយល់ព្រមឱ្យដោះលែងជនត្រូវចោទនោះភ្លាម ។ សេចក្តីសម្រេចជាលាយលក្ខណ៍អក្សររបស់ព្រះរាជអាជ្ញា ត្រូវដាក់បញ្ចូលក្នុងសំណុំរឿងនៃនីតិវិធី ។

ត្រូវធ្វើដូចគ្នានេះដែរ ចំពោះដីកាលើកលែងចោទប្រកាន់ កាលណាដីកានេះមានអានុភាពនាំឱ្យដោះលែងជនត្រូវចោទដែលជាប់ឃុំ ។

ក្នុងករណីមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាអំពីដីកាដោះលែងឱ្យនៅក្រៅឃុំ ឬ លើកលែងចោទប្រកាន់នោះ ជនត្រូវចោទដែលជាប់ឃុំ ត្រូវបានរក្សាទុកក្នុងពន្ធនាគារ រហូតទាល់តែសភាស៊ើបសួរបានសម្រេចអំពីបណ្តឹងឧទ្ធរណ៍ ។

ROYAUME DU CAMBODGE MINISTERE DU PALAIS ROYAL



134/240

**មាត្រា ២៧៧.-** បណ្ដឹងឧទ្ធរណ៍ចំពោះដីកាលើកលែងចោទប្រកាន់

កាលណាទទួលបណ្ដឹងឧទ្ធរណ៍ចំពោះដីកាលើកលែងចោទប្រកាន់ សភាស៊ើបសួរសម្រេចតាមបទប្បញ្ញត្តិដូចដែលបានចែងនៅចំណុចទី ៣ មាត្រា ២៨១ (ផលវិបាកនៃមោឃកម្ម) នៃក្រមនេះ ។

## ជំពូកទី ៣
## ការឃុំខ្លួនបណ្ដោះអាសន្ន

**មាត្រា ២៧៨.-** សាលដីកាដែលសម្រេចលើការឃុំខ្លួនបណ្ដោះអាសន្ន

ក្នុងរឿងឃុំខ្លួនបណ្ដោះអាសន្ន សាលដីការបស់សភាស៊ើបសួរត្រូវសម្រេចចេញនៅក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃបន្ទាប់ពីបានទទួលសំណុំរឿងនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ ។ បើផុតរយៈពេលនេះ ជនត្រូវចោទត្រូវបានដោះលែងឱ្យនៅក្រៅឃុំ លើកលែងតែក្នុងករណីដែលមានចេញបង្គាប់ឱ្យធ្វើការផ្ទៀងផ្ទាត់ ឬ ក្នុងករណីមានកាលៈទេសៈដែលមិនអាចមើលឃើញជាមុន ឬ មិនអាចជំនះបាននោះ បង្កជាឧបសគ្គមិនឱ្យប្រកាសសាលដីកាបាននៅក្នុងរយៈពេលនេះ ។

កាលណាសភាស៊ើបសួរបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្ន សភាស៊ើបសួរត្រូវសំអាងហេតុនៅក្នុងសាលដីការបស់ខ្លួនដោយយោងទៅតាមបទប្បញ្ញត្តិនៃមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន) នៃក្រមនេះ ។ ប្រធានសភាស៊ើបសួរចេញដីកាបង្គាប់ឱ្យឃុំខ្លួន ។

សំណុំរឿងត្រូវបញ្ជូនជាបន្ទាន់ទៅចៅក្រមស៊ើបសួរវិញ ក្រោយពីបានអនុវត្តសាលដីការួច ។

## ជំពូកទី ៤
## មោឃភាព

**មាត្រា ២៧៩.-** ភាពដែលមិនអាចទទួលយកបាននៃពាក្យប្ដឹងសុំមោឃកម្ម

សភាស៊ើបសួរអាចប្រកាសមិនទទួលពាក្យប្ដឹងសុំឱ្យមោឃកម្ម នៅក្នុងករណីដូចតទៅ :

- ពាក្យប្ដឹងសុំគ្មានសំអាងហេតុ
- ពាក្យប្ដឹងសុំទាក់ទងនឹងដីកាដែលអាចប្ដឹងឧទ្ធរណ៍បាន
- ពាក្យប្ដឹងសុំគ្មានមូលកភាពយ៉ាងជាក់ស្ដែង ។

សេចក្ដីសម្រេចរបស់សភាស៊ើបសួរមិនអាចតវ៉ាបានទេ ។

កាលណាពាក្យប្ដឹងសុំត្រូវបានប្រកាសមិនអាចទទួលបានទេ សំណុំរឿងត្រូវបង្វិលភ្លាមទៅចៅក្រមស៊ើបសួរ ។

**មាត្រា ២៨០.–** អានុភាពនៃមោឃកម្ម

កាលណាបានទទួលបណ្ដឹងសុំមោឃកម្មចំពោះកិច្ច ឬ លិខិតណាមួយនៃនីតិវិធី ប្រសិនបើសភាស៊ើបសួរយល់ព្រមតាមពាក្យប្ដឹងសុំនេះ សភាស៊ើបសួរសម្រេចថា តើមោឃកម្មនេះត្រូវធ្វើទៅលើកិច្ច ឬ លិខិតផ្សេងទៀតដែរឬទេ ។

កិច្ច ឬ លិខិតដែលត្រូវចាត់ទុកជាមោឃៈ ត្រូវដកចេញពីសំណុំរឿង ហើយតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ ។

**មាត្រា ២៨១.–** ផលវិបាកនៃមោឃកម្ម

ក្រោយពីធ្វើមោឃកម្មរួច សភាស៊ើបសួរអាច :

-បង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ

-ដកសមត្ថកិច្ចចៅក្រមស៊ើបសួរ ហើយបញ្ជូនសំណុំរឿងទៅចៅក្រមស៊ើបសួរម្នាក់ផ្សេងទៀត ឬ

-បន្តការស៊ើបសួរដោយខ្លួនឯងលើរឿងនោះ ។

**មាត្រា ២៨២.–** អំណាចបន្តការស៊ើបសួរដោយសភាស៊ើបសួរ

កាលណាសភាស៊ើបសួរសម្រេចថាបន្តការស៊ើបសួរដោយខ្លួនឯងនោះ សភាស៊ើបសួរប្រគល់ភារកិច្ចទៅសមាជិកខ្លួនម្នាក់ ដែលប្រើប្រាស់អំណាចជាចៅក្រមស៊ើបសួរ លើកលែងតែអំណាចដែលមានចែងនៅក្នុងជំពូកទី ៩ ស្ដីពីការបិទការស៊ើបសួរនៃមាតិកាទី ១ ស្ដីពីចៅក្រមស៊ើបសួរក្នុងគន្ថីនេះ ។

កាលណាការស៊ើបសួរហាក់ដូចជាត្រូវបញ្ចប់ សំណុំរឿងនៃនីតិវិធីត្រូវតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ ។ ប្រធាននៃសភាស៊ើបសួរកំណត់កាលបរិច្ឆេទនៃសវនាការ ។ បទប្បញ្ញត្តិនៃមាត្រា ២៥៩ (ការពិគ្រោះសំណុំរឿង និងសារណា) នៃក្រមនេះ ត្រូវយកមកអនុវត្ត ។

សភាស៊ើបសួរបិទការស៊ើបសួរ តាមសាលដីកាដំណោះស្រាយ ។ បទប្បញ្ញត្តិនៃមាត្រា ២៤៧ (ដីកាដំណោះស្រាយ) ដល់មាត្រា ២៥០ (ការបញ្ជូនដើម្បីបើកសវនាការជំនុំជម្រះ) ស្ដីពីដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ នៃក្រមនេះ ត្រូវយកមកអនុវត្តលើសាលដីកាដំណោះស្រាយរបស់សភាស៊ើបសួរ ។ ក្នុងករណីដែលសភាស៊ើបសួរសម្រេចដោះលែងជនត្រូវចោទដែល

134/240

ជាប់ឃុំ សេចក្តីសម្រេចនោះត្រូវមានអានុភាពអនុវត្តភ្លាម ។ បញ្ញត្តិនៃមាត្រា ២៧៦ (ការដោះលែងជនត្រូវចោទដែលជាប់ឃុំឱ្យមានសេរីភាព) នៃក្រមនេះ មិនត្រូវយកមកអនុវត្តទេ ។

## ជំពូកទី ៥
## អំណាចផ្ទាល់ខ្លួនរបស់ប្រធានសភាស៊ើបសួរ

**មាត្រា ២៨៣.-** អំណាចរបស់ប្រធានសភាស៊ើបសួរ

ប្រធានសភាស៊ើបសួរ ភ្ញាប់រងលើការប្រព្រឹត្តទៅដ៏ល្អនៃមន្ទីរស៊ើបសួរ នៃចៅក្រមស៊ើបសួរ ។ ប្រធានសភាស៊ើបសួរផ្ទៀងផ្ទាត់មើលជាអាទិ៍ លក្ខខណ្ឌនៃការអនុវត្តបទប្បញ្ញត្តិស្តីពីការឃុំខ្លួនបណ្តោះអាសន្ន ដីកាតុលាការផ្សេងៗ ដីកាចាត់ឱ្យស៊ើបសួរជំនួស និងកោសលវិច័យ ។

ប្រធានសភាស៊ើបសួរភ្ញាប់រងកុំឱ្យនីតិវិធីទាំងឡាយមានការយឺតយ៉ាវដោយមិនសមហេតុផល ។

ប្រធានសភាស៊ើបសួរអាចចុះទៅធ្វើអធិការកិច្ចនៅក្នុងមន្ទីរស៊ើបសួរ ។

**មាត្រា ២៨៤.-** តារាងរាយនាមនៃរឿងក្តី

ចៅក្រមស៊ើបសួរគ្រប់រូប នៅពេលដំណាច់ត្រីមាសនីមួយៗ ត្រូវធ្វើតារាងរាយនាមឈ្មោះរឿងទាំងអស់ដោយមានចុះនិទ្ទេស ស្តីពីកិច្ចចុងក្រោយនៃការស៊ើបសួរដែលបានបំពេញ ។

**មាត្រា ២៨៥.-** អធិការកិច្ចនៃមន្ទីរស៊ើបសួរ

គ្រប់អធិការកិច្ចនៃមន្ទីរស៊ើបសួរដោយប្រធានសភាស៊ើបសួរ ត្រូវតែធ្វើរបាយការណ៍ផ្ញើទៅប្រធានសាលាឧទ្ធរណ៍ ។

**មាត្រា ២៨៦.-** បណ្តឹងសុំបិទសំណុំរឿង

នៅពេលផុតថិរវេលា ១ (មួយ) ឆ្នាំ គិតពីថ្ងៃចោទប្រកាន់ ជនត្រូវចោទអាចសុំឱ្យចៅក្រមស៊ើបសួរបិទការស៊ើបសួរ ។ ក្នុងរយៈពេល ១ (មួយ) ខែ គិតពីថ្ងៃទទួលពាក្យសុំនេះ ចៅក្រមស៊ើបសួរត្រូវតែសម្រេច ។ ប្រសិនបើចៅក្រមស៊ើបសួរមិនសម្រេចនៅក្នុងរយៈពេលនេះទេ ជនត្រូវចោទអាចប្តឹងទៅប្រធានសភាស៊ើបសួរ ដែលធ្វើអធិបញ្ញាដល់ចៅក្រមស៊ើបសួរឱ្យសម្រេច ។

លុះផុតថិរវេលា ១ (មួយ) ឆ្នាំ គិតពីថ្ងៃតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដើមបណ្តឹងរដ្ឋប្បវេណីអាចសុំឱ្យចៅក្រមស៊ើបសួរបិទការស៊ើបសួរ ។ ក្នុងរយៈពេល ១ (មួយ) ខែ គិតពីការទទួលពាក្យប្តឹងសុំ ចៅក្រមស៊ើបសួរត្រូវតែសម្រេច ។ ប្រសិនបើចៅក្រមស៊ើបសួរមិនសម្រេចក្នុង

ROYAUME DU CAMBODGE
MINISTRE DU PALAIS

រយៈពេលនេះទេ ដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងទៅប្រធានសភាស៊ើបសួរ ដែលផ្ញើអធិបញ្ញាឱ្យចៅក្រមស៊ើបសួរសម្រេច ។

អំណាចដែលទទួលស្គាល់ដោយមាត្រានេះដល់ជនត្រូវចោទ និងដល់ដើមបណ្តឹងរដ្ឋប្បវេណី អាចត្រូវប្រើប្រាស់បានដោយមេធាវី ។

## គន្ថីទី ៥
## អំពីសាលក្រម
## មាតិកាទី ១
## សាលក្រមសាលាដំបូង
## ជំពូកទី ១
## សមត្ថកិច្ច និងការប្តឹងទៅតុលាការ
## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ២៨៧.-** ការរៀបចំតាមដែនដីរបស់តុលាការ

នៅទីប្រជុំជននៃខេត្ត ឬ ក្រុងនីមួយៗ មានតុលាការជាន់ដំបូងមួយដែលមានសមត្ថកិច្ចលាតសន្ធឹងលើដែនដីខេត្ត ឬ ក្រុងទាំងមូល ហៅថាសាលាដំបូង ។

**មាត្រា ២៨៨.-** វិសមិតភាពរវាងមុខងារផ្សេងៗរបស់ចៅក្រម

រវាងមុខងារជាចៅក្រម និងមុខងារជាព្រះរាជអាជ្ញា ឬ ជាព្រះរាជអាជ្ញារងនោះ គឺមានវិសមិតភាពនឹងគ្នាយ៉ាងដាច់ខាត ។

ចៅក្រមណាដែលបានបំពេញមុខងារក្នុងឋានៈជាព្រះរាជអាជ្ញា ជាព្រះរាជអាជ្ញារង ឬ ជាចៅក្រមស៊ើបសួរលើរឿងណាមួយ មិនអាចចូលរួមក្នុងការជំនុំជម្រះរឿងនោះបានទេ បើពុំដូច្នោះទេ សាលក្រមនឹងត្រូវទុកជាមោឃៈ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · ព្រះបរមរាជវាំង

138/240

# ផ្នែកទី ២

# សមត្ថកិច្ចសម្ភារៈ និងសមត្ថកិច្ចដែនដី

**មាត្រា ២៨៩.–** សមត្ថកិច្ចរបស់សាលាដំបូង

សាលាដំបូងជំនុំជម្រះបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ។ សាលាដំបូងសម្រេចជាក្រុមសមូហភាពដែលមានចៅក្រម ៣ (បី) រូប ចំពោះបទឧក្រិដ្ឋ ព្រមទាំងបទមជ្ឈិម និងបទលហុដែលជាប់ទាក់ទង ។

សាលាដំបូងសម្រេចជាចៅក្រមទោលចំពោះបទមជ្ឈិម និងបទលហុ ។

**មាត្រា ២៩០.–** វិវាទសមត្ថកិច្ចរវាងសាលាដំបូង

តុលាការដែលមានសមត្ថកិច្ចខាងដែនដីគឺ :

-តុលាការនាទីកន្លែងបទល្មើស

-តុលាការនាលំនៅឋានរបស់ជនជាប់ចោទ ឬ

-តុលាការនាទីកន្លែងចាប់ខ្លួនជនជាប់ចោទ ។

ក្នុងករណីដែលមានតុលាការពីរ ឬ ច្រើន ដែលស្ថិតនៅក្នុងមណ្ឌលនៃសាលាឧទ្ធរណ៍តែមួយបានទទួលពាក្យប្ដឹងលើរឿងតែមួយដូចគ្នា ប្រធានសាលាឧទ្ធរណ៍ចាត់តាំងតុលាការដែលនឹងត្រូវទទួលបន្ទុកលើសំណុំរឿង ។

វិវាទសមត្ថកិច្ចដែនដី រវាងតុលាការច្រើនដែលមានថ្នាក់ស្មើគ្នា ត្រូវសម្រេចដោយប្រធានតុលាការជាន់ខ្ពស់ ។

ការសម្រេចនេះបិទផ្លូវតវ៉ា ។

សមត្ថកិច្ចចំពោះជនជាប់ចោទត្រូវពន្លាតរហូតដល់សហចារី អ្នកផ្ដើមគំនិត និងអ្នកសមគំនិតទាំងអស់ ។

ប្រសិនបើតុលាការដែលបានទទួលពាក្យប្ដឹងយល់ឃើញថាពុំមានសមត្ថកិច្ចតាមដែនដី តុលាការនេះប្រកាសថាពុំមានសមត្ថកិច្ចដោយសាលក្រម និងបង្គាប់ឱ្យបង្វិលសំណុំរឿងជូនព្រះរាជអាជ្ញា ដើម្បីឱ្យព្រះរាជអាជ្ញាបញ្ជូនសំណុំរឿងនេះ ជូនតុលាការដែលមានសមត្ថកិច្ចតាមដែនដី ។ ជាយថាហេតុ តុលាការនេះសម្រេចសេចក្ដីលើការបន្តដាក់ជនជាប់ចោទឱ្យស្ថិតក្នុងការឃុំខ្លួន ឬ ការត្រួតពិនិត្យតាមផ្លូវតុលាការ ។

# ផ្នែកទី ៣

## ការប្ដឹងទៅតុលាការ

**មាត្រា ២៩១.-** របៀបប្ដឹងទៅតុលាការ

ក្នុងរឿងព្រហ្មទណ្ឌ សាលាដំបូងត្រូវបានទទួលបណ្ដឹងដោយ :

-ដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬ សាលដីកាបញ្ជូនរបស់សភាស៊ើបសួរ

-ដីកាបញ្ជូនទៅតុលាការជំនុំជម្រះដោយផ្ទាល់របស់ព្រះរាជអាជ្ញា

-កំណត់ហេតុស្ដីពីការចូលបង្ហាញខ្លួនភ្លាមដែលធ្វើដោយព្រះរាជអាជ្ញា ។

គ្រប់បុគ្គលដែលត្រូវបានបញ្ជូនទៅចំពោះមុខតុលាការតាមនីតិវិធីណាមួយដូចខាងលើនេះ មានឈ្មោះថាជនជាប់ចោទ ។

ជនរងគ្រោះនៃបទល្មើស អាចតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីបាននៅចំពោះមុខតុលាការ ប្រសិនបើខ្លួនពុំទាន់បានតាំងខ្លួននៅឡើយនៅមុខចៅក្រមស៊ើបសួរ ។

មានឈ្មោះហៅថាអ្នកទទួលខុសត្រូវរដ្ឋប្បវេណី គឺបុគ្គលគ្រប់រូប ដោយអនុវត្តតាមច្បាប់ដែលត្រូវតែជួសជុលព្យសនកម្មដែលបណ្ដាលឱ្យមានដល់ជនរងគ្រោះនៃបទល្មើស ។

**មាត្រា ២៩២.-** ការកំណត់កាលបរិច្ឆេទនៃសវនាការ

លើកលែងតែក្នុងករណីនៃនីតិវិធីចូលបង្ហាញខ្លួនភ្លាម កាលបរិច្ឆេទនៃសវនាការត្រូវកំណត់ដោយប្រធានតុលាការ ។

នៅក្នុងករណីដែលតុលាការបានទទួលបណ្ដឹងដោយការបញ្ជូនទៅជំនុំជម្រះផ្ទាល់ដោយដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬ សាលដីកាបញ្ជូនរបស់សភាស៊ើបសួរ ប្រធានតុលាការត្រូវតែគិតគូរតាមរយៈពេលដែលចែងនៅក្នុងមាត្រា ៤៥៧(រយៈពេលដែលត្រូវគោរពរវាងការប្រគល់ដីកាកោះហៅ បញ្ជូនទៅជំនុំជម្រះផ្ទាល់ និងការបង្គាប់ឱ្យចូលបង្ហាញខ្លួន) និងមាត្រា ៤៦៦ (រយៈពេលដែលត្រូវគោរពរវាងដីកាកោះហៅ និងការបង្គាប់ឱ្យចូលបង្ហាញខ្លួន) នៃក្រមនេះ ដើម្បីកំណត់កាលបរិច្ឆេទបើកសវនាការ ។

កាលបរិច្ឆេទនេះត្រូវជូនដំណឹងដោយផ្ទាល់មាត់ដល់ព្រះរាជអាជ្ញា ។

**មាត្រា ២៩៣.-** រយៈពេលរួម

គ្រប់ថិរវេលាដែលចែងដោយក្រមនេះ ដើម្បីបំពេញកិច្ច ឬ ទម្រង់ការណាមួយនោះ ត្រូវផុតរលត់នៅថ្ងៃចុងក្រោយវេលាម៉ោង ២៤ (ម្ភៃបួន) ។ តាមធម្មតា រយៈពេលដែលផុតកំណត់នៅថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬ ថ្ងៃបុណ្យ ត្រូវអូសបន្ទាយរហូតដល់ថ្ងៃទីមួយដែលបើកធ្វើការវិញ ។

នៅក្នុងគ្រប់ករណីដែលទាមទារហត្ថលេខារបស់បុគ្គលណាម្នាក់នៅលើកិច្ចណាមួយនោះ ហត្ថលេខានេះ អាចជំនួសដោយស្នាមម្រាមដៃ កាលណាបុគ្គលនោះមិនចេះចុះហត្ថលេខា ។

**មាត្រា ២៩៤.-** ការកោះហៅភាគីឱ្យចូលរួមក្នុងសវនាការតាមដីកាបញ្ជូន ឬ តាមសាលដីកាបញ្ជូន

ក្នុងករណីដែលតុលាការបានទទួលបណ្តឹងដោយដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬ សាលដីកាបញ្ជូនរបស់សភាស៊ើបសួរ ព្រះរាជអាជ្ញាត្រូវកោះហៅឱ្យចូលរួមក្នុងពេលសវនាការនូវ :

-ជនជាប់ចោទ

-ដើមបណ្តឹងរដ្ឋប្បវេណី

-ជនរងគ្រោះ កាលណាជននេះមិនទាន់បានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅមុខចៅក្រមស៊ើបសួរ

-សាក្សី

-អ្នកជំនាញ

-អ្នកបកប្រែ

-អ្នកទទួលខុសត្រូវរដ្ឋប្បវេណីតាមព័ត៌មានដែលផ្តល់ដោយជនជាប់ចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី ។

ការកោះហៅឱ្យចូលរួមក្នុងពេលសវនាការ ត្រូវធ្វើដូចដែលបានចែងនៅក្នុងមាតិកាទី ២ គន្ថីទី ៧ នៃក្រមនេះ ។ លិខិតចម្លងនៃដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬ នៃសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ ត្រូវភ្ជាប់ជាមួយនឹងដីកាកោះហៅនេះ ដើម្បីប្រគល់ឱ្យដល់ជនជាប់ចោទ ។

**មាត្រា ២៩៥.-** ការកោះហៅភាគីតាមដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

ក្នុងករណីតុលាការបានទទួលបណ្តឹងដោយដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ព្រះរាជអាជ្ញាត្រូវកោះហៅឱ្យចូលរួមក្នុងសវនាការនូវ :

-ជនរងគ្រោះ



141/240

-សាក្សី

-អ្នកបកប្រែ

-អ្នកទទួលខុសត្រូវរដ្ឋប្បវេណីតាមព័ត៌មានដែលផ្តល់ឱ្យដោយជនជាប់ចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី ។

ការកោះហៅឱ្យចូលរួមក្នុងសវនាការ ត្រូវធ្វើដូចដែលមានចែងនៅមាតិកាទី ១ គន្ថីទី ៧ នៃក្រមនេះ ។

**មាត្រា ២៩៦.–** ការកោះហៅភាគីនៅក្នុងករណីចូលបង្ហាញខ្លួនភ្លាម

នៅក្នុងករណីនៃនីតិវិធីចូលបង្ហាញខ្លួនភ្លាម ព្រះរាជអាជ្ញាត្រូវកោះហៅឱ្យចូលរួមក្នុងសវនាការនូវ :

-ជនរងគ្រោះ

-សាក្សី

-អ្នកបកប្រែ

-អ្នកទទួលខុសត្រូវរដ្ឋប្បវេណីតាមព័ត៌មានដែលផ្តល់ដោយជនជាប់ចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី ។

ការកោះហៅឱ្យចូលរួមក្នុងពេលសវនាការ ត្រូវធ្វើដូចដែលបានចែងនៅក្នុងមាតិកាទី ១ គន្ថីទី ៧ នៃក្រមនេះ ។ ប៉ុន្តែ ក្នុងករណីបន្ទាន់ ព្រះរាជអាជ្ញាអាចកោះហៅជនរងគ្រោះ សាក្សី អ្នកបកប្រែ និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីតាមគ្រប់មធ្យោបាយ ទោះបីដោយផ្ទាល់មាត់ក៏ដោយ ។

**មាត្រា ២៩៧.–** ការកោះហៅសាក្សី

សាក្សីខាងដាក់បន្ទុកដែលមិនទាន់បានសួរចម្លើយតទល់គ្នាជាមួយជនជាប់ចោទ ត្រូវតែកោះហៅឱ្យចូលរួមក្នុងសវនាការ ។

**មាត្រា ២៩៨.–** ការកោះហៅសាក្សីតាមរយៈជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី

ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណីអាចនាំចូលរួមក្នុងសវនាការនូវសាក្សីទាំងឡាយណា ដែលព្រះរាជអាជ្ញាមិនបានកោះហៅដោយខ្លួនជាអ្នកចេញសោហ៊ុយ ។ ការកោះហៅនេះត្រូវធ្វើតាមបែបបទដែលមានចែងនៅក្នុងមាតិកាទី ៣ គន្ថីទី ៧ នៃក្រមនេះ ។



142/240

**មាត្រា ២៩៩.–** ការបញ្ចូលនីតិវិធី

កាលណាតុលាការ បានទទួលនីតិវិធីច្រើន ដែលមានអង្គហេតុច្រើនជាប់ទាក់ទងគ្នា តុលាការអាចបង្គាប់ឱ្យបញ្ចូលនីតិវិធីទាំងនោះជាមួយគ្នាបាន ។

## ជំពូកទី ២

## ការចូលខ្លួនរបស់ភាគី

### ផ្នែកទី ១

### ការចូលខ្លួនរបស់ជនជាប់ចោទ

**មាត្រា ៣០០.–** ការចូលខ្លួនរបស់ជនជាប់ចោទ

ជនជាប់ចោទត្រូវចូលបង្ហាញខ្លួននៅពេលសវនាការរបស់តុលាការដោយផ្ទាល់ ។

ជនជាប់ចោទត្រូវអមដោយមេធាវីម្នាក់ដែលខ្លួនជ្រើសរើស ។ ជនជាប់ចោទក៏អាចសុំឱ្យចាត់តាំង មេធាវីឱ្យខ្លួនបានដែរ នៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។

**មាត្រា ៣០១.–** ជំនួយរបស់មេធាវី

ជំនួយពីមេធាវីត្រូវតែមានដាច់ខាតនៅក្នុងករណីដូចតទៅ :

១-ករណីបទឧក្រិដ្ឋ ។

២-កាលណាជនជាប់ចោទជាអនីតិជន ។ បើគ្មានការជ្រើសរើសដោយជនជាប់ចោទទេ មេធាវីត្រូវបានចាត់តាំងតាមគំនិតផ្តើមរបស់ប្រធានតុលាការ នៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។

**មាត្រា ៣០២.–** ការបង្ហាញខ្លួនដោយសេរីរបស់ជនជាប់ចោទ

នៅក្នុងករណីបញ្ជូនទៅជំនុំជម្រះផ្ទាល់ ជនជាប់ចោទចូលទៅបង្ហាញខ្លួនដោយខ្លួនឯងនៅពេលសវនាការ ។

**មាត្រា ៣០៣.–** ការបង្ហាញខ្លួនរបស់ជនជាប់ចោទដោយមានកងកម្លាំងអម

នៅក្នុងករណីនីតិវិធីចូលបង្ហាញខ្លួនភ្លាម ជនជាប់ចោទត្រូវឃុំគ្រងដោយកងការពាររហូតដល់សាមីខ្លួនចូលបង្ហាញខ្លួននៅមុខតុលាការ ។

តុលាការអាចសម្រេចឱ្យឃុំខ្លួនជនជាប់ចោទបណ្ដោះអាសន្នបាន ដូចដែលបានចែងនៅក្នុងមាត្រា ៤៨ (នីតិវិធីនៃការបង្ហាញខ្លួនភ្លាម) នៃក្រមនេះ ។

សាលក្រមលើអង្គសេចក្ដី ត្រូវតែប្រកាសនៅក្នុងរយៈពេលដែលមិនអាចលើសពី ២ (ពីរ) សប្ដាហ៍ គិតពីថ្ងៃបង្ហាញខ្លួនជនជាប់ចោទដល់តុលាការ ។

ការឃុំខ្លួនបណ្ដោះអាសន្នត្រូវបញ្ចប់ដោយពេញលក្ខណៈច្បាប់ នៅពេលផុតថិរវេលា ២ (ពីរ) សប្ដាហ៍ ។

**មាត្រា ៣០៤.-** នីតិវិធីនៃការបង្ហាញខ្លួនភ្លាម

កាលណាសម្រេចថាត្រូវប្រើនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ព្រះរាជអាជ្ញាត្រូវ :

-ពិនិត្យអត្តសញ្ញាណបុគ្គលដែលគេបញ្ជូនមកឱ្យខ្លួន

-ឱ្យដំណឹងដល់ជននោះ អំពីរឿងហេតុដែលចោទប្រកាន់ និងឈ្មោះបទល្មើស

-ទទួលចម្លើយរបស់បុគ្គលនោះ ប្រសិនបើសាមីខ្លួនចង់និយាយ

-ធ្វើកំណត់ហេតុស្ដីអំពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ។

ព្រះរាជអាជ្ញាប្រាប់ជនជាប់ចោទថា ខ្លួនមានសិទ្ធិសុំពឹងមេធាវីតាមការជ្រើសរើសរបស់ខ្លួន ឬ ចាត់តាំងឡើងដោយអនុលោមតាមច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី ។

មេធាវីជ្រើសរើស ឬ ចាត់តាំង ត្រូវបានទទួលដំណឹងភ្លាម ។ មេធាវីអាចពិនិត្យសំណុំរឿង និងទាក់ទងជាមួយជនជាប់ចោទបាន ។

និទ្ទេសនៃទម្រង់ការទាំងនេះត្រូវចុះនៅក្នុងកំណត់ហេតុ បើពុំដូច្នោះទេ នីតិវិធីត្រូវទុកជាមោឃៈ ។

តុលាការជាន់ដំបូងត្រូវបានទទួលបណ្ដឹងតាមកំណត់ហេតុស្ដីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ។

ជនជាប់ចោទត្រូវឃុំគ្រងដោយកងការពារ រហូតដល់ពេលសាមីខ្លួនចូលបង្ហាញខ្លួននៅមុខតុលាការ ដែលការបង្ហាញខ្លួននោះត្រូវប្រព្រឹត្តទៅនៅក្នុងថ្ងៃនោះតែម្ដង ។

នៅពេលបង្ហាញខ្លួននេះ តុលាការក្រោយពីបានផ្ទៀងផ្ទាត់មើលអត្តសញ្ញាណរបស់ជនជាប់ចោទ និងរៀបរាប់ការណ៍សង្ខេបរឿងហេតុដែលបានចោទប្រកាន់មក ត្រូវប្រាប់ដល់ជនជាប់ចោទថា សាមីខ្លួនអាចមានរយៈពេលដើម្បីរៀបចំការពារខ្លួន ។

ប្រសិនបើជនជាប់ចោទសុំរយៈពេល ឬ ប្រសិនបើតុលាការយល់ឃើញថារឿងនោះមិនទាន់អាចជំនុំជម្រះនោះ ត្រូវលើកទៅសវនាការក្រោយទៀត ។

ROYAUME DU CAMBODGE
MINISTÈRE DU PALAIS ROYAL



114/250

តុលាការអាចបង្គាប់ឱ្យឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្ន តាមសាលក្រមដែលមានសំអាងហេតុ ។ នៅក្នុងសាលក្រមនោះ តុលាការត្រូវយោងតាមលក្ខខណ្ឌនៃមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន) នៃក្រមនេះ ។ តុលាការត្រូវចេញដីកាបង្គាប់ឱ្យឃុំខ្លួន ។

សាលក្រមលើអង្គសេចក្តី ត្រូវតែប្រកាសក្នុងរយៈពេល ដែលមិនអាចលើសពី ២ (ពីរ) សប្តាហ៍ គិតពីថ្ងៃនៃការចូលទៅបង្ហាញខ្លួននៅមុខតុលាការ ។ ការឃុំខ្លួនបណ្តោះអាសន្នត្រូវតែបញ្ឈប់ដោយពេញលក្ខណៈច្បាប់ ក្រោយពីការផុតរយៈពេល ២ (ពីរ) សប្តាហ៍ ។

ប្រសិនបើតុលាការដែលបានទទួលបណ្តឹងតាមនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម យល់ឃើញថាលក្ខខណ្ឌនៃមាត្រា ៤៧ (ការបង្ហាញខ្លួនភ្លាម) នៃក្រមនេះ មិនបានបំពេញទេ ឬក៏ដោយភាពសាំញ៉ាំនៃរឿងទាមទារជាចាំបាច់ឱ្យធ្វើការស្រាវជ្រាវឱ្យបានជ្រាលជ្រៅបន្ថែម តុលាការត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីបើកធ្វើការស៊ើបសួរ ។ ជនជាប់ចោទត្រូវតែនាំទៅបង្ហាញខ្លួននៅថ្ងៃនោះតែម្តងនៅចំពោះមុខចៅក្រមស៊ើបសួរ បើពុំដូច្នោះទេ ជនជាប់ចោទត្រូវតែដោះលែងឱ្យមានសេរីភាពវិញដោយឯកឯង ។

**មាត្រា ៣០៥.-** ការបង្ហាញខ្លួនរបស់ជនជាប់ចោទ តាមដីកាបញ្ជូន ឬ សាលដីកាបញ្ជូន

ក្នុងករណីដែលតុលាការទទួលបណ្តឹង តាមដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬ សាលដីកា បញ្ជូនរបស់សភាស៊ើបសួរ ជនជាប់ចោទចូលបង្ហាញខ្លួនដោយសេរី លើកលែងតែចៅក្រមស៊ើបសួរ ឬ សភាស៊ើបសួរបានសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន ។

ព្រះរាជអាជ្ញាចាត់វិធានការចាំបាច់ ដើម្បីឱ្យជនជាប់ចោទដែលត្រូវបានឃុំខ្លួន ត្រូវបាននាំទៅកាន់សវនាការដោយកងកម្លាំងសាធារណៈ ។

ដូចដែលបានចែងនៅក្នុងមាត្រា ២៤៩ (សេចក្តីសម្រេចនៃដីកាដំណោះស្រាយទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ) នៃក្រមនេះ សេចក្តីសម្រេចរក្សាទុកខ្លួនជនជាប់ចោទនៅក្នុងឃុំបណ្តោះអាសន្ន ត្រូវអស់អានុភាពនៅពេលផុតថិរវេលា ៤ (បួន) ខែ ។ ប្រសិនបើជនជាប់ចោទមិនត្រូវបានឱ្យចូលទៅបង្ហាញខ្លួននៅមុខតុលាការក្នុងរយៈពេលនេះទេ ជនជាប់ចោទ ត្រូវតែបានដោះលែងឱ្យមានសេរីភាពវិញដោយឯកឯង ។

សាលក្រមលើអង្គសេចក្តីត្រូវធ្វើឡើងក្នុងរយៈពេលសមហេតុផល ។

ជនជាប់ចោទដែលចូលបង្ហាញខ្លួននៅពេលសវនាការក្នុងឋានៈជាជនជាប់ឃុំនោះ នៅតែជាប់ឃុំដដែលរហូតដល់មានសាលក្រមលើអង្គសេចក្តី លើកលែងតែតុលាការបង្គាប់ឱ្យដោះលែងឱ្យមានសេរីភាពវិញ ។

ROYAUME DU CAMBODGE
MINISTERE DU PALAIS ROYAL

115/240

**មាត្រា ៣០៦.-** ការដោះលែងជនជាប់ចោទដែលជាប់ឃុំឱ្យមានសេរីភាពដោយឯកឯង

នៅគ្រប់ពេលវេលា តុលាការអាចបង្គាប់ឱ្យដោះលែងជនជាប់ចោទដែលជាប់ឃុំ ឱ្យមានសេរីភាពវិញបាន ឬ ឱ្យបន្តការឃុំខ្លួនជនជាប់ចោទដោយយោងតាមមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន) នៃក្រមនេះ ។

តុលាការអាចសម្រេចក្រោយពីបានស្តាប់ជនជាប់ចោទ មេធាវី និងព្រះរាជអាជ្ញា ។

**មាត្រា ៣០៧.-** បណ្តឹងសុំដោះលែងឱ្យមានសេរីភាពរបស់ជនជាប់ចោទដែលជាប់ឃុំ

ជនជាប់ចោទដែលត្រូវបានឃុំខ្លួន អាចសុំដល់តុលាការឱ្យដោះលែងខ្លួនឱ្យមានសេរីភាពវិញ ដោយផ្ទាល់មាត់នៅពេលសវនាការ ឬ តាមលិខិតដែលផ្ញើជូនទៅក្រឡាបញ្ជី ។

ពាក្យសុំឱ្យដោះលែងនៅក្រៅឃុំ អាចធ្វើដោយមេធាវីរបស់ជនជាប់ចោទដែលត្រូវបានឃុំខ្លួនដោយផ្ទាល់មាត់នៅពេលសវនាការ ឬ តាមលិខិតដែលផ្ញើជូនទៅក្រឡាបញ្ជី ។

កាលណាពាក្យសុំបានធ្វើដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវកត់ត្រានៅក្នុងកំណត់ហេតុនៃសវនាការ ។ កាលណាពាក្យសុំបានធ្វើតាមលិខិត ក្រឡាបញ្ជីចុះនិទ្ទេសអំពីកាលបរិច្ឆេទទទួលនៅលើលិខិតនេះ ហើយបញ្ជូនជាបន្ទាន់ទៅដល់ប្រធានតុលាការ ។

តុលាការសម្រេច ក្រោយពីបានស្តាប់ជនជាប់ចោទ មេធាវី និងព្រះរាជអាជ្ញា ។ តុលាការត្រូវសម្រេចនៅក្នុងរយៈពេលដ៏ខ្លីបំផុត និងយ៉ាងយូរបំផុតក្នុងរយៈពេល ១០ (ដប់) ថ្ងៃ ក្រោយពីការសុំដោយផ្ទាល់មាត់ ឬ ក្រោយពីទទួលពាក្យសុំដែលធ្វើជាលាយលក្ខណ៍អក្សរ ។

**មាត្រា ៣០៨.-** ការដាក់ឱ្យនៅជាប់ឃុំរហូតដល់ផុតរយៈពេលប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា

កាលណាតុលាការបង្គាប់ឱ្យដោះលែងឱ្យមានសេរីភាពវិញនោះ ជនជាប់ចោទដែលត្រូវបានឃុំខ្លួននោះ ត្រូវរក្សាទុកនៅក្នុងពន្ធនាគារ រហូតដល់ផុតរយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា លើកលែងតែចៅក្រមនេះ យល់ព្រមដោះលែងជនជាប់ចោទដែលត្រូវបានឃុំខ្លួននោះភ្លាម ។ សេចក្តីសម្រេចយល់ព្រម ឬ មិនយល់ព្រមជាលាយលក្ខណ៍អក្សររបស់ព្រះរាជ-អាជ្ញាត្រូវតែដាក់បញ្ចូលក្នុងសំណុំរឿងនៃនីតិវិធី ។

ក្នុងករណីមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា អំពីសាលក្រមដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទដែលត្រូវបានឃុំខ្លួននោះ ជនជាប់ចោទត្រូវរក្សាទុកក្នុងពន្ធនាគារ រហូតទាល់តែសាលាឧទ្ធរណ៍បានសម្រេចអំពីបណ្តឹងឧទ្ធរណ៍នេះ ។

146/240

**មាត្រា ៣០៩.-** ជនជាប់ចោទដែលពុំអាចចូលបង្ហាញខ្លួន

ប្រសិនបើដោយមូលហេតុស្ថានភាពសុខភាព ឬ ដោយមូលហេតុធ្ងន់ធ្ងរ ដែលធ្វើឱ្យជនជាប់ចោទ មិនអាចចូលទៅបង្ហាញខ្លួននៅចំពោះមុខតុលាការបានទេ ប្រធានសវនាការអាចបង្គាប់ឱ្យសួរជនជាប់ចោទ នៅទីកន្លែងដែលជននោះនៅ ។

តុលាការកំណត់កាលបរិច្ឆេទនៃការសួរចម្លើយ ។

ការសួរចម្លើយត្រូវធ្វើដោយប្រធានសវនាការ នៅចំពោះមុខព្រះរាជអាជ្ញា ក្រឡាបញ្ជីនិងមេធាវីរបស់ជនជាប់ចោទ លើកលែងតែជនជាប់ចោទបោះបង់ចោលយ៉ាងជាក់លាក់នូវវត្តមានរបស់មេធាវីខ្លួន ។

ការសួរចម្លើយនេះត្រូវតែមានធ្វើកំណត់ហេតុ ។

**មាត្រា ៣១០.-** ដីកាបង្គាប់ឱ្យនាំខ្លួនដែលសម្រេចដោយតុលាការ

នៅក្នុងរឿងមជ្ឈិម និងឧក្រិដ្ឋ ប្រសិនបើជនជាប់ចោទមិនចូលបង្ហាញខ្លួនទេ តុលាការអាចបង្គាប់ឱ្យបង្អង់រឿងនេះទុកសិន និងឱ្យចេញដីកាបង្គាប់ឱ្យនាំខ្លួន ។ តុលាការត្រូវតែបញ្ជាក់អំពីកាលបរិច្ឆេទនៃការបើកសវនាការថ្មី ។

ដីកាបង្គាប់ឱ្យនាំខ្លួនមានចុះនិទ្ទេសដូចតទៅ :

-អត្តសញ្ញាណជនជាប់ចោទ

-បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ

-ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា ។

ដីកាបង្គាប់ឱ្យនាំខ្លួនត្រូវមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយប្រធានសវនាការ និងមានបោះត្រាផង ។

បទប្បញ្ញត្តិមាត្រា ១៩២ (ការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន) នៃក្រមនេះ ត្រូវយកមកអនុវត្ត ។

ជនជាប់ចោទត្រូវបាននាំខ្លួនទៅកាន់អង្គភាពនគរបាល កងរាជអាវុធហត្ថ មណ្ឌលឃុំខ្លួន ឬ ពន្ធនាគាររហូតដល់ពេលជនជាប់ចោទនេះចូលបង្ហាញខ្លួននៅមុខតុលាការ ។ ជនជាប់ចោទអាចសុំឱ្យព្រះរាជអាជ្ញាស្ដាប់ចម្លើយរបស់ខ្លួន ។ ព្រះរាជអាជ្ញាធ្វើកំណត់ហេតុស្ដីពីការស្ដាប់ចម្លើយនេះ ។

ROYAUME DU CAMBODGE MINISTERE DU PALAIS ROYAL

147/240

## ផ្នែកទី ២
## ការចូលខ្លួនរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

**មាត្រា ៣១១.–** ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងពេលសវនាការ

ក្នុងពេលសវនាការ ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីធ្វើតាមការប្រកាសប្ដឹងសាមញ្ញនៅចំពោះមុខក្រឡាបញ្ជី ។ ការប្រកាសប្ដឹងនេះត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុនៃសវនាការ ។

ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី មិនអាចទទួលបានទេ ក្រោយពីសេចក្ដីសន្និដ្ឋានសុំរបស់ព្រះរាជអាជ្ញាលើអង្គសេចក្ដី ។

ជនរងគ្រោះដែលបានតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរួចហើយ នៅពេលស៊ើបសួរនោះ មិនចាំបាច់បំពេញទម្រង់ការនេះជាថ្មីទៀតទេនៅមុខតុលាការ ។

**មាត្រា ៣១២.–** វិសមិតភាពរវាងឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណី និងឋានៈជាសាក្សី

ដើមបណ្ដឹងរដ្ឋប្បវេណី មិនអាចត្រូវគេស្ដាប់យកចម្លើយក្នុងឋានៈជាសាក្សីបានទេ ។

**មាត្រា ៣១៣.–** ជំនួយ និងការតំណាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

ដើមបណ្ដឹងរដ្ឋប្បវេណីក៏អាចត្រូវបានអមដោយមេធាវីដែលខ្លួនបានជ្រើសរើស ។ ដើមបណ្ដឹងរដ្ឋប្បវេណីក៏អាចត្រូវបានតំណាងដោយមេធាវី សហព័ទ្ធ ឬ ញាតិលោហិតផ្ទាល់ដែរ ។ អ្នកតំណាងដែលមិនមែនជាមេធាវី ត្រូវតែមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ។

## ផ្នែកទី ៣
## ការចូលខ្លួនរបស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី

**មាត្រា ៣១៤.–** ការចូលបង្ហាញខ្លួនរបស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី

អ្នកទទួលខុសត្រូវរដ្ឋប្បវេណីអាចត្រូវបានអមដោយមេធាវី ។ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ក៏អាចត្រូវបានតំណាងដោយមេធាវី ដោយសហព័ទ្ធ ឬ ដោយញាតិលោហិតផ្ទាល់ដែរ ។ អ្នកតំណាងដែលមិនមែនជាមេធាវី ត្រូវតែមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ។

ROYAUME DU CAMBODGE • LE MINISTÈRE DU PALAIS ROYAL •
ព.ប.ម.៣៧



148/250

## ផ្នែកទី ៤

## ការចូលខ្លួនរបស់សាក្សី

**មាត្រា ៣១៥.-** ការចូលបង្ហាញខ្លួនរបស់សាក្សី

សាក្សីត្រូវតែចូលមកបង្ហាញខ្លួននៅមុខតុលាការតាមការកោះហៅ ។ តុលាការអាចប្រើកងកម្លាំងសាធារណៈដើម្បីបង្ខំសាក្សីឱ្យចូលបង្ហាញខ្លួន ។

## ជំពូកទី ៣

## ការពិភាក្សាដេញដោល

## ផ្នែកទី ១

## សាធារណភាពនៃកិច្ចពិភាក្សាដេញដោល និងការដឹកនាំសវនាការ

**មាត្រា ៣១៦.-** សាធារណភាពនៃកិច្ចពិភាក្សាដេញដោល និងភាពសម្ងាត់នៃកិច្ចពិភាក្សាដេញដោល

ការពិភាក្សាដេញដោលប្រព្រឹត្តទៅនៅក្នុងពេលសវនាការសាធារណៈ ។

ប៉ុន្តែ បើតុលាការយល់ឃើញថាសាធារណភាព បង្កឱ្យមានគ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬ ដល់ទំនៀមទម្លាប់ នោះតុលាការតាមសេចក្តីសម្រេចមានសំអាងហេតុ អាចបង្គាប់ឱ្យការពិភាក្សាដេញដោលទាំងស្រុង ឬ មួយផ្នែកប្រព្រឹត្តទៅជាសម្ងាត់ ។ តុលាការសម្រេចតាមសាលក្រមមួយ ដាច់ដោយឡែកពីសាលក្រមអង្គសេចក្តី ឬ តាមសេចក្តីសម្រេចពិសេសនៃសាលក្រមលើអង្គសេចក្តី ។

សេចក្តីសម្រេចរបស់តុលាការដែលបង្គាប់ឱ្យធ្វើការពិភាក្សាដេញដោលជាសម្ងាត់ មិនអាចតវ៉ាបានទេ ។

**មាត្រា ៣១៧.-** ការប្រកាសសាលក្រម

នៅក្នុងគ្រប់ករណីទាំងអស់ សាលក្រមត្រូវតែប្រកាសនៅពេលសវនាការជាសាធារណៈ ។

**មាត្រា ៣១៨.-** ការធានាសណ្តាប់ធ្នាប់នៃសវនាការ

ប្រធានសវនាការដឹកនាំការពិភាក្សាដេញដោល ។ ប្រធានត្រូវរ៉ាប់រងឱ្យសិទ្ធិខាងការការពារបានប្រព្រឹត្តទៅដោយសេរី ។ ប៉ុន្តែ ប្រធានអាចបដិសេធចេញពីការពិភាក្សាដេញដោលនូវ



ROYAUME DU CAMBODGE · MINISTERE DU PALAIS ROYAL
149/260

អ្វីដែលមានគោលបំណងអូសបន្លាយការពិភាក្សាដេញដោលនេះដោយឥតប្រយោជន៍ គ្មានរួមវិភាគទានអ្វីដល់ការសំដែងឱ្យឃើញការពិត ។

ប្រធានសវនាការរ៉ាប់រងឱ្យមានសណ្តាប់ធ្នាប់ល្អនៅពេលសវនាការ ។

ប្រធានសវនាការអាចហាមឃាត់អនីតិជនខ្លះ ឬ ទាំងអស់មិនឱ្យចូលក្នុងបន្ទប់សវនាការ ។

ប្រធានសវនាការអាចបង្គាប់ឱ្យបណ្តេញបុគ្គលគ្រប់រូប ដែលបង្កឱ្យមានការច្របូកច្របល់ដល់របៀបរៀបរយនៃការពិភាក្សាដេញដោល ។

ក្នុងការបំពេញមុខងាររបស់ខ្លួន ប្រធានសវនាការអាចប្រើប្រាស់កងកម្លាំងសាធារណៈ ។

**មាត្រា ៣១៩.–** ការពិនិត្យមើលសំណុំរឿង

មុនពេលសវនាការ មេធាវីអាចពិនិត្យមើលសំណុំរឿងនៅការិយាល័យក្រឡាបញ្ជីនៃតុលាការនៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី ។

មេធាវី ឬ លេខាធិការរបស់មេធាវី អាចត្រូវបានអនុញ្ញាតដោយប្រធានតុលាការឱ្យធ្វើការចម្លងលិខិតនៃសំណុំរឿង ដោយខ្លួនជាអ្នកចេញសោហ៊ុយ និងនៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី ។

**មាត្រា ៣២០.–** បទល្មើសដែលត្រូវបានប្រព្រឹត្តនៅក្នុងពេលសវនាការ

ប្រសិនបើមានបទល្មើសបានកើតឡើងនៅក្នុងពេលសវនាការ ប្រធានសវនាការធ្វើកំណត់ហេតុពិនិត្យរឿងហេតុនេះ ។

ប្រធានសវនាការអាចបង្គាប់ឱ្យចាប់ និងនាំជនល្មើសភ្លាមជូនព្រះរាជអាជ្ញា ដើម្បីថ្លឹងថ្លែងពីវិធានការដែលត្រូវចាត់ ។

កាលណាបទល្មើសជាបទលហុ ឬ បទមជ្ឈិម តុលាការអាចជំនុំជម្រះជនល្មើសភ្លាម ប្រសិនបើព្រះរាជអាជ្ញាប្តឹងសុំ និងប្រសិនបើជនល្មើសយល់ព្រម ។

## វគ្គទី ២

## វិធាននៃភស្តុតាង

**មាត្រា ៣២១.–** ការវាយតម្លៃលើភស្តុតាងដោយតុលាការ

លើកលែងបទប្បញ្ញត្តិច្បាប់ផ្ទុយពីនេះ ភស្តុតាងក្នុងរឿងព្រហ្មទណ្ឌ អាចជូនបានដោយសេរី ។



150/240

តុលាការថ្លឹងថ្លែងដោយឥស្សរចិត្ត អំពីតម្លៃភស្តុតាងដែលគេដាក់ជូនមកខ្លួនពិនិត្យដោយផ្អែកទៅលើជំនឿស្មោះត្រង់ពិតប្រាកដរបស់ខ្លួន ។

តុលាការសំអាងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន តែទៅលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង ឬ ដែលត្រូវគេយកមកបង្ហាញនៅពេលសវនាការប៉ុណ្ណោះ ។

ការសារភាពក៏ដូចជាប្រភេទនៃភស្តុតាងដទៃទៀតដែរ ត្រូវដាក់ជូនតុលាការធ្វើការថ្លឹងថ្លែង ។ ចម្លើយដែលទទួលក្រោមការបង្ខិតបង្ខំខាងរូបកាយ ឬ ខាងផ្លូវចិត្តនេះ គ្មានតម្លៃជាភស្តុតាងទេ ។

ការឆ្លើយឆ្លងរវាងជនជាប់ចោទ និងមេធាវីរបស់ខ្លួន មិនអាចយកមកធ្វើជាភស្តុតាងបានឡើយ ។

## ផ្នែកទី ៣
## ដំណើរការនៃកិច្ចពិភាក្សាដេញដោល

**មាត្រា ៣២២.-** វិធានទាក់ទងនឹងភាគីដែលមានវត្តមាននៅក្នុងសវនាការ

ក្រឡាបញ្ជីហៅឈ្មោះជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញ ព្រមទាំងផ្ទៀងផ្ទាត់មើលអត្តសញ្ញាណជនទាំងនោះ ។

កាលណាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានតំណាងដោយសហព័ន្ធ ឬ ដោយញាតិលោហិតផ្ទាល់ ក្រឡាបញ្ជីពិនិត្យមើលអត្តសញ្ញាណនៃអ្នកតំណាង និងសុពលភាពនៃការប្រគល់សិទ្ធិ ។ ចំពោះអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ក៏ត្រូវធ្វើដូច្នេះដែរ ។ ក្រឡាបញ្ជីត្រូវសុំយោបល់ប្រធានសវនាការក្នុងករណីចាំបាច់ ។

ភាគីនីមួយៗ អង្គុយនៅតាមកន្លែងដែលទុកសម្រាប់ឱ្យខ្លួន នៅក្នុងបន្ទប់សវនាការ ។

ជនជាប់ចោទមិនត្រូវទាក់ទងនឹងគ្នាទេ ។

អ្នកជំនាញ និងសាក្សីថយខ្លួនទៅនៅក្នុងបន្ទប់រង់ចាំដែលទុកបម្រុងឱ្យខ្លួន ហើយដែលពីក្នុងបន្ទប់រង់ចាំនោះ ខ្លួនមិនអាចមើលឃើញ ឬ ឮអ្វីដែលប្រព្រឹត្តទៅនៅក្នុងបន្ទប់សវនាការទេ ។

នៅក្នុងពេលសវនាការ និងនៅក្នុងបន្ទប់រង់ចាំ សាក្សីមិនត្រូវទាក់ទងនឹងគ្នាទេ ។

**មាត្រា ៣២៣.-** វិវាទកម្មស្តីពីនិយតភាពនៃការកោះហៅ

វិវាទកម្មស្តីពីភាពត្រឹមត្រូវនៃដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ នៃកំណត់ហេតុចូលបង្ហាញខ្លួនភ្លាម ឬ ការកោះឱ្យចូលមកបង្ហាញខ្លួននៅពេលសវនាការ ត្រូវតែលើកឡើងនៅមុនពេលសួរចម្លើយជនជាប់ចោទលើអង្គសេចក្តី បើពុំដូច្នោះទេ វិវាទកម្មនេះមិនអាចទទួលបានឡើយ ។

ROYAUME DU CAMBODGE ... MINISTÈRE DU PALAIS



151/240

**មាត្រា ៣២៤.–** ការស្តាប់ចម្លើយរបស់សាក្សីដែលមិនត្រូវបានកោះហៅ

នៅពេលបើកពិភាក្សាដេញដោល ភាគីអាចសុំឱ្យតុលាការស្តាប់ចម្លើយក្នុងឋានៈជាសាក្សី នូវបុគ្គលដែលមានវត្តមាននៅក្នុងបន្ទប់ ប៉ុន្តែ មិនបានកោះហៅឱ្យ បានត្រឹមត្រូវទេ ។ ការស្តាប់ចម្លើយសាក្សីនេះត្រូវមានការយល់ព្រមពីប្រធានសវនាការ ។ ក្រឡាបញ្ជីស្រង់អត្តសញ្ញាណ និងអញ្ជើញសាក្សីនេះឱ្យថយទៅនៅបន្ទប់រង់ចាំ ។

**មាត្រា ៣២៥.–** ការសួរចម្លើយជនជាប់ចោទ

ប្រធានសវនាការប្រាប់ដល់ជនជាប់ចោទឱ្យ បានដឹង អំពីអំពើដែលគេចោទប្រកាន់លើខ្លួន និងធ្វើការសួរចម្លើយជនជាប់ចោទនេះ ។ ប្រធានសវនាការសួរគ្រប់សំណួរដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការសំដែងឱ្យឃើញការពិត ។ ប្រធានសវនាការមានករណីយកិច្ចសួរចម្លើយជនជាប់ចោទនេះ ទាំងខាងផ្នែកដាក់បន្ទុក ទាំងខាងផ្នែកដោះបន្ទុក ។

ក្រោយពីប្រធានសវនាការសួរចម្លើយរួចហើយ ព្រះរាជអាជ្ញា មេធាវី និងភាគី អាចត្រូវបានអនុញ្ញាតឱ្យលើកសំណួរសួរដល់ជនជាប់ចោទ ។ គ្រប់ការលើកសំណួរទាំងអស់ត្រូវតែបានការអនុញ្ញាតពីប្រធានសវនាការ ។ ក្រៅពីសំណួររបស់តំណាងអយ្យការ និងមេធាវី សំណួរផ្សេងៗទៀត ត្រូវសួរតាមរយៈប្រធានសវនាការ ។ ក្នុងករណីមានការតវ៉ា ប្រធានសវនាការសម្រេចដោយឥស្សរចិត្តថា តើសំណួរនេះត្រូវតែសួរឬទេ ។

**មាត្រា ៣២៦.–** ការស្តាប់ចម្លើយរបស់ភាគី

ប្រធានសវនាការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញ តាមលំដាប់លំដោយដែលខ្លួនយល់ឃើញថាមានប្រយោជន៍ ។ ប្រធានសវនាការអាចស្តាប់នូវចម្លើយមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ ដែលបានចូលរួមក្នុងការស៊ើបអង្កេតក្នុងឋានៈជាសាក្សី ។

ព្រះរាជអាជ្ញា មេធាវី និងភាគី អាចត្រូវបានអនុញ្ញាតឱ្យលើកសំណួរសួរ ។ គ្រប់ការលើកសំណួរទាំងអស់ត្រូវតែបានការអនុញ្ញាតពីប្រធានសវនាការ ។ ក្រៅពីសំណួររបស់តំណាងអយ្យ-ការ និងមេធាវី សំណួរផ្សេងៗទៀតត្រូវសួរតាមរយៈប្រធានសវនាការ ។ ក្នុងករណីមានការតវ៉ា ប្រធានសវនាការសម្រេចដោយឥស្សរចិត្ត ថាតើសំណួរនេះត្រូវតែសួរឬទេ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL



152/240

**មាត្រា ៣២៧.-** ការជំទាស់ទៅនឹងការស្ដាប់ចម្លើយរបស់សាក្សី

ព្រះរាជអាជ្ញា មេធាវី និងភាគី អាចជំទាស់នឹងការស្ដាប់សាក្សី ដែលខ្លួនយល់ឃើញថា ចម្លើយនេះគ្មានប្រយោជន៍អ្វីដល់ការសំដែងឱ្យឃើញការពិត ។ ក្នុងករណីមានការតវ៉ា ប្រធានសវនាការសម្រេចដោយឥស្សរចិត្តថា តើត្រូវស្ដាប់ ឬ មិនស្ដាប់ចម្លើយសាក្សីនេះ ។

**មាត្រា ៣២៨.-** ការស្បថរបស់សាក្សី

ប្រធានសវនាការសួរសាក្សីម្នាក់ៗថា តើជាញាតិលោហិត ឬ ញាតិពន្ធរបស់ជនជាប់ចោទ ដើមបណ្ដឹងរដ្ឋប្បវេណី ឬ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ឬ ក៏ជាអ្នកស៊ីឈ្នួលបម្រើជនទាំងនោះ ឬទេ ។

មុននឹងឆ្លើយទៅនឹងសំណួរ សាក្សីនីមួយៗត្រូវស្បថថា ខ្លួននិយាយតែការពិតស្របតាមសាសនា ឬ ជំនឿរបស់ខ្លួន ។

ក្រោយពេលឆ្លើយរួចហើយ សាក្សីនីមួយៗ ត្រូវតែនៅបម្រុងខ្លួនសម្រាប់សេចក្ដីត្រូវការរបស់តុលាការ ។ តុលាការអាចអនុញ្ញាតឱ្យសាក្សីនេះថយខ្លួន ប្រសិនបើវត្តមានរបស់សាក្សីនេះលែងចាំបាច់ទៀតហើយ ។

បទប្បញ្ញត្តិនៃមាត្រា ១៥៦ (សាក្សីដែលអនុញ្ញាតឱ្យរួចពីសម្បថ) នៃក្រមនេះ ត្រូវយកមកអនុវត្តផងដែរ ។

**មាត្រា ៣២៩.-** អ្នកប្ដឹងបរិហារ

អ្នកប្ដឹងបរិហារដែលបានទទួលរង្វាន់ពីបណ្ដឹងបរិហាររបស់ខ្លួន ក៏អាចត្រូវបានតុលាការស្ដាប់ចម្លើយយកជាព័ត៌មានបានដែរ ។

**មាត្រា ៣៣០.-** ជំនួយ និងសម្បថរបស់អ្នកបកប្រែ

ក្នុងករណីចាំបាច់ ប្រធានអាចហៅរកអ្នកបកប្រែ ។ អ្នកបកប្រែនេះត្រូវស្បថស្របតាមសាសនា ឬ ជំនឿរបស់ខ្លួនថា ខ្លួននឹងជួយដល់តុលាការ និងបកប្រែចម្លើយឱ្យបានស្មោះត្រង់ ។ នៅក្នុងករណីណាក៏ដោយ អ្នកបកប្រែមិនអាចត្រូវបានជ្រើសរើសក្នុងចំណោមចៅក្រម ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ គូភាគី ឬ សាក្សីទេ ។

បទប្បញ្ញត្តិនៃមាត្រា ១៥៦ (សាក្សីដែលអនុញ្ញាតឱ្យរួចពីសម្បថ) នៃក្រមនេះ ត្រូវយកមកអនុវត្តផងដែរ ។

ROYAUME DU CAMBODGE LE MINISTERE DU PALAIS ROYAL ព្រះបរមរាជវាំង

153/240

**មាត្រា ៣៣១.-** ជនគ ថ្លង់

កាលណាសំណួរត្រូវសួរដល់ជនគ ថ្លង់ ក្រឡាបញ្ជីសរសេរសំណួរ ហើយឱ្យសាមីខ្លួនអាន និងឆ្លើយដោយលាយលក្ខណ៍អក្សរ ។ ក្នុងករណីសាមីជនមិនចេះអាន ឬ មិនចេះអក្សរ ប្រធានសវនាការ ត្រូវរកអ្នកបកប្រែក្នុងលក្ខខណ្ឌដែលមានចែងដោយមាត្រា ៣៣០(ជំនួយ និងសម្បថរបស់អ្នកបកប្រែ) នៃក្រមនេះ ។

ប្រធានសវនាការអាចហៅរកអ្នកធ្លាប់ប្រាស្រ័យទាក់ទងជាមួយជននេះមកបកប្រែ ។ បុគ្គលនេះ ត្រូវស្បថតាមសាសនា និងជំនឿរបស់ខ្លួនថាជួយតុលាការ និងត្រូវបកប្រែចម្លើយឱ្យ បានស្មោះត្រង់ ។

**មាត្រា ៣៣២.-** ការបង្ហាញវត្ថុតាង

ប្រធានសវនាការអាចបង្គាប់ឱ្យជនណាម្នាក់បង្ហាញវត្ថុតាងបាន ។

**មាត្រា ៣៣៣.-** ការស្វែងរកការពិតក្នុងករណីអវត្តមានរបស់ជនជាប់ចោទ

ទោះបីជាជនជាប់ចោទអវត្តមានក៏ដោយ តុលាការត្រូវតែស្វែងរកឱ្យឃើញការពិត ស្តាប់ចម្លើយភាគីដទៃទៀត សាក្សី និងពិនិត្យវត្ថុតាង ។

**មាត្រា ៣៣៤.-** ការដាក់សេចក្តីសន្និដ្ឋានរហូតដល់បិទកិច្ចពិភាក្សាដេញដោល

រហូតទល់នឹងការបិទកិច្ចពិភាក្សាដេញដោល ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និង អ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងជូនលិខិតស្នាមទាំងអស់ដែលខ្លួនយល់ឃើញថា មានប្រយោជន៍ដល់ការសំដែងឱ្យឃើញការពិត ។

សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរត្រូវចុះទិដ្ឋាការដោយប្រធានសវនាការ និងក្រឡាបញ្ជី ហើយត្រូវភ្ជាប់ទៅក្នុងសំណុំរឿង ។

**មាត្រា ៣៣៥.-** សិទ្ធិនិយាយស្តីរបស់ភាគីបន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល

ក្រោយពិភាក្សាដេញដោល ប្រធានសវនាការបើកឱ្យជនដូចខាងក្រោមនេះ និយាយជាបន្តបន្ទាប់គ្នា :

-ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនជាប់ចោទ ដើម្បីធ្វើការកត់សំគាល់ខ្លីៗ

-មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីធ្វើសេចក្តីសន្និដ្ឋានការពារ

ROYAUME DU CAMBODGE * LE MINISTERE DU PALAIS ROYAL



154/240

-ព្រះរាជអាជ្ញា ដើម្បីធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំ

-មេធាវីរបស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី មេធាវីរបស់ជនជាប់ចោទ ដើម្បីធ្វើសេចក្ដីសន្និដ្ឋានការពារ ។

ដើមបណ្ដឹងរដ្ឋប្បវេណី និងព្រះរាជអាជ្ញា អាចឆ្លើយតបទៅវិញបាន ។ ប៉ុន្តែ ជនជាប់ចោទ និងមេធាវីរបស់ខ្លួន ត្រូវនិយាយក្រោយគេបង្អស់ជានិច្ច ។

ការបំពេញទម្រង់ការនេះ ត្រូវតែកត់ត្រាទុកក្នុងកំណត់ហេតុសវនាការ និងក្នុងសាលក្រម ។

**មាត្រា ៣៣៦.–** ពាក្យប្ដឹងសុំដោយផ្ទាល់មាត់របស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាធ្វើការសន្និដ្ឋានប្ដឹងសុំដោយផ្ទាល់មាត់ដែលខ្លួនយល់ឃើញថា សមស្របទៅនឹងប្រយោជន៍ល្អនៃយុត្តិធម៌ ។

**មាត្រា ៣៣៧.–** ការពិភាក្សាសម្រេចរបស់តុលាការ

តុលាការថយខ្លួនចូលទៅក្នុងបន្ទប់ពិភាក្សាដើម្បីសម្រេច ។ គ្មានបណ្ដឹងសុំណាមួយអាចត្រូវដាក់ជូនតុលាការបានទៀតទេ ។ គ្មានទឡ្ហីករណ៍ណាមួយអាចត្រូវបានលើកយកមកសំអាងទៀតបានឡើយ ។

ព្រះរាជអាជ្ញា និងក្រឡាបញ្ជី មិនត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងការពិភាក្សាសម្រេចនេះទេ ។

**មាត្រា ៣៣៨.–** ការចុះដល់កន្លែងរបស់តុលាការ

តុលាការអាចចុះទៅកាន់គ្រប់ទីកន្លែងនៃដែនដីជាតិ ក្នុងផលប្រយោជន៍នៃការសម្ដែងឱ្យឃើញការពិត ។

តុលាការត្រូវតែមានព្រះរាជអាជ្ញា និងក្រឡាបញ្ជីអមដំណើរជានិច្ច ។ ជនជាប់ចោទ ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ព្រមទាំងមេធាវី ក៏អាចជូនដំណើរតុលាការបានដែរ ប្រសិនបើខ្លួនបានស្នើសុំ ។

ប្រតិបត្តិការទាំងនេះ ត្រូវតែមានធ្វើកំណត់ហេតុ ។

**មាត្រា ៣៣៩.–** ព័ត៌មានបន្ថែមដែលបង្គាប់ដោយតុលាការ

ប្រសិនបើយល់ឃើញថា ការស្រាវជ្រាវថ្មីជាការចាំបាច់ តុលាការអាចបង្គាប់តាមសាលក្រមឱ្យធ្វើការស៊ើបសួរបន្ថែម ។

អ្នកដែលមានសមត្ថកិច្ចធ្វើការស៊ើបសួរបន្ថែមនេះគឺ :



155/240

-ប្រធានសវនាការ

-ចៅក្រមមួយរូបនៃក្រុមប្រឹក្សាជំនុំជម្រះ កាលណាតុលាការសម្រេចជាក្រុមសមូហភាព

-ចៅក្រមដទៃទៀត នៃតុលាការជាន់ដំបូង ។

សាលក្រមដែលបង្គាប់ធ្វើការស៊ើបសួរបន្ថែម ត្រូវចាត់តាំងចៅក្រមឱ្យទទួលភារកិច្ចនេះ ។

នៅក្នុងលក្ខខណ្ឌដូចគ្នានឹងចៅក្រមស៊ើបសួរ ចៅក្រមនេះអាច :

-ចុះទៅលើគ្រប់វិសាលភាពនៃដែនសមត្ថកិច្ចតុលាការ ឬ លើគ្រប់វិសាលភាពនៃដែនដីជាតិ

-ស្ដាប់ចម្លើយសាក្សី

-ធ្វើការឆែកឆេរ

-ចាប់យកវត្ថុតាង

-បង្គាប់ឱ្យធ្វើកោសលវិច័យ ។

ដើម្បីអនុវត្តការស៊ើបសួរបន្ថែមនេះ ចៅក្រមអាចចេញដីកាចាត់ឱ្យសួរជំនួសបានដែរ ។

**មាត្រា ៣៤០.–** រឿងក្ដីដែលត្រូវបានដាក់ឱ្យចាត់ការបន្ត

ប្រសិនបើការពិភាក្សាដេញដោលមិនបានបញ្ចប់នៅក្នុងពេលសវនាការនោះទេ តុលាការអាចបន្តនៅពេលសវនាការក្រោយ តាមកាលបរិច្ឆេទដែលខ្លួនកំណត់ ។

**មាត្រា ៣៤១.–** ការសរសេរកំណត់ហេតុសវនាការ

នៅពេលសវនាការក្រឡាបញ្ជីសរសេរកំណត់ហេតុសវនាការដែលមានគោលដៅផ្ដល់មធ្យោបាយដល់សាលាឧទ្ធរណ៍ធ្វើការត្រួតពិនិត្យនីត្យានុកូលភាពនៃនីតិវិធី និងបានយល់ដឹងអំពីការពិភាក្សាដេញដោល ។

ក្រឡាបញ្ជីត្រូវខិតខំរៀបរាប់ដោយយកចិត្តទុកដាក់អំពីការប្រព្រឹត្តទៅនៃសវនាការ និងកត់ត្រាឱ្យបានត្រឹមត្រូវតាមសំណួរដែលសួរ ព្រមទាំងចម្លើយរបស់ជនជាប់ចោទ ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញ ។

កំណត់ហេតុសវនាការត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងចុះទិដ្ឋាការក្រោយពីការផ្ទៀងផ្ទាត់ដោយប្រធានសវនាការក្នុងរយៈពេល ១០ (ដប់) ថ្ងៃ ក្រោយថ្ងៃប្រកាសសាលក្រម ។



126/240

ក្រឡាបញ្ជីណាដែលខ្ជីខ្ជានៅក្នុងការកាន់កាប់កំណត់ហេតុសវនាការ ត្រូវទទួលទណ្ឌកម្មខាងវិន័យ ។

## ផ្នែកទី ៤

## អញ្ញត្រកម្ម

**មាត្រា ៣៩២.-** សមត្ថកិច្ចរបស់តុលាការក្នុងរឿងអញ្ញត្រកម្ម

តុលាការដែលទទួលបណ្តឹងអាជ្ញាមានសមត្ថកិច្ច ដើម្បីសម្រេចអំពីគ្រប់អញ្ញត្រកម្មទាំងអស់ ដែលលើកឡើងដោយគូភាគី លើកលែងតែច្បាប់បានបញ្ញត្តផ្សេងពីនេះ ។

តុលាការមានសមត្ថកិច្ច ជាអាទិ៍ ដើម្បីសម្រេចពីអញ្ញត្រកម្ម ស្តីពីមោឃភាពនៃនីតិវិធី ដែលគេដាក់ជូនខ្លួនពិនិត្យ លើកលែងតែកាលណាតុលាការទទួលជំនុំជម្រះតាមដីកាបញ្ជូនពីចៅក្រមស៊ើបសួរ ឬ សាលដីកាបញ្ជូនរបស់សភាស៊ើបសួរ ។

**មាត្រា ៣៩៣.-** បញ្ហាបន្ទាន់បង្គ្រំ និងការបង្អង់មិនទាន់សម្រេច

តុលាការត្រូវបង្អង់មិនទាន់សម្រេច កាលណាភាគីណាមួយលើកបញ្ហាបន្ទាន់បង្គ្រំដែលការពិនិត្យបញ្ហានេះជាសមត្ថកិច្ចផ្តាច់មុខរបស់តុលាការមួយផ្សេងទៀត ។

បញ្ហាបន្ទាន់បង្គ្រំអាចនឹងទទួលបាន លុះត្រាតែបញ្ហានេះអាចនឹងលុបលាងចរិតជាបទល្មើសពីអំពើដែលចោទប្រកាន់លើជនជាប់ចោទ ។

ក្នុងរឿងរដ្ឋប្បវេណី បញ្ហាស្តីពីសិទ្ធិខាងកម្មសិទ្ធិ សិទ្ធិប្រត្យក្សលើអចលនវត្ថុ និងឋានៈបុគ្គលជាសមត្ថកិច្ចផ្តាច់មុខរបស់តុលាការរដ្ឋប្បវេណី ។

**មាត្រា ៣៩៤.-** ការបង្ហាញអញ្ញត្រកម្ម

អញ្ញត្រកម្មត្រូវតែលើកឡើងមុនដំណាក់កាលការពារដល់អង្គសេចក្តី បើពុំដូច្នេះទេពុំអាចទទួលបានឡើយ ។

**មាត្រា ៣៩៥.-** ការទទួលបញ្ហាបន្ទាន់បង្គ្រំ

តុលាការអាចប្រកាសថា មិនអាចទទួលបាននូវបញ្ហាបន្ទាន់បង្គ្រំតែតាមសាលក្រមដែលមានសំអាងហេតុប៉ុណ្ណោះ ។ កាលណាអញ្ញត្រកម្មមិនបានទទួលការយល់ព្រមទេ ការពិភាក្សាដេញដោលត្រូវបន្ត ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង



157/240

កាលណាបញ្ហាបន្ទាន់បន្ទិ៍ត្រូវបានលើកឡើង និងត្រូវបានទទួលយល់ព្រមដោយតុលាការនោះ តុលាការនេះត្រូវបង្អង់មិនទាន់សម្រេច ហើយកំណត់រយៈពេលឱ្យភាគីពាក់ព័ន្ធប្ដឹងទៅតុលាការមានសមត្ថកិច្ច ។

លុះផុតរយៈពេលនេះ ប្រសិនបើភាគីពាក់ព័ន្ធបង្ហាញភស្តុតាងថា បានប្ដឹងតុលាការមានសមត្ថកិច្ចហើយ តុលាការកំណត់រយៈពេលថ្មីមួយទៀត ដើម្បីឱ្យបានសេចក្ដីសម្រេចអំពីបញ្ហានេះ ។ តុលាការដែលទទួលបណ្ដឹង ត្រូវបានទទួលដំណឹងអំពីរយៈពេលនេះពីព្រះរាជអាជ្ញា ។

បើគ្មានសេចក្ដីសម្រេចនៅក្នុងរយៈពេលដែលកំណត់ដោយតុលាការនោះទេ រឿងក្ដីព្រហ្មទណ្ឌចាប់ដំណើរការតទៅទៀត ប្រសិនបើការយឺតយ៉ាវនេះជាកំហុសបណ្ដាលមកពីការធ្វេសប្រហែសរបស់ភាគីពាក់ព័ន្ធ ។

**មាត្រា ៣៤៦.–** ការជំនុំជម្រះលើអញ្ញត្រកម្ម

តុលាការត្រូវសម្រេចអំពីអញ្ញត្រកម្ម តាមសាលក្រមមួយដាច់ដោយឡែកពីសាលក្រមនៃអង្គសេចក្ដី ។

ប៉ុន្តែ តុលាការក៏អាចបញ្ចូលឧប្បត្តិហេតុទៅនឹងអង្គសេចក្ដី ហើយសម្រេចតាមសាលក្រមតែមួយដូចគ្នា អំពីអញ្ញត្រកម្មជាមួយនឹងអង្គសេចក្ដី ។

## ជំពូកទី ៤

## សេចក្ដីសម្រេច

### ផ្នែកទី ១

### ការប្រកាសសាលក្រម

**មាត្រា ៣៤៧.–** ការប្រកាសសាលក្រម

សាលក្រមត្រូវសម្រេចចេញនៅពេលសវនាការ ដែលធ្វើការពិភាក្សាដេញដោល ឬ នៅពេលសវនាការលើកក្រោយ ។ នៅក្នុងករណីខាងក្រោយនេះ ប្រធានសវនាការជូនដំណឹងដល់ភាគីទាំងឡាយដែលមានវត្តមាន អំពីថ្ងៃដែលត្រូវប្រកាសសាលក្រម ។

**មាត្រា ៣៤៨.–** ដែនកំណត់នៃការប្ដឹងទៅតុលាការចំពោះអង្គហេតុ

តុលាការអាចសម្រេចសេចក្ដីបានតែទៅលើអំពើទាំងឡាយណា ដែលមានបង្ហាញនៅក្នុងសាលដីកាបញ្ជូន ដីកាបញ្ជូន ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ កំណត់ហេតុនៃការបង្ហាញខ្លួនភ្លាម ។



158/249

ក្នុងករណីដែលតុលាការសម្រេចរួមជាក្រុម ហើយយល់ឃើញថាអង្គហេតុដែលត្រូវបានប្តឹងនោះ បង្កើតបានជាបទមជ្ឈិម ឬ បទលហុ តុលាការនោះនៅតែមានសមត្ថកិច្ចដើម្បីជម្រះសេចក្តីដដែល ។

ក្នុងករណីដែលតុលាការសម្រេចដោយមានចៅក្រមតែម្នាក់គត់ ហើយយល់ឃើញថាអង្គហេតុដែលត្រូវបានប្តឹងនោះ បង្កើតបានជាបទឧក្រិដ្ឋ តុលាការនោះបញ្ជូលសំណុំរឿងជូនព្រះរាជអាជ្ញា ដើម្បីបើកការស៊ើបសួរ ។

**មាត្រា ៣៤៩.–** ដែននៃការប្តឹងទៅតុលាការចំពោះបុគ្គល

តុលាការអាចជំនុំជម្រះបុគ្គលដែលបញ្ជូនទៅចំពោះមុខខ្លួនក្នុងឋានៈជាជនជាប់ចោទតែប៉ុណ្ណោះ ។

ប្រសិនបើបុគ្គលណាដែលកោះហៅឱ្យចូលទៅចំពោះមុខតុលាការក្នុងឋានៈជាសាក្សី អាចត្រូវចោទប្រកាន់ក្នុងឋានៈជាជនដៃដល់ ឬ អ្នកសមគំនិត បុគ្គលនោះនឹងអាចត្រូវជំនុំជម្រះបានក្រោយពីត្រូវបានចោទប្រកាន់ដូចមានចែងនៅមាត្រា ៤៣ (ការចោទប្រកាន់) តែប៉ុណ្ណោះ ។

**មាត្រា ៣៥០.–** ការប្រកាសពីពិរុទ្ធភាព

តុលាការពិនិត្យមើលថា :

- អំពើនោះជាបទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុ
- ជនជាប់ចោទបានប្រព្រឹត្តអំពើដែលចោទប្រកាន់លើខ្លួនឬទេ ។

ប្រសិនបើពិនិត្យឃើញថា មានពិរុទ្ធភាពលើជនជាប់ចោទ តុលាការប្រកាសផ្តន្ទាទោសតាមច្បាប់បញ្ញត្តិ ។

ប្រសិនបើតុលាការយល់ឃើញថាអំពីនោះមិនមែនជាបទល្មើសទេ ឬ ក៏ជនជាប់ចោទគ្មានកំហុសទេ ជនជាប់ចោទត្រូវបានរួចខ្លួនពីបទចោទ ។

**មាត្រា ៣៥១.–** អវត្តមានរបស់ជនជាប់ចោទ

វិមតិសង្ស័យត្រូវតែបានជាអត្ថប្រយោជន៍ដល់ជនជាប់ចោទជានិច្ច ។

ក្នុងករណីជនជាប់ចោទអវត្តមាន តុលាការត្រូវប្រកាសទោសដែលយល់ឃើញថាត្រឹមត្រូវប្រសិនបើខ្លួនប្រកាសថាជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើសដូចដែលបានចោទប្រកាន់នោះមែន ។



159/240

**មាត្រា ៣៥២.-** ការបញ្ឈប់ការត្រួតពិនិត្យតាមផ្លូវតុលាការ

ការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវបញ្ឈប់នៅពេលប្រកាសសាលក្រម ។

**មាត្រា ៣៥៣.-** ដីកាបង្គាប់ឱ្យឃុំខ្លួន និងដីកាបង្គាប់ឱ្យចាប់ខ្លួន ចេញដោយតុលាការ

ប្រសិនបើតុលាការប្រកាសផ្តន្ទាទោសដាក់ពន្ធនាគារ ១ (មួយ) ឆ្នាំ យ៉ាងតិច ដោយគ្មានការល្យូរទេ តុលាការតាមសេចក្តីសម្រេចពិសេស និងដោយមានសំអាងហេតុ អាចចេញនៅក្នុងពេលសវនាការ :

-ដីកាបង្គាប់ឱ្យឃុំខ្លួនជនជាប់ចោទដែលមានវត្តមាន

-ដីកាបង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទអវត្តមាន ។

ដីកាបង្គាប់ឱ្យឃុំខ្លួន និងដីកាបង្គាប់ឱ្យចាប់ខ្លួន មានអានុភាពអនុវត្តភ្លាមៗ ។

ដីកាទាំងនោះមានចុះនិទ្ទេសដូចតទៅ :

-អត្តសញ្ញាណរបស់ពិរុទ្ធជន

-ប្រភេទនៃទណ្ឌកម្ម និងអត្ថបទច្បាប់ដែលជាមូលដ្ឋាននៃការផ្តន្ទាទោសនេះ

-ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា ។

ដីកានេះត្រូវតែមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមនេះ និងបោះត្រាផង ។

ពិរុទ្ធជនដែលត្រូវបានចាប់ខ្លួនដោយអនុវត្តតាមដីកាបង្គាប់ឱ្យចាប់ខ្លួននោះ ត្រូវតែបានគេនាំទៅបង្ហាញខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុតនៅមុខព្រះរាជអាជ្ញានាទីកន្លែងចាប់ខ្លួនដែលឱ្យដំណឹងដល់សាមីខ្លួនអំពីដីកានេះ និងធ្វើការឃុំខ្លួន ។

កាលណាសាលក្រមត្រូវបានសម្រេចដោយកំបាំងមុខនោះ ពិរុទ្ធជនដែលសម្រេចចិត្តថាប្តឹងទាស់ ត្រូវតែចូលបង្ហាញខ្លួននៅក្នុងរយៈពេលយ៉ាងខ្លីបំផុត នៅមុខតុលាការដែលបានប្រកាសសាលក្រម ។ ពិរុទ្ធជនអាចធ្វើពាក្យសុំនៅក្រៅឃុំ ។ តុលាការត្រូវសម្រេចដូចដែលមានចែងនៅមាត្រា ៣០៧(បណ្តឹងសុំដោះលែងឱ្យមានសេរីភាពរបស់ជនជាប់ចោទដែលជាប់ឃុំ) នៃក្រមនេះ ។

**មាត្រា ៣៥៤.-** ការប្រគល់វត្ថុដែលចាប់យក

តុលាការមានសមត្ថកិច្ចសម្រេចអំពីការប្រគល់វត្ថុដែលចាប់យក ។

**មាត្រា ៣៥៥.-** ការសម្រេចអំពីប្រយោជន៍ផ្នែករដ្ឋប្បវេណី

នៅក្នុងសាលក្រមតែមួយជាមួយរឿងព្រហ្មទណ្ឌ តុលាការសម្រេចអំពីផលប្រយោជន៍ផ្នែករដ្ឋប្បវេណី ។ តុលាការវិនិច្ឆ័យអំពីភាពអាចទទួលបាននៃការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្ប-

ROYAUME DU CAMBODGE ROYAL MINISTERE DU PALAIS

160/240

វេណី ហើយសម្រេចអំពីពាក្យប្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ទៅលើជនជាប់ចោទ និងលើអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ។ កាលណាតុលាការមិនទាន់អាចសម្រេចបានលើផលប្រយោជន៍ផ្នែករដ្ឋប្បវេណីទេ តុលាការអាចបង្អង់ទៅសវនាការលើកក្រោយ និងអាចសម្រេចឱ្យប្រាក់បណ្តោះអាសន្ន ។

បុគ្គលដែលត្រូវផ្តន្ទាទោសក្នុងបទល្មើសតែមួយជាមួយគ្នានោះ ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដោយសាមគ្គីភាព ។

**មាត្រា ៣៥៦.-** អវត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសវនាការ

ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីបានជូនពាក្យសុំទាមទារសំណងការខូចខាតនៅមុនពេលសវនាការ តែអវត្តមាននៅពេលសវនាការ ហើយប្រសិនបើតុលាការប្រកាសថាមានពិរុទ្ធលើជនជាប់ចោទ នោះតុលាការត្រូវតែសម្រេចឱ្យសងការខូចខាតដល់ជនរងគ្រោះដោយផ្អែកលើអត្ថន័យនៃសំណុំរឿង ។

**មាត្រា ៣៥៧.-** ការសរសេរសាលក្រម : ផ្នែកសំអាងហេតុ និងផ្នែកសម្រេច

គ្រប់សាលក្រមត្រូវមានពីរផ្នែក :

-ផ្នែកសំអាងហេតុពោលគឺទឡ្ហីករណ៍នៃអង្គហេតុ និងអង្គច្បាប់ដែលនាំឱ្យតុលាការចេញសេចក្តីសម្រេច ។

-ផ្នែកសម្រេចពោលគឺសេចក្តីសម្រេចរបស់តុលាការ ។

អង្គហេតុត្រូវតែច្បាស់លាស់ និងគ្មានការសង្ស័យ ។ តុលាការត្រូវពិនិត្យមើលបទចោទនីមួយៗ និងទឡ្ហីករណ៍ដែលបានលើកនៅពេលសវនាការ ។

នៅក្នុងសំអាងហេតុ តុលាការត្រូវឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់គូភាគី ។

ផ្នែកសេចក្តីសម្រេចត្រូវចុះនិទ្ទេស អំពីបទល្មើសដែលជនជាប់ចោទបានប្រព្រឹត្តខុសអត្ថបទច្បាប់ដែលអនុវត្តទោស និងទណ្ឌកម្មរដ្ឋប្បវេណី ។

**មាត្រា ៣៥៨.-** និទ្ទេសដែលត្រូវចុះលើសាលក្រម

សាលក្រមត្រូវចុះហត្ថលេខាដោយប្រធាន និងក្រឡាបញ្ជី ។

សាលក្រមត្រូវមានចុះសេចក្តីដូចតទៅ :

-កាលបរិច្ឆេទនៃសវនាការ

-កាលបរិច្ឆេទនៃការប្រកាសសាលក្រម

-ឈ្មោះ និងឋានៈរបស់ចៅក្រមដែលជំនុំជម្រះ

-ឈ្មោះ និងឋានៈតំណាងអយ្យការ

-ឈ្មោះ និងឋានៈរបស់ក្រឡាបញ្ជី

-ឈ្មោះ ទីលំនៅ កាលបរិច្ឆេទ និងទីកន្លែងកំណើត មុខរបររបស់ជនជាប់ចោទរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី

-ឈ្មោះរបស់មេធាវី ។

ក្រោយពីបានចុះហត្ថលេខាដោយប្រធាន និងក្រឡាបញ្ជីរួច សាលក្រមដើមត្រូវតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីយ៉ាងយូរបំផុត ៨ (ប្រាំបី) ថ្ងៃ ក្រោយការប្រកាសសាលក្រម ។ ការិយាល័យក្រឡាបញ្ជីត្រូវតែរក្សាទុកសាលក្រមដើមជានិច្ច ។ ក្រឡាបញ្ជីអាចផ្តល់ច្បាប់ចម្លងនៃសាលក្រមជាអាទិ៍ ក្នុងករណីមានឧទ្ធរណ៍ ។

**មាត្រា ៣៥៩.–** ការប្រកាសសាលក្រមនៅក្នុងសវនាការសាធារណៈ

គ្រប់សាលក្រមត្រូវតែប្រកាសនៅពេលសវនាការសាធារណៈ ។ ផ្នែកនៃសេចក្តីសម្រេចត្រូវអានដោយសម្លេងខ្លាំងៗ ដោយប្រធានសវនាការ ។

## ផ្នែកទី ២
## ប្រភេទនៃសាលក្រម

**មាត្រា ៣៦០.–** សាលក្រមចំពោះមុខ

ប្រសិនបើជនជាប់ចោទចូលបង្ហាញខ្លួននៅពេលសវនាការ នោះសាលក្រមជាសាលក្រមចំពោះមុខជនជាប់ចោទ ។ សាលក្រមចំពោះមុខជនជាប់ចោទមិនត្រូវឱ្យដំណឹងដល់ជននេះទេ ។ សាលក្រមចំពោះមុខអាចត្រូវប្តឹងឧទ្ធរណ៍បាន ។

សាលក្រមនៅតែជាសាលក្រមចំពោះមុខដដែល ទោះបីជនជាប់ចោទចាកចេញពីបន្ទប់សវនាការក៏ដោយ ។

សាលក្រមក៏ជាសាលក្រមចំពោះមុខដែរ កាលណាជនជាប់ចោទត្រូវបានសួរចម្លើយនៅក្នុងលក្ខខណ្ឌដែលមានចែងនៅមាត្រា ៣០៩ (ជនជាប់ចោទដែលពុំអាចចូលបង្ហាញខ្លួន) នៃក្រមនេះ ។



162/290

**មាត្រា ៣៦១.-** សាលក្រមដែលត្រូវចាត់ទុកថាចំពោះមុខ

ប្រសិនបើជនជាប់ចោទមិនចូលមកបង្ហាញខ្លួននៅពេលសវនាការទេ ប៉ុន្តែ សាមីខ្លួនបានដឹងអំពីដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ បានដឹងពីការកោះហៅហើយនោះ សាលក្រមត្រូវចាត់ទុកថាជាសាលក្រមចំពោះមុខជនជាប់ចោទ ។

សាលក្រមដែលចាត់ទុកថាចំពោះមុខនេះ ត្រូវឱ្យដំណឹងដល់ជនជាប់ចោទ ។ សាលក្រមនេះ អាចត្រូវប្តឹងឧទ្ធរណ៍បាន ។

ក្នុងករណីដែលជនជាប់ចោទអវត្តមានបានបង្ហាញមូលហេតុអំពីការអវត្តមានរបស់ខ្លួន ហើយតុលាការក៏បានទទួលថាត្រឹមត្រូវ នោះតុលាការអាចលើករឿងទៅជំនុំជម្រះនៅសវនាការមួយក្រោយទៀត ។

**មាត្រា ៣៦២.-** សាលក្រមកំបាំងមុខ

ប្រសិនបើជនជាប់ចោទមិនចូលបង្ហាញខ្លួននៅពេលសវនាការទេ ហើយនិងប្រសិនបើគ្មានភស្តុតាងបង្ហាញឱ្យឃើញថាសាមីខ្លួនដឹងពីដីកាបញ្ជូនទៅជំនុំជម្រះ ឬ បានដឹងអំពីការកោះហៅនោះទេ សាលក្រមត្រូវប្រកាសដោយកំបាំងមុខជនជាប់ចោទ ។

សាលក្រមកំបាំងមុខជនជាប់ចោទ ត្រូវឱ្យដំណឹងដល់ជនជាប់ចោទនេះ ។ សាលក្រមនេះអាចត្រូវប្តឹងទាស់បាន ។

**មាត្រា ៣៦៣.-** សាលក្រមដែលចេញចំពោះដើមបណ្តឹងរដ្ឋប្បវេណី

ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីចូលបង្ហាញខ្លួននៅពេលសវនាការ ឬ មានអ្នកតំណាងដោយត្រឹមត្រូវនោះ សាលក្រមត្រូវតែជាសាលក្រមចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីនេះ ។ សាលក្រមចំពោះមុខ ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវជូនដំណឹងដល់សាមីខ្លួនទេ ។ សាលក្រមនេះអាចប្តឹងឧទ្ធរណ៍បាន ។

ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីមិនចូលបង្ហាញខ្លួននៅពេលសវនាការទេ និងគ្មានអ្នកតំណាងត្រឹមត្រូវទេ សាលក្រមត្រូវប្រកាសដោយកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ។ សាលក្រមកំបាំងមុខនេះ ត្រូវជូនដំណឹងដល់ដើមបណ្តឹងរដ្ឋប្បវេណី ។ សាលក្រមនេះអាចប្តឹងទាស់បាន ។

**មាត្រា ៣៦៤.-** សាលក្រមដែលចេញចំពោះអ្នកទទួលខុសត្រូវរដ្ឋប្បវេណី

ប្រសិនបើបុគ្គលដែលកោះហៅក្នុងឋានៈជាអ្នកទទួលខុសត្រូវរដ្ឋប្បវេណីចូលបង្ហាញខ្លួននៅពេលសវនាការ ឬ ក៏មានអ្នកតំណាងដោយត្រឹមត្រូវ សាលក្រមនោះជាសាលក្រមចំពោះមុខ

អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ។ សាលក្រមចំពោះមុខនេះមិនត្រូវឱ្យដំណឹងដល់អ្នកទទួលខុស-ត្រូវរដ្ឋប្បវេណីទេ ។ សាលក្រមនេះអាចត្រូវប្តឹងឧទ្ធរណ៍បាន ។

ប្រសិនបើបុគ្គលកោះហៅក្នុងឋានៈជាអ្នកទទួលខុសត្រូវរដ្ឋប្បវេណី មិនចូលបង្ហាញខ្លួននៅពេលសវនាការ និងគ្មានអ្នកតំណាងត្រឹមត្រូវទេ សាលក្រមត្រូវសម្រេចដោយកំបាំងមុខអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ។ សាលក្រមកំបាំងមុខនេះត្រូវឱ្យដំណឹងដល់អ្នកទទួលខុសត្រូវរដ្ឋប្ប-វេណី ។ សាលក្រមនេះ អាចប្តឹងទាស់បាន ។

## ផ្នែកទី ៣
## បណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ

**មាត្រា ៣៦៥.–** បណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ

ពិរុទ្ធជនអាចធ្វើបណ្តឹងទាស់នឹងសាលក្រមដែលប្រកាសដោយកំបាំងមុខខ្លួនបាន ។

**មាត្រា ៣៦៦.–** ទម្រង់ និងភាពដែលអាចទទួលយកបាននៃបណ្តឹងទាស់

បណ្តឹងទាស់ត្រូវធ្វើដោយពាក្យប្តឹងជាលាយលក្ខណ៍អក្សរ :

-នៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម

-នៅចំពោះមុខព្រះរាជអាជ្ញា អង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ ឬ នៅចំពោះមុខប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ។

ពិរុទ្ធជនអាចត្រូវបានតំណាងដោយមេធាវី ។ មេធាវីត្រូវតែមានលិខិតអនុញ្ញាតឱ្យធ្វើបណ្តឹងទាស់ ។ ប៉ុន្តែ ពិរុទ្ធជនជាអនីតិជនអាចត្រូវតំណាងដោយឪពុក ម្តាយ ឬ អ្នកអាណាព្យាបាល ។ ក្នុងករណីនេះ អ្នកតំណាងមិនចាំបាច់មានលិខិតប្រគល់សិទ្ធិទេ ។

កាលណាបានទទួលពាក្យប្តឹងទាស់ ព្រះរាជអាជ្ញា អង្គភាពនគរបាល និងកងរាជអាវុធហត្ថ ព្រមទាំងប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន បញ្ជូនបណ្តឹងទាស់នោះភ្លាមទៅក្រឡាបញ្ជីនៃតុលា-ការដែលបានប្រកាសសាលក្រម ។

កាលណាអ្នកប្តឹងទាស់មិនចេះចុះហត្ថលេខាទេ អ្នកប្តឹងទាស់នេះត្រូវផ្តិតម្រាមដៃ ។

**មាត្រា ៣៦៧.–** បញ្ជីបណ្តឹងទាស់

ក្រឡាបញ្ជីនៃតុលាការកាន់បញ្ជីបណ្តឹងទាស់ ។ គូភាគី និងមេធាវីអាចពិនិត្យមើលបញ្ជីនោះបានដោយសេរី ។



164/240 ,១៧

មាត្រា៣៦៨នេះត្រូវបានធ្វើវិសោធនកម្មដោយ នស/រកម/០៦១៣/០០៩
សូមចុចទីនេះដើម្បីមើលមាត្រា៣៦៨ថ្មីនៅទំព័រ២០៩

មាត្រា៣៦៨នេះត្រូវបានធ្វើវិសោធនកម្មដោយ នស/រកម/០៦១៣/០០៩
សូមចុចទីនេះដើម្បីមើលមាត្រា៣៦៨ថ្មីនៅទំព័រ២០៩

**មាត្រា ៣៦៨.–** រយៈពេលសម្រាប់ធ្វើបណ្តឹងទាស់

បណ្តឹងទាស់ត្រូវតែធ្វើនៅក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ផ្តើមគិត៖

-ពីថ្ងៃជូនដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រមត្រូវបានប្រគល់ឱ្យពិរុទ្ធជនដោយផ្ទាល់ដៃ ឬ

-ពីថ្ងៃដែលពិរុទ្ធជននេះបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលក្រមនេះ មិនបានប្រគល់ឱ្យដល់ពិរុទ្ធជនដោយផ្ទាល់ដៃទេ ។

**មាត្រា ៣៦៩.–** បណ្តឹងទាស់កម្រិតចំពោះសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី

បណ្តឹងទាស់អាចកម្រិតធ្វើទៅលើសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីនៃសាលក្រមក៏បាន ។

**មាត្រា ៣៧០.–** អានុភាពនៃបណ្តឹងទាស់

កាលណាបណ្តឹងទាស់ធ្វើប្រឆាំងទៅលើសាលក្រមទាំងមូល សាលក្រមនេះត្រូវទុកជាអសារបង់ ។ ការអនុវត្តសាលក្រមត្រូវល្បូរ ។

ប៉ុន្តែ ដីកាបង្គាប់ឱ្យចាប់ខ្លួននៅតែមានអានុភាព ។ តុលាការនៅតែមានសមត្ថកិច្ច ដើម្បីសម្រេចអំពីការដោះលែងជនជាប់ចោទឱ្យមានសេរីភាពវិញ ។

កាលណាបណ្តឹងទាស់ធ្វើប្រឆាំងទៅលើសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី មានតែសេចក្តីសម្រេចផ្នែកនេះប៉ុណ្ណោះ ដែលត្រូវទុកជាអសារបង់ ។ ការអនុវត្តសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីនេះត្រូវល្បូរ ។

**មាត្រា ៣៧១.–** សាលក្រមសម្រេចលើបណ្តឹងទាស់

សំណុំរឿងត្រូវបានលើកយកមកជំនុំជម្រះនៅមុខតុលាការដដែល ។

ភាគីទាំងអស់ត្រូវបានកោះហៅតាមគំនិតផ្តើមរបស់ព្រះរាជអាជ្ញា ។

ក្រោយពីបានពិនិត្យមើលភាពអាចទទួលបាននៃបណ្តឹងទាស់នេះ តុលាការសម្រេចលើអង្គសេចក្តីជាថ្មីម្តងទៀត ។

ប្រសិនបើអ្នកប្តឹងទាស់ដែលបានកោះហៅដោយត្រឹមត្រូវ ហើយមិនចូលបង្ហាញខ្លួននៅពេលសវនាការទេ តុលាការប្រកាសថាបណ្តឹងទាស់ទុកជាឯកសារឥតបានការ ។ សាលក្រមដែលគេប្តឹងទាស់ មិនអាចត្រូវកែប្រែទេ ។ សាលក្រមនេះមានអានុភាពទាំងស្រុងចំពោះភាគីទាំងអស់ ។ អ្នកប្តឹងទាស់នៅមានលទ្ធភាពប្តឹងឧទ្ធរណ៍នៅក្នុងលក្ខខណ្ឌដែលមានចែងនៅមាត្រា ៣៨២



165/240

(រយៈពេលប្ដឹងឧទ្ធរណ៍របស់ពិរុទ្ធជន ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី) នៃក្រមនេះ ។

មាត្រា៣៧២នេះត្រូវបានធ្វើវិសោធនកម្មដោយ នស/រកម/០៦១៣/០០៩
សូមចុចទីនេះដើម្បីមើលមាត្រា៣៧២ថ្មីនៅទំព័រ២១០

~~**មាត្រា ៣៧២.-** បណ្ដឹងទាស់ដែលធ្វើឡើងដោយដើមបណ្ដឹងរដ្ឋប្បវេណី ឬ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី~~

~~ដើមបណ្ដឹងរដ្ឋប្បវេណីក៏អាចប្ដឹងទាស់នឹងសាលក្រម ដែលសម្រេចដោយកំបាំងមុខខ្លួនបានដែរ ។ បណ្ដឹងទាស់នេះ ត្រូវកំណត់ទៅលើសេចក្ដីសម្រេចផ្នែករដ្ឋប្បវេណីនៃសាលក្រមតែប៉ុណ្ណោះ ។~~

~~បណ្ដឹងទាស់ត្រូវធ្វើក្នុងរយៈពេល ១៥ (ដប់ប្រាំ)ថ្ងៃ គិតពី :~~

~~-ថ្ងៃឱ្យដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រមបានប្រគល់ឱ្យដើមបណ្ដឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃ ឬ~~

~~-ថ្ងៃដែលដើមបណ្ដឹងរដ្ឋប្បវេណីបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលក្រមនេះមិនបានប្រគល់ឱ្យដល់ដើមបណ្ដឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃទេ ។~~

~~បណ្ដឹងទាស់ត្រូវធ្វើជាលាយលក្ខណ៍អក្សរ នៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម ។~~

~~ដើមបណ្ដឹងរដ្ឋប្បវេណីអាចត្រូវតំណាងដោយមេធាវី សហព័ទ្ធ ឬ ញាតិលោហិតផ្ទាល់ ។ អ្នកតំណាងត្រូវមានលិខិតប្រគល់សិទ្ធិឱ្យប្ដឹងទាស់ ។~~

~~បទប្បញ្ញត្តិនៃមាត្រានេះ ត្រូវយកមកអនុវត្តលើបុគ្គលដែលតុលាការប្រកាសថាត្រូវទទួលខុសត្រូវរដ្ឋប្បវេណីផងដែរ ។~~

## មាតិកាទី ២

## បណ្ដឹងឧទ្ធរណ៍ចំពោះសាលក្រម

### ជំពូកទី ១

### សមត្ថកិច្ចរបស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍

**មាត្រា ៣៧៣.-** សមត្ថកិច្ចរបស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍មានសមត្ថកិច្ច ដើម្បីសម្រេចអំពីបណ្ដឹងឧទ្ធរណ៍ដែលធ្វើប្រឆាំងនឹងសេចក្ដីសម្រេចរបស់តុលាការជាន់ដំបូង ដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួនក្នុងរឿងព្រហ្មទណ្ឌ ។

ROYAUME DU CAMBODGE
SECRÉTARIAT DU PALAIS ROYAL
166/240

**មាត្រា ៣៧៤.-** អនុបវាទនៃចៅក្រមមួយចំនួន

ចៅក្រមណាម្នាក់ដែលបានបំពេញកិច្ចចោទប្រកាន់ ឬ ស៊ើបសួរ ឬ ដែលបានចូលរួមជំនុំជម្រះសាលាដំបូងរួចហើយនោះ មិនអាចនឹងចូលរួមជំនុំជម្រះនៅសាលាឧទ្ធរណ៍ក្នុងឋានៈជាប្រធាន ឬ ចៅក្រមចំពោះរឿងដដែលនោះបានឡើយ ។

## ជំពូកទី ២

## ភាពដែលអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

**មាត្រា ៣៧៥.-** បុគ្គលដែលអាចធ្វើបណ្តឹងឧទ្ធរណ៍

អាចប្តឹងឧទ្ធរណ៍បាន :

-ព្រះរាជអាជ្ញានៃតុលាការជាន់ដំបូង និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

-ពិរុទ្ធជន

-ដើមបណ្តឹងរដ្ឋប្បវេណី ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី

-អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី ។

**មាត្រា ៣៧៦.-** ទម្រង់នៃបណ្តឹងឧទ្ធរណ៍ដោយព្រះរាជអាជ្ញា ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី

បណ្តឹងរបស់ព្រះរាជអាជ្ញា ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម ។

ពិរុទ្ធជនអាចត្រូវបានតំណាងដោយមេធាវី ។ មេធាវីត្រូវតែមានលិខិតប្រគល់សិទ្ធិឱ្យធ្វើបណ្តឹងឧទ្ធរណ៍ ។ ប៉ុន្តែ ពិរុទ្ធជនជាអនីតិជន អាចតំណាងដោយឪពុក ម្តាយ ឬ អ្នកអាណាព្យាបាល ។ ក្នុងករណីនេះអ្នកតំណាងមិនចាំបាច់មានលិខិតប្រគល់សិទ្ធិទេ ។

ដើមបណ្តឹងរដ្ឋប្បវេណីអាចតំណាងដោយមេធាវី សហព័ទ្ធ ឬ ញាតិលោហិតផ្ទាល់ ។ អ្នកតំណាងត្រូវតែមានលិខិតប្រគល់សិទ្ធិឱ្យធ្វើបណ្តឹងឧទ្ធរណ៍នេះ ។

អ្នកទទួលខុសត្រូវរដ្ឋប្បវេណីអាចតំណាងដោយមេធាវី សហព័ទ្ធ ឬ ញាតិលោហិតផ្ទាល់ ។ អ្នកតំណាង ត្រូវតែមានលិខិតប្រគល់សិទ្ធិឱ្យធ្វើបណ្តឹងឧទ្ធរណ៍នេះ ។

ក្រឡាបញ្ជីចុះបណ្តឹងឧទ្ធរណ៍នៅលើបញ្ជីពិសេសដែលរក្សាទុកនៅក្នុងបញ្ជីនៃតុលាការ ។ លិខិតប្តឹងឧទ្ធរណ៍ត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងអ្នកប្តឹងឧទ្ធរណ៍ ឬ អ្នកតំណាង ។ លិខិតប្រគល់សិទ្ធិ ត្រូវភ្ជាប់នឹងលិខិតប្តឹងឧទ្ធរណ៍ ។

**មាត្រា ៣៧៧.–** ការប្រកាសបណ្ដឹងឧទ្ធរណ៍ដោយពិរុទ្ធជនដែលជាប់ឃុំ

ពិរុទ្ធជនដែលជាប់ឃុំ អាចសំដែងឆន្ទៈរបស់ខ្លួនក្នុងការប្ដឹងឧទ្ធរណ៍នៅមុខប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ។ ពិរុទ្ធជននេះបំពេញពាក្យប្ដឹងឧទ្ធរណ៍ដែលត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា ។

ពាក្យប្ដឹងឧទ្ធរណ៍ត្រូវចុះបញ្ជីដោយប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួននៅលើបញ្ជីពិសេស ។ ពិរុទ្ធជនចុះហត្ថលេខានៅរឹមនៃបញ្ជីនេះ ។

ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ត្រូវបញ្ជូនពាក្យប្ដឹងឧទ្ធរណ៍នៅក្នុងរយៈពេលដ៏ខ្លីបំផុតទៅក្រឡាបញ្ជីនៃតុលាការដែលត្រូវចុះនិទ្ទេសអំពីពាក្យប្ដឹងឧទ្ធរណ៍នេះ នៅលើបញ្ជីប្ដឹងឧទ្ធរណ៍នៃតុលាការ ។

**មាត្រា ៣៧៨.–** អ្នកប្ដឹងឧទ្ធរណ៍ជាអនក្ខរជន

កាលណាអ្នកប្ដឹងឧទ្ធរណ៍មិនចេះចុះហត្ថលេខា អ្នកប្ដឹងឧទ្ធរណ៍នេះត្រូវផ្ដិតម្រាមដៃ ។

**មាត្រា ៣៧៩.–** ទម្រង់នៃបណ្ដឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា

ការប្ដឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា ត្រូវធ្វើតាមពាក្យប្ដឹងនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ។

ក្រឡាបញ្ជីចុះលិខិតប្ដឹងឧទ្ធរណ៍នៅលើបញ្ជីពិសេសដែលរក្សាទុកនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ។ លិខិតប្ដឹងឧទ្ធរណ៍ត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងអគ្គព្រះរាជអាជ្ញា ។

**មាត្រា ៣៨០.–** ការបើកពិនិត្យមើលបញ្ជីបណ្ដឹងឧទ្ធរណ៍

បញ្ជីបណ្ដឹងឧទ្ធរណ៍នៃតុលាការជាន់ដំបូង និងសាលាឧទ្ធរណ៍អាចត្រូវបានភាគី និងមេធាវីពិនិត្យមើលបានដោយសេរី ។

**មាត្រា ៣៨១.–** រយៈពេលប្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញា

ការប្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាត្រូវតែធ្វើក្នុងរយៈពេល ១ (មួយ) ខែ ។

ការប្ដឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញាត្រូវតែធ្វើក្នុងរយៈពេល ៣ (បី) ខែ ។

រយៈពេលប្ដឹងឧទ្ធរណ៍ផ្ដើមគិតពីពេលប្រកាសសាលក្រម ។

168/240

មាត្រា៣៨២នេះត្រូវបានធ្វើវិសោធនកម្មតាមរយៈ នស/រកម/០៦១៣/០០៩
សូមចុចទីនេះដើម្បីមើលមាត្រា៣៨២ថ្មី ទំព័រទី២១១

**មាត្រា ៣៨២.–** រយៈពេលប្តឹងឧទ្ធរណ៍របស់ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី

ការប្តឹងឧទ្ធរណ៍របស់ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ត្រូវតែធ្វើក្នុងរយៈពេល ១ (មួយ) ខែ ។

កាលណាសាលក្រមនោះជាសាលក្រមចំពោះមុខ រយៈពេលប្តឹងឧទ្ធរណ៍ផ្តើមគិតពីពេលប្រកាសសាលក្រម ។

កាលណាសាលក្រមនោះជាសាលក្រមចាត់ទុកថាចំពោះមុខ រយៈពេលប្តឹងឧទ្ធរណ៍ផ្តើមគិតពីពេលទទួលដំណឹងសាលក្រម ទោះបីការឱ្យដំណឹងនេះធ្វើតាមវិធីណាក៏ដោយ ។

**មាត្រា ៣៨៣.–** រយៈពេលបន្ថែមសម្រាប់ធ្វើបណ្តឹងឧទ្ធរណ៍ : បណ្តឹងឧទ្ធរណ៍ឧបប្បត្តិហេតុ

ក្នុងករណីដែលភាគីណាមួយបានប្តឹងឧទ្ធរណ៍នៅក្នុងរយៈពេលខាងលើនេះ ភាគីដទៃទៀតមានរយៈពេលបន្ថែម ៧ (ប្រាំពីរ) ថ្ងៃ ដើម្បីធ្វើបណ្តឹងឧទ្ធរណ៍ឧបប្បត្តិហេតុ ។ រយៈពេលបន្ថែមនេះផ្តើមគិតពីការផុតរយៈពេលធម្មតា ។

**មាត្រា ៣៨៤.–** រយៈពេលធ្វើបណ្តឹងឧទ្ធរណ៍ក្នុងករណីមានការឃុំខ្លួនរបស់ព្រះរាជអាជ្ញា និងពិរុទ្ធជន

ក្នុងរឿងឃុំខ្លួន ការប្តឹងឧទ្ធរណ៍ត្រូវតែធ្វើដោយព្រះរាជអាជ្ញានៅក្នុងរយៈពេល ៤៨ (សែសិបប្រាំបី) ម៉ោង និងដោយពិរុទ្ធជនក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ។ រយៈពេលនេះផ្តើមគិតពីថ្ងៃដែលតុលាការសម្រេចពីការឃុំខ្លួន ។

**មាត្រា ៣៨៥.–** បណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមចាត់របៀប

កាលណាតុលាការចេញសាលក្រមចាត់របៀប បណ្តឹងឧទ្ធរណ៍អាចត្រូវទទួលបានភ្លាមប្រសិនបើសាលក្រមនេះបញ្ចប់នីតិវិធី ។ ក្នុងករណីផ្ទុយពីនេះ សាលក្រមចាត់របៀបនឹងអាចត្រូវដាក់ជូនសាលាឧទ្ធរណ៍ពិនិត្យបានលុះត្រាតែធ្វើព្រមគ្នាជាមួយសាលក្រមលើអង្គសេចក្តី ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

169/246

## ជំពូកទី ៣
## នីតិវិធីនៅចំពោះមុខសាលាឧទ្ធរណ៍

**មាត្រា ៣៨៦.–** ការបញ្ជូនសំណុំរឿងទៅសាលាឧទ្ធរណ៍

ក្នុងករណីមានបណ្តឹងឧទ្ធរណ៍ ក្រឡាបញ្ជីនៃតុលាការជាន់ដំបូងរៀបចំសំណុំរឿងដើម្បីបញ្ជូនទៅសាលាឧទ្ធរណ៍ ។

ក្រឡាបញ្ជីត្រូវផ្ញើនៅក្នុងរយៈពេលដ៏ខ្លីបំផុតជូនទៅដល់ការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍នូវ:

-សំណុំរឿងនៃនីតិវិធី

-សេចក្តីចម្លងនៃលិខិតប្តឹងឧទ្ធរណ៍នីមួយៗដោយមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម

-សេចក្តីចម្លងនៃសាលក្រមដោយមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម ។

ក្នុងករណីមានបណ្តឹងឧទ្ធរណ៍អំពីសេចក្តីសម្រេចរបស់តុលាការស្តីអំពីការឃុំខ្លួនជនជាប់ចោទ សំណុំរឿងត្រូវបញ្ជូនក្នុងរយៈពេល ១០ (ដប់) ថ្ងៃ យ៉ាងយូរគិតពីថ្ងៃប្តឹងឧទ្ធរណ៍ លើកលែងតែមានកាលៈទេសៈមិនអាចជំនះបានដែលត្រូវតែមានបញ្ជាក់នៅក្នុងលិខិតបញ្ជូន ។

**មាត្រា ៣៨៧.–** ការកំណត់កាលបរិច្ឆេទនៃសវនាការ និងរយៈពេលជំនុំជម្រះ

នៅពេលសំណុំរឿងទៅដល់សាលាឧទ្ធរណ៍ ប្រធានសភាព្រហ្មទណ្ឌពិនិត្យផ្ទៀងផ្ទាត់មើលថា តើទម្រង់បែបបទនៃបណ្តឹងឧទ្ធរណ៍បានត្រឹមត្រូវឬទេ និងកំណត់កាលបរិច្ឆេទនៃសវនាការ ។

សាលាឧទ្ធរណ៍ត្រូវសម្រេចនៅក្នុងរយៈពេលសមស្រប ។ ក្នុងករណីប្តឹងឧទ្ធរណ៍អំពីសេចក្តីសម្រេចរបស់តុលាការជាន់ដំបូងស្តីពីការឃុំខ្លួនជនជាប់ចោទ សាលាឧទ្ធរណ៍ត្រូវសម្រេចក្នុងរយៈពេលដ៏ខ្លីបំផុត និងយ៉ាងយូរបំផុតក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ គិតពីថ្ងៃទទួលសំណុំរឿង ។

**មាត្រា ៣៨៨.–** ការជូនដំណឹង និងដីកាកោះហៅឱ្យចូលមកក្នុងសវនាការ

ប្រធានសភាព្រហ្មទណ្ឌជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការ ដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

អគ្គព្រះរាជអាជ្ញាកោះហៅជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ដូចដែលមានចែងនៅក្នុងមាតិកាទី ២ ស្តីពីដីកាកោះហៅជនជាប់ចោទឱ្យចូលសវនា-

ROYAUME DU CAMBODGE
ក្រសួងព្រះបរមរាជវាំង
MINISTERE DU PALAIS ROYAL

174/240

ការ និងមាតិកាទី ៣ ស្ដីពីដីកាកោះហៅជនក្រៅពីជនជាប់ចោទឱ្យចូលសវនាការនៃគន្ថីទី ៧ ស្ដីពីដីកាកោះហៅ បញ្ជូនទៅជំនុំជម្រះផ្ទាល់ ដីកាកោះហៅ និងដីកាជូនដំណឹងនៃក្រមនេះ ។

**មាត្រា ៣៨៩.–** ការផ្ទេរជនជាប់ចោទដែលជាប់ឃុំ

ជនជាប់ចោទដែលជាប់ឃុំត្រូវតែផ្ទេរនៅក្នុងរយៈពេលយ៉ាងខ្លីបំផុត តាមបញ្ជារបស់អគ្គ-ព្រះរាជអាជ្ញាឱ្យទៅនៅក្នុងពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនដែលនៅជិតជាងគេបំផុតនៃទីស្នាក់ការរបស់សាលាឧទ្ធរណ៍ ។

**មាត្រា ៣៩០.–** របាយការណ៍ឧទ្ធរណ៍

ប្រធានសភាព្រហ្មទណ្ឌចាត់តាំងចៅក្រមធ្វើរបាយការណ៍ម្នាក់ ។ ចៅក្រមធ្វើរបាយការណ៍នេះ អាចជាប្រធាន ឬ ជាចៅក្រមអម ។

របាយការណ៍មានកម្មវត្ថុរៀបរាប់អំពីដំណើររឿង ហើយនិងធ្វើឱ្យដឹងអំពីសាលក្រមដែលជូនមកសាលាឧទ្ធរណ៍នេះ ។ របាយការណ៍ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវដាក់ក្នុងសំណុំរឿង ។ របាយការណ៍ត្រូវតែស្មោះស្ម័គ្រ ដើម្បីឱ្យតុលាការបានទទួលព័ត៌មានយ៉ាងពេញលេញ ។

**មាត្រា ៣៩១.–** ការបើកពិនិត្យមើលសំណុំរឿង និងការប្រគល់សារណា

អគ្គព្រះរាជអាជ្ញា និងមេធាវីអាចពិនិត្យមើលសំណុំរឿងបានរហូតដល់ពេលសវនាការ ។

ភាគី និងមេធាវីអាចប្រគល់សារណាដល់ក្រឡាបញ្ជី ។ សារណាត្រូវចុះទិដ្ឋាការដោយក្រឡាបញ្ជី ដោយមានកាលបរិច្ឆេទផង និងត្រូវដាក់បញ្ចូលក្នុងសំណុំរឿងភ្លាម ។

**មាត្រា ៣៩២.–** សាធារណភាពនៃកិច្ចពិភាក្សាដេញដោល និងភាពជាសម្ងាត់នៃការពិភាក្សាដេញដោល

ការពិភាក្សាដេញដោលប្រព្រឹត្តទៅនៅពេលសវនាការជាសាធារណៈ ។

ប៉ុន្តែ ប្រសិនបើតុលាការយល់ឃើញថា ភាពជាសាធារណៈនាំឱ្យមានគ្រោះថ្នាក់ដល់សណ្ដាប់ធ្នាប់សាធារណៈ ឬ ដល់ទំនៀមទម្លាប់ តុលាការអាចបង្គាប់ឱ្យធ្វើការពិភាក្សាដេញដោលជាសម្ងាត់ទាំងស្រុង ឬ មួយផ្នែកបាន តាមសេចក្ដីសម្រេចដោយមានសំអាងហេតុ ។ តុលាការសម្រេចតាមសាលដីកាមួយដាច់ដោយឡែកពីសាលដីកាលើអង្គសេចក្ដី ឬ តាមសេចក្ដីសម្រេចពិសេសនៃសាលដីកាលើអង្គសេចក្ដី ។



171/240

សេចក្ដីសម្រេចរបស់តុលាការដែលបង្គាប់ឱ្យធ្វើការពិភាក្សាដេញដោលជាសម្ងាត់ មិនអាចតវ៉ាបានឡើយ ។

**មាត្រា ៣៩៣.–** ការសួរចម្លើយជនជាប់ចោទ

ក្រោយពីអានរបាយការណ៍រួច ប្រធានសួរចម្លើយជនជាប់ចោទ ។

អគ្គព្រះរាជអាជ្ញា មេធាវី និងភាគីទាំងឡាយ អាចអនុញ្ញាតឱ្យលើកជាសំណួរចោទសួរជនជាប់ចោទ ។ គ្រប់ការលើកសំណួរទាំងអស់ត្រូវតែបានការអនុញ្ញាតពីប្រធានសវនាការ ។ ក្រៅពីសំណួររបស់តំណាងអយ្យការ និងមេធាវី សំណួរផ្សេងៗទៀតត្រូវសួរតាមរយៈប្រធានសវនាការ ។ ក្នុងករណីមានការជំទាស់ ប្រធានសម្រេចដោយឥស្សរចិត្តថាតើសំណួរនោះត្រូវសួរឬយ៉ាងណា ។

**មាត្រា ៣៩៤.–** ការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី អ្នកជំនាញសាក្សី

ក្រោយពេលសួរចម្លើយជនជាប់ចោទរួច ប្រធានស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីនិងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី តាមលំដាប់លំដោយដែលខ្លួនយល់ឃើញថាមានប្រយោជន៍ ។

សាក្សី និងអ្នកជំនាញនឹងត្រូវបានគេស្ដាប់ចម្លើយលុះត្រាតែតុលាការបង្គាប់ឱ្យស្ដាប់ចម្លើយជនទាំងនេះ ។

**មាត្រា ៣៩៥.–** លំដាប់លំដោយនៃការនិយាយ

អគ្គព្រះរាជអាជ្ញា និងមេធាវី ឡើងនិយាយតាមលំដាប់លំដោយនៃការហៅឈ្មោះ ។

នៅក្នុងគ្រប់ករណីទាំងអស់ ជនជាប់ចោទនិយាយក្រោយគេបំផុត ។ មេធាវីរបស់ជនជាប់ចោទត្រូវបានអនុញ្ញាតឱ្យធ្វើការកត់សំគាល់ជាបន្ថែមដោយសង្ខេប ។

**មាត្រា ៣៩៦.–** ការពន្យាតដល់សាលាឧទ្ធរណ៍នូវវិធានដែលអនុវត្តចំពោះសាលាដំបូង

លើសពីនេះវិធានដែលអនុវត្តចំពោះតុលាការជាន់ដំបូង ត្រូវយកមកអនុវត្តចំពោះសាលាឧទ្ធរណ៍ ។

ROYAUME DU CAMBODGE • LE MINISTERE DU PALAIS ROYAL • ព្រះបរមរាជវាំង



172/240

# ជំពូកទី ៤
# អានុភាពនៃបណ្តឹងឧទ្ធរណ៍

**មាត្រា ៣៩៧.-** អានុភាពផ្ទេរនៃបណ្តឹងឧទ្ធរណ៍

សំណុំរឿងត្រូវបានផ្ទេរជូនសាលាឧទ្ធរណ៍នៅក្នុងព្រំដែនដែលកំណត់ដោយលិខិតប្តឹងឧទ្ធរណ៍ និងតាមឋានៈរបស់អ្នកប្តឹងឧទ្ធរណ៍ ។

**មាត្រា ៣៩៨.-** អានុភាពនៃបណ្តឹងឧទ្ធរណ៍លើការអនុវត្តសាលក្រម

នៅក្នុងរយៈពេលប្តឹងឧទ្ធរណ៍ ការអនុវត្តសាលក្រមត្រូវបង្អង់សិន ។

ប៉ុន្តែ ជនជាប់ចោទដែលជាប់ឃុំដែលបានចូលបង្ហាញខ្លួន នៅមុខតុលាការជាន់ដំបូងត្រូវនៅក្នុងពន្ធនាគារនៅក្នុងរយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា និងក្នុងករណីមានបណ្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចខាងបទព្រហ្មទណ្ឌ នោះជនជាប់ចោទត្រូវនៅក្នុងពន្ធនាគាររហូតដល់សាលាឧទ្ធរណ៍សម្រេច ។ ក្នុងករណីដែលតុលាការជាន់ដំបូងបានសម្រេចឱ្យរួចខ្លួន ឬបានផ្តន្ទាទោសដាក់ពន្ធនាគារ រយៈពេលតិចជាងឬស្មើនឹងរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ព្រះរាជអាជ្ញាអាចយល់ព្រមដោះលែងជនជាប់ចោទឱ្យមានសេរីភាព មុនពេលផុតកំណត់នៃរយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍ ។

រយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញាមិនមែនជាឧបសគ្គដល់ការអនុវត្តទោសទេ ។

**មាត្រា ៣៩៩.-** អានុភាពនៃបណ្តឹងឧទ្ធរណ៍តែពីជនជាប់ចោទប៉ុណ្ណោះ

សាលាឧទ្ធរណ៍កាលណាបានទទួលបណ្តឹងឧទ្ធរណ៍តែពីជនជាប់ចោទប៉ុណ្ណោះ មិនអាចដាក់ទម្ងន់ទោសជននោះទេ ។ តុលាការអាចកែប្រែសាលក្រមបាននៅក្នុងន័យដែលអនុគ្រោះដល់ជននេះតែប៉ុណ្ណោះ ។ សាលាឧទ្ធរណ៍មិនអាចបន្ថែមទោសបន្ថែមពីលើមូលទោសបានទេ ។

សាលាឧទ្ធរណ៍អាចជំនួសឈ្មោះបទល្មើសដែលកំណត់ដោយតុលាការជាន់ដំបូង ដោយឈ្មោះបទល្មើសមួយទៀតបាន ប៉ុន្តែ មិនអាចដាក់ទម្ងន់ទោសលើជនជាប់ចោទនេះទេ ។

ប្រសិនបើតុលាការជាន់ដំបូងភ្លេចប្រកាសទោសបន្ថែមណាមួយដែលដាច់ខាតត្រូវតែប្រកាសនោះ សាលាឧទ្ធរណ៍បដិសេធសាលក្រមហើយសម្រេចអំពីទោសជាថ្មីម្តងទៀត ។

កាលណាបានទទួលបណ្តឹងតែពីជនជាប់ចោទប៉ុណ្ណោះ សាលាឧទ្ធរណ៍មិនអាចបន្ថែមចំនួនទឹកប្រាក់ សម្រាប់ជួសជុលការខូចខាតឱ្យដល់ដើមបណ្តឹងរដ្ឋប្បវេណីទេ ។



173/240

**មាត្រា ៤០០.-** អានុភាពនៃបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញា

បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា និងរបស់អគ្គព្រះរាជអាជ្ញា នាំឱ្យសើរើឡើងវិញនូវសេចក្តីសម្រេចខាងព្រហ្មទណ្ឌនៃតុលាការជាន់ដំបូង ។

សាលាឧទ្ធរណ៍ ជាយថាហេតុ អាចបដិសេធសាលក្រមដែលសម្រេចឱ្យរួចខ្លួន ឬ អាចសម្រេចដាក់ទម្ងន់ទោសដែលបានប្រកាសឡើងដោយតុលាការជាន់ដំបូង ។ សាលាឧទ្ធរណ៍អាចសម្រេចឱ្យជនជាប់ចោទរួចខ្លួនជានិច្ច ប្រសិនបើយល់ឃើញថាពិរុទ្ធភាពលើជននេះមិនអាចបង្ហាញឱ្យឃើញទេ ។

សាលាឧទ្ធរណ៍អាចប្រកាសទោសបន្ថែម ដែលដាច់ខាតត្រូវតែប្រកាសដោយខានមិនបានដែលតុលាការជាន់ដំបូងភ្លេចមិនបានប្រកាស ។

**មាត្រា ៤០១.-** ការកំណត់ប្រភេទគតិយុត្តនៃអង្គហេតុជាថ្មីដោយសាលាឧទ្ធរណ៍

សាលាឧទ្ធរណ៍អាចកែប្រែប្រភេទគតិយុត្តនៃអង្គហេតុដែលសាលាដំបូងបានកំណត់ តែមិនត្រូវបន្ថែមធាតុថ្មីណាមួយដែលមិនបានដាក់ជូនតុលាការជាន់ដំបូងសម្រេចនោះទេ ។

**មាត្រា ៤០២.-** អានុភាពនៃបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ឬ របស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី

បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីអាចធ្វើបានតែលើផលប្រយោជន៍ផ្នែករដ្ឋប្បវេណីប៉ុណ្ណោះ ។

នៅមុខសាលាឧទ្ធរណ៍ ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចធ្វើពាក្យប្តឹងសុំថ្មីដែលមិនបានដាក់ជូនតុលាការពិនិត្យនោះទេ ។

**មាត្រា ៤០៣.-** ទម្រង់ និងហត្ថលេខាលើសាលដីកា

វិធានស្តីពីទម្រង់ និងហត្ថលេខាលើសាលក្រមរបស់តុលាការជាន់ដំបូងត្រូវយកមកអនុវត្តលើសាលដីការបស់សាលាឧទ្ធរណ៍ ។

**មាត្រា ៤០៤.-** បណ្តឹងឧទ្ធរណ៍ដែលមិនអាចទទួលយកបាន

កាលណាសាលាឧទ្ធរណ៍យល់ឃើញថាបណ្តឹងឧទ្ធរណ៍ធ្វើហួសពេលកំណត់ ឬ ធ្វើនៅក្នុងលក្ខខណ្ឌមិនត្រឹមត្រូវនោះ សាលាឧទ្ធរណ៍ប្រកាសថា បណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបាន ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ព្រះបរមរាជវាំង



174/240

**មាត្រា ៤០៥.-** ការបដិសេធសាលក្រម

កាលណាសាលាឧទ្ធរណ៍យល់ឃើញថាគ្មានពិរុទ្ធភាពលើជនជាប់ចោទទេ ឬ ក៏អំពើនោះមិនមែនជាបទល្មើសទេ សាលាឧទ្ធរណ៍បដិសេធសាលក្រម ហើយឱ្យជនជាប់ចោទរួចខ្លួន ។

**មាត្រា ៤០៦.-** សិទ្ធិលើកមកជាសំអាងរបស់សាលាឧទ្ធរណ៍

កាលណាសាលាឧទ្ធរណ៍ពិនិត្យមើលឃើញថាសាលក្រមរបស់តុលាការជាន់ដំបូងមានជាប់មោឃភាព សាលាឧទ្ធរណ៍អាចសម្រេចលើអង្គសេចក្ដីឡើញវិញដូចតុលាការជាន់ដំបូង ។

**មាត្រា ៤០៧.-** ដីកាបង្គាប់ឱ្យឃុំខ្លួន ឬ ដីកាបង្គាប់ឱ្យចាប់ខ្លួនចេញដោយសាលាឧទ្ធរណ៍

ប្រសិនបើសាលាឧទ្ធរណ៍សម្រេចទោសដាក់ពន្ធនាគារយ៉ាងតិច ១ (មួយ) ឆ្នាំ ដោយគ្មានល្បូរទេ ហើយប្រសិនបើវិធានការសន្តិសុខតម្រូវនោះ សាលាឧទ្ធរណ៍តាមរយៈសេចក្ដីសម្រេចមានលក្ខណៈពិសេស និងមានសំអាងហេតុ អាចចេញនៅពេលសវនាការនូវ :

-ដីកាបង្គាប់ឱ្យឃុំខ្លួនជនជាប់ចោទដែលមានវត្តមាន

-ដីកាបង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទដែលអវត្តមាន ។

ដីកាបង្គាប់ឱ្យឃុំ និងដីកាបង្គាប់ឱ្យចាប់ខ្លួនមានអានុភាពអនុវត្តភ្លាម ។

ដីកាទាំងនេះមានចុះនិទ្ទេសដូចតទៅ :

-អត្តសញ្ញាណនៃពិរុទ្ធជន

-ប្រភេទនៃទណ្ឌកម្ម និងអត្ថបទច្បាប់ដែលជាមូលដ្ឋាននៃទណ្ឌកម្មនេះ

-ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា ។

ដីកាទាំងនេះត្រូវតែមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមនេះ និងមានបោះត្រាផង ។

ពិរុទ្ធជនដែលត្រូវចាប់ខ្លួនដោយអនុវត្តតាមដីកាបង្គាប់ឱ្យចាប់ខ្លួន ត្រូវនាំខ្លួនក្នុងរយៈពេលដ៏ខ្លីបំផុតទៅបង្ហាញជូនអគ្គព្រះរាជអាជ្ញានាទីកន្លែងចាប់ខ្លួន ដែលត្រូវឱ្យដំណឹងពីដីកានេះដល់សាមីខ្លួន និងធ្វើការឃុំខ្លួនជននេះ ។

កាលណាសាលដីកាបានប្រកាសដោយកំបាំងមុខ ពិរុទ្ធជនដែលសម្រេចចិត្តថាប្ដឹងទាស់ត្រូវតែចូលបង្ហាញខ្លួនក្នុងរយៈពេលដ៏ខ្លីបំផុតទៅសាលាឧទ្ធរណ៍ដែលបានប្រកាសសាលដីកានេះ ។ ពិរុទ្ធជនអាចដាក់ពាក្យប្ដឹងសុំឱ្យនៅក្រៅឃុំ ។ ក្នុងករណីនេះ សាលាឧទ្ធរណ៍សម្រេចទៅ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង



175/240

តាមមាត្រា ៣០៧ (បណ្តឹងសុំដោះលែងឱ្យមានសេរីភាពរបស់ជនជាប់ចោទដែលជាប់ឃុំ) នៃក្រមនេះ ។

**មាត្រា ៤០៨.–** ប្រភេទនៃសាលដីកា

សាលដីកាប្រកាសដោយសាលាឧទ្ធរណ៍ជាសាលដីកាចំពោះមុខ ជាសាលដីកាដែលចាត់ទុកថាចំពោះមុខ ឬ ជាសាលដីកាកំបាំងមុខ តាមការវែកញែកដែលអនុវត្តចំពោះសាលក្រមដែលប្រកាសដោយតុលាការជាន់ដំបូង ។

## ជំពូកទី ៥

## បណ្តឹងទាស់ចំពោះសាលដីកាចេញដោយកំបាំងមុខ

**មាត្រា ៤០៩.–** បណ្តឹងទាស់ចំពោះសាលដីកាកំបាំងមុខ

ពិរុទ្ធជនអាចប្តឹងទាស់នឹងសាលដីកាដែលសម្រេចដោយកំបាំងមុខខ្លួន ។

**មាត្រា ៤១០.–** ទម្រង់នៃបណ្តឹងទាស់

បណ្តឹងទាស់អាចធ្វើ :

-តាមពាក្យប្តឹងលាយលក្ខណ៍អក្សរនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ដែលបានសម្រេចចេញសាលដីកា ឬ

-តាមពាក្យប្តឹងជាលាយលក្ខណ៍អក្សរនៅចំពោះមុខអគ្គព្រះរាជអាជ្ញា អង្គភាពនគរ-បាល ឬ កងរាជអាវុធហត្ថ ឬ ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ។

ពិរុទ្ធជនអាចត្រូវតំណាងដោយមេធាវី ។ មេធាវីត្រូវតែមានលិខិតអនុញ្ញាតឱ្យធ្វើបណ្តឹងទាស់ ។ ប៉ុន្តែ ពិរុទ្ធជនជាអនីតិជនអាចត្រូវតំណាងដោយឪពុក ម្តាយ ឬ អ្នកអាណាព្យាបាល ។ ក្នុងករណីនេះ អ្នកតំណាងមិនចាំបាច់មានលិខិតប្រគល់សិទ្ធិទេ ។

កាលណាបានទទួលពាក្យប្តឹងទាស់ អគ្គព្រះរាជអាជ្ញា អង្គភាពនគរបាល និងកងរាជអាវុធ-ហត្ថ ព្រមទាំងប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន បញ្ជូនសំណុំរឿងនោះភ្លាមទៅសាលាឧទ្ធរណ៍ដែលបានប្រកាសចេញសាលដីកា ។

កាលណាអ្នកប្តឹងទាស់មិនចេះចុះហត្ថលេខាទេ សាមីខ្លួនត្រូវផ្តិតម្រាមដៃ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង



146/249

**មាត្រា ៤១១.-** បញ្ជីនៃបណ្ដឹងទាស់

ក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍កាន់បញ្ជីបណ្ដឹងទាស់ ។ គូភាគី និងមេធាវីអាចបើកពិនិត្យមើលបានដោយសេរី ។

**មាត្រា ៤១២.-** រយៈពេលនៃបណ្ដឹងទាស់

បណ្ដឹងទាស់ត្រូវធ្វើក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ គិតពី :

-ថ្ងៃឱ្យដំណឹងអំពីសាលដីកាកំបាំងមុខ កាលណាសាលដីកានេះ ត្រូវបានប្រគល់ឱ្យដល់ពិរុទ្ធជនដោយផ្ទាល់ដៃ ។

-ថ្ងៃដែលពិរុទ្ធជនបានដឹងយ៉ាងពិតប្រាកដអំពីសាលដីកា កាលណាសាលដីកានេះមិនបានប្រគល់ឱ្យពិរុទ្ធជនដោយផ្ទាល់ដៃទេ ។

**មាត្រា ៤១៣.-** បណ្ដឹងទាស់ដែលកម្រិតចំពោះសេចក្ដីសម្រេចផ្នែករដ្ឋប្បវេណី

បណ្ដឹងទាស់អាចកំណត់ទៅលើតែសេចក្ដីសម្រេចផ្នែករដ្ឋប្បវេណីនៃសាលដីកាបាន ។

**មាត្រា ៤១៤.-** បណ្ដឹងទាស់ចំពោះសេចក្ដីសម្រេចផ្នែកព្រហ្មទណ្ឌ ឬ រដ្ឋប្បវេណីនៃសាលដីកា

កាលណាបណ្ដឹងទាស់ធ្វើប្រឆាំងនឹងសាលដីកាទាំងមូល សាលដីកានេះ ត្រូវទុកជាអសារបង់ ។ ការអនុវត្តនៃសាលដីកាត្រូវល្បុរ ។ ប៉ុន្តែ ដីកាបង្គាប់ឱ្យចាប់ខ្លួននៅតែមានអានុភាព ។ សាលាឧទ្ធរណ៍មានសមត្ថកិច្ចដើម្បីសម្រេចពីការដោះលែងឱ្យមានសេរីភាពវិញ ។

កាលណាបណ្ដឹងទាស់ធ្វើប្រឆាំងនឹងសេចក្ដីសម្រេចផ្នែករដ្ឋប្បវេណី នោះសេចក្ដីសម្រេចត្រង់ផ្នែកនេះត្រូវទុកជាអសារបង់ ហើយការអនុវត្តត្រូវល្បុរ ។

**មាត្រា ៤១៥.-** សាលដីកាចេញតាមបណ្ដឹងទាស់

រឿងត្រូវលើកមកជំនុំជម្រះនៅមុខសាលាឧទ្ធរណ៍ដដែល ។

គូភាគីត្រូវបានកោះហៅតាមគំនិតផ្ដើមរបស់អគ្គព្រះរាជអាជ្ញា ។

ក្រោយពីសម្រេចលើភាពដែលអាចទទួលបាននៃបណ្ដឹងទាស់ តុលាការសម្រេចជាថ្មីលើអង្គសេចក្ដី ។

ប្រសិនបើអ្នកប្តឹងទាស់ដែលបានកោះហៅយ៉ាងត្រឹមត្រូវហើយតែមិនចូលមកបង្ហាញខ្លួន នៅពេលសវនាការ តុលាការប្រកាសថាបណ្តឹងទាស់ត្រូវទុកជាអសារឥតការ ។ សាលដីកាដែលប្តឹងទាស់ មិនអាចត្រូវបានកែប្រែបានទេ ។ សាលដីកានេះមានអានុភាពទាំងស្រុងចំពោះគូភាគី ។ ប៉ុន្តែ ពិរុទ្ធជន អាចប្តឹងតវ៉ាទៅតុលាការកំពូលបាន ។

**មាត្រា ៤១៦.–** បណ្តឹងទាស់ធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី ឬ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី : រយៈពេល ទម្រង់ ការតំណាង

ដើមបណ្តឹងរដ្ឋប្បវេណីក៏អាចប្តឹងទាស់នឹងសាលដីកាកំបាំងមុខខ្លួនបានផងដែរ ។ បណ្តឹងទាស់នេះ កំណត់ទៅលើតែសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីនៃសាលដីកាប៉ុណ្ណោះ ។

បណ្តឹងទាស់ត្រូវធ្វើក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ គិតពី :

-ថ្ងៃឱ្យដំណឹងពីសាលដីកាកំបាំងមុខ កាលណាសាលដីកានេះត្រូវបានប្រគល់ឱ្យដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃ

-ថ្ងៃដែលដើមបណ្តឹងរដ្ឋប្បវេណីបានដឹងយ៉ាងពិតប្រាកដ អំពីសាលដីកា កាលណាសាលដីកានេះមិនបានប្រគល់ឱ្យដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃទេ ។

បណ្តឹងទាស់អាចធ្វើជាលាយលក្ខណ៍អក្សរនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ដែលបានប្រកាសសាលដីកា ។

ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវតំណាងដោយមេធាវី សហព័ទ្ធ ឬ ដោយញាតិលោហិតផ្ទាល់ ។ អ្នកតំណាងត្រូវតែមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរដែលអនុញ្ញាតឱ្យប្តឹងទាស់ ។

បទប្បញ្ញត្តិនៃមាត្រានេះត្រូវយកទៅអនុវត្តលើបុគ្គលដែលសាលាឧទ្ធរណ៍ប្រកាសឱ្យទទួលខុសត្រូវរដ្ឋប្បវេណី ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

178/240

# គន្ថីទី ៦

# តុលាការកំពូល

## មាតិកាទី ១

## បណ្តឹងសាទុក្ខ

## ជំពូកទោល

## បណ្តឹងសាទុក្ខ

**មាត្រា ៤១៧.–** សេចក្តីសម្រេចដែលអាចធ្វើបណ្តឹងសាទុក្ខ

សាលដីកានៃសភាស៊ើបសួរ ដោយគិតបញ្ចូលទាំងរឿងបស្សាប័ន ព្រមទាំងសាលដីកាដែលសម្រេចជាសមត្ថកិច្ចចុងក្រោយដោយសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ អាចត្រូវប្តឹងសាទុក្ខបាន ។

ប៉ុន្តែ វិធីតវ៉ានេះមិនអាចធ្វើបានទេចំពោះសាលដីកានៃសភាស៊ើបសួរ ដែលបង្គាប់ឱ្យបញ្ជូនជនជាប់ចោទទៅតុលាការជំនុំជម្រះនោះ ។

**មាត្រា ៤១៨.–** បុគ្គលដែលអាចធ្វើបណ្តឹងសាទុក្ខ

បណ្តឹងសាទុក្ខអាចត្រូវធ្វើដោយ :

-អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

-អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

-ជនជាប់ចោទ ឬ ពិរុទ្ធជន

-បុគ្គលដែលត្រូវគេទាមទារក្នុងករណីនៃនីតិវិធីបស្សាប័ន

-ដើមបណ្តឹងរដ្ឋប្បវេណី

-អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ។

បណ្តឹងសាទុក្ខ ត្រូវពិនិត្យដោយសភាព្រហ្មទណ្ឌនៃតុលាការកំពូល ។

**មាត្រា ៤១៩.–** មូលហេតុនៃបណ្តឹងសាទុក្ខ

តុលាការកំពូលអាចបដិសេធសេចក្តីសម្រេចក្នុងករណីដូចតទៅ :

-សមាសភាពមិនស្របច្បាប់នៃតុលាការ

-អសមត្ថកិច្ចនៃតុលាការ

-ការរំលោភអំណាច

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL



179/249

-ការបំពានច្បាប់ ឬ ការអនុវត្តខុសច្បាប់

-ការបំពាន ឬ ភ្លេចទម្រង់ការ ដែលច្បាប់បញ្ញត្តិថាត្រូវទុកជាមោឃៈ

-ការមិនបានសម្រេចលើពាក្យប្តឹងសុំរបស់អយ្យការ ឬ ភាគី កាលណាពាក្យប្តឹងសុំនេះ ធ្វើជាលាយលក្ខណ៍អក្សរនិងមានន័យយ៉ាងច្បាស់លាស់

-ការបំភ្លៃអង្គហេតុ

-គ្មានសំអាងហេតុ

-ការផ្ទុយគ្នារវាងសំអាងហេតុ និងសេចក្តីសម្រេច ។

**មាត្រា ៤២០.–** រយៈពេលដើម្បីធ្វើបណ្តឹងសាទុក្ខ

បណ្តឹងសាទុក្ខ ត្រូវធ្វើក្នុងរយៈពេលដូចតទៅ :

-១ (មួយ) ខែ ចំពោះសាលដីការបស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍

-១៥ (ដប់ប្រាំ) ថ្ងៃ ចំពោះសាលដីការបស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍

-៥ (ប្រាំ) ថ្ងៃ ចំពោះមតិរបស់សភាស៊ើបសួរដែលបញ្ចេញក្នុងរឿងបត្យាប័ន ។

កាលណាសាលដីកាដែលប្តឹងសាទុក្ខនេះ ជាសាលដីកាចំពោះមុខ រយៈពេលត្រូវផ្តើមគិតពីការប្រកាសសាលដីកា ។

កាលណាសាលដីកាដែលប្តឹងសាទុក្ខ ជាសាលដីកាដែលចាត់ទុកថាចំពោះមុខ រយៈពេលត្រូវផ្តើមពីការឱ្យដំណឹង ។

កាលណាសាលដីកាសម្រេចដោយកំបាំងមុខ រយៈពេលត្រូវផ្តើមគិតពីការផុតរយៈពេលប្តឹងទាស់ ។

**មាត្រា ៤២១.–** បណ្តឹងសាទុក្ខចំពោះសាលដីកាចាត់របៀប

កាលណាសាលាឧទ្ធរណ៍ចេញសាលដីកាចាត់របៀប បណ្តឹងសាទុក្ខ ត្រូវទទួលបានភ្លាម ប្រសិនបើសាលដីកានេះបញ្ចប់នីតិវិធី ។ ក្នុងករណីផ្ទុយពីនេះ សាលដីកាចាត់របៀបអាចដាក់ជូនតុលាការកំពូលពិនិត្យជាមួយគ្នានឹងសាលដីកាលើអង្គសេចក្តីតែប៉ុណ្ណោះ ។

**មាត្រា ៤២២.–** ទម្រង់នៃការប្រកាសបណ្តឹងសាទុក្ខ

បណ្តឹងសាទុក្ខត្រូវធ្វើតាមពាក្យប្តឹង នៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ដែលបានចេញសេចក្តីសម្រេច ។ ពាក្យប្តឹងនេះត្រូវចុះក្នុងបញ្ជីពិសេសដែលរក្សាទុកនៅការិយាល័យក្រឡាបញ្ជីនៃតុលាការនេះ ។

180/240

ជនជាប់ចោទ ពិរុទ្ធជន និងបុគ្គលដែលត្រូវគេទាមទារក្នុងក្របខ័ណ្ឌនីតិវិធីបព្ឈប់ននអាច តំណាងដោយមេធាវី ។ មេធាវីត្រូវមានលិខិតប្រគល់សិទ្ធិឱ្យប្តឹងសាទុក្ខ ។ ប៉ុន្តែជនជាប់ចោទ ឬ ពិរុទ្ធជនជាអនីតិជនអាចត្រូវតំណាងដោយឪពុក ម្តាយ ឬ អ្នកអាណាព្យាបាល ។ ក្នុងករណីនេះ អ្នកតំណាងមិនចាំបាច់មានលិខិតប្រគល់សិទ្ធិទេ ។

ដើមបណ្តឹងរដ្ឋប្បវេណីអាចតំណាងដោយមេធាវី សហព័ទ្ធ ឬ ដោយញាតិលោហិតផ្ទាល់ ។ អ្នកតំណាងត្រូវមានលិខិតប្រគល់សិទ្ធិឱ្យធ្វើបណ្តឹងសាទុក្ខ ។

អ្នកទទួលខុសត្រូវរដ្ឋប្បវេណីអាចតំណាងដោយមេធាវី សហព័ទ្ធ ឬ ដោយញាតិលោហិត ផ្ទាល់ ។ អ្នកតំណាងត្រូវមានលិខិតប្រគល់សិទ្ធិឱ្យធ្វើបណ្តឹងសាទុក្ខ ។

**មាត្រា ៤២៣.-** ការចុះហត្ថលេខាលើបណ្តឹងសាទុក្ខ

បណ្តឹងសាទុក្ខត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងអ្នកប្តឹង ឬ តំណាង ។ កាលណាអ្នក ប្តឹងមិនចេះចុះហត្ថលេខាទេ សាមីខ្លួន ឬ អ្នកតំណាងត្រូវផ្តិតម្រាមដៃ ។ លិខិតប្រគល់សិទ្ធិត្រូវតែ ភ្ជាប់ជាមួយនឹងពាក្យសុំប្តឹងសាទុក្ខ ។

ប្រសិនបើខ្វះហត្ថលេខារបស់ក្រឡាបញ្ជី ឬ ខ្វះកាលបរិច្ឆេទ ពាក្យប្តឹងសាទុក្ខអាចទទួល បាន ប្រសិនបើគ្មានឃើញការបន្លំអ្វីទេ ។ ក្រឡាបញ្ជីត្រូវរងទោសពិន័យ ៥.០០០ (ប្រាំពាន់) រៀល ។ ប្រាក់ពិន័យនេះត្រូវប្រកាសដោយតុលាការកំពូលនៅក្នុងសាលដីការបស់ខ្លួន ។

**មាត្រា ៤២៤.-** ការបញ្ជូនសំណុំរឿងទៅតុលាការកំពូល

នៅក្នុងរយៈពេលដ៏ខ្លីបំផុត ក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ រៀបចំសំណុំរឿង ហើយបញ្ជូន ទៅក្រឡាបញ្ជីតុលាការកំពូល ។

**មាត្រា ៤២៥.-** ការចុះបញ្ជីនៃសំណុំរឿងនៅតុលាការកំពូល

នៅពេលដែលសំណុំរឿងបានទៅដល់តុលាការកំពូល ក្រឡាបញ្ជីត្រូវចុះបញ្ជី ។

**មាត្រា ៤២៦.-** ការតាំងមេធាវី

ភាគីអាចតាំងមេធាវីបានចាប់តាំងពីពេលចុះបញ្ជីសំណុំរឿង ហើយយ៉ាងយូរបំផុតរហូត ដល់មុនថ្ងៃបើកសវនាការ ១ (មួយ) ថ្ងៃ ។ ភាគីត្រូវបញ្ជូនឈ្មោះមេធាវីរបស់ខ្លួនជាលាយលក្ខណ៍ អក្សរឱ្យដល់ក្រឡាបញ្ជីតុលាការកំពូល ។

ROYAUME DU CAMBODGE
SECRETARIAT
LE MINISTRE DU PALAIS ROYAL



181/240

**មាត្រា ៤២៧.-** រយៈពេលសម្រាប់សរសេរសារណា

ក្រឡាបញ្ជីតុលាការកំពូលឱ្យដំណឹងដល់គូភាគីអំពីការចុះបញ្ជីនៃសំណុំរឿង ។

ក្នុងរយៈពេល ១០ (ដប់) ថ្ងៃ ក្រោយការឱ្យដំណឹងនេះ ក្រឡាបញ្ជីឱ្យដំណឹងដល់អ្នកប្ដឹងសាទុក្ខថាខ្លួនមានថិរវេលា ២០ (ម្ភៃ) ថ្ងៃ ដើម្បីផ្ញើជូនសភាព្រហ្មទណ្ឌតុលាការកំពូលនូវសារណាមួយដែលខ្លួនត្រូវរៀបរាប់អំពីមធ្យោបាយខាងច្បាប់ ។ ប្រសិនបើអ្នកប្ដឹងសាទុក្ខបានតាំងមេធាវី និងបានបញ្ជូនឈ្មោះមេធាវីនេះទៅក្រឡាបញ្ជី ការជូនដំណឹងនេះក៏ត្រូវផ្ញើទៅមេធាវីផងដែរ ។

ប្រសិនបើអ្នកប្ដឹងសាទុក្ខបានជូនសារណា ក្រឡាបញ្ជីឱ្យដំណឹងដល់ភាគីដទៃទៀត និងជាយថាហេតុដល់មេធាវីដែលមានថិរវេលា ២០ (ម្ភៃ) ថ្ងៃ ដែរ ដើម្បីឆ្លើយតបទៅនឹងសារណារបស់អ្នកប្ដឹងសាទុក្ខ ។

**មាត្រា ៤២៨.-** ការដាក់សំណុំរឿងជូនពិនិត្យ

សំណុំរឿងត្រូវដាក់ជូនមេធាវីពិនិត្យមើលតាមត្រូវការ និងធ្វើការចម្លង ដោយសាមីខ្លួនជាអ្នកចេញសោហ៊ុយ ។

**មាត្រា ៤២៩.-** ការពន្យាររយៈពេលនៃការសរសេរសារណា

កាលណារយៈពេល ២០ (ម្ភៃ) ថ្ងៃនេះមិនគ្រប់គ្រាន់ទេ ភាគីអាចសុំទៅដល់ប្រធានសភាព្រហ្មទណ្ឌឱ្យពន្យារពេល ។ ការពន្យារពេលនេះមិនអាចលើសពី ១០ (ដប់) ថ្ងៃទេ ។

**មាត្រា ៤៣០.-** ការចាត់តាំងចៅក្រមរបាយការណ៍

លុះដល់ផុតរយៈពេលកំណត់ដើម្បីជូនសារណា ប្រធានចាត់តាំងចៅក្រមរបាយការណ៍ម្នាក់ និងបញ្ជូនសំណុំរឿងទៅចៅក្រមនេះ ដោយមានភ្ជាប់សារណាទៅជាមួយផង ។

**មាត្រា ៤៣១.-** ការសរសេររបាយការណ៍

របាយការណ៍ជាលាយលក្ខណ៍អក្សរត្រូវមានរៀបរាប់អំពី :

- នីតិវិធី និងរឿងហេតុ
- ចំណុចច្បាប់ដែលភាគីបានលើក
- ដំណោះស្រាយដែលចៅក្រមរបាយការណ៍ស្នើសុំ ។

របាយការណ៍ត្រូវបញ្ចូលទៅក្នុងសំណុំរឿង ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

182/240

**មាត្រា ៤៣២.-** ការបញ្ជូនសំណុំរឿងទៅអគ្គព្រះរាជអាជ្ញា និងសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ

សំណុំរឿងដោយមានសារណា និងរបាយការណ៍ភ្ជាប់ជាមួយផង ត្រូវបញ្ជូនទៅអគ្គព្រះ-រាជអាជ្ញាអមតុលាការកំពូល ។

អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល រៀបចំសេចក្ដីសន្និដ្ឋានសុំជាលាយលក្ខណ៍អក្សរដែលត្រូវបញ្ចូលទៅក្នុងសំណុំរឿង ។

សំណុំរឿងត្រូវបញ្ជូនត្រឡប់ទៅប្រធានសភាព្រហ្មទណ្ឌវិញ ។

**មាត្រា ៤៣៣.-** ការជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការចំពោះភាគី

ប្រធានសភាព្រហ្មទណ្ឌកំណត់កាលបរិច្ឆេទនៃសវនាការ និងជូនដំណឹងដោយផ្ទាល់មាត់ដល់អគ្គព្រះរាជអាជ្ញាអំពីកាលបរិច្ឆេទនៃសវនាការនេះ ។ អគ្គព្រះរាជអាជ្ញាឱ្យដំណឹងអំពីកាលបរិច្ឆេទនេះដល់ភាគី និងមេធាវី ។

ការឱ្យដំណឹងដល់ជនជាប់ចោទដែលជាប់ឃុំ ដល់ពិរុទ្ធជនដែលឃុំខ្លួន ឬ ដល់បុគ្គលដែលគេទាមទារនៅក្នុងរឿងបត្យាប័ន ត្រូវធ្វើឡើងតាមរបៀបដូចតទៅ :

-ដោយផ្ទាល់មាត់ ឬ

-តាមរយៈប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ។

ការឱ្យដំណឹងដល់ពិរុទ្ធជន ឬ ជនជាប់ចោទនៅក្រៅឃុំ ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី និងដល់មេធាវី ត្រូវធ្វើដូចតទៅ :

-ដោយផ្ទាល់មាត់

-តាមផ្លូវរដ្ឋបាល ឬ

-តាមរយៈអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ ។

កាលណាការឱ្យដំណឹងត្រូវធ្វើដោយផ្ទាល់មាត់ ក្រឡាបញ្ជីចុះនិទ្ទេសអំពីកាលបរិច្ឆេទនៃការឱ្យដំណឹងទៅលើសំណុំរឿង ។ ពិរុទ្ធជន ជនជាប់ចោទ ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ឬ មេធាវី ចុះហត្ថលេខារបស់ខ្លួន ។

នៅក្នុងករណីដទៃទៀត ការឱ្យដំណឹងត្រូវធ្វើដោយមានបង្កាន់ដៃបញ្ជាក់ថាបានទទួលសម្រាប់ទុកជាសម្គាល់ ។

ROYAUME du CAMBODGE MINISTÈRE du PALAIS ROYAL



183/240

**មាត្រា ៤៣៤.-** សាធារណភាពនៃកិច្ចពិភាក្សាដេញដោល

ការពិភាក្សាដេញដោលត្រូវប្រព្រឹត្តនៅពេលសវនាការជាសាធារណៈ ។

ភាគីមិនត្រូវបានសភាព្រហ្មទណ្ឌនៃតុលាការកំពូលស្ដាប់ចម្លើយទេ លើកលែងតែក្នុងករណីដែលប្រធានបង្គាប់ឱ្យចូលមកបង្ហាញខ្លួន ។

ចៅក្រមរបាយការណ៍ធ្វើសេចក្ដីរាយការណ៍ ។ អគ្គព្រះរាជអាជ្ញាធ្វើសេចក្ដីសន្និដ្ឋានសុំ ។ មេធាវីធ្វើសេចក្ដីសន្និដ្ឋានការពារ ។

ក្រោយពេលពិភាក្សាដេញដោល សភាព្រហ្មទណ្ឌថយខ្លួនទៅពិភាក្សាសម្រេច និងតែងសាលដីការបស់ខ្លួន ។ សាលដីកាអាចត្រូវប្រកាសក្នុងថ្ងៃជាមួយនោះតែម្ដង ឬ ក៏នៅពេលសវនាការលើកក្រោយដែលត្រូវកំណត់ដោយតុលាការ ។

នៅក្នុងគ្រប់ករណី តុលាការកំពូលមិនអាចពិភាក្សាសម្រេចលើរឿងណាមួយដោយគ្មានធ្វើការពិភាក្សាដេញដោលនៅពេលសវនាការ ។

គ្រប់ភាគីទាំងអស់អាចដាក់ជូនសារណា ឬ សារណាថ្មីទៀត រហូតដល់បិទការពិភាក្សាដេញដោល ។

**មាត្រា ៤៣៥.-** អានុភាពបង្អង់នៃបណ្ដឹងសាទុក្ខ

នៅក្នុងរយៈពេលសម្រាប់ធ្វើបណ្ដឹងសាទុក្ខនោះ ការអនុវត្តសាលដីការបស់សាលាឧទ្ធរណ៍ត្រូវបង្អង់សិន ។

បណ្ដឹងសាទុក្ខមានអានុភាពព្យួរ ។ ការអនុវត្តសេចក្ដីសម្រេចដែលត្រូវតវ៉ានេះ ត្រូវតែបង្អង់ក្នុងខណៈដែលតុលាការកំពូលមិនទាន់បានសម្រេច ។

ប៉ុន្តែ ការអនុវត្តដាក់ពន្ធនាគារមិនត្រូវបង្អង់ទេ នៅក្នុងករណីដែលជនជាប់ចោទបានបង្ហាញខ្លួននៅមុខសាលាឧទ្ធរណ៍ក្នុងឋានៈជាជនជាប់ឃុំនោះ ។

ដីកាបង្គាប់ឱ្យចាប់ខ្លួននៅតែមានអានុភាព ។

ការឃុំខ្លួនបណ្ដោះអាសន្ននៅតែបន្តអនុវត្ត ។

បុគ្គលជាប់ឃុំនៅក្នុងក្របខ័ណ្ឌនីតិវិធីបត្យាប័ននៅតែជាប់ឃុំដដែល ។

ក្នុងករណីមានការសម្រេចឱ្យរួចខ្លួន ជនជាប់ចោទត្រូវបានដោះលែងឱ្យមានសេរីភាព ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ៤៣៦.-** សេចក្តីសម្រេចលើបញ្ហាគតិយុត្ត

តុលាការកំពូលត្រូវសម្រេចលើបញ្ហាច្បាប់ដែលលើកឡើងដោយអ្នកប្តឹងសាទុក្ខ និងដែលមានរៀបរាប់នៅក្នុងសារណា ។

**មាត្រា ៤៣៧.-** ការបោះបង់ចោលបណ្តឹងសាទុក្ខ

ជនជាប់ចោទ ពិរុទ្ធជន បុគ្គលដែលត្រូវគេទាមទារក្នុងរឿងបស្សាប័ន ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីអាចបោះបង់ចោលបណ្តឹងសាទុក្ខរបស់ខ្លួន ។ ការបោះបង់ចោលនេះ ត្រូវពិនិត្យកត់ត្រាដោយប្រធានសភាព្រហ្មទណ្ឌនៃតុលាការកំពូល ។

**មាត្រា ៤៣៨.-** រយៈពេលសម្រាប់សម្រេចសេចក្តី

តុលាការកំពូលត្រូវសម្រេចក្នុងរយៈពេលយ៉ាងយូរ ៦ (ប្រាំមួយ) ខែ គិតពីពេលទទួលសំណុំរឿង លើកលែងតែមានកាលៈទេសៈដែលមិនអាចជំនះបាន ។

**មាត្រា ៤៣៩.-** ជំពូកនៃសេចក្តីសម្រេចរបស់តុលាការកំពូល

សភាព្រហ្មទណ្ឌនៃតុលាការកំពូលអាច :

-បដិសេធបណ្តឹងសាទុក្ខទាំងស្រុង ឬ មួយផ្នែក

-បដិសេធសាលដីការបស់សាលាឧទ្ធរណ៍ដែលគេតវ៉ានេះចោលទាំងស្រុង ឬ មួយផ្នែក ។

ប្រសិនបើបណ្តឹងសាទុក្ខត្រូវបានបដិសេធ នោះសេចក្តីសម្រេចដែលតវ៉ាមានអាជ្ញាអស់ជំនុំ ។

អ្នកប្តឹងសាទុក្ខមិនត្រូវបានអនុញ្ញាតឱ្យប្តឹងសាទុក្ខជាថ្មីម្តងទៀត អំពីសាលដីកាដដែលនោះទេ ។

កាលណាតុលាការកំពូលបដិសេធសេចក្តីសម្រេចដែលគេតវ៉ា តុលាការកំពូលបញ្ជូនរឿង និងគូភាគីនៅចំពោះមុខសាលាឧទ្ធរណ៍មួយផ្សេងទៀត ឬ នៅចំពោះមុខសាលាឧទ្ធរណ៍ដដែល ប៉ុន្តែមានសមាសភាពថ្មីផ្សេងពីសមាសភាពមុន ។

**មាត្រា ៤៤០.-** ការបដិសេធដោយគ្មានបង្វិលសំណុំរឿង

កាលណាអំពើដែលចោទប្រកាន់មិនមែនជាបទល្មើសទេ តុលាការកំពូលប្រកាសបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ដោយគ្មានបង្វិលសំណុំរឿងទៅវិញឡើយ ។

ROYAUME DU CAMBODGE
MINISTRE DU PALAIS ROYAL



185/240

**មាត្រា ៤៤១.–** ការបដិសេធដោយមានការបង្វិលសំណុំរឿង

កាលណាតុលាការកំពូលយល់ឃើញថា អំពើដែលចោទប្រកាន់នោះ ជាបទល្មើសផ្សេងអំពីបទល្មើសនៅក្នុងសេចក្ដីសម្រេចដែលគេតវ៉ា ប៉ុន្តែ បទល្មើសនេះត្រូវផ្តន្ទាទោសដូចគ្នា តុលាការកំពូលដោយមិនចាំបាច់ប្រកាសបដិសេធ អាចកែប្រែប្រភេទគតិយុត្តនៃអង្គហេតុជាថ្មី ដោយរក្សាទោសដែលបានប្រកាសហើយ និងសេចក្ដីសម្រេចផ្នែករដ្ឋប្បវេណីនៅដដែល ។

កាលណាតុលាការកំពូលយល់ឃើញថា អំពើដែលចោទប្រកាន់នោះ ជាបទល្មើសផ្សេងពីបទល្មើសនៅក្នុងសេចក្ដីសម្រេចដែលគេតវ៉ា ហើយបទល្មើសនេះត្រូវផ្តន្ទាទោសផ្សេងនោះ តុលាការកំពូលត្រូវបដិសេធសាលដីកាសាលាឧទ្ធរណ៍ និងបង្គាប់ឱ្យបញ្ជូនរឿងទៅសាលាជម្រះក្តីមានសមត្ថកិច្ច ដើម្បីជំនុំជម្រះ ។

**មាត្រា ៤៤២.–** សាលដីកាជំនុំជម្រះពេញអង្គ

ប្រសិនបើតុលាការទទួលសំណុំរឿង បង្វិលមិនអនុលោមតាមសាលដីកាទីមួយ របស់តុលាការកំពូលទេ ហើយប្រសិនបើមធ្យោបាយដែលត្រូវបានលើកយកមកធ្វើជាសំអាងសម្រាប់បណ្តឹងសាទុក្ខលើកទីពីរ តុលាការកំពូលដែលជំនុំជម្រះជាសភាពេញអង្គនោះ សម្រេចសេចក្ដីលើអង្គហេតុ និងអង្គច្បាប់ ដោយចេញសាលដីកាស្ថាពរមួយ ។

## មាតិកាទី ២

## បណ្តឹងសើរើរឿងក្តី

## ជំពូកទោល

## បណ្តឹងសើរើរឿងក្តី

**មាត្រា ៤៤៣.–** បណ្តឹងសើរើ

បណ្តឹងសើរើ គឺជាផ្លូវតវ៉ាមួយប្រឆាំងនឹងសាលក្រម និងសាលដីកាដែលស្ថាពរ ហើយដែលមានអាជ្ញាអស់ជំនុំ ។

សភាពេញអង្គនៃតុលាការកំពូលមានសមត្ថកិច្ចលើបណ្តឹងសើរើ ។

**មាត្រា ៤៤៤.–** បណ្តឹងសើរើក្នុងរឿងព្រហ្មទណ្ឌ

បណ្តឹងសើរើអាចត្រូវធ្វើបាននៅក្នុងរឿងព្រហ្មទណ្ឌ ទោះបីតុលាការដែលបានសម្រេចនោះជាតុលាការណាក៏ដោយ និងទោះបីទោសដែលបានប្រកាសនោះជាទោសអ្វីក៏ដោយ ។

186/240 ኬ

**មាត្រា ៤៤៥.–** ករណីបើកការសើរើរឿងក្តី

បណ្តឹងសើរើរឿងក្តីអាចធ្វើបានតែនៅក្នុងករណីដូចតទៅប៉ុណ្ណោះ :

១-កាលណាក្រោយពីការផ្តន្ទាទោសពីបទមនុស្សឃាតមានលេចតម្រុយយ៉ាងគ្រប់គ្រាន់ ដែលអនុញ្ញាតឱ្យគិតថាជនរងគ្រោះនោះនៅរស់រានមានជីវិតនៅឡើយ ។

២-កាលណាជនជាប់ចោទពីរនាក់ត្រូវបានផ្តន្ទាទោស ចំពោះបទល្មើសដដែលនេះ ដោយការផ្តន្ទាទោសទាំងពីរនេះមិនចុះសម្រុងគ្នាទេ ។

៣-កាលណាសាក្សីណាមួយត្រូវបានផ្តន្ទាទោសពីបទល្មើស ធ្វើជាសាក្សីដោយក្លែងប្រឆាំងនឹងជនជាប់ចោទ ។

៤-កាលណាមានអង្គហេតុថ្មី ឬ លិខិត ឬ ភស្តុតាងថ្មីដែលនាំឱ្យគេសង្ស័យលើពិរុទ្ធ-ភាពនៃទណ្ឌិត ។

**មាត្រា ៤៤៦.–** បុគ្គលដែលអាចប្តឹងសើរើរឿងក្តី

សិទ្ធិប្តឹងសុំឱ្យសើរើរឿងក្តីជាសិទ្ធិរបស់ :

១-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

២-ទណ្ឌិត ឬ អ្នកតំណាងស្របច្បាប់ ប្រសិនបើទណ្ឌិតនេះជាអសមត្ថជន

៣-សហព័ទ្ធ ឪពុក ម្តាយ កូន និងជាទូទៅ ជនណាដែលមានប្រយោជន៍ខាងសម្ភារៈ ឬ ខាងផ្លូវចិត្តក្នុងការលុបបំបាត់ទណ្ឌកម្មនេះ ក្នុងករណីដែលទណ្ឌិតបានទទួលមរណភាព ឬ បាត់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មុននឹងទៅប្តឹងតុលាការកំពូល អាចសុំដល់អគ្គព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដីឱ្យធ្វើការស្រាវជ្រាវបន្ថែម ។

**មាត្រា ៤៤៧.–** ការចុះបញ្ជីបណ្តឹងសើរើ និងការបើកពិនិត្យមើលសំណុំរឿង

ពាក្យប្តឹងសុំសើរើត្រូវចុះក្នុងបញ្ជីដោយក្រឡាបញ្ជីនៃតុលាការកំពូល ។

សំណុំរឿងនៃបណ្តឹងសើរើ អាចពិនិត្យមើលបាននៅការិយាល័យក្រឡាបញ្ជីនៃតុលាការកំពូលដោយអ្នកប្តឹងសុំសើរើ និងមេធាវីរបស់ខ្លួន ។ មេធាវីអាចចម្លងសំណុំរឿងនេះបាន ។

កាលណាបណ្តឹងសុំបានធ្វើដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សំណុំរឿងអាចពិនិត្យមើលបានដោយទណ្ឌិត និងមេធាវីរបស់ខ្លួន ។ ក្នុងករណីទណ្ឌិតបាត់ខ្លួន សំណុំរឿងអាចត្រូវពិនិត្យមើលបានដោយសហព័ទ្ធ ឪពុក ម្តាយ ឬ កូនរបស់ខ្លួនបាន ។

ROYAUME DU CAMBODGE MINISTRE DU PALAIS ROYAL

187/240

**មាត្រា ៤៤៨.-** នីតិវិធីសើរើ : រយៈពេល

ក្រឡាបញ្ជីផ្តល់ដំណឹងដល់ដើមបណ្តឹងថា ខ្លួនមានរយៈពេល ៣០ (សាមសិប) ថ្ងៃ ដើម្បីបំពេញពាក្យប្តឹងរបស់ខ្លួន ។ ជាលក្ខណៈពិសេស រយៈពេលនេះអាចពន្យារបានដោយប្រធានតុលាការកំពូល ។

ផុតរយៈពេលនេះ ប្រធានតុលាការកំពូលចាត់តាំងចៅក្រមរបាយការណ៍ម្នាក់ ។ កាលណារបាយការណ៍ធ្វើរួចហើយ សំណុំរឿងត្រូវបញ្ជូនទៅអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ។ អគ្គព្រះរាជអាជ្ញាធ្វើដីកាសន្និដ្ឋានជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ ។

**មាត្រា ៤៤៩.-** សេចក្តីសម្រេចបង្អង់ការអនុវត្តទោស

សភាព្រហ្មទណ្ឌនៃតុលាការកំពូលដែលបានទទួលពាក្យប្តឹងសើរើ អាចសម្រេចល្បួរការអនុវត្តទោសបាន ប្រសិនបើមានមូលហេតុច្បាស់លាស់ ។

**មាត្រា ៤៥០.-** ការបញ្ជូនបណ្តឹងសើរើទៅតុលាការកំពូល

កាលបើសភាព្រហ្មទណ្ឌសម្រេចថា បណ្តឹងសើរើអាចទទួលយកបាននោះ សភាត្រូវបញ្ជូនសំណុំរឿងនៃបណ្តឹងសើរើទៅតុលាការកំពូល ដើម្បីជំនុំជម្រះជាសភាពេញអង្គ និងសម្រេចលើអង្គហេតុ និងអង្គច្បាប់ដោយសាលដីកាស្ថាពរ ។

**មាត្រា ៤៥១.-** ការជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការ និងសាធារណភាពនៃកិច្ចពិភាក្សាដេញដោល

ប្រធានតុលាការកំពូលកំណត់កាលបរិច្ឆេទនៃសវនាការ និងជូនដំណឹងដោយផ្ទាល់មាត់ដល់អគ្គព្រះរាជអាជ្ញា អំពីកាលបរិច្ឆេទនៃសវនាការនេះ ។ អគ្គព្រះរាជអាជ្ញាជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការដល់អ្នកប្តឹងសើរើ និងមេធាវី ដូចបានចែងនៅមាត្រា ៤៣៣ (ការជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការចំពោះភាគី) នៃក្រមនេះ ។ ប្រសិនបើបណ្តឹងសើរើត្រូវបានធ្វើដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អគ្គព្រះរាជអាជ្ញាជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការដល់ទណ្ឌិត ឬដល់គ្រួសារ ។

ការពិភាក្សាដេញដោលប្រព្រឹត្តទៅនៅក្នុងពេលសវនាការសាធារណៈ ។

តុលាការស្តាប់សេចក្តីរាយការណ៍របស់ចៅក្រមរបាយការណ៍ រួចស្តាប់មេធាវីរបស់អ្នកប្តឹងសុំ ។ កាលណាបណ្តឹងសើរើបានធ្វើដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ តុលាការស្តាប់មេធាវីរបស់ទណ្ឌិត ឬរបស់គ្រួសារ ។ ប្រសិនបើយល់ឃើញថាមានប្រយោជន៍ តុលាការស្តាប់ចម្លើយទណ្ឌិត ។



ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL
188/240

តុលាការស្តាប់សេចក្តីសន្និដ្ឋានរបស់អគ្គព្រះរាជអាជ្ញា ។ មេធាវីរបស់អ្នកប្តឹងអាចនិយាយម្តងទៀតបាន ។

**មាត្រា ៤៥២.–** ការស្រាវជ្រាវបន្ថែម

ប្រសិនបើតុលាការកំពូលយល់ឃើញថា រឿងនោះល្មមជំនុំជម្រះបាន តុលាការកំពូលសម្រេចពីបណ្តឹងសើរើតាមសាលដីកាមួយដែលមិនអាចតវ៉ាបានទេ ។

នៅក្នុងករណីផ្ទុយពីនេះ តុលាការកំពូលបង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែម ។ តុលាការកំពូលចាត់តាំងសមាជិករបស់ខ្លួនម្នាក់ដើម្បីបំពេញកិច្ចនេះ ។ ចៅក្រមដែលចាត់តាំងនេះ មានអំណាចដូចចៅក្រមស៊ើបសួរ លើកលែងតែការឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ ។

កាលណាការស្រាវជ្រាវបានបញ្ចប់ ការស្រាវជ្រាវនេះត្រូវឱ្យដំណឹងដល់អ្នកប្តឹង និងមេធាវីឱ្យបានដឹង ។

ប្រធានកំណត់កាលបរិច្ឆេទសវនាការ ដូចដែលមានចែងនៅមាត្រា ៤៥១ (ការជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការ និងសាធារណភាពនៃកិច្ចពិភាក្សាដេញដោល) នៃក្រមនេះ ។

**មាត្រា ៤៥៣.–** ការសំអាងហេតុចំពោះសាលដីកា

សាលដីកាត្រូវតែមានសំអាងហេតុ ។ សាលដីកានេះត្រូវប្រកាសនៅពេលសវនាការសាធារណៈ ។

**មាត្រា ៤៥៤.–** សេចក្តីសម្រេចផ្អាកការអនុវត្តទណ្ឌកម្ម

ក្រោយពីបានទទួលរឿងក្តីប្តឹងសើរើ តុលាការកំពូលជំនុំជម្រះជាសភាពេញអង្គ អាចបង្គាប់ឱ្យផ្អាកការអនុវត្តទណ្ឌកម្មបានគ្រប់ពេលវេលា ។ តុលាការកំពូលសម្រេចតាមសាលដីកាដោយមានសំអាងហេតុ ។

**មាត្រា ៤៥៥.–** ផលវិបាកនៃការអនុគ្រោះទោស និងការលើកលែងទោសជាទូទៅតាមបណ្តឹងសើរើ

ការអនុគ្រោះទោស និងការលើកលែងទោសមិនមែនជាឧបសគ្គដល់ការប្តឹងសើរើទេ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

189/240

# គន្ថីទី ៧

# ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដីកាកោះហៅ និងដីកាជូនដំណឹង

## មាតិកាទី ១

## ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

### ជំពូកទោល

### ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

**មាត្រា ៤៥៦.-** ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ : ទម្រង់

ដូចដែលមានចែងនៅក្នុងមាត្រា ៤៦ (ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់) នៃក្រមនេះ ស្រាប់ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់គឺជាបញ្ជា ដល់ជនជាប់ចោទឱ្យចូលបង្ហាញខ្លួននៅតុលាការជាន់ដំបូង ដែលសម្រេចពីរឿងព្រហ្មទណ្ឌ ។

ដើមដីកាដែលមានចុះកាលបរិច្ឆេទ ទីកន្លែងកំណើត និងលំនៅឋានរបស់ជនជាប់ចោទ ត្រូវតែមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា ។

**មាត្រា ៤៥៧.-** រយៈពេលដែលត្រូវគោរពរវាងការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងការបង្គាប់ឱ្យចូលបង្ហាញខ្លួន

រយៈពេលដែលត្រូវគោរពរវាង ការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ឱ្យដល់ជនជាប់ចោទ និងថ្ងៃកំណត់ឱ្យចូលបង្ហាញខ្លួននៅមុខតុលាការត្រូវកំណត់ដូចតទៅ :

-១៥ (ដប់ប្រាំ) ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃទីស្នាក់ការរបស់តុលាការជាន់ដំបូង

-២០ (ម្ភៃ) ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងមួយផ្សេងទៀតក្នុងដែនដីជាតិ

-២ (ពីរ) ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា

-៣ (បី) ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងដទៃផ្សេងទៀត ។

**មាត្រា ៤៥៨.-** ការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ដោយព្រះរាជអាជ្ញា

ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ អាចត្រូវប្រគល់ឱ្យជនជាប់ចោទដោយផ្ទាល់ដៃដោយព្រះរាជអាជ្ញា ។

ក្នុងករណីនេះ ព្រះរាជអាជ្ញាប្រគល់ចុងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដល់ជនជាប់ចោទ ។ ព្រះរាជអាជ្ញាចុះនិទ្ទេសស្ដីពីកាលបរិច្ឆេទ និងទីកន្លែងប្រគល់ដីកានៅលើដើមដីកា ។ ជនជាប់ចោទចុះហត្ថលេខានៅលើដើមដីកានេះ ។

**មាត្រា ៤៥៩.-** ការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ដោយអាជ្ញាសាលា

ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ក៏អាចត្រូវបានប្រគល់ដោយអាជ្ញាសាលាបានដែរ ។ អាជ្ញាសាលាត្រូវប្រើគ្រប់មធ្យោបាយដើម្បីប្រគល់ដីកានេះឱ្យជនជាប់ចោទដោយផ្ទាល់ដៃ ។

**មាត្រា ៤៦០.-** ការប្រគល់ចុងដីកាកោះហៅដោយអាជ្ញាសាលាដល់ជនជាប់ចោទ

ប្រសិនបើអាជ្ញាសាលាជួបប្រទះជនជាប់ចោទនៅក្នុងផ្ទះ ឬ នៅកន្លែងដទៃទៀត អាជ្ញាសា-លាប្រគល់ចុងដីកាកោះដល់សាមីខ្លួន ។ អាជ្ញាសាលាចារសេចក្ដីលើដើមដីកាថា បានប្រគល់ចុងដីកាដល់ជនជាប់ចោទផ្ទាល់ដៃ ។ អាជ្ញាសាលាចុះនិទ្ទេសស្ដីពីកាលបរិច្ឆេទ និងទីកន្លែងនៃការប្រគល់ ។ ជនជាប់ចោទចុះហត្ថលេខានៅលើដើមដីកា ។ ដើមដីកាត្រូវបញ្ជូនវិលត្រឡប់ទៅព្រះរាជអាជ្ញាវិញភ្លាម ។

**មាត្រា ៤៦១.-** ការប្រគល់ចុងដីកាកោះហៅដោយអាជ្ញាសាលាក្នុងករណីជនជាប់ចោទអវត្តមាន

ប្រសិនបើជនជាប់ចោទអវត្តមានពីលំនៅឋានរបស់ខ្លួន អាជ្ញាសាលាត្រូវប្រគល់ចុងដីកាឱ្យដល់បុគ្គលទាំងឡាយណាជាញាតិជនដែលមានវត្តមាននៅលំនៅឋាននោះ ។

អាជ្ញាសាលាចុះសេចក្ដីលើដើមដីកាថា ចុងដីកាត្រូវបានប្រគល់ឱ្យបុគ្គលដែលមានវត្តមាននៅលំនៅឋាន ។ អាជ្ញាសាលាត្រូវចុះនិទ្ទេសស្ដីពីអត្តសញ្ញាណនៃបុគ្គលនោះ និងកាលបរិច្ឆេទនៃការប្រគល់ដីកា ។ បុគ្គលដែលទទួលចុងដីកាត្រូវចុះហត្ថលេខានៅលើដើមដីកា ។ ដើមដីកាត្រូវបង្វិលមកព្រះរាជអាជ្ញាវិញភ្លាម ។

បុគ្គលដែលទទួលដីកាត្រូវសន្យាថា នឹងប្រគល់ដីកានេះក្នុងរយៈពេលយ៉ាងខ្លីបំផុតឱ្យដល់ជនជាប់ចោទ ។



ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL
191/240

**មាត្រា ៤៦២.–** ការប្រគល់ចុងដីកាកោះហៅដោយអាជ្ញាសាលាដល់មេឃុំ ឬ ចៅសង្កាត់

អាជ្ញាសាលាប្រគល់ចុងដីកា ឱ្យដល់មេឃុំ ឬ ចៅសង្កាត់ ឬ ជំទប់ ឬ ចៅសង្កាត់រង នៅក្នុងករណីដូចតទៅ :

-ជនជាប់ចោទមិនព្រមទទួលដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

-គ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់ជនជាប់ចោទទេ

-គ្មានបុគ្គលណាម្នាក់ដែលមានវត្តមាននៅក្នុងលំនៅឋានរបស់ជនជាប់ចោទ យល់ព្រមទទួលដីកាកោះទេ ។

អាជ្ញាសាលាចុះនិទ្ទេសនៅលើដើមដីកា អំពីអត្តសញ្ញាណ និងឋានៈរបស់បុគ្គលដែលបានទទួលចុងដីកាព្រមទាំងកាលបរិច្ឆេទនៃការប្រគល់ដីកា ។ បុគ្គលដែលទទួលចុងដីកាចុះហត្ថលេខារបស់ខ្លួននៅលើដើមដីកា ។ ដើមដីកាត្រូវបង្វិលត្រលប់ជូនព្រះរាជអាជ្ញាវិញភ្លាម ។

បុគ្គលដែលទទួលដីកាត្រូវសន្យាថា នឹងប្រគល់ដីកានោះក្នុងរយៈពេលដ៏ខ្លីបំផុតឱ្យដល់ជនជាប់ចោទ ។

**មាត្រា ៤៦៣.–** របៀបផ្សេងទៀតនៃការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ក៏អាចត្រូវបានប្រគល់ដោយ :

-ក្រឡាបញ្ជី

-តាមផ្លូវរដ្ឋបាល

-ដោយប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ប្រសិនបើជនជាប់ចោទត្រូវឃុំខ្លួនពីបទល្មើសផ្សេងទៀត

-តាមរយៈអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ ។

ក្រឡាបញ្ជី អាជ្ញាធររដ្ឋបាល អាជ្ញាធរពន្ធនាគារ មន្ត្រីនគរបាលជាតិ ឬ អាវុធហត្ថដែលព្រះរាជអាជ្ញាសុំឱ្យប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ត្រូវតែគោរពតាមបញ្ជារបស់ព្រះរាជអាជ្ញា ។

ត្រូវបំពេញកិច្ចនេះដូចមានចែងនៅក្នុងមាត្រា ៤៦០ (ការប្រគល់ចុងដីកាកោះហៅដោយអាជ្ញាសាលាដល់ជនជាប់ចោទ) ដល់មាត្រា ៤៦២ (ការប្រគល់ចុងដីកាកោះហៅដោយអាជ្ញាសាលាដល់មេឃុំ ឬ ចៅសង្កាត់) នៃក្រមនេះ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង
192/240

**មាត្រា ៤៦៤.-** ជនជាប់ចោទគ្មានលំនៅឋាន ឬ គ្មានទីសំណាក់ដែលគេស្គាល់

ប្រសិនបើជនជាប់ចោទគ្មានលំនៅឋាន ឬ ទីសំណាក់ ឬ ក៏រស់នៅក្រៅដែនដីជាតិព្រះរាជអាជ្ញាក៏អាចធ្វើការចោទប្រកាន់លើជនជាប់ចោទនេះ តាមផ្លូវដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់បានដែរ ។ ក្នុងករណីនេះ កាលបរិច្ឆេទនៃការធ្វើដីកា ត្រូវចាត់ទុកថាជាកាលបរិច្ឆេទនៃការប្រគល់ដីកា ។

## ផ្នែកទី ២
## ដីកាកោះហៅជនជាប់ចោទឱ្យចូលសវនាការ
## ជំពូកគោល
## ដីកាកោះហៅជនជាប់ចោទឱ្យចូលសវនាការ

**មាត្រា ៤៦៥.-** ទម្រង់នៃដីកាកោះហៅឱ្យចូលសវនាការ

ដូចដែលបានចែងនៅមាត្រា ២៩៤ (ការកោះហៅភាគីឱ្យចូលរួមក្នុងសវនាការតាមដីកាបញ្ជូន ឬ តាមសាលដីកាបញ្ជូន) នៃក្រមនេះ នៅក្នុងករណីនៃដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬ សាលដីកាបញ្ជូនរបស់សភាស៊ើបសួរ ព្រះរាជអាជ្ញាត្រូវកោះហៅជនជាប់ចោទឱ្យចូលសវនាការ ។

ដីកាកោះហៅជនជាប់ចោទឱ្យចូលសវនាការ ត្រូវមាននិទ្ទេសដូចតទៅ :

- -អត្តសញ្ញាណនៃជនជាប់ចោទ
- -កាលបរិច្ឆេទ និងទីកន្លែងកំណើតនៃជនជាប់ចោទ
- -លំនៅឋាននៃជនជាប់ចោទ
- -ការយោងដីកា ឬ សាលដីកាបញ្ជូន
- -តុលាការដែលទទួលបណ្ដឹងដើម្បីជំនុំជម្រះ
- -ទីកន្លែង កាលបរិច្ឆេទ និងម៉ោងនៃសវនាការ
- -កាលបរិច្ឆេទ និងហត្ថលេខារបស់ព្រះរាជអាជ្ញា ។

ដីកាកោះត្រូវបញ្ជាក់ថា ជនជាប់ចោទអាចអមដោយមេធាវី ។

**មាត្រា ៤៦៦.-** រយៈពេលដែលត្រូវគោរពរវាងដីកាកោះហៅ និងការបង្គាប់ឱ្យចូលបង្ហាញខ្លួន

រយៈពេលរវាងការប្រគល់ដីកាកោះហៅឱ្យជនជាប់ចោទ និងថ្ងៃកំណត់ឱ្យចូលបង្ហាញខ្លួននៅមុខតុលាការ ត្រូវកំណត់ដូចតទៅ :

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL



13/240

-១៥ (ដប់ប្រាំ) ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃតុលាការជាន់ដំបូង

-២០ (ម្ភៃ) ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅទីកន្លែងមួយផ្សេងទៀតនៃដែនដីជាតិ

-២ (ពីរ) ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា

-៣ (បី) ខែ ប្រសិនបើជនជាប់ចោទរស់នៅទីកន្លែងមួយផ្សេងទៀត ។

ប៉ុន្តែក្នុងករណីជនជាប់ចោទត្រូវឃុំខ្លួន គ្មានរយៈពេលណាមួយត្រូវបានទាមទារឡើយរវាងការប្រគល់ដីកាដល់ជនជាប់ចោទ និងថ្ងៃកំណត់ឱ្យចូលបង្ហាញខ្លួននៅមុខតុលាការ ។

**មាត្រា ៤៦៧.–** ដីកាកោះហៅដែលប្រគល់ឱ្យដោយផ្ទាល់ដៃដោយព្រះរាជអាជ្ញា

ដីកាកោះហៅអាចប្រគល់ឱ្យដល់ជនជាប់ចោទដោយផ្ទាល់ដៃដោយព្រះរាជអាជ្ញា ។

ក្នុងករណីនេះព្រះរាជអាជ្ញាប្រគល់ចុងដីកាកោះឱ្យដល់ជនជាប់ចោទ ។ ព្រះរាជអាជ្ញាចុះនិទ្ទេសលើដើមដីកា អំពីកាលបរិច្ឆេទ និងទីកន្លែងប្រគល់ ។ ជនជាប់ចោទចុះហត្ថលេខានៅលើដើមដីកាកោះនេះ ។

**មាត្រា ៤៦៨.–** ដីកាកោះហៅដែលប្រគល់ដោយផ្ទាល់ដៃដោយអាជ្ញាសាលា

ដីកាកោះក៏អាចត្រូវបានប្រគល់ដោយអាជ្ញាសាលាផងដែរ ។

អាជ្ញាសាលាត្រូវប្រើគ្រប់មធ្យោបាយដើម្បីប្រគល់ដីកាកោះហៅ ដល់ជនជាប់ចោទដោយផ្ទាល់ដៃ ។

**មាត្រា ៤៦៩.–** ការប្រគល់ចុងដីកាកោះហៅដោយអាជ្ញាសាលាដល់ជនជាប់ចោទ

ប្រសិនបើអាជ្ញាសាលាជួបប្រទះជនជាប់ចោទនៅក្នុងលំនៅឋាន ឬ នៅកន្លែងដទៃទៀត អាជ្ញាសាលាប្រគល់ចុងដីកាកោះហៅឱ្យដល់ជនជាប់ចោទនេះ ។

អាជ្ញាសាលាចារនៅលើដើមដីកាកោះហៅថា ចុងដីកាត្រូវបានប្រគល់ឱ្យដល់ជនជាប់ចោទដោយផ្ទាល់ដៃ ។ អាជ្ញាសាលាចុះនិទ្ទេសអំពីកាលបរិច្ឆេទ និងទីកន្លែងដែលបានប្រគល់ដីកាកោះហៅ ។ ជនជាប់ចោទចុះហត្ថលេខានៅលើដើមដីកា ។ ដើមដីកាកោះហៅនេះ ត្រូវបញ្ជូនមកព្រះរាជអាជ្ញាវិញភ្លាម ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
194/240

**មាត្រា ៤៧០.–** ការប្រគល់ចុងដីកាកោះហៅដោយអាជ្ញាសាលាក្នុងករណីអវត្តមានរបស់ជនជាប់ចោទ

ប្រសិនបើជនជាប់ចោទអវត្តមានពីលំនៅឋាន អាជ្ញាសាលាប្រគល់ចុងដីកាកោះឱ្យដល់បុគ្គលទាំងឡាយណាជានីតិជន ដែលមានវត្តមានក្នុងលំនៅឋាន ។

អាជ្ញាសាលាចារនៅលើដើមដីកាកោះថា ចុងដីកាកោះត្រូវបានប្រគល់ឱ្យដល់បុគ្គលដែលមានវត្តមាននៅលំនៅឋាន ។ អាជ្ញាសាលាចុះនិទ្ទេសអំពីអត្តសញ្ញាណនៃបុគ្គលនេះ និងអំពីកាលបរិច្ឆេទនៃការប្រគល់ដីកាកោះ ។ បុគ្គលដែលទទួលចុងដីកាកោះចុះហត្ថលេខានៅលើដើមដីកា ។ ដើមដីកាកោះនេះត្រូវបញ្ជូនទៅព្រះរាជអាជ្ញាវិញភ្លាម ។

បុគ្គលដែលទទួលដីកាកោះត្រូវសន្យាថា នឹងប្រគល់ដីកានេះដល់ជនជាប់ចោទក្នុងរយៈពេលខ្លីបំផុត ។

**មាត្រា ៤៧១.–** ការប្រគល់ចុងដីកាកោះហៅដោយអាជ្ញាសាលាដល់មេឃុំ ឬ ចៅសង្កាត់

អាជ្ញាសាលាប្រគល់ចុងដីកាកោះឱ្យដល់មេឃុំ ឬ ចៅសង្កាត់ ឬ ជំទប់ ឬ ចៅសង្កាត់រងណាមួយ ក្នុងករណីដូចតទៅ :

-ជនជាប់ចោទមិនព្រមទទួលដីកាកោះ

-គ្មានបុគ្គលណាមានវត្តមាននៅក្នុងលំនៅឋានរបស់ជនជាប់ចោទទេ

-គ្មានបុគ្គលណាម្នាក់ដែលមានវត្តមាននៅក្នុងលំនៅឋានរបស់ជនជាប់ចោទ យល់ព្រមទទួលដីកាកោះទេ ។

អាជ្ញាសាលាចុះនិទ្ទេសនៅលើដើមដីកាកោះអំពីអត្តសញ្ញាណ និងឋានៈរបស់បុគ្គលដែលបានទទួលចុងដីកា ព្រមទាំងអំពីកាលបរិច្ឆេទនៃការប្រគល់ ។ បុគ្គលដែលទទួលដីកាកោះចុះហត្ថលេខានៅលើដើមដីកាកោះ ។ ដើមដីកាកោះត្រូវបញ្ជូនទៅព្រះរាជអាជ្ញាវិញភ្លាម ។

បុគ្គលដែលទទួលដីកាកោះត្រូវសន្យាថា នឹងប្រគល់ដីកាឱ្យដល់ជនជាប់ចោទនៅក្នុងរយៈពេលដ៏ខ្លីបំផុត ។

**មាត្រា ៤៧២.–** របៀបផ្សេងទៀតនៃការប្រគល់ដីកាកោះហៅ

ដីកាកោះក៏អាចត្រូវប្រគល់ឱ្យ :

-ដោយក្រឡាបញ្ជី

-តាមផ្លូវរដ្ឋបាល

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL



195/240

-ដោយប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ប្រសិនបើជនជាប់ចោទត្រូវឃុំពីរឿងមួយផ្សេងទៀត

-តាមរយៈអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ ។

ក្រឡាបញ្ជី អាជ្ញាធររដ្ឋបាល អាជ្ញាធរពន្ធនាគារ មន្ត្រីនគរបាលជាតិ ឬ អាវុធហត្ថដែលព្រះរាជអាជ្ញាសុំឱ្យប្រគល់ដីកាកោះ ត្រូវតែគោរពតាមបញ្ជាព្រះរាជអាជ្ញា ។

កិច្ចនេះត្រូវធ្វើដូចដែលមានចែងនៅក្នុងមាត្រា ៤៦៩ (ការប្រគល់ចុងដីកាដោយអាជ្ញាសាលាដល់ជនជាប់ចោទ) ដល់មាត្រា ៤៧១ (ការប្រគល់ចុងដីកាកោះហៅដោយអាជ្ញាសាលាដល់មេឃុំ ឬ ចៅសង្កាត់) នៃក្រមនេះ ។

**មាត្រា ៤៧៣.-** ជនជាប់ចោទគ្មានលំនៅឋាន និងគ្មានទីសំណាក់ដែលគេស្គាល់

ប្រសិនបើជនជាប់ចោទគ្មានលំនៅឋាន ឬ ទីសំណាក់ ឬ ប្រសិនបើជនជាប់ចោទនៅក្រៅដែនដីជាតិ ព្រះរាជអាជ្ញាក៏អាចកោះហៅជនជាប់ចោទឱ្យមកកាន់សវនាការបានដែរ ។ ក្នុងករណីនេះ កាលបរិច្ឆេទនៃការធ្វើដីកាកោះត្រូវចាត់ទុកជាកាលបរិច្ឆេទនៃការប្រគល់ដីកាកោះ ។

**មាត្រា ៤៧៤.-** ឯកសារភ្ជាប់ទៅនឹងចុងដីកាកោះហៅ

នៅក្នុងគ្រប់ករណីទាំងអស់លិខិតចម្លងមួយច្បាប់នៃដីកា ឬ សាលដីកាបញ្ជូនរឿងទៅតុលា-ការជំនុំជម្រះត្រូវភ្ជាប់ជាមួយនឹងចុងដីកាកោះ ។

## មាតិកាទី ៣

## ដីកាកោះហៅជនក្រៅពីជនជាប់ចោទឱ្យចូលសវនាការ

## ជំពូកទោល

## ដីកាកោះហៅជនក្រៅពីជនជាប់ចោទឱ្យចូលសវនាការ

**មាត្រា ៤៧៥.-** ដីកាកោះហៅដើមបណ្ដឹងរដ្ឋប្បវេណី

ដីកាកោះហៅដើមបណ្ដឹងរដ្ឋប្បវេណីឱ្យ ចូលមកកាន់សវនាការមានចុះនិទ្ទេសដូចតទៅ :

-អត្តសញ្ញាណដើមបណ្ដឹងរដ្ឋប្បវេណី

-លំនៅឋានដើមបណ្ដឹងរដ្ឋប្បវេណី

-ឈ្មោះជនជាប់ចោទ និងបទល្មើសដែលចោទប្រកាន់

-តុលាការដែលត្រូវជំនុំជម្រះ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

196/240

-ទីកន្លែង កាលបរិច្ឆេទ និងម៉ោងនៃសវនាការ

-កាលបរិច្ឆេទ និងហត្ថលេខារបស់ព្រះរាជអាជ្ញា ។

ដីកាកោះត្រូវបញ្ជាក់ថា បុគ្គលពាក់ព័ន្ធត្រូវបានកោះហៅក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ។

**មាត្រា ៤៧៦.–** ដីកាកោះហៅជនរងគ្រោះ

ដីកាកោះហៅជនរងគ្រោះឱ្យចូលមកកាន់សវនាការ កាលណាជននេះមិនបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅមុខចៅក្រមស៊ើបសួរទេ ។ ដីកាកោះហៅនេះមានចុះនិទ្ទេសដូចតទៅ :

-អត្តសញ្ញាណជនរងគ្រោះ

-លំនៅឋានជនរងគ្រោះ

-ឈ្មោះជនជាប់ចោទ និងបទល្មើសដែលចោទប្រកាន់

-តុលាការដែលត្រូវជំនុំជម្រះ

-ទីកន្លែង កាលបរិច្ឆេទ និងម៉ោងនៃសវនាការ

-កាលបរិច្ឆេទ និងហត្ថលេខារបស់ព្រះរាជអាជ្ញា ។

ដីកាកោះហៅត្រូវបញ្ជាក់ថា បុគ្គលពាក់ព័ន្ធត្រូវបានកោះហៅក្នុងឋានៈជាជនរងគ្រោះ ។

**មាត្រា ៤៧៧.–** ដីកាកោះហៅសាក្សី

ដីកាកោះហៅសាក្សីឱ្យមកកាន់សវនាការ មានចុះនិទ្ទេសដូចតទៅ :

-អត្តសញ្ញាណសាក្សី

-លំនៅឋានសាក្សី

-ឈ្មោះជនជាប់ចោទ

-តុលាការដែលត្រូវជំនុំជម្រះ

-ទីកន្លែង កាលបរិច្ឆេទ និងម៉ោងសវនាការ

-កាលបរិច្ឆេទ និងហត្ថលេខារបស់ព្រះរាជអាជ្ញា ។

ដីកាកោះហៅត្រូវបញ្ជាក់ថា :

-បុគ្គលពាក់ព័ន្ធត្រូវបានកោះហៅក្នុងឋានៈជាសាក្សី

-ការមិនចូលបង្ហាញខ្លួននៅពេលសវនាការ ការមិនព្រមឆ្លើយឱ្យព័ត៌មានក្នុងឋានៈជាសាក្សី ឬ ការឆ្លើយឱ្យព័ត៌មានក្លែងក្លាយត្រូវផ្តន្ទាទោសតាមច្បាប់ ។



197/240

**មាត្រា ៤៧៨.–** ដីកាកោះហៅអ្នកជំនាញ

ដីកាកោះហៅអ្នកជំនាញឱ្យចូលមកកាន់សវនាការ មានចុះនិទ្ទេសដូចតទៅ :

-អត្តសញ្ញាណអ្នកជំនាញ

-លំនៅឋានអ្នកជំនាញ

-ឈ្មោះជនជាប់ចោទ

-តុលាការដែលត្រូវជំនុំជម្រះ

-ទីកន្លែង កាលបរិច្ឆេទ និងម៉ោងនៃសវនាការ

-កាលបរិច្ឆេទ និងហត្ថលេខារបស់ព្រះរាជអាជ្ញា ។

ដីកាកោះហៅត្រូវបញ្ជាក់ថា បុគ្គលពាក់ព័ន្ធត្រូវបានកោះហៅក្នុងឋានៈជាអ្នកជំនាញ ។

**មាត្រា ៤៧៩.–** ដីកាកោះហៅអ្នកបកប្រែ

ដីកាកោះហៅអ្នកបកប្រែឱ្យចូលមកកាន់សវនាការ មានចុះនិទ្ទេសដូចតទៅ :

-អត្តសញ្ញាណអ្នកបកប្រែ

-លំនៅឋានអ្នកបកប្រែ

-ឈ្មោះជនជាប់ចោទ

-តុលាការដែលត្រូវជំនុំជម្រះ

-ទីកន្លែង កាលបរិច្ឆេទ និងម៉ោងនៃសវនាការ

-កាលបរិច្ឆេទ និងហត្ថលេខារបស់ព្រះរាជអាជ្ញា ។

ដីកាកោះត្រូវបញ្ជាក់ថា បុគ្គលពាក់ព័ន្ធត្រូវបានកោះហៅក្នុងឋានៈជាអ្នកបកប្រែ ។

**មាត្រា ៤៨០.–** ដីកាកោះហៅអ្នកទទួលខុសត្រូវរដ្ឋប្បវេណី

ដីកាកោះហៅអ្នកទទួលខុសត្រូវរដ្ឋប្បវេណីឱ្យចូលមកកាន់សវនាការ មានចុះនិទ្ទេសដូចតទៅ :

-អត្តសញ្ញាណអ្នកទទួលខុសត្រូវរដ្ឋប្បវេណី

-លំនៅឋានអ្នកទទួលខុសត្រូវរដ្ឋប្បវេណី

-ឈ្មោះជនជាប់ចោទ

-តុលាការដែលត្រូវជំនុំជម្រះ

-ទីកន្លែង កាលបរិច្ឆេទ និងម៉ោងនៃសវនាការ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង



198/240

-កាលបរិច្ឆេទ និងហត្ថលេខារបស់ព្រះរាជអាជ្ញា ។

ដីកាកោះហៅត្រូវបញ្ជាក់ថា បុគ្គលពាក់ព័ន្ធត្រូវបានកោះហៅក្នុងឋានៈជាអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ។

**មាត្រា ៤៨១.-** បទប្បញ្ញត្តិរួម

ដីកាកោះហៅដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី អ្នកជំនាញ អ្នកបកប្រែ និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីឱ្យចូលមកកាន់សវនាការ ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃមាត្រា ៤៦៧ (ដីកាកោះហៅដែលប្រគល់ឱ្យដោយផ្ទាល់ដៃដោយព្រះរាជអាជ្ញា) ដល់មាត្រា ៤៧២ (របៀបផ្សេងទៀតនៃការប្រគល់ដីកាកោះហៅ) នៃក្រមនេះ ។

## មាតិកាទី ៤

## ដីកាឱ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ

## ជំពូកទោល

## ដីកាឱ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ

**មាត្រា ៤៨២.-** កម្មវត្ថុនៃដីកាឱ្យដំណឹង

ដីកាឱ្យដំណឹងគឺជាលិខិតដែលឱ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ ដែលបញ្ញត្តិច្បាប់តម្រូវឱ្យជូនដំណឹងដល់ភាគីពាក់ព័ន្ធ ដើម្បីឱ្យភាគីពាក់ព័ន្ធទទួលបានដំណឹងអំពីសេចក្តីសម្រេចនោះ ។

ដីកាឱ្យដំណឹងត្រូវធ្វើតាមគំនិតផ្តើមរបស់ព្រះរាជអាជ្ញា របស់អគ្គព្រះរាជអាជ្ញា ឬរបស់ភាគី ។

**មាត្រា ៤៨៣.-** និទ្ទេសដែលត្រូវចុះលើដីកាឱ្យដំណឹង

ដីកាឱ្យដំណឹងមានចុះនិទ្ទេសដូចតទៅ :

-ប្រភេទ និងការយោងនៃសេចក្តីសម្រេចដែលត្រូវជូនដំណឹង

-អត្តសញ្ញាណ និងលំនៅឋាននៃភាគីដែលត្រូវទទួលដំណឹងអំពីសេចក្តីសម្រេច

-កាលបរិច្ឆេទ និងហត្ថលេខារបស់អ្នកដែលធ្វើការជូនដំណឹង ។

ដីកាឱ្យដំណឹងបញ្ជាក់ប្រាប់អំពីផ្លូវតវ៉ាដែលអាចធ្វើបាន ប្រឆាំងទៅនឹងសេចក្តីសម្រេចដែលត្រូវបានជូនដំណឹង ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

199/240

លិខិតចម្លងនៃសេចក្ដីសម្រេច ដែលត្រូវជូនដំណឹងត្រូវភ្ជាប់ទៅនឹងដីកាឱ្យដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការ ។

**មាត្រា ៤៨៤.–** ការជូនដំណឹងដែលធ្វើឡើងដោយព្រះរាជអាជ្ញា

ការជូនដំណឹងដល់ភាគីពាក់ព័ន្ធអាចត្រូវធ្វើដោយព្រះរាជអាជ្ញា ។

ក្នុងករណីនេះ ព្រះរាជអាជ្ញាប្រគល់លិខិតចម្លងនៃសេចក្ដីសម្រេចរបស់តុលាការឱ្យដល់ភាគីពាក់ព័ន្ធ ។

ព្រះរាជអាជ្ញាចុះនិទ្ទេសលើសេចក្ដីសម្រេចដើមអំពីកាលបរិច្ឆេទ និងទីកន្លែងនៃការប្រគល់លិខិតចម្លង ។ ភាគីពាក់ព័ន្ធចុះហត្ថលេខានៅលើសេចក្ដីសម្រេចដើមនេះ ។

**មាត្រា ៤៨៥.–** ការជូនដំណឹងដែលធ្វើឡើងដោយអាជ្ញាសាលា

ការជូនដំណឹងក៏អាចត្រូវធ្វើដោយអាជ្ញាសាលាផងដែរ ។

អាជ្ញាសាលាប្រើគ្រប់មធ្យោបាយ ដើម្បីជូនដំណឹងដល់បុគ្គលពាក់ព័ន្ធអំពីសេចក្ដីសម្រេចរបស់តុលាការ ។

**មាត្រា ៤៨៦.–** ការប្រគល់លិខិតចម្លងនៃសេចក្ដីសម្រេច ជូនដល់ភាគីដែលពាក់ព័ន្ធដោយអាជ្ញាសាលា

ប្រសិនបើអាជ្ញាសាលាជួបប្រទះភាគីពាក់ព័ន្ធនៅក្នុងលំនៅឋាន ឬ នៅទីកន្លែងដទៃទៀត អាជ្ញាសាលាត្រូវប្រគល់លិខិតចម្លងនៃសេចក្ដីសម្រេចដល់ភាគីពាក់ព័ន្ធ ។

អាជ្ញាសាលាត្រូវចារលើសេចក្ដីសម្រេចដើមថា លិខិតចម្លងត្រូវបានប្រគល់ឱ្យភាគីពាក់ព័ន្ធដោយផ្ទាល់ដៃ ។ អាជ្ញាសាលាចុះនិទ្ទេសអំពីកាលបរិច្ឆេទ និងទីកន្លែងដែលបានប្រគល់លិខិតចម្លង ។ ភាគីពាក់ព័ន្ធចុះហត្ថលេខាលើសេចក្ដីសម្រេចដើម ។ សេចក្ដីសម្រេចដើមនេះ ត្រូវបង្វិលទៅព្រះរាជអាជ្ញាវិញជាបន្ទាន់ ។

**មាត្រា ៤៨៧.–** ករណីអវត្តមាននៃភាគីដែលពាក់ព័ន្ធ

ប្រសិនបើភាគីពាក់ព័ន្ធអវត្តមានពីលំនៅឋាន អាជ្ញាសាលាត្រូវប្រគល់លិខិតចម្លងនៃសេចក្ដីសម្រេចឱ្យបុគ្គលជានីតិជនដែលមានវត្តមាននៅក្នុងលំនៅឋាន ។

អាជ្ញាសាលាត្រូវចារលើសេចក្ដីសម្រេចដើមថាលិខិតចម្លងនៃសេចក្ដីសម្រេច ត្រូវបានប្រគល់ឱ្យដល់ដៃបុគ្គលដែលមានវត្តមាននៅក្នុងលំនៅឋាន ។ អាជ្ញាសាលាត្រូវចុះនិទ្ទេសអំពីអត្តសញ្ញាណនៃបុគ្គលនោះ កាលបរិច្ឆេទប្រគល់លិខិតចម្លងនៃសេចក្ដីសម្រេច ។ បុគ្គលដែល

ទទួលលិខិតត្រូវចុះហត្ថលេខានៅលើសេចក្ដីសម្រេចដើម ។ សេចក្ដីសម្រេចដើមនេះត្រូវបង្វិលទៅព្រះរាជអាជ្ញាវិញភ្លាម ។

បុគ្គលដែលទទួលលិខិតចម្លងនៃសេចក្ដីសម្រេចត្រូវសន្យាថានឹងប្រគល់ឱ្យដល់ភាគីពាក់ព័ន្ធក្នុងរយៈពេលដ៏ខ្លីបំផុត ។

**មាត្រា ៤៨៨.–** ការប្រគល់លិខិតចម្លងនៃសេចក្ដីសម្រេចដល់មេឃុំ ឬ ចៅសង្កាត់

អាជ្ញាសាលាប្រគល់លិខិតនៃសេចក្ដីសម្រេចទៅមេឃុំ ឬ ចៅសង្កាត់ ឬ ទៅជំទប់ ឬ ចៅសង្កាត់រងណាមួយ នៅក្នុងករណីដូចតទៅ :

-ភាគីពាក់ព័ន្ធមិនព្រមទទួលសេចក្ដីសម្រេច

-គ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់ភាគីពាក់ព័ន្ធទេ

-គ្មានបុគ្គលណាម្នាក់ដែលមានវត្តមាននៅក្នុងលំនៅឋានរបស់ភាគីពាក់ព័ន្ធ យល់ព្រមទទួលសេចក្ដីសម្រេចនោះទេ ។

អាជ្ញាសាលាចុះនិទ្ទេសនៅលើសេចក្ដីសម្រេចដើមអំពីអត្តសញ្ញាណ និងឋានៈរបស់បុគ្គលដែលបានទទួលលិខិតចម្លងនៃសេចក្ដីសម្រេច ព្រមទាំងកាលបរិច្ឆេទនៃការប្រគល់ ។ បុគ្គលដែលទទួលលិខិតចម្លងចុះហត្ថលេខានៅលើសេចក្ដីសម្រេចដើម ។ សេចក្ដីសម្រេចដើមត្រូវបង្វិលជូនទៅព្រះរាជអាជ្ញាវិញភ្លាម ។

បុគ្គលដែលទទួលលិខិតចម្លងនៃសេចក្ដីសម្រេចត្រូវសន្យាថា នឹងប្រគល់ឱ្យដល់ភាគីពាក់ព័ន្ធក្នុងរយៈពេលខ្លីបំផុត ។

**មាត្រា ៤៨៩.–** របៀបផ្សេងទៀតនៃការជូនដំណឹង

ការជូនដំណឹងក៏អាចប្រគល់ឱ្យផងដែរ :

-ដោយក្រឡាបញ្ជី

-តាមផ្លូវរដ្ឋបាល

-ដោយប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ប្រសិនបើជនជាប់ចោទត្រូវឃុំខ្លួនពីបទដទៃផ្សេងទៀត

-តាមរយៈអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ព្រះបរមរាជវាំង



201/240

ក្រឡាបញ្ជី អាជ្ញាធររដ្ឋបាល អាជ្ញាធរពន្ធនាគារ មន្ត្រីនគរបាលជាតិ ឬ អាវុធហត្ថដែលព្រះរាជអាជ្ញាសុំឱ្យជូនដំណឹងពីសេចក្តីសម្រេចរបស់តុលាការ ត្រូវតែគោរពតាមបញ្ជារបស់ព្រះរាជអាជ្ញា ។

កិច្ចនេះត្រូវធ្វើដូចមានចែងនៅមាត្រា ៤៨៦ (ការប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចជូនដល់ភាគីដែលពាក់ព័ន្ធដោយអាជ្ញាសាលា) ដល់មាត្រា ៤៨៨ (ការប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចដល់មេឃុំ ឬ ចៅសង្កាត់) នៃក្រមនេះ ។

**មាត្រា ៤៩០.-** ភាគីដែលពុំមានលំនៅឋាន ឬ ទីសំណាក់ដែលគេស្គាល់

ប្រសិនបើភាគីពាក់ព័ន្ធគ្មានលំនៅឋាន ឬ ទីសំណាក់ទេ ឬ ប្រសិនបើភាគីពាក់ព័ន្ធនេះរស់នៅក្រៅដែនដីជាតិ សេចក្តីសម្រេចរបស់តុលាការក៏អាចជូនដំណឹងដល់សាមីខ្លួនបានដែរ ។ ក្នុងករណីនេះ កាលបរិច្ឆេទនៃសេចក្តីសម្រេចតុលាការត្រូវចាត់ទុកថា ជាកាលបរិច្ឆេទនៃការជូនដំណឹង ។

## មាតិកាទី ៥
## បទប្បញ្ញត្តិរួម
## ជំពូកទោល
## បទប្បញ្ញត្តិរួម

**មាត្រា ៤៩១.-** ផលវិបាកនៃការពុំបានគោរពរយៈពេល

ក្នុងករណីដែលរយៈពេលបញ្ញត្តិដោយមាត្រា ៤៥៧ (រយៈពេលដែលត្រូវគោរពរវាងការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងការបង្គាប់ឱ្យចូលបង្ហាញខ្លួន) និងមាត្រា ៤៦៦ (រយៈពេលដែលត្រូវគោរពរវាងដីកាកោះហៅ និងការបង្គាប់ឱ្យចូលបង្ហាញខ្លួន) នៃក្រមនេះ មិនបានគោរពទេ ត្រូវធ្វើដូចតទៅនេះ :

-ប្រសិនបើជនជាប់ចោទមិនចូលបង្ហាញខ្លួនទេ តុលាការពិនិត្យមោឃភាពនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ ដីកាកោះហៅឱ្យចូលបង្ហាញខ្លួន ។ តុលាការបង្គាប់ឱ្យចេញដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ ដីកាកោះហៅបង្គាប់ឱ្យចូលខ្លួនជាថ្មីម្តងទៀត លើកលែងតែបណ្តឹងអាជ្ញាត្រូវផុតរលត់ ។

-ប្រសិនបើជនជាប់ចោទចូលបង្ហាញខ្លួននៅពេលសវនាការ តុលាការអាចពិនិត្យ

មើលរឿង ប្រសិនបើជនជាប់ចោទយល់ព្រមយ៉ាងជាក់លាក់ឱ្យជំនុំជម្រះភ្លាម ។ ប្រសិនបើជនជាប់ចោទមិនព្រមឱ្យជំនុំជម្រះភ្លាមទេ តុលាការបង្គាប់ឱ្យលើករឿងនេះទៅជំនុំជម្រះនៅពេលសវនាការក្រោយទៀត ។

**មាត្រា ៤៩២.–** មោឃភាពនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងដីកាកោះហៅ

មោឃភាពនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ អាចនឹងប្រកាសបាន កាលណាដីកាកោះហៅនេះមានអានុភាពធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ជនជាប់ចោទតែប៉ុណ្ណោះ ។

មោឃភាពនៃដីកាកោះហៅឱ្យចូលសវនាការដែលប្រគល់ឱ្យជនជាប់ចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី ឬ អ្នកទទួលខុសត្រូវរដ្ឋប្បវេណីអាចនឹងត្រូវប្រកាសបាន កាលណាដីកាកោះហៅនេះមានអានុភាពធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីពាក់ព័ន្ធតែប៉ុណ្ណោះ ។

**មាត្រា ៤៩៣.–** និទ្ទេសដែលត្រូវកត់ត្រានៅលើដីកាកោះបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ ដីកាកោះហៅ

កាលណាដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ ដីកាកោះហៅឱ្យចូលខ្លួន ត្រូវបានប្រគល់ដោយអាជ្ញាសាលា ដោយក្រឡាបញ្ជី តាមផ្លូវរដ្ឋបាល ដោយប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ឬ តាមរយៈអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ ដីកាកោះហៅនោះត្រូវមានចុះនិទ្ទេសដូចតទៅ :

-អត្តសញ្ញាណ និងឋានៈរបស់អ្នកប្រគល់ដីកា

-ហត្ថលេខារបស់អ្នកប្រគល់ដីកា ។

**មាត្រា ៤៩៤.–** និទ្ទេសដែលត្រូវកត់ត្រាលើស្រោមសំបុត្រ

នៅក្នុងករណីដែលមានចែងដោយមាត្រា ៤៦១ (ការប្រគល់ចុងដីកាកោះដោយអាជ្ញាសាលាក្នុងករណីជនជាប់ចោទអវត្តមាន) មាត្រា ៤៦២(ការប្រគល់ចុងដីកាកោះដោយអាជ្ញាសាលាដល់មេឃុំ ឬ ចៅសង្កាត់) មាត្រា ៤៧០ (ការប្រគល់ចុងដីកាដោយអាជ្ញាសាលាក្នុងករណីអវត្តមានរបស់ជនជាប់ចោទ) និងមាត្រា ៤៧១(ការប្រគល់ចុងដីកាកោះហៅដោយអាជ្ញាសាលាដល់មេឃុំ ឬ ចៅសង្កាត់)នៃក្រមនេះ ចុងដីកាត្រូវប្រគល់ ត្រូវដាក់ក្នុងស្រោមសំបុត្របិទជិតដោយមានចុះនិទ្ទេសដូចតទៅ :

-ឈ្មោះ និងអាសយដ្ឋានរបស់សាមីខ្លួនដែលត្រូវទទួលដីកានៅផ្នែកខាងមុខស្រោមសំបុត្រ

-ត្រារបស់អ្នកប្រគល់ដីកានៅផ្នែកខាងក្រោយស្រោមសំបុត្រ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

បទប្បញ្ញត្តិនេះត្រូវយកមកអនុវត្តនៅក្នុងករណីឱ្យដឹណឹងអំពីសេចក្តីសម្រេចរបស់តុលាការ ។

**មាត្រា ៤៩៥.–** ហត្ថលេខា និងស្នាមម្រាមដៃ

នៅក្នុងគ្រប់ករណីដែលតម្រូវឱ្យមានចុះហត្ថលេខារបស់បុគ្គលណាម្នាក់ អ្នកទទួលនៅលើលិខិតណាមួយ ហត្ថលេខានេះអាចត្រូវបានជំនួសដោយការផ្តិតម្រាមដៃ ប្រសិនបើបុគ្គលនោះមិនចេះចុះហត្ថលេខាទេ ។

## គន្ថីទី ៨
## នីតិវិធីប្រតិបត្តិ
## មាតិកាទី ១
## បទប្បញ្ញត្តិទូទៅ
## ជំពូកតោល
## បទប្បញ្ញត្តិទូទៅ

**មាត្រា ៤៩៦.–** ការអនុវត្តទោស និងទណ្ឌកម្មរដ្ឋប្បវេណី

ការអនុវត្តទោស និងការបង្ខំដល់រូបកាយត្រូវធ្វើតាមគំនិតផ្តើមរបស់អយ្យការ ។

ការអនុវត្តទណ្ឌកម្មរដ្ឋប្បវេណីត្រូវតែធ្វើតាមគំនិតផ្តើមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

**មាត្រា ៤៩៧.–** សេចក្តីសម្រេចស្ថាពរ

អយ្យការធ្វើការអនុវត្តទោស នៅពេលដែលសេចក្តីសម្រេចរបស់តុលាការបានក្លាយទៅជាស្ថាពរ ។

រយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា មិនមែនជាឧបសគ្គដល់ការអនុវត្តទោសទេ ។

**មាត្រា ៤៩៨.–** ការប្រមូលប្រាក់ពិន័យ និងប្រាក់ពន្ធនៃនីតិវិធី

ការប្រមូលប្រាក់ពិន័យ និងប្រាក់ពន្ធនៃនីតិវិធីត្រូវធ្វើដោយភ្នាក់ងាររតនាគារ នៅក្រោមនីតិវិធីរបស់អយ្យការ ។ ប្រាក់ពិន័យ និងប្រាក់ពន្ធនៃនីតិវិធីដែលប្រមូលបាននេះ ត្រូវបង់ចូលថវិការដ្ឋ ។



204/240

គ្រប់សេចក្ដីសម្រេចផ្ដន្ទាទោសជាស្ថាពរ មានតម្លៃជាបញ្ជាឱ្យបង់ប្រាក់ពិន័យ និងប្រាក់ពន្ធនៃនីតិវិធី ។

**មាត្រា ៤៩៩.-** ការសុំកងកម្លាំងសាធារណៈ

ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញា អាចសុំកងកម្លាំងសាធារណៈ ដើម្បីធានាការប់រងការអនុវត្តទោស ។

**មាត្រា ៥០០.-** ការលំបាកទាក់ទងនឹងការអនុវត្តទោស

ការលំបាកទាំងឡាយដែលទាក់ទងនឹងការអនុវត្តទោស ត្រូវតែលើកជូនតុលាការជាន់ដំបូង ឬ តុលាការជាន់ខ្ពស់ ដែលបានសម្រេចផ្ដន្ទាទោសនោះ ដោះស្រាយ ។

តុលាការទទួលបណ្ដឹង តាមពាក្យប្ដឹងរបស់អយ្យការ ឬ របស់ភាគីពាក់ព័ន្ធ ។ តុលាការនេះសម្រេចនៅពេលសវនាការសាធារណៈ ក្រោយពីបានស្ដាប់អយ្យការ ភាគីពាក់ព័ន្ធ និងជាយថាហេតុ មេធាវីរបស់ភាគីនេះ ។

ការអនុវត្តទោសអាចត្រូវបានព្យួរដោយតុលាការ ។

**មាត្រា ៥០១.-** ពាក្យសុំឱ្យស្រូបទោសបញ្ចូលគ្នា

ពាក្យសុំឱ្យស្រូបទោសបញ្ចូលគ្នា ត្រូវលើកនៅមុខតុលាការដែលបានសម្រេចចុងក្រោយគេ ។

តុលាការនេះទទួលបណ្ដឹង តាមពាក្យប្ដឹងរបស់អយ្យការ ឬ របស់ភាគីពាក់ព័ន្ធ ។ តុលាការសម្រេចក្នុងពេលសវនាការសាធារណៈ ក្រោយពីបានស្ដាប់អយ្យការ ភាគីពាក់ព័ន្ធ និងជាយថាហេតុ មេធាវីរបស់ភាគីនេះ ។

## មាតិកាទី ២

## ការប្រតិបត្តិការឃុំខ្លួនបណ្ដោះអាសន្ន និងទោសដកហូតសេរីភាព

### ជំពូកទី ១

### វិធានទាក់ទងនឹងការឃុំខ្លួន

**មាត្រា ៥០២.-** ការគណនាថិរវេលានៃការដាក់ពន្ធនាគារ

ទោសដាក់ពន្ធនាគារក្នុង ១ (មួយ) ថ្ងៃ មានថិរវេលា ២៤ (ម្ភៃបួន) ម៉ោង ។

ទោសដាក់ពន្ធនាគារ ក្នុង ១ (មួយ) ខែ មានថិរវេលា ៣០ (សាមសិប) ថ្ងៃ ។

ទោសដាក់ពន្ធនាគារលើសពី ១ (មួយ) ខែ ត្រូវគិតតាមលេខរៀងនៃថ្ងៃក្នុងខែទី ១ (មួយ) ទៅលេខរៀងនៃថ្ងៃក្នុងខែមួយទៀត ។

ទណ្ឌិតដែលបានអនុវត្តទោសរបស់ខ្លួនរួចហើយ ត្រូវដោះលែងនៅក្នុងចន្លោះពីម៉ោង ៦ (ប្រាំមួយ) ព្រឹក ដល់ម៉ោង ១៨ (ដប់ប្រាំបី) ល្ងាច ។

**មាត្រា ៥០៣.-** ការគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន

ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ត្រូវបានគិតបញ្ចូលទាំងស្រុងទៅក្នុងថិរវេលានៃទោស ដែលបានប្រកាស ឬ ជាយថាហេតុនៃថិរវេលាសរុបនៃទោសដែលត្រូវទទួលរង បន្ទាប់ពីការស្រូបទោសបញ្ចូលគ្នា ។

**មាត្រា ៥០៤.-** ការរៀបចំពន្ធនាគារ

ការរៀបចំ និងរបបផ្ទៃក្នុងនៃពន្ធនាគារ និងមណ្ឌលឃុំខ្លួន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងដែលគ្រប់គ្រងពន្ធនាគារ ។

ប្រកាសនេះកំណត់ផងដែរ អំពីលក្ខខណ្ឌនៃការបែងចែកទណ្ឌិតនៅតាមពន្ធនាគារ និងមណ្ឌលឃុំខ្លួននានា អំពីបែបបទអនុវត្តទោសដកហូតសេរីភាព និងអំពីរបបឃុំខ្លួន ។

**មាត្រា ៥០៥.-** បញ្ជីជនជាប់ឃុំ

គ្រប់ពន្ធនាគារ និងមណ្ឌលឃុំខ្លួនទាំងអស់ ត្រូវមានបញ្ជីមួយដែលចុះនិទ្ទេសអំពីអត្តសញ្ញាណបុគ្គលឃុំខ្លួន កាលបរិច្ឆេទឃុំខ្លួន និងកាលបរិច្ឆេទដោះលែង ។ បញ្ជីនេះត្រូវបានត្រួតពិនិត្យជារឿយៗដោយអយ្យការ ។ ទំព័រនីមួយៗ ត្រូវតែចុះទិដ្ឋាការដោយអយ្យការ ។

គ្រប់ភ្នាក់ងារនៃរដ្ឋបាលពន្ធនាគារ និងមណ្ឌលឃុំខ្លួន ត្រូវតែជូនបញ្ជីទៅចៅក្រមពិនិត្យមើលតាមការស្នើសុំ ព្រមទាំងបង្ហាញដល់មន្ត្រីនគរបាលយុត្តិធម៌ដែលបំពេញភារកិច្ចតាមការប្រគល់អំណាចពីអាជ្ញាធរតុលាការ ។

**មាត្រា ៥០៦.-** លិខិតឃុំខ្លួន

គ្មានភ្នាក់ងាររដ្ឋបាលពន្ធនាគារណា អាចទទួល និងឃុំខ្លួនបុគ្គលណាម្នាក់ដោយគ្មានលិខិតចេញដោយអាជ្ញាធរតុលាការបានឡើយ ។

ភ្នាក់ងាររដ្ឋបាលពន្ធនាគារណាដែលបានទទួល និងឃុំខ្លួនបុគ្គលណាម្នាក់ដោយគ្មានលិខិតចេញដោយអាជ្ញាធរតុលាការទេនោះ ត្រូវជាប់ពិរុទ្ធពីបទបង្ខាំងមនុស្សដោយខុសច្បាប់ ។



ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
206/240

**មាត្រា ៥០៧.–** ការឃុំខ្លួនដោយខុសច្បាប់

គ្រប់ចៅក្រមទាំងអស់ដែលបានទទួលបណ្ដឹងស្ដីពីការឃុំខ្លួនបុគ្គលណាម្នាក់ដោយខុសច្បាប់ ត្រូវធ្វើការផ្ទៀងផ្ទាត់ជាចាំបាច់ភ្លាម ។

**មាត្រា ៥០៨.–** ការបង្ហាញខ្លួនជនជាប់ឃុំតាមការស្នើសុំ

គ្រប់ភ្នាក់ងាររដ្ឋបាលពន្ធនាគារ ត្រូវតែបង្ហាញខ្លួនជនជាប់ឃុំដល់ចៅក្រមតាមការស្នើសុំ ព្រមទាំងដល់មន្ត្រីនគរបាលយុត្តិធម៌ដែលបំពេញភារកិច្ច តាមការប្រគល់អំណាចពីអាជ្ញាធរតុលាការ ។

**មាត្រា ៥០៩.–** អធិការកិច្ចពន្ធនាគារ

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញា ប្រធានសភាស៊ើបសួរ និងចៅក្រមស៊ើបសួរត្រូវធ្វើអធិការកិច្ចលើពន្ធនាគារជាប្រចាំ ។

**មាត្រា ៥១០.–** ការសន្ទនារបស់ជនជាប់ឃុំជាមួយនឹងមេធាវីរបស់ខ្លួន

ជនជាប់ឃុំត្រូវតែមានសិទ្ធិសន្ទនាជាសម្ងាត់ជាមួយនឹងមេធាវីរបស់ខ្លួន ។

**មាត្រា ៥១១.–** ការផ្ដល់ដំណឹងដល់ព្រះរាជអាជ្ញាក្នុងករណីមានឧប្បត្តិហេតុធ្ងន់ធ្ងរ

គ្រប់ឧប្បត្តិហេតុធ្ងន់ធ្ងរនៅក្នុងពន្ធនាគារ ក្នុងមណ្ឌលឃុំខ្លួន ត្រូវតែជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា ។

ក្នុងករណីដែលអ្នកទោសរត់ចេញពីពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន នោះព្រះរាជអាជ្ញាចេញបញ្ជាស្វែងរកចាប់ខ្លួន និងចាត់វិធានការជាបន្ទាន់ ដើម្បីអនុវត្តបញ្ជាស្វែងរកចាប់ខ្លួន ដោយអនុលោមតាមបញ្ញត្តិដែលចែងក្នុងមាត្រា ១៩៦ (ដីកាបង្គាប់ឱ្យចាប់ខ្លួន) និងមាត្រាបន្តបន្ទាប់នៃក្រមនេះ ។

## ជំពូកទី ២

## ការដោះលែងដោយមានលក្ខខណ្ឌ

**មាត្រា ៥១២.–** លក្ខខណ្ឌទាក់ទងនឹងគំនិតមារយាទ

គ្រប់ទណ្ឌិតដែលត្រូវទទួលទោសពន្ធនាគារមួយ ឬ ច្រើន អាចត្រូវបានដោះលែងដោយមានលក្ខខណ្ឌ ប្រសិនបើទណ្ឌិតនេះបានបង្ហាញឱ្យឃើញថា ខ្លួនមានគំនិតមារយាទល្អក្នុងរយៈពេលជាប់ឃុំ និងមានសម្បទាដែលអាចបញ្ចូលខ្លួនទៅក្នុងសង្គមវិញបាន ។

ROYAUME DU CAMBODGE MINISTRE DU PALAIS ROYAL



207/240

**មាត្រា ៥១៣.-** លក្ខខណ្ឌទាក់ទងនឹងថិរវេលានៃទោសដែលត្រូវបានទទួលរួចរាល់ហើយ

ការដោះលែងដោយមានលក្ខខណ្ឌ អាចត្រូវផ្តល់ឱ្យដល់ទណ្ឌិត ដែលទទួលរងទោសជាប់ពន្ធនាគារ :

-ចំនួនពាក់កណ្តាលនៃទោស ប្រសិនបើទោសនោះតិចជាង ឬ ស្មើ ១ (មួយ) ឆ្នាំ

-ចំនួនពីរភាគបីនៃទោស ក្នុងករណីផ្សេងទៀត ។

ទណ្ឌិតដែលត្រូវជាប់ពន្ធនាគារអស់មួយជីវិត អាចទទួលការដោះលែងដោយមានលក្ខខណ្ឌ ប្រសិនបើទណ្ឌិតបានទទួលទោសជាប់ពន្ធនាគារយ៉ាងតិចបំផុត ២០ (ម្ភៃ) ឆ្នាំ រួចមកហើយ ។

**មាត្រា ៥១៤.-** អាជ្ញាធរមានសមត្ថកិច្ចសម្រាប់ផ្តល់ការដោះលែងដោយមានលក្ខខណ្ឌ

ការដោះលែងដោយមានលក្ខខណ្ឌ ត្រូវផ្តល់ឱ្យដោយប្រធានតុលាការជាន់ដំបូងនៃទីកន្លែងឃុំខ្លួន ។ ប្រធានតុលាការនេះ សម្រេចក្រោយពីបានទទួលយោបល់ពីគណៈកម្មការជាតិដែលត្រូវប្រជុំនៅក្រសួងយុត្តិធម៌ ។

គណៈកម្មការជាតិរួមមាន :

-សមាជិក ២ (ពីរ) រូប ចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែល ១ (មួយ) រូប ជាប្រធាន

-ប្រធានពន្ធនាគារ ឬ តំណាងជាសមាជិក ។

**មាត្រា ៥១៥.-** យោបល់របស់គណៈកម្មការជាតិ

ក្រោយពីបានទទួលពាក្យសុំដោះលែងដោយមានលក្ខខណ្ឌ ប្រធានតុលាការជាន់ដំបូង បញ្ជូនទៅគណៈកម្មការជាតិនូវ :

-ពាក្យសុំ

-សាលក្រម ឬ សាលដីកាផ្តន្ទាទោស

-ជាយថាហេតុសាលក្រម និងសាលដីកាទាំងឡាយ ប្រសិនបើទណ្ឌិតទទួលទោសច្រើន

-ព្រឹត្តិបត្រលេខ ១ នៃបញ្ជីថ្កោលទោស

-យោបល់ព្រះរាជអាជ្ញា

-គ្រប់លិខិតទាំងអស់ដែលមានប្រយោជន៍ ។

គណៈកម្មការជាតិបញ្ចេញយោបល់របស់ខ្លួននៅក្នុងរយៈពេលយ៉ាងខ្លីបំផុត ។ យោបល់នេះធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុត្រូវផ្ញើជូនទៅប្រធានតុលាការជាន់ដំបូងភ្លាម ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង



205/240

**មាត្រា ៥១៦.-** សេចក្តីសម្រេចទាក់ទងនឹងការដោះលែងដោយមានលក្ខខណ្ឌ

ប្រធានតុលាការជាន់ដំបូងមិនត្រូវជាប់ជំពាក់នឹងយោបល់របស់គណៈកម្មការជាតិទេ ។

ប្រធានតុលាការសម្រេចតាមដីកាដោយមានសំអាងហេតុ ។

សេចក្តីសម្រេចរបស់ប្រធានតុលាការនេះ អាចត្រូវតវ៉ាទៅប្រធានសាលាឧទ្ធរណ៍បានក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ។ បណ្តឹងតវ៉ានេះ អាចធ្វើបានដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬ ព្រះរាជអាជ្ញានៃតុលាការសាមីតែប៉ុណ្ណោះ ។

កាលណាប្រធានតុលាការជាន់ដំបូង បង្គាប់ឱ្យដោះលែងដោយមានលក្ខខណ្ឌ សេចក្តីសម្រេចនេះគ្មានអានុភាពអនុវត្តទេ នៅក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ដែលចែងក្នុងកថាខណ្ឌទី ៣ នៃមាត្រានេះ ។ ប្រសិនបើមានការតវ៉ាសេចក្តីសម្រេចនេះគ្មានអានុភាពអនុវត្តទេ រហូតដល់មានដីការបស់ប្រធានសាលាឧទ្ធរណ៍ ។

ប្រធានសាលាឧទ្ធរណ៍សម្រេចតាមដីកាដោយមានសំអាងហេតុ និងមិនអាចតវ៉ាបានឡើយ ។

**មាត្រា ៥១៧.-** បែបបទនៃការអនុវត្ត និងលក្ខខណ្ឌនៃការដោះលែងដោយមានលក្ខខណ្ឌ

សេចក្តីសម្រេចឱ្យដោះលែងដោយមានលក្ខខណ្ឌ ត្រូវកំណត់បែបបទនៃការអនុវត្ត និងលក្ខខណ្ឌនៃការដោះលែងទណ្ឌិត ។

សេចក្តីសម្រេចនេះកំណត់រយៈពេលសាកល្បង ដែលមិនអាចលើសពីថិរវេលានៃទោសដែលនៅសល់មិនទាន់បានទទួលរងឡើយ ។

**មាត្រា ៥១៨.-** ការដកហូតសេចក្តីសម្រេច

ក្នុងករណីមានការផ្តន្ទាទោសជាថ្មី ឬ ក្នុងករណីមិនគោរពលក្ខខណ្ឌដែលកំណត់ដោយដីកាទេ ប្រធានតុលាការជាន់ដំបូងអាចដកហូតសេចក្តីសម្រេចរបស់ខ្លួនវិញបាន ។

**មាត្រា ៥១៩.-** ការចាប់ខ្លួនទណ្ឌិតដែលត្រូវបានដោះលែង

ក្នុងករណីបន្ទាន់ ព្រះរាជអាជ្ញានៃតុលាការសាមី អាចបង្គាប់ឱ្យចាប់ខ្លួនទណ្ឌិតដែលបានដោះលែងនោះបាន ។ ព្រះរាជអាជ្ញាត្រូវជូនដំណឹងដល់ប្រធានតុលាការជាន់ដំបូងភ្លាម ។

**មាត្រា ៥២០.-** ការដកហូតការដោះលែងដោយមានលក្ខខណ្ឌ

ក្នុងករណីដកហូតការដោះលែងដោយមានលក្ខខណ្ឌ ទណ្ឌិតត្រូវទទួលទោសរបស់ខ្លួនដែលនៅសេសសល់ ។

រយៈពេលសេសសល់ ត្រូវគិតចាប់ពីពេលដែលទណ្ឌិតបានទទួលសេចក្តីសម្រេចឱ្យដោះលែង ដោយមានលក្ខខណ្ឌ ។

ប្រសិនបើទណ្ឌិតត្រូវបានចាប់ខ្លួនដោយអនុវត្តតាមមាត្រា ៥១៩ (ការចាប់ខ្លួនទណ្ឌិតដែលត្រូវបានដោះលែង) នៃក្រមនេះ រយៈពេលឃុំខ្លួនរហូតមកទល់នឹងសេចក្តីសម្រេចដកហូតការដោះលែង ដោយមានលក្ខខណ្ឌនេះ ត្រូវយកមកគិតក្នុងថិរវេលានៃទោសដែលនៅសេសសល់ ។

**មាត្រា ៥២១.–** ផលវិបាកនៃការមិនដកហូត

ប្រសិនបើការដោះលែងដោយមានលក្ខខណ្ឌ មិនត្រូវបានដកហូតក្នុងរយៈពេលសាកល្បងទេ លុះផុតរយៈពេលសាកល្បងដែលកំណត់តាមមាត្រា ៥១៧ (បែបបទនៃការអនុវត្ត និងលក្ខខណ្ឌនៃការដោះលែងដោយមានលក្ខខណ្ឌ) នៃក្រមនេះ ការដោះលែងក្លាយទៅជាស្ថាពរ ។

ក្នុងករណីនេះទោសត្រូវចាត់ទុកថាបានទទួលតាំងពីថ្ងៃដោះលែងដោយមានលក្ខខណ្ឌមកម្ល៉េះ ។

**មាត្រា ៥២២.–** ប្រកាសរបស់ក្រសួងយុត្តិធម៌

បែបបទនៃការឃ្លាំមើលតាមដាន ការត្រួតពិនិត្យ និងការបញ្ចូលទៅក្នុងសង្គមវិញនៃទណ្ឌិតដែលដោះលែងដោយមានលក្ខខណ្ឌត្រូវកំណត់ដោយប្រកាសរបស់ក្រសួងយុត្តិធម៌ ។ ប្រកាសនេះ អាចប្រគល់ឱ្យស្ថាប័នសាធារណៈ ឬ ឯកជន នូវការយកចិត្តទុកដាក់ធានារ៉ាប់រងលើការបញ្ចូលទណ្ឌិតទៅក្នុងសង្គមវិញ ។

## មាតិកាទី ៣

## ការបង្ខំដល់រូបកាយ

## ជំពូកទោល

## ការបង្ខំដល់រូបកាយ

**មាត្រា ៥២៣.–** ករណីអនុវត្តការបង្ខំដល់រូបកាយ

ការបង្ខំដល់រូបកាយត្រូវអនុវត្តលើបុគ្គលដែលត្រូវផ្តន្ទាទោសដោយតុលាការព្រហ្មទណ្ឌហើយដែលមិនបង់ :

-ប្រាក់ពិន័យ

-ប្រាក់ពន្ធនៃនីតិវិធី



ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL
210/240

-ប្រាក់សំណង និងជម្ងឺចិត្តដែលត្រូវបង់ឱ្យដើមបណ្តឹងរដ្ឋប្បវេណី ។

**មាត្រា ៥២៤.–** ការអនុវត្តដោយពេញលក្ខណៈច្បាប់

ការបង្ខិតលំរូបកាយត្រូវអនុវត្តដោយពេញលក្ខណៈច្បាប់ ។ ការបង្ខិតលំរូបកាយមិនចាំបាច់ប្រកាសដោយតុលាការទេ ។

**មាត្រា ៥២៥.–** ការបង្ខិតលំរូបកាយក្នុងករណីមិនបង់ប្រាក់ពិន័យ ឬ ប្រាក់ពន្ធនៃនីតិវិធី

ប្រសិនបើទណ្ឌិតមិនបង់ប្រាក់ពិន័យ ឬ ប្រាក់ពន្ធនៃនីតិវិធីទេ អង្គភាពរតនាគារជូនដំណឹងដល់ព្រះរាជអាជ្ញានៃតុលាការអមសាលាដំបូង ។

ព្រះរាជអាជ្ញាកំណត់រយៈពេលចុងក្រោយដល់ទណ្ឌិត ដើម្បីបង់ប្រាក់នោះ ហើយឱ្យដំណឹងថា ប្រសិនបើមិនបង់ទេនោះ សាមីខ្លួនអាចត្រូវបង្ខិតលំរូបកាយ ។ រយៈពេលនេះមិនអាចតិចជាង ១០ (ដប់) ថ្ងៃ ទេ ។

ការឱ្យដំណឹងត្រូវធ្វើ :

-ដោយផ្ទាល់មាត់ ឬ

-តាមផ្លូវរដ្ឋបាល ឬ

-តាមរយៈអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ ។

ត្រូវតែមានធ្វើកំណត់ហេតុស្តីពីការឱ្យដំណឹងនេះ ។ កំណត់ហេតុនេះត្រូវចុះហត្ថលេខាដោយទណ្ឌិត ។ ប្រសិនបើទណ្ឌិតមិនចេះចុះហត្ថលេខាទេ ទណ្ឌិតត្រូវផ្តិតស្រាមដៃ ។

**មាត្រា ៥២៦.–** បញ្ជាឱ្យបង្ខិត និងឱ្យឃុំខ្លួន

លុះផុតរយៈពេលកំណត់ ប្រសិនបើទណ្ឌិតមិនបានបង់ប្រាក់នោះទេ ព្រះរាជអាជ្ញាចេញបញ្ជាឱ្យបង្ខិត និងឱ្យឃុំខ្លួន ។ ព្រះរាជអាជ្ញាអាចបង្អង់សេចក្តីសម្រេចនេះបាន ដោយមូលហេតុមនុស្សធម៌ជាអាទិ៍ ដូចជាស្ថានភាពនៃសុខភាពរបស់ទណ្ឌិត ។

បញ្ជាឱ្យបង្ខិតនិងឱ្យឃុំខ្លួនមានចុះនិទ្ទេសដូចតទៅ :

-អត្តសញ្ញាណនៃទណ្ឌិត

-ប្រភេទ និងការយោងនៃទណ្ឌកម្ម

-ការយោងនៃដីកាឱ្យដំណឹងដែលមានចែងនៅក្នុងមាត្រា ៥២៥ (ការបង្ខិតលំរូបកាយ ក្នុងករណីមិនបង់ប្រាក់ពិន័យ ឬ ប្រាក់ពន្ធនៃនីតិវិធី) នៃក្រមនេះ

-ចំនួនទឹកប្រាក់ដែលមិនបានបង់



211/240

-ថិរវេលានៃការបង្ខំដល់រូបកាយ ។

បញ្ជានេះត្រូវចុះហត្ថលេខាដោយព្រះរាជអាជ្ញា និងមានបោះត្រាផង ។

ព្រះរាជអាជ្ញាសុំឱ្យកម្លាំងសាធារណៈចាប់ និងឃុំខ្លួនទណ្ឌិត ។

**មាត្រា ៥២៧.-** ការតវ៉ានឹងបញ្ជាឱ្យបង្ខំ និងឱ្យឃុំខ្លួន

ប្រសិនបើពេលចាប់ខ្លួន ឃុំខ្លួន ឬ ក្រោយមកទណ្ឌិតតវ៉ាអំពីសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា ទណ្ឌិតត្រូវបានគេនាំខ្លួនទៅជូនប្រធានតុលាការ ។

ប្រធានតុលាការពិនិត្យមើលនីត្យានុកូលភាពនៃបញ្ជាឱ្យបង្ខំ និងឱ្យឃុំខ្លួន ។ ក្នុងករណីមានការបំពានច្បាប់ ប្រធានតុលាការលុបចោលបញ្ជាឱ្យបង្ខំ និងឱ្យឃុំខ្លួននេះ ។

ប្រធានតុលាការសម្រេចតាមដីកាដោយមានសំអាងហេតុ ។

សេចក្តីសម្រេចរបស់ប្រធានតុលាការជាន់ដំបូង អាចត្រូវតវ៉ាទៅប្រធានសាលាឧទ្ធរណ៍បានក្នុងរយៈពេល ២ (ពីរ) ថ្ងៃ ។ បណ្តឹងតវ៉ានេះអាចធ្វើបានដោយអគ្គព្រះរាជអាជ្ញា ព្រះរាជអាជ្ញារមសាលាដំបូង ឬ ទណ្ឌិត ។

កាលណាប្រធានតុលាការជាន់ដំបូងលុបចោលបញ្ជាឱ្យបង្ខំ និងឱ្យឃុំខ្លួន សេចក្តីសម្រេចនេះ គ្មានអានុភាពអនុវត្តទេ ក្នុងរយៈពេល ២ (ពីរ) ថ្ងៃ ដូចមានចែងនៅកថាខណ្ឌទី ៤ នៃមាត្រានេះ ។ ប្រសិនបើមានការតវ៉ា សេចក្តីសម្រេចនេះគ្មានអានុភាពអនុវត្ត រហូតដល់មានដីការបស់ប្រធានសាលាឧទ្ធរណ៍ ។

ប្រធានសាលាឧទ្ធរណ៍សម្រេចតាមដីកាមានសំអាងហេតុ និងមិនអាចតវ៉ាបាន ។

**មាត្រា ៥២៨.-** ការដោះលែងឱ្យមានសេរីភាពវិញ

ក្នុងករណីលុបចោលបញ្ជាឱ្យបង្ខំ និងឱ្យឃុំខ្លួននោះ ទណ្ឌិតត្រូវដោះលែងឱ្យមានសេរីភាពវិញ ។

**មាត្រា ៥២៩.-** លក្ខខណ្ឌដូចគ្នាទៅនឹងការដាក់ពន្ធនាគារ

ការបង្ខំដល់រូបកាយមានលក្ខខណ្ឌដូចគ្នានឹងការជាប់ទោសពន្ធនាគារដែរ ។

**មាត្រា ៥៣០.-** ថិរវេលានៃការបង្ខំដល់រូបកាយ

ថិរវេលានៃការបង្ខំដល់រូបកាយត្រូវកំណត់ដូចតទៅ :

-១០ (ដប់) ថ្ងៃ កាលណាទឹកប្រាក់ដែលមិនបង់នោះមានចំនួនមិនលើសពី ២៥០.០០០ (ពីរសែនប្រាំម៉ឺន) រៀល ។



ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

212/240

-២០ (ម្ភៃ) ថ្ងៃ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ២៥០.០០១ (ពីរសែនប្រាំម៉ឺនមួយ) រៀល ដល់ ៥០០.០០០ (ប្រាំសែន) រៀល ។

-១ (មួយ) ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ៥០០.០០១ (ប្រាំសែនមួយ) រៀល ដល់ ១.០០០.០០០ (មួយលាន) រៀល ។

-២ (ពីរ) ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ១.០០០.០០១ (មួយលានមួយ) រៀល ដល់ ២.៥០០.០០០ (ពីរលានប្រាំសែន) រៀល ។

-៣ (បី) ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ២.៥០០.០០១ (ពីរលានប្រាំសែនមួយ) រៀល ដល់ ៥.០០០.០០០ (ប្រាំលាន) រៀល ។

-៦ (ប្រាំមួយ) ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ៥.០០០.០០១ (ប្រាំលានមួយ) រៀល ដល់ ១០.០០០.០០០ (ដប់លាន) រៀល ។

-១ (មួយ) ឆ្នាំ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ១០.០០០.០០១ (ដប់លានមួយ) រៀល ដល់ ២០.៥០០.០០០ (ម្ភៃលានប្រាំសែន) រៀល ។

-១៨ (ដប់ប្រាំបី) ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ២០.៥០០.០០១ (ម្ភៃលានប្រាំសែនមួយ) រៀល ដល់ ៥០.០០០.០០០ (ហាសិបលាន) រៀល ។

-២ (ពីរ) ឆ្នាំ ប្រសិនបើទឹកប្រាក់នេះមានចំនួនលើសពី ៥០.០០០.០០០ (ហាសិបលាន) រៀល ។

កាលណាការបង្ខំដល់រូបកាយធានាការប្រមូលឥណទេយ្យច្រើននោះ ថិរវេលានៃការបង្ខំនេះ ត្រូវកំណត់ដោយគិតគូរតាមចំនួនសរុបនៃទណ្ឌកម្ម ។

**មាត្រា ៥៣១.-** ការរួចខ្លួនពីការបង្ខំដល់រូបកាយ

ការបង្ខំដល់រូបកាយ មិនអាចធ្វើទៅលើទណ្ឌិតជាអនីតិជននៅពេលប្រព្រឹត្តបទល្មើសទៅលើស្ត្រីដែលមានអាយុចាប់ពី ៦៥ (ហុកសិបប្រាំ) ឆ្នាំ ឡើងទៅ និងទៅលើបុរសអាយុចាប់ពី ៧០ (ចិតសិប) ឆ្នាំ ឡើងទៅបានឡើយ ។

ការបង្ខំដល់រូបកាយមិនអាចធ្វើបានព្រមជាមួយគ្នាទៅលើប្ដី និងប្រពន្ធបានទេ ទោះបីជាការបង្ខំនេះធ្វើឡើង ដើម្បីប្រមូលធនទណ្ឌផ្សេងគ្នាក៏ដោយ ។

**មាត្រា ៥៣២.-** ភាពនៅតែមិនរួចពីបំណុលដដែល

ទណ្ឌិតដែលបានទទួលការបង្ខិតបង្ខំរូបកាយរួចហើយនោះ នៅតែជំពាក់ចំនួនទឹកប្រាក់ដែលត្រូវបង់ដដែល ។ ប៉ុន្តែ ទណ្ឌិតនេះមិនត្រូវទទួលរងការបង្ខិតបង្ខំរូបកាយចំពោះបំណុលដដែលនេះទៀតទេ ។

**មាត្រា ៥៣៣.-** ការបង្ខំដល់រូបកាយតាមពាក្យប្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី

កាលណាដើមបណ្តឹងរដ្ឋប្បវេណីមិនបានទទួលប្រាក់សំណង និងជម្ងឺចិត្តពីទណ្ឌិត ឬ ពីអ្នកទទួលខុសត្រូវរដ្ឋប្បវេណីទេ ដើមបណ្តឹងរដ្ឋប្បវេណី អាចសុំដល់ព្រះរាជអាជ្ញាឱ្យធ្វើការបង្ខំដល់រូបកាយបាន ។

ការបង្ខំដល់រូបកាយដើម្បីទារសំណង និងជម្ងឺចិត្ត អាចអនុវត្តបានតែនៅលើទណ្ឌិតប៉ុណ្ណោះ ។

ដើមបណ្តឹងរដ្ឋប្បវេណីត្រូវផ្តល់ភស្តុតាងថា ខ្លួនបានប្រើអស់មធ្យោបាយអនុវត្តដែលមានចែងក្នុងច្បាប់ដូចជាការរឹបអូសចលនវត្ថុ ឬ អចលនវត្ថុជាដើម ។ ព្រះរាជអាជ្ញាអាចហៅដើមបណ្តឹងរដ្ឋប្បវេណីឱ្យធ្វើនីតិវិធីថ្មី ដើម្បីសាកល្បងទារប្រាក់សំណង និងជម្ងឺចិត្តនេះ ។

ប្រសិនបើទណ្ឌិតមិនព្រមបង់ ការបង្ខំដល់រូបកាយត្រូវយកមកអនុវត្តនៅក្នុងលក្ខខណ្ឌដែលមានចែងនៅមាត្រា ៥២៣ (ការបង្ខំដល់រូបកាយក្នុងករណីមិនបង់ប្រាក់ពិន័យ ឬ ប្រាក់ពន្ធនៃនីតិវិធី) ដល់មាត្រា ៥៣២ (ភាពនៅតែមិនរួចពីបំណុលដដែល) នៃក្រមនេះ ។ ក្នុងករណីមានការប្រជែងគ្នារវាងប្រាក់ពិន័យ ប្រាក់ពន្ធនៃនីតិវិធី និងប្រាក់សំណង និងជម្ងឺចិត្ត នោះប្រាក់សំណង និងជម្ងឺចិត្ត ត្រូវមានអាទិភាពទទួលសងមុនគេ ។

## មាតិកាទី ៤

## ការផ្តល់ និងការមាននីតិសម្បទាឡើងវិញ

## ជំពូកទី ១

## ការផ្តល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការ

**មាត្រា ៥៣៤.-** សាលាជម្រះក្តីដែលមានសមត្ថកិច្ចប្រកាសការផ្តល់ឱ្យមាននីតិសម្បទាឡើងវិញ

ការផ្តល់ឱ្យមាននីតិសម្បទាឡើងវិញតាមផ្លូវតុលាការ អាចត្រូវបានផ្តល់ឱ្យ ឬ មិនព្រមផ្តល់ឱ្យដោយសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ដែលមានការប្រកាសផ្តន្ទាទោសដោយតុលាការនៅក្នុងសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍នេះ ។

**មាត្រា ៥៣៥.–** លក្ខខណ្ឌលើរយៈពេលទាក់ទងនឹងពាក្យសុំឱ្យមានការផ្តល់នីតិសម្បទាឡើងវិញ

ពាក្យសុំឱ្យមាននីតិសម្បទាឡើងវិញ អាចនឹងដាក់ជូនសភាព្រហ្មទណ្ឌពិនិត្យបាន លុះត្រាតែផុតរយៈពេលដូចតទៅ :

-៥ (ប្រាំ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ

-៣ (បី) ឆ្នាំ ចំពោះបទមជ្ឈិម

-១ (មួយ) ឆ្នាំ ចំពោះបទលហុ ។

រយៈពេលនេះចាប់ផ្តើមគិត :

-ពីការអនុវត្តទោសរួច

-ពីការអនុវត្តការបង្ខំដល់រូបកាយរួច នៅក្នុងករណីដែលមានចែងនៅក្នុងកថាខណ្ឌទី ២ មាត្រា ៥៣៦ (ការផ្តល់ភស្តុតាងចាំបាច់) នៃក្រមនេះ ។

**មាត្រា ៥៣៦.–** ការផ្តល់ភស្តុតាងចាំបាច់

ទណ្ឌិតត្រូវជូនភស្តុតាងដែលបញ្ជាក់ថា ខ្លួនបានបង់ប្រាក់ពិន័យ ប្រាក់ពន្ធនៃនីតិវិធី និងប្រាក់សំណង និងជម្ងឺចិត្តរួចហើយ ។ ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីបានបោះបង់ចោលមិនទារប្រាក់សំណង និងជម្ងឺចិត្តទេ ទណ្ឌិតត្រូវផ្តល់ការបញ្ជាក់អំពីការបោះបង់នេះ លើកលែងតែរកដើមបណ្តឹងរដ្ឋប្បវេណីមិនឃើញ ។

ប្រសិនបើទណ្ឌិតត្រូវបានបង្ខំដល់រូបកាយ ការមិនបង់ប្រាក់ពិន័យ ប្រាក់ពន្ធនៃនីតិវិធី ឬប្រាក់សំណង និងជម្ងឺចិត្ត មិនមែនជាឧបសគ្គដល់ការឱ្យមាននីតិសម្បទាឡើងវិញទេ ប្រសិនបើទណ្ឌិតជូនភស្តុតាងថា ខ្លួនស្ថិតក្នុងភាពអសាធនី ។

ប្រសិនបើអ្នកប្តឹងសុំត្រូវបានផ្តន្ទាទោសពីបទនិទ្ទនភាព សាមីខ្លួនត្រូវជូនភស្តុតាងដែលបញ្ជាក់ថា បានទូទាត់ប្រាក់បំណុលនៃការក្ស័យធនរួចហើយ ។ ប្រសិនបើម្ចាស់បំណុលបានបោះបង់ចោលមិនឱ្យទូទាត់ប្រាក់បំណុលនេះទេ ទណ្ឌិតត្រូវផ្តល់ការបញ្ជាក់ពីការបោះបង់នេះ ។

**មាត្រា ៥៣៧.–** ទម្រង់នៃពាក្យសុំឱ្យមានការផ្តល់នីតិសម្បទាឡើងវិញ

ទណ្ឌិតផ្ញើពាក្យសុំឱ្យមានការផ្តល់នីតិសម្បទាឡើងវិញជូនទៅព្រះរាជអាជ្ញា ដែលមានសមត្ថកិច្ចខាងដែនដី ។ ទណ្ឌិតត្រូវចង្អុលបង្ហាញប្រភេទនៃទណ្ឌកម្មដែលខ្លួនបានរង និងបញ្ជាក់ពីទីកន្លែងដែលខ្លួនបានរស់នៅតាំងពីពេលដែលខ្លួនត្រូវបានដោះលែងឱ្យមានសេរីភាពវិញ ។

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
LE MINISTRE DU PALAIS ROYAL
815/240

**មាត្រា ៥៣៨.-** ការបញ្ជូនសំណុំរឿងដោយព្រះរាជអាជ្ញាជូនអគ្គព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាចាត់ធ្វើការស៊ើបអង្កេតអំពីសីលធម៌នៅគ្រប់ទីកន្លែង ដែលទណ្ឌិតធ្លាប់បានរស់នៅ តាំងពីពេលខ្លួនត្រូវបានដោះលែងឱ្យមានសេរីភាពវិញ ។

ព្រះរាជអាជ្ញាសុំឱ្យគេប្រគល់មកខ្លួននូវ :

-លិខិតចម្លងនៃសេចក្ដីសម្រេចផ្ដន្ទាទោស

-លិខិតជូនដំណឹងអំពីកាលបរិច្ឆេទនៃការអនុវត្តទោសរួចហើយ

-ព្រឹត្តិបត្រលេខ ១ នៃបញ្ជីថ្កោលទោស ។

ព្រះរាជអាជ្ញាបញ្ជូនសំណុំរឿង ដោយមានយោបល់ដែលមានសំអាងហេតុរបស់ខ្លួនភ្ជាប់ជាមួយទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

**មាត្រា ៥៣៩.-** នីតិវិធីនៅចំពោះមុខសាលាឧទ្ធរណ៍

អគ្គព្រះរាជអាជ្ញាប្ដឹងទៅសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ។

អគ្គព្រះរាជអាជ្ញាជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការដល់អ្នកប្ដឹងសុំ និងដល់មេធាវី ។

តុលាការត្រូវសម្រេចនៅពេលសវនាការសាធារណៈ ក្រោយពីបានស្ដាប់ទណ្ឌិត មេធាវី និងអគ្គព្រះរាជអាជ្ញា ។

**មាត្រា ៥៤០.-** ការបដិសេធពាក្យសុំឱ្យមានការផ្ដល់នីតិសម្បទាឡើងវិញ

ក្នុងករណីដែលតុលាការបដិសេធពាក្យសុំ សាមីជនមិនអាចជូនពាក្យសុំថ្មីទៀត មុនផុតរយៈពេល ២ (ពីរ) ឆ្នាំ បានឡើយ ។

ប៉ុន្តែប្រសិនបើពាក្យសុំលើកទី ១ ត្រូវបានតុលាការបដិសេធមកពីមិនគោរពរយៈពេលដែលចែងនៅមាត្រា ៥៣៥ (លក្ខខណ្ឌលើរយៈពេលទាក់ទងនឹងពាក្យសុំឱ្យមានការផ្ដល់នីតិ-សម្បទាឡើងវិញ) នៃក្រមនេះ ពាក្យសុំថ្មីអាចធ្វើបានចាប់ពីផុតរយៈពេលនោះ ។

## ជំពូកទី ២

## ការមាននីតិសម្បទាឡើងវិញដោយពេញលក្ខណៈច្បាប់

**មាត្រា ៥៤១.-** ការមាននីតិសម្បទាឡើងវិញដោយពេញលក្ខណៈច្បាប់

នីតិសម្បទាត្រូវមានឡើងវិញដោយពេញលក្ខណៈច្បាប់ នៅក្នុងករណីដូចតទៅ :

-នៅពេលផុតរយៈពេល ៥ (ប្រាំ) ឆ្នាំ គិតពីថ្ងៃអនុវត្តទោសរួចហើយ ឬ នៅពេល

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ព្រះបរមរាជវាំង



186/240

ទោសត្រូវផុតអាជ្ញាយុកាល ក្នុងករណីដែលបុគ្គលនោះ ត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនា-គារមិនលើសពី ៥ (ប្រាំ) ឆ្នាំ ទេ ឬ ក៏ផ្តន្ទាទោសពិន័យ ។

-នៅពេលផុតរយៈពេល ១០ (ដប់) ឆ្នាំ គិតពីថ្ងៃអនុវត្តទោសរួចហើយ ឬ នៅពេលទោសត្រូវផុតអាជ្ញាយុកាល ក្នុងករណីដែលបុគ្គលនោះ ត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនា-គារលើសពី ៥ (ប្រាំ) ឆ្នាំ ។

## មាតិកាទី ៥
## បញ្ជីថ្កោលទោស
## ជំពូកទោល
## បញ្ជីថ្កោលទោស

**មាត្រា ៥៩២.–** ការគ្រប់គ្រងសលាកបត្រផ្តន្ទាទោសនៃបញ្ជីថ្កោលទោស

បញ្ជីថ្កោលទោសត្រូវបានកាន់កាប់ដោយអង្គភាពមួយនៃក្រសួងយុត្តិធម៌ ។

ចំពោះបុគ្គលដែលកើតនៅកម្ពុជា បញ្ជីថ្កោលទោសនេះ ទទួលសលាកបត្រដែលកត់ត្រា ៖

-គ្រប់ការផ្តន្ទាទោសចំពោះមុខ ការផ្តន្ទាទោសដែលទុកជាចំពោះមុខ និងការផ្តន្ទា-ទោសដោយកំបាំងមុខទាំងអស់ដែលត្រូវបានប្រកាសដោយតុលាការព្រហ្មទណ្ឌកម្ពុជា

-ការផ្តន្ទាទោសដែលត្រូវបានប្រកាសដោយតុលាការបរទេស ហើយដែលអនុវត្តតាមកិច្ចព្រមព្រៀងអន្តរជាតិ ត្រូវបានជូនដំណឹងមកដល់អាជ្ញាធរកម្ពុជា

-វិធានការលើកលែងទោស និងបន្ធូរបន្ថយទោស ដែលប្រទានដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-សេចក្តីសម្រេចក្នុងរឿងដោះលែងដោយមានលក្ខខណ្ឌ

-សេចក្តីសម្រេចស្តីពីការបង្ខឹដល់រូបកាយ

-សាលក្រម ឬ សាលដីកាដែលប្រកាសការក្ស័យធន

-សេចក្តីសម្រេចឱ្យមានការផ្តល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការ

-សេចក្តីសម្រេចបណ្តេញជនបរទេស ។

កាលណាពិរុទ្ធជនបានទទួលទោសពន្ធនាគារ ឬ ការបង្ខឹដល់រូបកាយរួចរាល់ហើយ កាលបរិច្ឆេទនៃការអនុវត្តទោស ឬ ការបង្ខឹដល់រូបកាយនេះ ត្រូវចុះនិទ្ទេសនៅក្នុងបញ្ជីថ្កោលទោស ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

217/240

កាលណាទណ្ឌិតបានបង់ប្រាក់ពិន័យ និងប្រាក់ពន្ធនៃនីតិវិធី កាលបរិច្ឆេទនៃការបង់ប្រាក់នេះ ត្រូវចុះនិទ្ទេសនៅក្នុងបញ្ជីថ្កោលទោស ។

កាលណាការផ្តន្ទាទោសណាមួយត្រូវបានទទួលនីតិសម្បទាជាថ្មីដោយពេញលក្ខណៈច្បាប់នោះ និទ្ទេសនេះត្រូវចុះនៅក្នុងបញ្ជីថ្កោលទោស ។

ត្រូវដកចេញពីបញ្ជីថ្កោលទោស :

-ការផ្តន្ទាទោសដែលសម្រេចដោយកំបាំងមុខ កាលណាការផ្តន្ទាទោសនេះត្រូវទុកជាអសារបង់បន្ទាប់ពីមានបណ្តឹងទាស់

-ការផ្តន្ទាទោសដែលត្រូវបានលុបលាងដោយការលើកលែងទោសជាទូទៅ

-ការផ្តន្ទាទោសដែលកើតមកដោយការភន្តច្រឡំអត្តសញ្ញាណ

-ការផ្តន្ទាទោសដែលត្រូវបានចាត់ទុកជាអសារបង់ដោយនីតិវិធីនៃបណ្តឹងសើរើ ។

**មាត្រា ៥៤៣.–** និទ្ទេសទាក់ទងនឹងអត្តសញ្ញាណ

បញ្ជីថ្កោលទោសក៏ទទួលផងដែរនូវសលាកបត្រដែលទាក់ទងនឹង :

-បុគ្គលដែលកើតនៅឯបរទេស

-បុគ្គលដែលអត្តសញ្ញាណមិនអាចផ្ទៀងផ្ទាត់មើលបាន ឬ ដែលគួរឱ្យសង្ស័យ ។

នៅក្នុងករណីទីពីរនេះ ត្រូវចុះនិទ្ទេសពិសេសនៅក្នុងបញ្ជីថ្កោលទោសថា អត្តសញ្ញាណមិនអាចផ្ទៀងផ្ទាត់មើលបាន ឬ អត្តសញ្ញាណគួរឱ្យសង្ស័យ ។

**មាត្រា ៥៤៤.–** ព័ត៌មាននៃបញ្ជីថ្កោលទោស

ក្រឡាបញ្ជីតុលាការ ត្រូវតែផ្ញើជូនអង្គភាពនៃបញ្ជីថ្កោលទោស ក្រោមការត្រួតពិនិត្យរបស់ប្រធានតុលាការនូវសលាកបត្រចំពោះសេចក្តីសម្រេចនីមួយៗដែលត្រូវចុះក្នុងបញ្ជីថ្កោលទោស ។

ប្រធានពន្ធនាគារជូនដំណឹងដល់អង្គភាពបញ្ជីថ្កោលទោសអំពីកាលបរិច្ឆេទនៃការអនុវត្តទោស ឬ ការបង្ខំដល់រូបកាយរួចរាល់ហើយ ។

អង្គភាពរតនាគារជូនដំណឹងដល់អង្គភាពបញ្ជីថ្កោលទោសអំពីការបង់ប្រាក់ពិន័យ និងប្រាក់ពន្ធនៃនីតិវិធី ។

អង្គភាពបញ្ជីថ្កោលទោសរ៉ាប់រងទទួលព័ត៌មាន អំពីវិធានការលើកលែងទោស និងបន្ធូរបន្ថយទោស ដែលប្រទានដោយព្រះមហាក្សត្រ និងសេចក្តីសម្រេចបណ្តេញជនបរទេស ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

218/240

**មាត្រា ៥៤៥.-** ព័ត៌មាននៃបញ្ជីថ្កោលទោសទាក់ទងនឹងនីតិបុគ្គល

បញ្ជីថ្កោលទោសត្រូវទទួលចុះសលាកបត្រទាំងឡាយដែលបញ្ជាក់ពីការផ្តន្ទាទោសគ្រប់ប្រភេទ ដោយតុលាការព្រហ្មទណ្ឌចំពោះនីតិបុគ្គល ។

**មាត្រា ៥៤៦.-** ការចេញព្រឹត្តិបត្រ

អង្គភាពបញ្ជីថ្កោលទោសអាចចេញព្រឹត្តិបត្របញ្ជីថ្កោលទោស ។ ព្រឹត្តិបត្រគឺជាសម្រង់នៃនិទ្ទេសទាំងអស់ ឬ មួយផ្នែកដែលមានចុះនៅក្នុងបញ្ជីថ្កោលទោសចំពោះបុគ្គលណាមួយជាកំណត់ ។

**មាត្រា ៥៤៧.-** ព្រឹត្តិបត្រលេខ ១

ព្រឹត្តិបត្រលេខ ១ នៃបញ្ជីថ្កោលទោសរួមមាននិទ្ទេសទាំងអស់ដែលចុះនៅក្នុងបញ្ជីថ្កោលទោសបុគ្គលនីមួយៗ ។

ព្រឹត្តិបត្រលេខ ១ អាចចេញឱ្យដល់អាជ្ញាធរតុលាការតែប៉ុណ្ណោះ ។

**មាត្រា ៥៤៨.-** ព្រឹត្តិបត្រលេខ ២

ព្រឹត្តិបត្រលេខ ២ មាននិទ្ទេសទាំងអស់ដែលចុះនៅក្នុងព្រឹត្តិបត្រលេខ ១ លើកលែងតែ :

-ការផ្តន្ទាទោសដែលត្រូវបានលុបបំបាត់ដោយការផ្តល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការ ឬ ដោយពេញលក្ខណៈច្បាប់

-ការផ្តន្ទាទោសព្យួរដោយគ្មានការដកហូត

-សាលក្រម ឬ សាលដីកាដែលប្រកាសការក្ស័យធនក្នុងករណីទទួលបាននីតិសម្បទាឡើងវិញ ។

ព្រឹត្តិបត្រលេខ ២ ត្រូវចេញឱ្យដល់ :

-អាជ្ញាធរតុលាការ

-អាជ្ញាធរយោធាដែលទទួលពាក្យសុំចូលបំរើក្នុងកងទ័ព

-ភ្នាក់ងារដែលកាន់បញ្ជីពាណិជ្ជកម្ម

ព្រឹត្តិបត្រលេខ ២ នេះក៏អាចត្រូវចេញឱ្យដល់អភិបាលខេត្ត ក្រុង និងអង្គភាពរដ្ឋផងដែរ :

-កាលណាអភិបាលខេត្ត ក្រុង និងអង្គភាពរដ្ឋបានទទួលពាក្យសុំធ្វើការងាររដ្ឋ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



219/240

-កាលណាអភិបាលខេត្ត ក្រុង និងអង្គភាពរដ្ឋបានទទួលពាក្យស្នើសុំពីការងារសាធារណៈ ឬ អាបណសញ្ញាសាធារណៈ

-កាលណាអភិបាលខេត្ត ក្រុង និងអង្គភាពរដ្ឋបានទទួលពាក្យសុំបើកគ្រឹះស្ថានដែលត្រូវតែមានការអនុញ្ញាត

-នៅក្នុងក្របខ័ណ្ឌនៃនីតិវិធីខាងវិន័យ ។

**មាត្រា ៥៤៩.-** ព្រឹត្តិបត្រលេខ ៣

ព្រឹត្តិបត្រលេខ ៣ មានចុះតែការផ្តន្ទាទោសជាប់ពន្ធនាគារដោយគ្មានការព្យួរទោសដែលប្រកាសទៅលើបុគ្គលណាមួយពីបទឧក្រិដ្ឋ ឬ មជ្ឈិមប៉ុណ្ណោះ ។

ប៉ុន្តែ ការផ្តន្ទាទោសដែលបានទទួលនីតិសម្បទាឡើងវិញហើយ គ្មានចុះក្នុងព្រឹត្តិបត្រលេខ ៣ ទេ ។

ព្រឹត្តិបត្រលេខ ៣ ត្រូវចេញឱ្យដល់សាមីជនដែលពាក់ព័ន្ធ ។ ក្នុងករណីណាក៏ដោយព្រឹត្តិបត្រលេខ ៣ មិនត្រូវចេញឱ្យដល់តតិយជនទេ ។

**មាត្រា ៥៥០.-** ការប្រព្រឹត្តទៅនៃបញ្ជីថ្កោលទោស : ប្រកាស

ប្រកាសរបស់ក្រសួងយុត្តិធម៌កំណត់វិធានការទាំងឡាយណាដែលចាំបាច់ សម្រាប់ការប្រព្រឹត្តទៅនៃអង្គភាពបញ្ជីថ្កោលទោស ។ ប្រកាសនេះកំណត់ជាអាទិ៍នូវលក្ខខណ្ឌទាំងឡាយដែលសលាកបត្រត្រូវបានបង្កើតឡើង ត្រូវបានត្រួតពិនិត្យ និងត្រូវបានបញ្ជូនដោយក្រឡាបញ្ជីព្រមទាំងលក្ខខណ្ឌទាំងឡាយនៃការបង្កើត ការត្រួតពិនិត្យ និងការចេញព្រឹត្តិបត្រ ។

**មាត្រា ៥៥១.-** ការកែតម្រូវបញ្ជីថ្កោលទោស

កាលណាបុគ្គលណាមួយត្រូវបានផ្តន្ទាទោសដោយមានការខុសអត្តសញ្ញាណ អយ្យការត្រូវតែសុំឱ្យធ្វើការកែតម្រូវបញ្ជីថ្កោលទោសភ្លាម ។

**មាត្រា ៥៥២.-** អានុភាពនៃការទទួលបាននីតិសម្បទាឡើងវិញ

ការឱ្យមាននីតិសម្បទាឡើងវិញ លុបលាងចោលទណ្ឌកម្មព្រហ្មទណ្ឌ ។ ប៉ុន្តែទោសនេះនៅតែមានចុះនៅក្នុងបញ្ជីថ្កោលទោសដដែល ដោយមានចុះនិទ្ទេសថា ត្រូវបាននីតិសម្បទាឡើងវិញ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL ព្រះបរមរាជវាំង



220/240

## មាតិកាទី ៦
## ប្រាក់ប្រដាប់ក្តី
## ជំពូកតោល
## ប្រាក់ប្រដាប់ក្តី

**មាត្រា ៥៥៣.-** ប្រាក់ប្រដាប់ក្តី

ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់រដ្ឋ ។

បញ្ជីនៃប្រាក់ប្រដាប់ក្តី តារាងតម្លៃនៃប្រាក់ប្រដាប់ក្តី និងវិធីទូទាត់ត្រូវកំណត់ដោយប្រកាស ។

**មាត្រា ៥៥៤.-** ប្រាក់នៃនីតិវិធី

ទណ្ឌិតម្នាក់ៗ ត្រូវបង់សរុបនៃនីតិវិធីជូនរដ្ឋ ។ ចំនួនប្រាក់នៃនីតិវិធីអាចប្រែប្រួលទៅតាមប្រភេទរឿងក្តី ។

ចំនួនប្រាក់នៃនីតិវិធីត្រូវកំណត់ដោយប្រកាស ។

## គន្ថីទី ៩
## នីតិវិធីដោយឡែក
## មាតិកាទី ១
## បទប្បញ្ញត្តិទាក់ទងនឹងបុគ្គល
## ជំពូកទី ១
## ចៅក្រម
## ផ្នែកទី ១
## ការដកខ្លួនដោយឯកឯង

**មាត្រា ៥៥៥.-** មូលហេតុត្រឹមត្រូវនៃការដកខ្លួន

ចៅក្រមដែលមានមូលហេតុត្រឹមត្រូវមិនព្រមចូលរួមក្នុងការស៊ើបសួរ ឬ ការជំនុំជម្រះរឿងណាមួយនោះអាចសុំឱ្យគេជំនួសខ្លួនបាន ។ ពាក្យសុំនេះត្រូវជូនទៅប្រធានតុលាការរបស់ខ្លួន ។ ប្រសិនបើយល់ឃើញថាមូលហេតុនេះត្រឹមត្រូវ ប្រធានតុលាការចាត់ចៅក្រមផ្សេងជំនួសចៅក្រមនេះ ។ សេចក្តីសម្រេចរបស់ប្រធានតុលាការមិនអាចតវ៉ាបានឡើយ ។



221/240

# ផ្នែកទី ២

## បណ្ដឹងជំទាស់ចិត្តចៅក្រមអាសនៈ

**មាត្រា ៥៥៦.–** មូលហេតុនៃការប្ដឹងជំទាស់ចិត្តចៅក្រមអាសនៈ

បណ្ដឹងជំទាស់ចិត្តអាចត្រូវទទួលបានពាក់ព័ន្ធតែចៅក្រមអាសនៈប៉ុណ្ណោះ ។

ចៅក្រមទាំងឡាយ អាចត្រូវប្ដឹងជំទាស់ចិត្ត ដោយមូលហេតុដូចខាងក្រោមនេះ :

-កាលណាចៅក្រម ឬ សហព័ទ្ធរបស់ចៅក្រម ឬ អតីតសហព័ទ្ធរបស់ចៅក្រមជាភាគីណាមួយក្នុងរឿងក្ដី

-កាលណាចៅក្រមជាញាតិលោហិតរហូតដល់ថ្នាក់ទី ៦ ឬ ញាតិពន្ធរហូតដល់ថ្នាក់ទី ៣ ឬ អតីតញាតិពន្ធរហូតដល់ថ្នាក់ទី ៣ របស់ភាគីណាមួយ

-កាលណាចៅក្រមជាអ្នកអាណាព្យាបាលរបស់ភាគីណាមួយ

-កាលណាចៅក្រមដែលទទួលបន្ទុករឿងក្ដី ធ្លាប់ ឬ កំពុងមានវិវាទនៅតុលាការជាមួយភាគីណាមួយ

-កាលណាចៅក្រមបានធ្វើជាសាក្សី ឬ អ្នកជំនាញក្នុងរឿងក្ដី

-កាលណាចៅក្រមជា ឬ ធ្លាប់ជាអ្នកតំណាង ឬ ជាអ្នកជំនួយឱ្យភាគីចំពោះរឿងក្ដី ឬ

-កាលណាចៅក្រមបានចូលរួមក្នុងការសម្រេចសេចក្ដីក្នុងនាមជាមជ្ឈត្តករចំពោះរឿងក្ដី ឬ បានចូលរួមក្នុងការសម្រេចសេចក្ដីនៅសាលាដំបូងដែលបានប្ដឹងឧបាស្រ័យ ឬ ការជំនុំជម្រះនៃបណ្ដឹងឧទ្ធរណ៍ដែលបានឧបាស្រ័យ ឬ បង្ហាញមតិយោបល់ណែនាំផ្នែកច្បាប់ចំពោះរឿងក្ដី ។

**មាត្រា ៥៥៧.–** ពាក្យប្ដឹងជំទាស់ចិត្តចៅក្រមអាសនៈ

ភាគីដែលចង់ប្ដឹងជំទាស់ចិត្តចៅក្រមអាសនៈណាមួយ ត្រូវតែជូនពាក្យប្ដឹងតាំងពីពេលខ្លួនបានដឹងពីមូលហេតុនៃការប្ដឹងជំទាស់ចិត្ត បើពុំដូច្នេះទេ មិនអាចទទួលបានឡើយ ។

ក្នុងករណីណាក៏ដោយ ពាក្យប្ដឹងជំទាស់ចិត្តចៅក្រមមិនអាចធ្វើបានឡើយ នៅក្រោយពេលបិទការពិភាក្សាដេញដោល ។

**មាត្រា ៥៥៨.–** អ្នកទទួលពាក្យប្ដឹងជំទាស់ចិត្តចៅក្រមអាសនៈ

ភាគីត្រូវជូនពាក្យប្ដឹង :

-ទៅប្រធានសាលាឧទ្ធរណ៍ កាលណាពាក្យប្ដឹងជំទាស់ចិត្តនោះទាក់ទងដល់ប្រធាន ឬ



ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ចៅក្រមតុលាការជាន់ដំបូង

-ប្រធានតុលាការកំពូល កាលណាពាក្យប្ដឹងជំទាស់ចិត្តនោះទាក់ទងដល់ចៅក្រមនៃតុលាការកំពូលដល់ប្រធានសាលាឧទ្ធរណ៍ ឬ ចៅក្រមណាមួយនៃសាលាឧទ្ធរណ៍ ។

ពាក្យប្ដឹងត្រូវតែចង្អុលឱ្យច្បាស់លាស់អំពីមូលហេតុនៃការប្ដឹងជំទាស់ចិត្ត ហើយត្រូវមានភស្តុតាងបញ្ជាក់ច្បាស់លាស់ បើពុំដូច្នោះទេពាក្យប្ដឹងពុំអាចទទួលយកបានឡើយ ។

**មាត្រា ៥៥៩.–** ការជូនដំណឹងអំពីពាក្យប្ដឹងជំទាស់ចិត្តចៅក្រមអាសនៈ

ពាក្យប្ដឹងត្រូវជូនដំណឹងដល់ចៅក្រមដែលគេប្ដឹងជំទាស់ចិត្ត ។ ចៅក្រមនេះត្រូវដកខ្លួនចេញក្នុងការស៊ើបសួរ ឬ ក្នុងការជំនុំជម្រះ ។

ក្នុងករណីបន្ទាន់ ចៅក្រមនោះត្រូវបានជំនួសដោយចៅក្រមម្នាក់ទៀត ដែលត្រូវចាត់តាំងដោយប្រធានតុលាការរបស់ខ្លួន ។

**មាត្រា ៥៦០.–** របាយការណ៍របស់ចៅក្រមពាក់ព័ន្ធនឹងការប្ដឹងជំទាស់ចិត្ត

ក្នុងរយៈពេល ៨ (ប្រាំបី) ថ្ងៃ បន្ទាប់ពីការជូនដំណឹងនេះ ចៅក្រមពាក់ព័ន្ធត្រូវប្រាប់ឱ្យដឹងនៅក្នុងរបាយការណ៍ដោយមានសំអាងហេតុថា ខ្លួនយល់ព្រម ឬ ជំទាស់នឹងការប្ដឹងជំទាស់ចិត្តនេះ ។ របាយការណ៍នេះត្រូវបញ្ជូនទៅប្រធានសាលាឧទ្ធរណ៍ ឬ ប្រធានតុលាការកំពូលយោងទៅតាមករណីដើម្បីសម្រេចលើពាក្យប្ដឹងជំទាស់ចិត្តនេះ ។

ប្រសិនបើចៅក្រមនេះ យល់ព្រមតាមការជំទាស់ចិត្ត សាមីខ្លួនត្រូវបានចៅក្រមផ្សេងជំនួសភ្លាម ។

ប្រសិនបើចៅក្រមនេះជំទាស់នឹងការជំទាស់ចិត្ត នោះត្រូវធ្វើការសម្រេចលើមូលកភាពនៃពាក្យប្ដឹងនេះ ។

**មាត្រា ៥៦១.–** ការពិនិត្យពាក្យប្ដឹងជំទាស់ចិត្តចៅក្រមអាសនៈ

ពាក្យប្ដឹងត្រូវបានពិនិត្យដោយមិនចាំបាច់ស្ដាប់ភាគី ឬ ចៅក្រមពាក់ព័ន្ធទេ ។

ប្រសិនបើការប្ដឹងជំទាស់ចិត្តត្រូវបានទទួលយក នោះត្រូវធ្វើការចាត់តាំងចៅក្រមថ្មីជំនួសចៅក្រមពាក់ព័ន្ធ ។

នៅក្នុងករណីផ្ទុយពីនេះ អ្នកប្ដឹងជំទាស់ចិត្តអាចត្រូវទទួលពិន័យមិនលើសពី ២០០.០០០ (ពីរសែន) រៀល ដោយមិនទាន់គិតដល់សំណងជម្ងឺចិត្ត ដែលអាចត្រូវផ្ដល់ឱ្យចៅក្រមដែលត្រូវគេប្ដឹងជំទាស់ចិត្តនោះទេ ។



223/240

**មាត្រា ៥៦២.–** សេចក្តីសម្រេចលើពាក្យប្តឹងជិតចិត្តចៅក្រមអាសនៈ

អាជ្ញាធរមានចែងនៅមាត្រា ៥៥៨ (អ្នកទទួលពាក្យប្តឹងជិតចិត្តចៅក្រមអាសនៈ) នៃក្រមនេះ សម្រេចតាមដីកាមួយដែលមិនអាចប្តឹងតវ៉ាបាន ។ ដីកានេះត្រូវជូនដំណឹងដោយក្រឡាបញ្ជីដល់ចៅក្រមពាក់ព័ន្ធ និងដល់អ្នកប្តឹងសុំជិតចិត្ត ។

**មាត្រា ៥៦៣.–** កិច្ចដែលត្រូវបានបំពេញមុនពេលជូនដំណឹងអំពីពាក្យប្តឹង

កិច្ចដែលបានបំពេញដោយចៅក្រម ដែលត្រូវគេប្តឹងជិតចិត្តមុនការជូនដំណឹងអំពីពាក្យប្តឹងជិតចិត្តនោះ មិនអាចត្រូវសើរើបានឡើយ ។

**មាត្រា ៥៦៤.–** ពាក្យប្តឹងចំពោះចៅក្រមច្រើនរូប

កាលណាអ្នកប្តឹងចង់សុំបដិសេធចៅក្រមច្រើនរូប ដែលឡើងជំនុំជម្រះនៅក្នុងក្រុមសមូហភាពជាមួយគ្នានោះ អ្នកប្តឹងអាចដាក់ពាក្យប្តឹងតែមួយគត់ ។ អ្នកប្តឹងអាចដាក់ពាក្យប្តឹងបន្ថែមប្រសិនបើមានមូលហេតុថ្មីនៃការប្តឹងជិតចិត្តបានលេចឡើងតាមក្រោយ ។

**មាត្រា ៥៦៥.–** ការប្តឹងជិតចិត្តប្រធានតុលាការកំពូលមិនឱ្យជំនុំជម្រះ

កាលណាពាក្យប្តឹងជិតចិត្តទៅលើប្រធានតុលាការកំពូលនោះ ប្រធានតុលាការកំពូលត្រូវសម្រេចតាមសម្បជញ្ញៈថា តើត្រូវ ឬ មិនត្រូវដកខ្លួនពីការជំនុំជម្រះ ។

# ជំពូកទី ២

# បត្យាប័ន

## ផ្នែកទី ១

## បត្យាប័នដែលស្នើសុំដោយរដ្ឋបរទេស

### កថាភាគទី ១

### បត្យាប័ន

**មាត្រា ៥៦៦.–** បត្យាប័ននៃអាណិកជនបរទេសលើដែនដី

ព្រះរាជាណាចក្រកម្ពុជាអាចយល់ព្រមប្រគល់ដល់រដ្ឋបរទេស នូវអាណិកជនបរទេសដែលស្នាក់នៅលើដែនដីកម្ពុជា ហើយដែល :

ROYAUME DU CAMBODGE MINISTRE DU PALAIS ROYAL



224/240

-ជាកម្មវត្ថុនៃនីតិវិធីចោទប្រកាន់តាមផ្លូវតុលាការនៅក្នុងរដ្ឋនេះ ឬ

-ត្រូវបានផ្តន្ទាទោសដោយដាក់ពន្ធនាគារដោយតុលាការនៃរដ្ឋនេះ ។

**មាត្រា ៥៦៧.-** សន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ

បត្យាប័នអាណិកជនបរទេស ដែលត្រូវចាប់ខ្លួននៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានគ្រប់គ្រងដោយបទប្បញ្ញត្តិនៃសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិដែលត្រូវបានទទួលសច្ចាប័នពីព្រះរាជាណាចក្រកម្ពុជា ។ ក្នុងករណី គ្មានសន្ធិសញ្ញា ឬ អនុសញ្ញាអន្តរជាតិដែលត្រូវបានទទួលសច្ចាប័នពីព្រះរាជាណាចក្រកម្ពុជាទេ បទប្បញ្ញត្តិនៃជំពូកនេះត្រូវយកមកអនុវត្ត លើកលែងតែមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ផ្សេងទៀត ។

**មាត្រា ៥៦៨.-** និយមន័យ : រដ្ឋផ្ញើសំណើ បុគ្គលដែលគេទាមទារ

នៅក្នុងផ្នែកនេះត្រូវមានឈ្មោះហៅថា :

-រដ្ឋផ្ញើសំណើ គឺរដ្ឋបរទេសដែលស្នើសុំឱ្យធ្វើបត្យាប័នអាណិកជនបរទេស

-បុគ្គលដែលគេទាមទារ គឺជាអាណិកជនបរទេសដែលស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងដែលជាកម្មវត្ថុនៃពាក្យស្នើសុំឱ្យធ្វើបត្យាប័ន ។

## កថាភាគទី ២
## លក្ខខណ្ឌនៃបត្យាប័ន

**មាត្រា ៥៦៩.-** លក្ខខណ្ឌនៃបត្យាប័នទាក់ទងនឹងអំពើ

បត្យាប័នអាចធ្វើទៅបានលុះត្រាតែអំពើដែលត្រូវចោទប្រកាន់លើបុគ្គលដែលគេទាមទារនោះ ជាបទល្មើសតាមច្បាប់របស់រដ្ឋផ្ញើសំណើផង និងតាមច្បាប់កម្ពុជាផង ទោះបីជា :

-អំពើដែលជាបទល្មើស ស្ថិតនៅក្នុងប្រភេទបទល្មើសមិនដូចគ្នាក្តី ឬ

-ឈ្មោះបទល្មើស ការប្រើបច្ចេកស័ព្ទ ឬ និយមន័យ ឬ ការកំណត់លក្ខណៈបទល្មើសមិនដូចគ្នាក្តី ឬ

-ធាតុផ្សំបទល្មើសនៃច្បាប់របស់រដ្ឋផ្ញើសំណើ ខុសគ្នាពីធាតុផ្សំបទល្មើសដែលកំណត់ដោយច្បាប់កម្ពុជាក៏ដោយ ប្រសិនបើពិចារណាទៅលើចំនួនសរុបនៃអំពើដែលត្រូវបានបង្ហាញដោយរដ្ឋផ្ញើសំណើគឺជាការប្រព្រឹត្តិបទល្មើសតាមបញ្ញត្តិនៃច្បាប់ជាធរមាននៅកម្ពុជា ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL



885/249

**មាត្រា ៥៧០.–** ករណីនៃការប៉ុនប៉ងប្រព្រឹត្តិបទល្មើស និងការសមគំនិត

ប្រសិនបើ អំពើដែលត្រូវចោទប្រកាន់តាមច្បាប់នៃរដ្ឋផ្ញើសំណើ ជាការប៉ុនប៉ងប្រព្រឹត្តិបទល្មើសបត្យាប័នអាចធ្វើទៅបាន លុះត្រាតែការប៉ុនប៉ងប្រព្រឹត្តិបទល្មើសនោះ ត្រូវបានផ្តន្ទាទោសតាមច្បាប់កម្ពុជាដែរ ។

បទប្បញ្ញត្តិនៃមាត្រានេះ ត្រូវយកមកអនុវត្តផងដែរលើករណីសមគំនិត ។

**មាត្រា ៥៧១.–** លក្ខខណ្ឌទាក់ទងនឹងទោសពន្ធនាគារ

បត្យាប័នអាចធ្វើបាន លុះត្រាតែអំពើដែលត្រូវចោទប្រកាន់ទៅលើបុគ្គលដែលគេទាមទារនោះ មានកម្រិតអតិបរមានៃទោសពន្ធនាគារយ៉ាងតិចស្មើនឹង ២ (ពីរ) ឆ្នាំ តាមច្បាប់នៃរដ្ឋផ្ញើសំណើ ។

ប៉ុន្តែបត្យាប័នក៏អាចធ្វើបានដែរ ប្រសិនបើបុគ្គលដែលគេទាមទារនោះ ត្រូវបានតុលាការនៃរដ្ឋផ្ញើសំណើផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិចបំផុតស្មើនឹង ៦ (ប្រាំមួយ) ខែ ហើយសេចក្តីសម្រេចផ្តន្ទាទោសនេះបានចូលជាស្ថាពររួចហើយ ទោះបីជាទោសដែលកំណត់ដោយច្បាប់មានថិរវេលាប៉ុន្មានក៏ដោយ ។

**មាត្រា ៥៧២.–** លក្ខខណ្ឌទាក់ទងនឹងទីកន្លែងប្រព្រឹត្តិបទល្មើស

កាលណាអំពើដែលត្រូវចោទប្រកាន់លើបុគ្គលដែលគេទាមទារ ត្រូវបានប្រព្រឹត្តនៅលើដែនដីនៃរដ្ឋផ្ញើសំណើ បត្យាប័នក៏អាចធ្វើបានដែរ ទោះបីជាបុគ្គលដែលគេទាមទារមិនមានសញ្ជាតិរបស់រដ្ឋផ្ញើសំណើក៏ដោយ ។

កាលណាអំពើដែលត្រូវចោទប្រកាន់លើបុគ្គលដែលគេទាមទារនោះ ត្រូវបានប្រព្រឹត្តនៅក្រៅដែនដីនៃរដ្ឋផ្ញើសំណើ បត្យាប័នអាចនឹងត្រូវធ្វើបាន លុះត្រាតែបុគ្គលដែលគេទាមទារនោះមានសញ្ជាតិរបស់រដ្ឋផ្ញើសំណើ ។

**មាត្រា ៥៧៣.–** អំពើដែលមានលក្ខណៈនយោបាយ

បត្យាប័នមិនអាចធ្វើបានទេ កាលណាអំពើដែលត្រូវចោទប្រកាន់មានលក្ខណៈនយោបាយ ។

ប៉ុន្តែមិនត្រូវចាត់ទុកថា ជាបទល្មើសនយោបាយទេ ចំពោះអំពើហិង្សាដែលធ្វើឱ្យមានគ្រោះថ្នាក់ដល់ជីវិត ដល់បូរណភាពខាងរូបកាយ ឬ ដល់សេរីភាពរបស់បុគ្គល ។

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
MINISTRE DU PALAIS ROYAL

**មាត្រា ៥៧៤.–** អំពើដែលត្រូវបានប្រព្រឹត្តលើដែនដី និងដែលត្រូវបានជំនុំជម្រះជាស្ថាពររួចហើយ

បត្យាប័នមិនអាចធ្វើបានទេ កាលណាអំពើដែលត្រូវចោទប្រកាន់បានប្រព្រឹត្តនៅលើដែនដីកម្ពុជា ហើយត្រូវបានជំនុំជម្រះជាស្ថាពររួចហើយនៅកម្ពុជា ។

**មាត្រា ៥៧៥.–** ការរលត់នៃបណ្តឹងអាជ្ញា

បត្យាប័នមិនអាចធ្វើបានទេ នៅក្នុងករណីដែលបណ្តឹងអាជ្ញាបានផុតរលត់តាមច្បាប់របស់រដ្ឋធ្វើសំណើ ។

កាលណាអំពើដែលត្រូវចោទប្រកាន់បានប្រព្រឹត្តនៅលើដែនដីកម្ពុជា បត្យាប័នមិនអាចធ្វើបានទេ នៅក្នុងករណីដែលបណ្តឹងអាជ្ញាត្រូវបានផុតរលត់តាមច្បាប់កម្ពុជា ។

**មាត្រា ៥៧៦.–** ពាក្យសុំធ្វើបត្យាប័នជាច្រើនទាក់ទងនឹងបុគ្គលតែម្នាក់

កាលណាមានរដ្ឋបរទេសច្រើនបានសុំធ្វើបត្យាប័នសំដៅលើបុគ្គលតែម្នាក់ដូចគ្នា ប្រសិនបើធ្វើបត្យាប័ននោះ ត្រូវពិចារណាគ្រប់ស្ថានភាពដូចខាងក្រោម :

-កាតព្វកិច្ចសន្ធិសញ្ញាពាក់ព័ន្ធ

-ភាពធ្ងន់ធ្ងរនៃបទល្មើស

-ពេលវេលា និងទីកន្លែងនៃការប្រព្រឹត្តិបទល្មើស

-កាលបរិច្ឆេទ និងលំដាប់មកដល់នៃសំណើសុំ

-សញ្ជាតិ លំនៅឋាន ទីសំណាក់នៃបុគ្គលដែលគេទាមទារ និងជនរងគ្រោះ

-លទ្ធភាពប្រគល់មកវិញនូវបុគ្គលដែលគេទាមទាររបស់រដ្ឋធ្វើសំណើ ។

**មាត្រា ៥៧៧.–** លក្ខខណ្ឌធ្វើបត្យាប័នទាក់ទងនឹងពាក្យសុំ

បត្យាប័នអាចធ្វើបាន លុះត្រាតែរដ្ឋធ្វើសំណើនោះសន្យាថា មិនធ្វើការចោទប្រកាន់ពីបទល្មើសណាមួយផ្សេងក្រៅពីបទល្មើសដែលចែងនៅក្នុងពាក្យស្នើសុំឱ្យធ្វើបត្យាប័ននោះទេ ហើយកាលណាបទល្មើសនោះបានប្រព្រឹត្តមុនពេលចាប់ខ្លួនបុគ្គលដែលគេទាមទារ ។

ប៉ុន្តែការចោទប្រកាន់អាចធ្វើទៅបានលុះត្រាតែមានការយល់ព្រមពីព្រះរាជាណាចក្រកម្ពុជា ។ ក្នុងករណីនេះ រដ្ឋធ្វើសំណើត្រូវផ្ញើនពាក្យស្នើសុំបន្ថែមមកអាជ្ញាធរកម្ពុជា ។

**មាត្រា ៥៧៨.–** ការព្យួរបត្យាប័ន

កាលណាបុគ្គលដែលគេទាមទារនោះ ត្រូវបានចោទប្រកាន់តាមផ្លូវតុលាការនៅកម្ពុជា បត្យាប័នត្រូវព្យួរក្នុងខណៈដែលការចោទប្រកាន់កំពុងប្រព្រឹត្តទៅ ឬ ក្នុងករណីមានផ្តន្ទាទោស នោះបត្យាប័នត្រូវព្យួរដែរ ក្នុងខណៈដែលទោសមិនទាន់ត្រូវបានអនុវត្ត ។

ប៉ុន្តែ ព្រះរាជាណាចក្រកម្ពុជា អាចយល់ព្រមឱ្យផ្ទេរបុគ្គលដែលគេទាមទារនោះជាបណ្តោះអាសន្នទៅឱ្យរដ្ឋផ្ញើសំណើ ដើម្បីជំនុំជម្រះនៅទីនោះ ។ រដ្ឋផ្ញើសំណើត្រូវសន្យាថា នឹងប្រគល់បុគ្គលពាក់ព័ន្ធមកឱ្យអាជ្ញាធរកម្ពុជាវិញ ក្រោយពេលបញ្ចប់នីតិវិធីជំនុំជម្រះ ។

## កថាភាគទី ៣
## នីតិវិធីនៃបត្យាប័ន

**មាត្រា ៥៧៩.–** ការបញ្ជាក់ថាត្រឹមត្រូវចំពោះពាក្យសុំធ្វើបត្យាប័ន

គ្រប់ពាក្យសុំធ្វើបត្យាប័នត្រូវតែជូនរដ្ឋាភិបាលកម្ពុជាតាមផ្លូវទូត ។ ពាក្យសុំនេះត្រូវមានលិខិតបញ្ជាក់ភស្តុតាងអមជាមួយផង ។

លិខិតបញ្ជាក់ភស្តុតាងត្រូវមាន :

-ឯកសារដែលមានលក្ខណៈគ្រប់គ្រាន់ក្នុងការកំណត់អត្តសញ្ញាណបុគ្គលដែលគេទាមទារ

-របាយការណ៍អំពីអង្គហេតុដែលត្រូវចោទប្រកាន់លើបុគ្គលដែលគេទាមទារ

-អត្ថបទច្បាប់ដែលអនុវត្តទៅលើអំពើនោះ និងទោសដែលត្រូវទទួលរង

-លិខិតចម្លងនៃសេចក្តីសម្រេចផ្តន្ទាទោសប្រសិនបើមាន ។

ឯកសារទាំងអស់ត្រូវចុះហត្ថលេខា បោះត្រាជាផ្លូវការ និងបិទស្រោម ហើយប្រសិនបើមិនមែនជាភាសាខ្មែរ បារាំង ឬ អង់គ្លេស ត្រូវតែភ្ជាប់មកជាមួយនូវឯកសារបកប្រែជាភាសាមួយនៃភាសាទាំងបីនេះ ដោយមានសេចក្តីបញ្ជាក់ផង ។

**មាត្រា ៥៨០.–** ការបញ្ជូនពាក្យសុំធ្វើបត្យាប័ន

រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជាបញ្ជូនពាក្យសុំឱ្យធ្វើបត្យាប័ន និងលិខិតបញ្ជាក់ភស្តុតាងទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ផ្ទៀងផ្ទាត់មើលនិយតភាពនៃពាក្យសុំ និងបញ្ជូនពាក្យនោះទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ ។

ROYAUME DU CAMBODGE * MINISTRE DU PALAIS ROYAL ក្រសួងព្រះបរមរាជវាំង



228/240

**មាត្រា ៥៨១.-** ពាក្យសុំឱ្យចាប់ខ្លួនបណ្តោះអាសន្ន

រដ្ឋផ្ញើសំណើឱ្យផ្ញើបត្យាប័ន អាចសុំឱ្យចាប់ខ្លួនបណ្តោះអាសន្ននូវបុគ្គលដែលគេទាមទារ ។

ក្នុងករណីបន្ទាន់ ពាក្យសុំឱ្យចាប់ខ្លួនបណ្តោះអាសន្ន អាចធ្វើមុនពាក្យសុំឱ្យធ្វើបត្យាប័នដែលមានចែងនៅក្នុងមាត្រា ៥៧៩ (ការបញ្ជាក់ថាត្រឹមត្រូវចំពោះពាក្យសុំធ្វើបត្យាប័ន) នៃក្រមនេះ ។

ពាក្យសុំឱ្យចាប់ខ្លួនបណ្តោះអាសន្ន ដែលមានគោលដៅរារាំងការគេចខ្លួនបុគ្គលដែលគេទាមទារ មិនតម្រូវឱ្យគោរពទម្រង់បែបបទដោយឡែកឡើយ ។

បុគ្គលដែលត្រូវស្ថិតនៅក្រោមនីតិវិធីនៃការចាប់ខ្លួនបណ្តោះអាសន្ន ត្រូវតែបានដោះលែងឱ្យមានសេរីភាពឡើងវិញដោយឯកឯង ប្រសិនបើរាជរដ្ឋាភិបាលពុំបានទទួលឯកសារទាំងឡាយដូចដែលមានចែងនៅក្នុងមាត្រា ៥៧៩ (ការបញ្ជាក់ថាត្រឹមត្រូវចំពោះពាក្យសុំធ្វើបត្យាប័ន) នៃក្រមនេះ ក្នុងរយៈពេល ២ (ពីរ) ខែ គិតពីថ្ងៃចាប់ខ្លួនទេនោះ ។

**មាត្រា ៥៨២.-** បញ្ជាឱ្យចាប់ខ្លួន និងឃុំខ្លួនចំពោះបុគ្គលដែលគេទាមទារ

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍នៅភ្នំពេញអាចចេញបញ្ជាឱ្យចាប់ និងឃុំខ្លួនបុគ្គលដែលគេទាមទារ ។

បញ្ជានេះមានចុះនិទ្ទេសដូចតទៅ :

-អត្តសញ្ញាណនៃបុគ្គលដែលគេទាមទារ

-ការយោងនៃពាក្យសុំឱ្យចាប់ខ្លួនជាបណ្តោះអាសន្នរបស់រដ្ឋបរទេស

-ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញបញ្ជានេះ ។

បញ្ជានេះត្រូវមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយអគ្គព្រះរាជអាជ្ញា និងមានបោះត្រាផង ។

បញ្ជាឱ្យចាប់ និងឃុំខ្លួនមានអានុភាពអនុវត្តនៅលើដែនដីកម្ពុជាទាំងមូល ។

**មាត្រា ៥៨៣.-** ការបង្ហាញបុគ្គលដែលគេទាមទារ ជូនព្រះរាជអាជ្ញា ឬ អគ្គព្រះរាជអាជ្ញាដែលមានសមត្ថកិច្ច

ក្នុងករណីចាប់ខ្លួនបុគ្គលដែលគេទាមទារ ត្រូវតែនាំទៅបង្ហាញខ្លួនក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដី ដែលត្រូវឱ្យដំណឹងដល់បុគ្គលនោះអំពីបញ្ជាឱ្យចាប់ និងឃុំខ្លួន ហើយនិងទទួលចម្លើយពីបុគ្គលនេះ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL ព្រះបរមរាជវាំង

បុគ្គលដែលគេទាមទារត្រូវផ្ទេរមកឃុំខ្លួននៅពន្ធនាគារភ្នំពេញ ។ បុគ្គលនោះ អាចសុំឱ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញស្តាប់ចម្លើយខ្លួន ។

**មាត្រា ៥៨៤.–** ការប្តឹងទៅសភាស៊ើបសួរ

អគ្គព្រះរាជអាជ្ញារៀបចំសំណុំរឿង ដើម្បីប្តឹងទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញ ។

**មាត្រា ៥៨៥.–** នីតិវិធីនៅចំពោះមុខសភាស៊ើបសួរ

បុគ្គលដែលគេទាមទារ ត្រូវតែចូលបង្ហាញខ្លួននៅមុខសភាស៊ើបសួរ ។ បុគ្គលនេះអាចត្រូវអមដោយមេធាវីដែលខ្លួនជ្រើសរើស ឬ ដែលចាត់តាំងដោយអនុវត្តតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។

ការពិភាក្សាដេញដោលប្រព្រឹត្តទៅនៅក្នុងបន្ទប់សម្ងាត់ ។ នៅក្នុងករណីចាំបាច់ សភាស៊ើបសួរអាចហៅកអ្នកបកប្រែ ។

ក្រោយពីបានស្តាប់ចម្លើយរបស់បុគ្គលដែលគេទាមទារ សេចក្តីសន្និដ្ឋានសុំរបស់អគ្គព្រះ-រាជអាជ្ញា និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីរួចមក សភាស៊ើបសួរផ្តល់យោបល់ជាសាល-ដីកាដែលមានសំអាងហេតុស្តីពីពាក្យសុំឱ្យធ្វើបត្យាប័ននេះ ។

**មាត្រា ៥៨៦.–** យោបល់របស់សភាស៊ើបសួរ

សភាស៊ើបសួរផ្តល់យោបល់មិនយល់ព្រម ប្រសិនបើយល់ឃើញថាលក្ខខណ្ឌច្បាប់នៃបត្យាប័នមិនត្រូវបានបំពេញទេ ។

**មាត្រា ៥៨៧.–** ពាក្យសុំដោះលែងឱ្យនៅក្រៅឃុំរបស់បុគ្គលដែលគេទាមទារ

បុគ្គលដែលគេទាមទារ អាចសុំឱ្យគេដោះលែងឱ្យនៅក្រៅឃុំបាន ។

ពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរ ។

ពាក្យសុំត្រូវដាក់ជូនសភាស៊ើបសួរ ដែលសម្រេចក្រោយពីបានស្តាប់ចម្លើយបុគ្គលដែលគេទាមទារសេចក្តីសន្និដ្ឋានសុំរបស់អគ្គព្រះរាជអាជ្ញា និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវី ។

**មាត្រា ៥៨៨.–** ការយល់ព្រមឱ្យគេធ្វើបត្យាប័ន

ប្រសិនបើបុគ្គលដែលគេទាមទារយល់ព្រមឱ្យគេបញ្ជូនខ្លួនតាមពាក្យសុំរបស់រដ្ឋធ្វើសំណើក្រោយពីបានទទួលព័ត៌មានពេញលេញអំពីផលវិបាកនៃការយល់ព្រមចំពោះបត្យាប័ន សភាស៊ើបសួរ ត្រូវចុះនិទ្ទេសនេះនៅក្នុងសាលដីការបស់ខ្លួន ។

ROYAUME DU CAMBODGE · MINISTRE DU PALAIS ROYAL



២៣០/២៤០

**មាត្រា ៥៨៩.–** អានុភាពនៃយោបល់របស់សភាស៊ើបសួរ

កាលណាបានទៅជាស្ថាពរួចហើយ សាលដីកានៃសភាស៊ើបសួរត្រូវបានជូនដំណឹងភ្លាមដល់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ប្រសិនបើសភាស៊ើបសួរផ្តល់យោបល់មិនយល់ស្របទេ បត្យាប័នមិនអាចធ្វើបានដោយរាជរដ្ឋាភិបាលកម្ពុជាទេ ។ បុគ្គលដែលគេទាមទារត្រូវបានដោះលែងឱ្យមានសេរីភាពវិញភ្លាម លើកលែងតែបុគ្គលនេះ ជាកម្មវត្ថុនៃសេចក្តីសម្រេចឱ្យឃុំខ្លួនពីរឿងផ្សេងទៀត ។

ប្រសិនបើសភាស៊ើបសួរបញ្ចេញយោបល់យល់ព្រម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចបញ្ជូនរឿងនេះទៅរាជរដ្ឋាភិបាល ដើម្បីចេញអនុក្រឹត្យបង្គាប់ឱ្យធ្វើបត្យាប័នចំពោះបុគ្គលដែលគេទាមទារនោះ ។

កាលណាបត្យាប័នត្រូវបានបង្គាប់ បុគ្គលដែលគេទាមទារត្រូវបានប្រគល់ឱ្យដល់រដ្ឋធ្វើសំណើ ។ សោហ៊ុយក្នុងការធ្វើបត្យាប័នជាបន្ទុករបស់រដ្ឋធ្វើសំណើ ។ នៅពេលដែលបុគ្គលដែលគេទាមទារនោះ ចាកចេញផុតពីដែនដីកម្ពុជា ក្បួនការពារត្រូវទទួលខុសត្រូវដោយរដ្ឋធ្វើសំណើ ។

ប្រសិនបើរដ្ឋធ្វើសំណើមិនបានចាប់ផ្តើមនីតិវិធីធ្វើមាតុភូមិនិវត្តន៍នៅក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីការជូនដំណឹងអំពីអនុក្រឹត្យបង្គាប់ឱ្យធ្វើបត្យាប័នទេ បុគ្គលដែលគេទាមទារត្រូវបានដោះលែងឱ្យមានសេរីភាពវិញ ។

## ផ្នែកទី ២

## បត្យាប័នដែលស្នើសុំដោយព្រះរាជាណាចក្រកម្ពុជាចំពោះរដ្ឋបរទេស

**មាត្រា ៥៩០.–** សមត្ថកិច្ចរបស់សភាស៊ើបសួរ

សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញ ជាអង្គការតែមួយគត់ដែលមានសមត្ថកិច្ច ដើម្បីពិចារណាលើនិយតភាពនៃបត្យាប័នដែលរាជរដ្ឋាភិបាលកម្ពុជាបានទទួល ។

បុគ្គលដែលត្រូវបានធ្វើបត្យាប័ន មានរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ គិតពីពេលដែលសាមីខ្លួនមកដល់កម្ពុជា ដើម្បីលើកអំពីមោឃភាពនៃបត្យាប័ន ។

ពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរ ។

**មាត្រា ៥៩១.–** នីតិវិធីនៅចំពោះមុខសភាស៊ើបសួរ

សភាស៊ើបសួរធ្វើការសម្រេច ក្រោយពីបានស្តាប់ចម្លើយរបស់បុគ្គលដែលត្រូវបានធ្វើបត្យាប័ន សេចក្តីសន្និដ្ឋានសុំរបស់អគ្គព្រះរាជអាជ្ញា និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវី ។



ROYAUME DU CAMBODGE * LE MINISTÈRE DU PALAIS ROYAL * ក្រសួងព្រះបរមរាជវាំង

231/240

**មាត្រា ៥៩២.–** អានុភាពមិនផ្អាកនៃបណ្តឹងសុំមោឃភាព

ពាក្យសុំមោឃភាពនៃបត្យាប័ន មិនផ្អាកនីតិវិធីចោទប្រកាន់ដែលកំពុងធ្វើទៅលើជនដែលត្រូវបានធ្វើបត្យាប័នឡើយ ។

**មាត្រា ៥៩៣.–** អានុភាពនៃមោឃកម្មចំពោះបត្យាប័ន

ប្រសិនបើបត្យាប័នត្រូវបានចាត់ទុកជាមោឃៈ ដោយសេចក្តីសម្រេចជាស្ថាពររបស់សភាស៊ើបសួរ នីតិវិធីចោទប្រកាន់ដែលកំពុងប្រព្រឹត្តទៅត្រូវបញ្ឈប់ ។ បុគ្គលដែលត្រូវបានធ្វើបត្យាប័នត្រូវបានដោះលែងឱ្យមានសេរីភាពវិញ និងមានលទ្ធភាពចាកចេញដោយសេរីពីដែនដីកម្ពុជា ។

ប៉ុន្តែ លុះផុតរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃដោះលែងឱ្យមានសេរីភាព បុគ្គលដែលត្រូវបានធ្វើបត្យាប័ន អាចត្រូវបានគេចាប់ខ្លួនម្តងទៀតនៅលើដែនដីកម្ពុជា និងត្រូវជាកម្មវត្ថុនៃនីតិវិធីចោទប្រកាន់ជាថ្មីចំពោះអំពើដែលនាំឱ្យមានការធ្វើបត្យាប័នបុគ្គលនេះបាន ។

**មាត្រា ៥៩៤.–** ការយល់ព្រមរបស់រដ្ឋដែលបានប្រគល់អាណិកជនមកព្រះរាជាណាចក្រកម្ពុជា

កាលណាព្រះរាជាណាចក្រកម្ពុជាបានទទួលបត្យាប័ននៃអាណិកជនបរទេស ហើយក្រោយមកទៀតបានទទួលពាក្យប្តឹងសុំឱ្យធ្វើបត្យាប័នពីរដ្ឋបរទេសណាមួយផ្សេង ព្រះរាជាណាចក្រកម្ពុជានឹងអាចយល់ព្រមតាមពាក្យប្តឹងសុំនេះបាន ក្រោយពីបានទទួលការយល់ព្រមពីរដ្ឋដែលបានប្រគល់អាណិកជននេះ មករាជរដ្ឋាភិបាលកម្ពុជា ។

ប៉ុន្តែការយល់ព្រមខាងលើនេះ មិនជាការចាំបាច់ទេ កាលណាអាណិកជនបរទេសនេះមានលទ្ធភាពចាកចេញដោយសេរីពីដែនដីកម្ពុជារួចទៅហើយ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ ។

## ជំពូកទី ៣

## ការឆ្លងកាត់

**មាត្រា ៥៩៥.–** ពាក្យសុំឆ្លងកាត់

ការឆ្លងកាត់ដែនដីកម្ពុជា ដោយបុគ្គលណាម្នាក់ដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃនីតិវិធីបត្យាប័ន អាចត្រូវបានអនុញ្ញាត កាលណាបត្យាប័ននេះមិនទាក់ទងនឹងបទល្មើសនយោបាយទេ ។ ពាក្យសុំត្រូវផ្ញើតាមផ្លូវទូត ។ ពាក្យសុំត្រូវតែមានលិខិតបញ្ជាក់ភស្តុតាងបញ្ជាក់ថាត្រឹមត្រូវអមជាមួយផង ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

232/240

# ជំពូកទី ៤
# បទប្បញ្ញត្តិដោយឡែកស្តីពីការប្រតិបត្តិទោសមួយចំនួន

**មាត្រា ៥៩៦.–** បទប្បញ្ញត្តិស្តីពីការអនុវត្តទោសមួយចំនួន

ចំពោះវិវាទទាក់ទងនឹងការអនុវត្តទោស ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ តុលាការទទួលបណ្តឹងពីព្រះរាជអាជ្ញាតាមរយៈពាក្យសុំធម្មតា ។ អយ្យការឱ្យដំណឹងអំពីកាលបរិច្ឆេទនៃសវនាការដល់ភាគីពាក់ព័ន្ធ ។

# ជំពូកទី ៥
# នីតិបុគ្គល

**មាត្រា ៥៩៧.–** សមត្ថកិច្ចទាក់ទងនឹងនីតិបុគ្គល

ចំពោះការចោទប្រកាន់ ការស៊ើបសួរ និងការជំនុំជម្រះបទល្មើសដែលប្រព្រឹត្តដោយនីតិបុគ្គល អាជ្ញាធរមានសមត្ថកិច្ចមានដូចតទៅ :

-ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ និងសាលាដំបូងនៃទីកន្លែងដែលមានការប្រព្រឹត្តបទល្មើស

-ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ និងសាលាដំបូងនៃទីកន្លែងដែលនីតិបុគ្គលតាំងទីស្នាក់ការរបស់ខ្លួន ។

**មាត្រា ៥៩៨.–** ការតំណាងនីតិបុគ្គលនៅចំពោះមុខតុលាការ

ការចោទប្រកាន់ត្រូវបានអនុវត្តប្រឆាំងនឹងនីតិបុគ្គល តាមរយៈអ្នកតំណាងស្របច្បាប់ក្នុងពេលធ្វើការចោទប្រកាន់នោះ ។ អ្នកតំណាងស្របច្បាប់ តំណាងឱ្យនីតិបុគ្គលក្នុងការបំពេញគ្រប់កិច្ចទាំងអស់នៃនីតិវិធី ។

កាលណាអ្នកតំណាងស្របច្បាប់មានធុរៈ ព្រះរាជអាជ្ញា អាចស្នើសុំដល់ប្រធានសាលាដំបូងឱ្យចាត់តាំងអាណត្តិគាហកម្នាក់ ដើម្បីតំណាងឱ្យនីតិបុគ្គល ។

កាលណាការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ត្រូវបានធ្វើឡើងចំពោះអង្គហេតុដដែល ឬចំពោះអង្គហេតុទាក់ទងគ្នាប្រឆាំងនឹងនីតិបុគ្គល និងអ្នកតំណាងស្របច្បាប់នៃនីតិបុគ្គលនេះ អ្នកតំណាងស្របច្បាប់នេះ អាចប្តឹងសុំដល់ប្រធានសាលាដំបូងឱ្យចាត់តាំង អាណត្តិគាហកម្នាក់ដើម្បីតំណាងនីតិបុគ្គល ។



ROYAUME DU CAMBODGE MINISTRE DU PALAIS ROYAL

833/240

បណ្ដឹងសុំនេះ អាចធ្វើឡើងតាមរយៈពាក្យសុំជាលាយលក្ខណ៍អក្សរ ។

**មាត្រា ៥៩៩.–** អត្តសញ្ញាណនៃអ្នកតំណាងរបស់នីតិបុគ្គល

បុគ្គលដែលទទួលបន្ទុកតំណាងឱ្យនីតិបុគ្គល ត្រូវតែបង្ហាញអត្តសញ្ញាណរបស់ខ្លួនចំពោះតុលាការដែលបានទទួលពាក្យប្ដឹង ។ ការបង្ហាញអត្តសញ្ញាណនេះក៏ត្រូវធ្វើដូចគ្នាផងដែរ ក្នុងករណីផ្លាស់ប្ដូរអ្នកតំណាងស្របច្បាប់ ក្នុងពេលដំណើរការនីតិវិធី ។

**មាត្រា ៦០០.–** វិធានការបង្ខំដែលយកមកអនុវត្តចំពោះនីតិបុគ្គល

ក្នុងឋានៈជាអ្នកតំណាងឱ្យនីតិបុគ្គល អ្នកតំណាងនេះពុំអាចទទួលរងវិធានការបង្ខំណាមួយបានឡើយ ក្រៅពីវិធានការដែលអាចយកមកអនុវត្តបានចំពោះសាក្សី ។

**មាត្រា ៦០១.–** ការដាក់នីតិបុគ្គលឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ចៅក្រមស៊ើបសួរអាចដាក់នីតិបុគ្គលឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ។ ចៅក្រមនេះ អាចប្រកាសបាននូវកាតព្វកិច្ចដូចតទៅ :

១-ដាក់ប្រាក់ធានា ដែលមានកំណត់ចំនួនទឹកប្រាក់ ចិរវេលានៃការបង់ និងបែបបទទាំងឡាយ ។

២-មិនត្រូវអនុវត្តសកម្មភាពវិជ្ជាជីវៈមួយចំនួន ។

៣-ស្ថិតនៅក្រោមការតាមដានរបស់តុលាការ ក្នុងចិរវេលាមួយដែលមិនលើសពី ៦ (ប្រាំមួយ) ខែ ។

សេចក្ដីសម្រេចដាក់ឱ្យស្ថិតនៅក្រោមការតាមដានរបស់តុលាការ បណ្ដាលឱ្យមានការចាត់តាំងអាណាព្យាបាលតុលាការម្នាក់ ដែលមានបេសកកម្មត្រូវបានបញ្ជាក់ដោយចៅក្រមស៊ើបសួរ ។

**មាត្រា ៦០២.–** ដីកាកោះ និងដីកាជូនដំណឹងដល់នីតិបុគ្គល

ដីកាកោះហៅ និងសេចក្ដីសម្រេចទាំងឡាយ ដែលមានចែងនៅក្នុងក្រមនេះ ត្រូវបានបញ្ជូន និងឱ្យដំណឹងទៅនីតិបុគ្គល តាមរយៈអ្នកតំណាងស្របច្បាប់របស់នីតិបុគ្គលនោះ នៅក្នុងលក្ខខណ្ឌដូចគ្នានឹងលក្ខខណ្ឌដែលមានចែងសម្រាប់រូបវន្តបុគ្គលដែរ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · ព្រះបរមរាជវាំង

234/240

# មាតិកាទី ២

# ការបាត់បង់លិខិតស្នាម ការបកស្រាយ និងការកែសម្រួលសេចក្តីសម្រេច

## ជំពូកទី ១

## ការបាត់បង់លិខិតស្នាម

**មាត្រា ៦០៣.–** បទប្បញ្ញត្តិដែលអនុវត្តក្នុងករណីបាត់បង់លិខិតស្នាម

បទប្បញ្ញត្តិនៃមាតិកានេះត្រូវអនុវត្តនៅក្នុងករណីមានការបំផ្លិចបំផ្លាញ ការបំបាត់ ឬ ការបាត់បង់លិខិតស្នាមដូចខាងក្រោម ៖

-សេចក្តីសម្រេចដើមរបស់តុលាការ ឬ

-លិខិតនៃនីតិវិធី ។

**មាត្រា ៦០៤.–** លិខិតចម្លងដែលជំនួសលិខិតដើម

ប្រសិនបើបានលិខិតចម្លងនៃសេចក្តីសម្រេចរបស់តុលាការ ដែលមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើមដោយក្រឡាបញ្ជី ឬ ដោយអាជ្ញាធរមួយផ្សេងទៀត លិខិតចម្លងនោះត្រូវចាត់ទុកថាជាសេចក្តីសម្រេចដើមរបស់តុលាការ ។ អ្នកដែលមានលិខិតចម្លងដោយមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើមត្រូវតែប្រគល់លិខិតនោះ ដល់ក្រឡាបញ្ជីតាមការស្នើសុំរបស់ប្រធានតុលាការ ។ លិខិតចម្លងថ្មីមួយដែលមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម ត្រូវបានប្រគល់ឱ្យដល់សាមីជននោះ ដោយក្រឡាបញ្ជី ។

ប្រសិនបើគ្មានលិខិតចម្លងដោយមានបញ្ជាក់ថា ត្រឹមត្រូវតាមច្បាប់ដើមទេ នោះសេចក្តីសម្រេចថ្មីមួយត្រូវធ្វើឡើង ដោយផ្អែកទៅលើលិខិតចម្លង កំណត់ហេតុសវនាការ និងឯកសារដែលមាននៅក្នុងសំណុំរឿង ។

**មាត្រា ៦០៥.–** ការបង្កើតឡើងវិញនូវលិខិតនៃនីតិវិធី

លិខិតនៃនីតិវិធីត្រូវបង្កើតឡើងវិញតាមលិខិតចម្លង ដែលរក្សាទុកដោយអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ ភាគីអ្នកជំនាញ ក្រឡាបញ្ជី ឬ បុគ្គលផ្សេងទៀត ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
835/240

# ជំពូកទី ២
## ការបកស្រាយ និងការកែតម្រូវសេចក្តីសម្រេច

**មាត្រា ៦០៦.-** សមត្ថកិច្ចរបស់តុលាការដែលបានប្រកាសសេចក្តីសម្រេច

គ្រប់ការលំបាកក្នុងការបកស្រាយសេចក្តីសម្រេចរបស់តុលាការ ត្រូវដាក់ជូនតុលាការដែលបានប្រកាសសេចក្តីសម្រេចនោះពិនិត្យ ។

តុលាការនេះក៏អាចមានសមត្ថកិច្ចដើម្បីធ្វើការកែតម្រូវការភ័ន្តច្រឡំ ខាងសម្ភារៈសុទ្ធសាធដែលមាននៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ។ តុលាការទទួលពាក្យប្តឹងពីអយ្យការ តាមគំនិតផ្តើមរបស់ខ្លួនផ្ទាល់ ឬ តាមពាក្យប្តឹងរបស់ភាគី ។ អយ្យការឱ្យដំណឹងអំពីកាលបរិច្ឆេទនៃសវនាការដល់ភាគីដែលពាក់ព័ន្ធ ។ នៅក្នុងគ្រប់ករណីទាំងអស់ អយ្យការត្រូវឱ្យយោបល់នៅពេលសវនាការ ។

# គន្ថីទី ១០
## អន្តរប្បញ្ញត្តិ
## ជំពូកទោល
## អន្តរប្បញ្ញត្តិ

**មាត្រា ៦០៧.-** លក្ខខណ្ឌនៃការផ្តល់គុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ចំពោះនាយនគរ-បាលជាតិ និងនាយទាហាននៃកងរាជអាវុធហត្ថ

នាយនគរបាលជាតិ ដែលមានវិញ្ញាបនប័ត្របញ្ជាក់ការសិក្សាស្តីពីមន្ត្រីនគរបាលយុត្តិធម៌ មុនពេលក្រមនេះចូលជាធរមាន ត្រូវទទួលបានដោយស្វ័យប្រវត្តិនូវសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ ហើយត្រូវតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌ដោយប្រកាសរួមរបស់ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ ។

នាយទាហាននៃកងរាជអាវុធហត្ថដែលមានវិញ្ញាបនប័ត្រនៃមន្ត្រីប៉ូលីសតុលាការមុនក្រមនេះចូលជាធរមាន ត្រូវទទួលបានដោយស្វ័យប្រវត្តិនូវសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ ហើយត្រូវតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌ ដោយប្រកាសរួមរបស់ក្រសួងការពារជាតិ និងក្រសួងយុត្តិធម៌ ។

ROYAUME DU CAMBODGE
MINISTRE DU PALAIS ROYAL



236/240

បន្ទាប់ពីក្រមនេះចូលជាធរមាន ដើម្បីទទួលបាននូវគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវបំពេញលក្ខខណ្ឌដែលមានចែងនៅក្នុងមាត្រា ៦០ (មន្ត្រីនគរបាលយុត្តិធម៌) នៃក្រមនេះ ។

**មាត្រា ៦០៨.-** ការអនុវត្តនៅក្នុងពេលវេលានូវរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន

ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចំពោះរឿងក្តីកំពុងចាត់ការ គឺជារយៈពេលដែលមានចែងនៅក្នុងច្បាប់ចាស់ លើកលែងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ បទឧក្រិដ្ឋប្រល័យពូជសាសន៍ ឬ បទឧក្រិដ្ឋសង្គ្រាម ។

**មាត្រា ៦០៩.-** ការអនុវត្តនៅក្នុងពេលវេលានូវរយៈពេលនៃបណ្តឹងឧបាស្រ័យ និងបណ្តឹងទាស់

រាល់សេចក្តីសម្រេចរបស់តុលាការដែលចេញនៅមុនក្រមនេះចូលជាធរមាន ត្រូវគោរពតាមរយៈពេលនៃបណ្តឹងឧបាស្រ័យ និងបណ្តឹងទាស់ តាមបទប្បញ្ញត្តិនៃច្បាប់ចាស់ ។

**មាត្រា ៦១០.-** ការអនុវត្តនៅក្នុងពេលវេលានូវវិធានស្តីពីអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា និងអាជ្ញាយុកាលនៃទោស

អាជ្ញាយុកាលនៃបណ្តឹងអាជ្ញា និងអាជ្ញាយុកាលនៃទោស ចំពោះបទល្មើសដែលត្រូវបានប្រព្រឹត្តនៅមុនក្រមនេះចូលជាធរមាន ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ចាស់ ។

## គន្ថីទី ១១

## អវសានប្បញ្ញត្តិ

## ជំពូកតែមួយ

## អវសានប្បញ្ញត្តិ

**មាត្រា ៦១១.-** និរាករណ៍នៃអត្ថបទច្បាប់ស្តីពីនីតិវិធីពីមុន

បទប្បញ្ញត្តិដូចតទៅនេះត្រូវទុកជានិរាករណ៍ :

-រាល់បទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌមុនឆ្នាំ ១៩៩២

-បទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌនៃបទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ១៩៩២

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង



237/240

-ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើដោយក្រឹត្យលេខ ២១ ក្រ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៣

-ព្រះរាជក្រមលេខ ០៨៩៩/០៩ ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន

-ច្បាប់ស្តីពីវិសោធនកម្មមាត្រា ៣៦ មាត្រា ៣៨ មាត្រា ៩០ និងមាត្រា ៩១នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០២/០០៥ ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០២

បទប្បញ្ញត្តិស្តីពីនីតិវិធីនៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ពុំអាចអនុវត្តចំពោះរឿងព្រហ្មទណ្ឌបានឡើយ ។

**មាត្រា ៦១២.–** ការអនុវត្តភ្លាមនូវក្រមនីតិវិធីព្រហ្មទណ្ឌ

ក្រមនេះត្រូវអនុវត្តភ្លាម ចំពោះគ្រប់កិច្ចនីតិវិធីក្រោយក្រមនេះចូលជាធរមាន ។

ការអនុវត្តភ្លាមនូវបទប្បញ្ញត្តិនៃក្រមនេះ ពុំមានអានុភាពលើសុពលភាពនៃកិច្ចនីតិវិធីទាំងឡាយដែលត្រូវបានបំពេញរួចរាល់ហើយ ដោយអនុលោមតាមច្បាប់ចាស់ឡើយ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី *១០* ខែ *សីហា* ឆ្នាំ២០០៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

*ព.រ.ល.០៨០៧.៣៧១* **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ហត្ថលេខា**

**អង្គ វង្សវឌ្ឍានា**

លេខៈ **៣៤៩**ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី **១១** ខែ សីហា ឆ្នាំ២០០៧

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

838/240

# ឧបសម្ព័ន្ធ
# នីតិវិធីក្នុងការធ្វើសម្បថ

ការធ្វើសច្ចាប្រណិធាន ត្រូវដឹកនាំដោយក្រឡាបញ្ជីម្នាក់ ហើយត្រូវធ្វើនៅចំពោះមុខវត្ថុសក្តិសិទ្ធិ នៅទីកន្លែងនៃតុលាការនីមួយៗ ។

មុននឹងចាប់ផ្តើមធ្វើសម្បថ អ្នកស្បថត្រូវអុជទៀន ធូប បូជាចំពោះវត្ថុសក្តិសិទ្ធិដែលខ្លួនត្រូវស្បថនោះ ។ បន្ទាប់មកក្រឡាបញ្ជីត្រូវអានប្រារព្ធវាទខ្លាំងៗ ច្បាស់ៗ ឱ្យអ្នកស្បថស្តាប់ រួចអាន **ពាក្យសច្ចាប្រណិធាន** ឱ្យអ្នកស្បថថាតាម ។

ក្រោយពីធ្វើសម្បថរួច ក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុដែលបានឱ្យស្បថនោះ បញ្ជាក់ថាបានធ្វើត្រឹមត្រូវហើយ សេចក្តីបានចេញវាចាឱ្យស្បថយ៉ាងណា ត្រូវកត់ក្នុងកំណត់ហេតុយ៉ាងនោះផង ។

## ប្រារព្ធវាទ

បពិត្រអស់ទេព្រក្ស អារុក្ខអារក្សអ្នកតា និងបារមីដ៏សក្តិសិទ្ធិ មានព្រះអង្គដងកើរ ព្រះអង្គក្រពុំឈូក ព្រះអង្គស្វេតឆ្ងត្រ ព្រះអង្គចេក ព្រះអង្គចម អ្នកតាឃ្លាំងមឿង អ្នកតាក្រហមក លោកតាដំបងដែក លោកតាដំបងក្រញូង លោកយាយទេព ព្រះអង្គវិហារសួគ៌ ព្រះអង្គព្រះជីវិវត្តបារាយណ៍ ព្រះអង្គវត្តភ្នំខ្មែង ជាដើម សូមយាងអញ្ជើញមកធ្វើជាអធិបតីក្នុងពិធីសម្បថនេះ ត្បិតគូក្តីនេះបានឈ្លោះទាស់ទែងគ្នា ហើយអះអាងលើសាក្សីថាជាអ្នកបានដឹង បានឃើញ បានឮ និងបានចាំដោយផ្ទាល់ ហើយច្បាប់តម្រូវឱ្យយកអ្នកទាំងនេះ មកធ្វើជាសាក្សីឱ្យឆ្លើយឱ្យបានទៀងត្រង់តាមពិត ។

បើអ្នកណាឆ្លើយមិនពិត តាមដែលខ្លួនបានដឹង បានឃើញ កានឮ និងបានចាំទេ សូមអស់ទេព្រក្ស អារុក្ខអារក្សអ្នកតា យាយទេព និងបារមីដ៏សក្តិសិទ្ធិ បំផ្លាញឱ្យលាញ ឱ្យស្លាប់តែហោងយ៉ាងវេទនា ដោយគ្រាប់កាំភ្លើង ខ្សែភ្លើងឆក់ រន្ទះបាញ់ ខ្លាខាំ ពស់ចឹក លុះអនាគតជាតិឱ្យព្រាត់ប្រាសឪពុកម្តាយ បងប្អូន កូនចៅ ឱ្យក្ររហេមរហាម ខ្សត់ទ្រព្យ រងទុក្ខវេទនា អស់ព្រាំរយជាតិ ។

បើអ្នកណាឆ្លើយឱ្យការណ៍ដោយពិតត្រង់ មិនវៀចវេរ មិនភូតកុហក មិនលំអៀង ព្រោះជាញាតិសាលោហិត មិនសមគំនិត ព្រោះខ្លាច ព្រោះស្អប់ ព្រោះលាភសក្ការៈ ព្រោះស៊ីសំណូកទេ សូមអស់ទេព្រក្ស អារុក្ខអារក្សអ្នកតា យាយទេព និងបារមីដ៏សក្តិសិទ្ធិ ក្នុងលោកជួយឱ្យគេមាន

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



239/240

អាយុយឺនយូរ មានសុខភាពល្អ មានទ្រព្យសម្បត្តិសម្បូរណ៍ហូរហៀរ មានញាតិផៅគោរពស្រលាញ់រាប់អាន លុះអនាគតជាតិបានជួបតែសេចក្ដីល្អ ចម្រុងចម្រើន ថ្កុំថ្កើង រុងរឿង សមដូចសេចក្ដីបំណងប៉ងប្រាថ្នា កុំបីអាក់ខានឡើយ ។

## ពាក្យសច្ចាប្រណិធាន

ខ្ញុំសូមឆ្លើយតែការពិត ដែលខ្ញុំបានឃើញ បានឮ បានដឹង និងបានចាំផ្ទាល់ ។

បើខ្ញុំឆ្លើយមិនពិត ដោយប្រការណាមួយ សូមអស់ទេព្រក្ស អារក្សអ្នកតា និងបារមីដ៏សក្ដិសិទ្ធិទាំងអស់ បរាមុខខ្ញុំ ឱ្យវិនាសលាញ អន្តរាយទ្រព្យសម្បត្តិ និងស្លាប់តែហោង យ៉ាងវេទនា តែបើខ្ញុំឆ្លើយពិតត្រង់ សូមទេវតាជួយឱ្យខ្ញុំ មានទ្រព្យសម្បត្តិសម្បូរណ៍ហូរហៀរ និងរស់នៅប្រកបដោយសេចក្ដីសុខក្សេមក្សាន្ត ជួបជុំបងប្អូន ញាតិផៅសន្ដាន ជារៀងរហូតគ្រប់ជាតិកុំបីអាក់ខានឡើយ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង



210/250

# ព្រះរាជក្រម

នស/រកម/០៦១៣/០០៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រត្នត្រ័យ ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីវិសោធនកម្មមាត្រា២៥.៧ មាត្រា៣៦៨ មាត្រា៣៧២ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣ នាសម័យប្រជុំលើកទី៣ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE
MINISTERE DU PALAIS ROYAL

# ច្បាប់

# ស្ដីពី

# វិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨
# មាត្រា៣៧២ និងមាត្រា៣៨២
# នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា មួយ.-**

មាត្រា២៤៧ (ដីកាដំណោះស្រាយ) មាត្រា៣៦៨ (រយៈពេលសម្រាប់ធ្វើបណ្ដឹងទាស់) មាត្រា៣៧២ (បណ្ដឹងទាស់ដែលធ្វើឡើងដោយដើមបណ្ដឹងរដ្ឋប្បវេណីឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី) និងមាត្រា៣៨២ (រយៈពេលប្ដឹងឧទ្ធរណ៍របស់ពិរុទ្ធជន ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី) នៃក្រមនីតិវិធីព្រហ្មទណ្ឌត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

**មាត្រា ២៤៧ថ្មី.- ដីកាដំណោះស្រាយ**

ចៅក្រមស៊ើបសួរបិទការស៊ើបសួរតាមដីកាដំណោះស្រាយ។ ដីកានេះអាចជាដីកាបញ្ជូនទៅជំនុំជម្រះឬដីកាលើកលែងចោទប្រកាន់ ។

ប្រសិនបើយល់ឃើញថាអំពើនោះជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនត្រូវចោទទៅមុខតុលាការជំនុំជម្រះ។ ដីកាត្រូវរៀបរាប់អំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់ ។

ចៅក្រមស៊ើបសួរចេញដីកាលើកលែងចោទប្រកាន់នៅក្នុងករណីដូចតទៅ ៖

១- អំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ។

២- ជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់ ។

៣- គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ ។

៤- ករណីដែលបណ្ដឹងអាជ្ញារលត់ ។

ដីកាដំណោះស្រាយជានិច្ចកាលត្រូវតែមានសំអាងហេតុ ។ ចៅក្រមស៊ើបសួរមិនត្រូវជាប់កាតព្វកិច្ចគោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាទេ ។ ដីកាអាចជាដីកាបញ្ជូនទៅតុលាការជំនុំជម្រះចំពោះអំពើមួយចំនួន និងជាដីកាលើកលែងចោទប្រកាន់ចំពោះអំពើដទៃទៀត ។

ក្នុងករណីដែលសំណុំរឿងស៊ើបសួរពាក់ព័ន្ធនឹងអង្គហេតុច្រើន ចៅក្រមស៊ើបសួរអាចចេញដីកាដំណោះស្រាយចំពោះអង្គហេតុដែលការស៊ើបសួរបានចប់សព្វគ្រប់ និងបន្តការស៊ើបសួរចំពោះអង្គហេតុផ្សេងទៀតបាន។ ចៅក្រមស៊ើបសួរក៏អាចចេញដីកាលើកលែងចោទប្រកាន់ចំពោះជនត្រូវចោទដែលត្រូវបានស៊ើបសួររកឃើញថា មិនមានការពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើស ឬការចូលរួមប្រព្រឹត្តបទល្មើស និងធ្វើការស៊ើបសួររកអត្តសញ្ញាណជនល្មើសបន្តទៀតបាន ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · ក្រសួងព្រះបរមរាជវាំង

Rsl

ដីកាដំណោះស្រាយត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី ។

ក្នុងករណីដែលមានការលើកលែងចោទប្រកាន់ដោយមូលហេតុអត្តសញ្ញាណរបស់ជនត្រូវចោទមិនត្រូវបានស្គាល់ ឬក្នុងករណីដែលជនត្រូវចោទទទួលមរណភាព ចៅក្រមស៊ើបសួរអាចប្ដឹងសុំទៅតុលាការព្រហ្មទណ្ឌតាមដីកាបញ្ជូនឲ្យសម្រេចរឹបអូសឧបករណ៍ សម្ភារៈ មូលនិធិ ផលទុនឬទ្រព្យសម្បត្តិ ប្រសិនបើមានការសង្ស័យដោយសមហេតុផលថា ឧបករណ៍ សម្ភារៈ មូលនិធិ ផលទុន ឬទ្រព្យសម្បត្តិទាំងនោះពាក់ព័ន្ធនឹងបទល្មើស ។ ក្នុងករណីនេះ តុលាការព្រហ្មទណ្ឌត្រូវសម្រេចអំពីការរឹបអូសដោយសាលក្រមក្នុងសវនាការជាសាធារណៈ ដោយមានការចូលរួមពីតំណាងអយ្យការនិងបុគ្គលពាក់ព័ន្ធ ប្រសិនបើមាន ។ សាលក្រមដែលសម្រេចអំពីការរឹបអូសត្រូវបិទផ្សាយនៅទីកន្លែងដែលតុលាការបានចេញសាលក្រម និងផ្សាយជាសាធារណៈតាមសារព័ត៌មានឬមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ។

បុគ្គលដែលមានប្រយោជន៍ពាក់ព័ន្ធ ឬដែលអះអាងថាខ្លួនជាម្ចាស់នៃវត្ថុដែលជាកម្មវត្ថុនៃការរឹបអូស មានសិទ្ធិប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេចនោះបានក្នុងរយៈពេល ១ (មួយ) ខែ គិតពីថ្ងៃប្រកាសសាលក្រម ប្រសិនបើបុគ្គលនេះបានចូលរួមនៅក្នុងនីតិវិធីនៃការជំនុំជម្រះរបស់តុលាការ និងក្នុងរយៈពេល២ (ពីរ) ខែ គិតពីថ្ងៃប្រកាសផ្សាយជាសាធារណៈតាមសារព័ត៌មាន ឬមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ប្រសិនបើបុគ្គលនេះមិនបានចូលរួមនៅក្នុងនីតិវិធីតុលាការ ។ បែបបទ និងនីតិវិធីនៃការប្ដឹងឧទ្ធរណ៍នេះត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃក្រមនេះ ។

**មាត្រា ៣៦៨ថ្មី.- រយៈពេលសម្រាប់ធ្វើបណ្ដឹងទាស់**

បណ្ដឹងទាស់ត្រូវតែធ្វើនៅក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ ផ្ដើមគិត ៖

- ពីថ្ងៃជូនដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រមត្រូវបានប្រគល់ឲ្យពិរុទ្ធជនដោយផ្ទាល់ដៃ ឬ
- ពីថ្ងៃដែលពិរុទ្ធជននេះបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលក្រមនេះ មិនបានប្រគល់ឲ្យដល់ពិរុទ្ធជនដោយផ្ទាល់ដៃទេ ។ ពិរុទ្ធជនត្រូវចាត់ទុកថា បានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម ក្នុងករណីដែលនីតិវិធីនៃការឲ្យដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវស្របតាម

ROYAUME DU CAMBODGE
MINISTÈRE DU PALAIS ROYAL
ព្រះបរមរាជវាំង

បទប្បញ្ញត្តិដែលមានចែងក្នុងគន្ថីទី៧ (ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដីកាកោះហៅ និងដីកាជូនដំណឹង) មាតិកាទី៤ (ដីកាឲ្យដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការ) នៃក្រមនេះ ។

## មាត្រា ៣៧២ថ្មី.- បណ្ដឹងទាស់ដែលធ្វើឡើងដោយដើមបណ្ដឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី

ដើមបណ្ដឹងរដ្ឋប្បវេណីក៏អាចប្ដឹងទាស់នឹងសាលក្រម ដែលសម្រេចដោយកំបាំងមុខខ្លួនបានដែរ ។ បណ្ដឹងទាស់នេះ ត្រូវកំណត់ទៅលើសេចក្ដីសម្រេចផ្នែករដ្ឋប្បវេណីនៃសាលក្រមតែប៉ុណ្ណោះ ។

បណ្ដឹងទាស់ត្រូវធ្វើក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ គិតពី ៖

- ថ្ងៃឲ្យដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រមបានប្រគល់ឲ្យដើមបណ្ដឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃ ឬ
- ថ្ងៃដែលដើមបណ្ដឹងរដ្ឋប្បវេណីបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលក្រមនេះមិនបានប្រគល់ឲ្យដល់ដើមបណ្ដឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃទេ ។ ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវចាត់ទុកថាបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម ក្នុងករណីដែលនីតិវិធីនៃការឲ្យដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងគន្ថីទី៧ (ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដីកាកោះហៅ និងដីកាជូនដំណឹង) មាតិកាទី៤ (ដីកាឲ្យដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការ) នៃក្រមនេះ ។

បណ្ដឹងទាស់ត្រូវធ្វើជាលាយលក្ខណ៍អក្សរ នៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម ។

ដើមបណ្ដឹងរដ្ឋប្បវេណីអាចត្រូវតំណាងដោយមេធាវី សហព័ទ្ធ ឬញាតិលោហិតផ្ទាល់ ។ អ្នកតំណាងត្រូវមានលិខិតប្រគល់សិទ្ធិឲ្យប្ដឹងទាស់ ។

បទប្បញ្ញត្តិនៃមាត្រានេះ ត្រូវយកទៅអនុវត្តលើបុគ្គលដែលតុលាការប្រកាសថា ត្រូវទទួលខុសត្រូវរដ្ឋប្បវេណីផងដែរ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · ព្រះបរមរាជវាំង

Ksl

## មាត្រា ៣៨២ថ្មី.- រយៈពេលប្ដឹងឧទ្ធរណ៍របស់ពិរុទ្ធជន ដើម្បីបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី

ការប្ដឹងឧទ្ធរណ៍របស់ពិរុទ្ធជន ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីត្រូវតែធ្វើក្នុងរយៈពេល១ (មួយ) ខែ ។

កាលណាសាលក្រមនោះជាសាលក្រមចំពោះមុខ រយៈពេលប្ដឹងឧទ្ធរណ៍ផ្ដើមគិតពីពេលប្រកាសសាលក្រម ។

កាលណាសាលក្រមនោះជាសាលក្រមចាត់ទុកថាចំពោះមុខ រយៈពេលប្ដឹងឧទ្ធរណ៍ផ្ដើមគិតពីពេលទទួលដំណឹងសាលក្រម ទោះបីការឲ្យដំណឹងនេះធ្វើតាមវិធីណាក៏ដោយ ។

កាលណាសាលក្រមនោះជាសាលក្រមកំបាំងមុខ រយៈពេលប្ដឹងឧទ្ធរណ៍ផ្ដើមគិតពីពេលផុតកំណត់ប្ដឹងទាស់ ។

## មាត្រាពីរ.-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៣

នស/រកម.០៦១៣-០០៧

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី
ហត្ថលេខា
សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្ដីគោរពជម្រាបជូនសម្ដេចអគ្គមហាសេនាបតីតេជោ
ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
ហត្ថលេខា
អង្គ វង្ស វឌ្ឍានា

លេខៈ ៥៩៣ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ,ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ២០១៣
អគ្គលេខាធិការរងទីស្ដីការគណៈរដ្ឋមន្ត្រីរាជរដ្ឋាភិបាល
សយ សុខា

# ក្រមនីតិវិធីព្រហ្មទណ្ឌ

## មាតិកាពិស្តារ


គន្ថីទី ១ បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី..........................................១

មាតិកាទី ១ គោលការណ៍ទូទៅ..........................................១

ជំពូកទោល គោលការណ៍ទូទៅ..........................................១

មាត្រា ១.- គោលបំណងនៃក្រមនីតិវិធីព្រហ្មទណ្ឌ..........................................១

មាត្រា ២.- បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី..........................................១

មាតិកាទី ២ បណ្តឹងអាជ្ញា..........................................១

ជំពូកទោល បណ្តឹងអាជ្ញា..........................................១

មាត្រា ៣.- កម្មវត្ថុនៃបណ្តឹងអាជ្ញា..........................................១

មាត្រា ៤.- ការចាប់ផ្តើមដំណើរការនៃបណ្តឹងអាជ្ញាដោយអយ្យការ..........................................២

មាត្រា ៥.- ការដាក់បណ្តឹងអាជ្ញាឱ្យមានចលនាដោយជនរងគ្រោះ..........................................២

មាត្រា ៦.- ការដាក់ពាក្យប្តឹងទាមទារដោយជនរងគ្រោះ..........................................២

មាត្រា ៧.- ការរលត់នៃបណ្តឹងអាជ្ញា..........................................២

មាត្រា ៨.- មូលហេតុផ្សេងទៀតនៃការរលត់បណ្តឹងអាជ្ញា..........................................៣

មាត្រា ៩.-ឧក្រិដ្ឋកម្មដែលគ្មានអាជ្ញាយុកាលកំណត់..........................................៣

មាត្រា ១០.- អាជ្ញាយុកាលនៃបទល្មើស..........................................៣

មាត្រា ១១.-ការផ្អាច់រយៈពេលនៃអាជ្ញាយុកាល..........................................៣

មាត្រា ១២.- អាជ្ញាអស់ជំនុំ..........................................៤

មាតិកាទី ៣ បណ្តឹងរដ្ឋប្បវេណី..........................................៤

ជំពូកទោល បណ្តឹងរដ្ឋប្បវេណី..........................................៤

មាត្រា ១៣.-បណ្តឹងរដ្ឋប្បវេណី និងល្យសនកម្ម..........................................៤

មាត្រា ១៤.- ការផ្សះផ្សាល្យសនកម្ម..........................................៤

មាត្រា ១៥.- ដើមបណ្តឹងរដ្ឋប្បវេណី..........................................៤

មាត្រា ១៦.- បណ្តឹងរដ្ឋប្បវេណីរបស់សិទ្ធិវិន្តនៃជនរងគ្រោះ..........................................៥


ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

1/2404

**មាត្រា ១៧.–** សមាគមប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាខាងផ្លូវភេទ អំពើហិង្សាក្នុងគ្រួសារ ឬ អំពើហិង្សាប្រឆាំងនឹងកុមារ...៥

**មាត្រា ១៨.–** សមាគមប្រយុទ្ធប្រឆាំងនឹងការចាប់ពង្រត់ ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ...៥

**មាត្រា ១៩.–** សមាគមប្រយុទ្ធប្រឆាំងនឹងការប្រកាន់ពូជសាសន៍ និងការរើសអើង...៥

**មាត្រា ២០.–** ភាពដែលអាចទទួលយកបាននូវបណ្តឹងរបស់សមាគម...៦

**មាត្រា ២១.–** ចុងចម្លើយនៃបណ្តឹងរដ្ឋប្បវេណី...៦

**មាត្រា ២២.–** ទំនាក់ទំនងសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌ និងតុលាការរដ្ឋប្បវេណី...៦

**មាត្រា ២៣.–** ការប្រកាសជាមុនអំពីពិរុទ្ធភាព...៧

**មាត្រា ២៤.–** មរណភាពរបស់ជនជាប់ចោទ...៧

**មាត្រា ២៥.–** ការលះបង់ និងការដកពាក្យប្តឹងរបស់ជនរងគ្រោះ...៧

**មាត្រា ២៦.–** អាជ្ញាយុកាលនៃបណ្តឹងរដ្ឋប្បវេណី...៧

**គន្ថីទី ២ អាជ្ញាធរទទួលបន្ទុកចោទប្រកាន់ ស៊ើបសួរ និងស៊ើបអង្កេត**...៨

**មាតិកាទី ១ អង្គការអយ្យការ**...៨

**ជំពូកទី ១ បទប្បញ្ញត្តិទូទៅ**...៨

**មាត្រា ២៧.–** តួនាទីរបស់អង្គការអយ្យការ...៨

**មាត្រា ២៨.–** ចៅក្រមអយ្យការ...៨

**មាត្រា ២៩.–** ឋានានុក្រមនៃអង្គការអយ្យការ...៨

**មាត្រា ៣០.–** បណ្តឹងដោយផ្ទាល់មាត់...៩

**ជំពូកទី ២ មុខការរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល**...៩

**មាត្រា ៣១.–** ការតំណាងនៃអង្គការអយ្យការអមតុលាការកំពូល...៩

**មាត្រា ៣២.–** តួនាទីរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល...៩

**ជំពូកទី ៣ មុខការរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍**...១០

**មាត្រា ៣៣.–** ការតំណាងនៃអង្គការអយ្យការអមសាលាឧទ្ធរណ៍...១០

**មាត្រា ៣៤.–** តួនាទីរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍...១០

**មាត្រា ៣៥.–** អំណាចរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍...១០

ជំពូកទី ៤ មុខការរបស់ព្រះរាជអាជ្ញាអមសាលាដំបូង……………………………………………១១
ផ្នែកទី ១ អង្គការអយ្យការអមសាលាដំបូង………………………………………………………១១
មាត្រា ៣៦.- ការតំណាងអង្គការអយ្យការអមសាលាដំបូង……………………………………១១
មាត្រា ៣៧.- អំណាចរបស់ព្រះរាជអាជ្ញា……………………………………………………………១១
មាត្រា ៣៨.- អំណាចរបស់ព្រះរាជអាជ្ញារង…………………………………………………………១១
មាត្រា ៣៩.- សមត្ថកិច្ចតាមដែនដីរបស់ព្រះរាជអាជ្ញា……………………………………………១២
ផ្នែកទី ២ ការអនុវត្តបណ្តឹងអាជ្ញា………………………………………………………………………១២
មាត្រា ៤០.- ជម្រើសនៃការចោទប្រកាន់…………………………………………………………………១២
មាត្រា ៤១.- ការតម្កល់រឿងទុកឥតចាត់ការ……………………………………………………………១២
មាត្រា ៤២.- កាតព្វកិច្ចធ្វើបណ្តឹងឧទ្ធរណ៍ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម…………………១៣
មាត្រា ៤៣.- ការចោទប្រកាន់…………………………………………………………………………………១៣
មាត្រា ៤៤.- ការបើកការស៊ើបសួរ…………………………………………………………………………១៣
មាត្រា ៤៥.-ការចោទប្រកាន់ក្នុងករណីបទមជ្ឈិម………………………………………………………១៤
មាត្រា ៤៦.- ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់……………………………………………………១៤
មាត្រា ៤៧.- ការបង្ហាញខ្លួនភ្លាម……………………………………………………………………………១៥
មាត្រា ៤៨.- នីតិវិធីនៃការបង្ហាញខ្លួនភ្លាម……………………………………………………………១៥
មាត្រា ៤៩.- ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ក្នុងករណីបទលហុ…………………១៦
មាត្រា ៥០.- បញ្ជីនៃពាក្យប្តឹង…………………………………………………………………………………១៧
មាតិកាទី ២ ចៅក្រមស៊ើបសួរ………………………………………………………………………………………១៧
ជំពូកតោល ចៅក្រមស៊ើបសួរ…………………………………………………………………………………១៧
មាត្រា ៥១.- ការចាត់តាំងដោយប្រធានតុលាការ……………………………………………………………១៧
មាត្រា ៥២.- ការបែងចែកសំណុំរឿងដោយប្រធានតុលាការ…………………………………………១៨
មាត្រា ៥៣.- ការដកហូតសំណុំរឿងពីចៅក្រមស៊ើបសួរ………………………………………………១៨
មាត្រា ៥៤.- ករណីមិនព្រមរៀវចាកដែលនាំឱ្យមោឃភាព……………………………………………១៨
មាតិកាទី ៣ សភាស៊ើបសួរ……………………………………………………………………………………………១៨
ជំពូកតោល សភាស៊ើបសួរ……………………………………………………………………………………………១៨

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *



3/249

**មាត្រា ៥៥.–** សភាពិសេសនៃសាលាឧទ្ធរណ៍..............................១៨
**មាតិកាទី ៤ នគរបាលយុត្តិធម៌**..............................១៩
**ជំពូកទី ១ បទប្បញ្ញត្តិទូទៅ**..............................១៩
**មាត្រា ៥៦.–** បេសកកម្មរបស់នគរបាលយុត្តិធម៌..............................១៩
**មាត្រា ៥៧.–** សមាសភាពរបស់នគរបាលយុត្តិធម៌..............................១៩
**មាត្រា ៥៨.–** ការសម្របសម្រួលសកម្មភាពការងាររបស់នគរបាលយុត្តិធម៌.......១៩
**មាត្រា ៥៩.–** ការត្រួតពិនិត្យលើនគរបាលយុត្តិធម៌..............................២០
**ជំពូកទី ២ មន្ត្រីនគរបាលយុត្តិធម៌**..............................២០
**ផ្នែកទី ១ ការទទួលបាននូវគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌**..............................២០
**មាត្រា ៦០.–** មន្ត្រីនគរបាលយុត្តិធម៌..............................២០
**មាត្រា ៦១.–** សញ្ញាប័ត្រជាន់ខ្ពស់របស់នគរបាលយុត្តិធម៌..............................២២
**មាត្រា ៦២.–** គណៈមេប្រយោគ..............................២៣
**មាត្រា ៦៣.–** សម្បថនៃមន្ត្រីនគរបាលយុត្តិធម៌..............................២៣
**ផ្នែកទី ២ កំហុសប្រព្រឹត្តក្នុងពេលអនុវត្តមុខងារ**..............................២៣
**មាត្រា ៦៤.–** នីតិវិធីខាងវិន័យ..............................២៣
**មាត្រា ៦៥.–** ទណ្ឌកម្មខាងវិន័យ..............................២៤
**មាត្រា ៦៦.–** ការហាមឃាត់មិនឱ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌.......២៤
**ផ្នែកទី ៣ សមត្ថកិច្ចដែនដីរបស់មន្ត្រីនគរបាលយុត្តិធម៌**..............................២៥
**មាត្រា ៦៧.–** មណ្ឌលរដ្ឋបាលបំពេញការងារ..............................២៥
**មាត្រា ៦៨.–** ការពន្លាតសមត្ថកិច្ចដែនដី..............................២៦
**មាត្រា ៦៩.–** កម្មវិបាកនៃការមិនគោរពវិធានសមត្ថកិច្ច..............................២៦
**មាត្រា ៧០.–** សេចក្តីបង្គាប់បញ្ជារបស់អាជ្ញាធរតុលាការ..............................២៦
**ផ្នែកទី ៤ បេសកកម្មនៃមន្ត្រីនគរបាលយុត្តិធម៌**..............................២៦
**មាត្រា ៧១.–** កំណត់ហេតុនៃបទល្មើស..............................២៦
**មាត្រា ៧២.–** កំណត់ហេតុ..............................២៧
**មាត្រា ៧៣.–** បញ្ជីបណ្តឹង..............................២៧

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង



4/240

**មាត្រា ៧៤.–** ចំណាត់ការបន្តពីការដាក់ពាក្យប្តឹង..............................២៨

**មាត្រា ៧៥.–** ការបំពានលើសកម្មភាពតុលាការ..............................២៨

**ជំពូកទី ៣ ភ្នាក់ងារនគរបាលយុត្តិធម៌**..............................២៨

**មាត្រា ៧៦.–** ការទទួលបាននូវគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌.........២៨

**មាត្រា ៧៧.–** សម្បថរបស់ភ្នាក់ងារនគរបាលយុត្តិធម៌..............................២៩

**មាត្រា ៧៨.–** បេសកកម្មរបស់ភ្នាក់ងារនគរបាលយុត្តិធម៌..............................២៩

**មាត្រា ៧៩.–** កំហុសដែលត្រូវបានប្រព្រឹត្តនៅក្នុងពេលបំពេញមុខងារ............២៩

**មាត្រា ៨០.–** ទណ្ឌកម្មខាងវិន័យ..............................៣០

**ជំពូកទី ៤ ការកំណត់សមត្ថកិច្ចរបស់នគរបាលជាតិ និងកងរាជអាវុធហត្ថ**..............៣០

**មាត្រា ៨១.–** ការកំណត់សមត្ថកិច្ច..............................៣០

**ជំពូកទី ៥ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតដែលមាននីតិសម្បទាពិសេសសម្រាប់ពិនិត្យបទល្មើសមួយចំនួន**..............................៣០

**មាត្រា ៨២.–** ការផ្តល់នីតិសម្បទាចំពោះមន្ត្រីរាជការនិងភ្នាក់ងារសាធារណៈដទៃទៀត..៣០

**គន្ថីទី ៣ ការស៊ើបអង្កេត**..............................៣១

**មាតិកាទី ១ បទប្បញ្ញត្តិទូទៅ**..............................៣១

**ជំពូកគោល បទប្បញ្ញត្តិទូទៅ**..............................៣១

**មាត្រា ៨៣.–** ការសម្ងាត់នៃការស៊ើបអង្កេត..............................៣១

**មាត្រា ៨៤.–** ភាពខុសគ្នានៃអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ទៅតាមការស៊ើបអង្កេត.៣២

**មាតិកាទី ២ ការស៊ើបអង្កេតករណីជាក់ស្តែង**..............................៣២

**ជំពូកទី ១ បទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង**..............................៣២

**មាត្រា ៨៥.–** អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ នៅក្នុងករណីស៊ើបអង្កេតបទល្មើសជាក់ស្តែង..............................៣២

**មាត្រា ៨៦.–** និយមន័យបទឧក្រិដ្ឋឬបទមជ្ឈិមជាក់ស្តែង..............................៣២

**មាត្រា ៨៧.–** ការចាប់ខ្លួនក្នុងករណីបទឧក្រិដ្ឋឬបទមជ្ឈិមជាក់ស្តែង............៣៣

**មាត្រា ៨៨.–** ការចាត់ទុកដូចជាបទឧក្រិដ្ឋឬបទមជ្ឈិមជាក់ស្តែង..............៣៣

**ជំពូកទី ២ វិធានការស្រាវជ្រាវ**..............................៣៣

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *



5/240

**មាត្រា ៨៩.-** វិធានការដំបូងក្នុងករណីបទឧក្រិដ្ឋឬបទមជ្ឈិមជាក់ស្តែង............៣៣
**មាត្រា ៩០.-** កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យ........................៣៤
**មាត្រា ៩១.-** ការឆែកឆេរ..........................................................................៣៤
**មាត្រា ៩២.-** ការបិទស្លាកបោះត្រាលើវត្ថុតាង...............................................៣៥
**មាត្រា ៩៣.-** កំណត់ហេតុលើការស្តាប់ចម្លើយ...............................................៣៥
**មាត្រា ៩៤.-** បទបញ្ជាឱ្យចូលខ្លួនក្នុងករណីការស៊ើបអង្កេតបទល្មើសជាក់ស្តែង.....៣៦
**មាត្រា ៩៥.-** ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ........................៣៦
**ជំពូកទី ៣ ការឃាត់ខ្លួន**.................................................................................៣៦
**មាត្រា ៩៦.-** ការឃាត់ខ្លួន..........................................................................៣៦
**មាត្រា ៩៧.-** កំណត់ហេតុស្តីពីការឃាត់ខ្លួន...................................................៣៧
**មាត្រា ៩៨.-** ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន.......................................៣៨
**មាត្រា ៩៩.-** ជំនួយរបស់គ្រូពេទ្យនៅក្នុងពេលឃាត់ខ្លួន.....................................៣៨
**មាត្រា ១០០.-** អនីតិជនដែលត្រូវបានឃាត់ខ្លួន.............................................៣៩
**មាត្រា ១០១.-** បញ្ជីនៃការឃាត់ខ្លួន..............................................................៣៩
**មាត្រា ១០២.-** កំណត់ហេតុសរុបនៃការឃាត់ខ្លួន...........................................៣៩
**ជំពូកទី ៤ ការបញ្ជូនខ្លួន**...............................................................................៤០
**មាត្រា ១០៣.-** ការបញ្ជូនខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន................................៤០
**មាត្រា ១០៤.-** រយៈពេលនៃការបញ្ជូនខ្លួន......................................................៤០
**ជំពូកទី ៥ វិធានទាក់ទងនឹងការស៊ើបអង្កេតករណីជាក់ស្តែង**...........................៤១
**មាត្រា ១០៥.-** ការហាមឃាត់មិនឱ្យស្តាប់ដោយឯកឯងជាអាទិ៍...........................៤១
**មាត្រា ១០៦.-** ថិរវេលានៃការស៊ើបអង្កេតករណីជាក់ស្តែង................................៤១
**មាត្រា ១០៧.-** ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា...................................៤១
**មាត្រា ១០៨.-** និទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ.....................................៤១
**មាត្រា ១០៩.-** មោឃភាពនៃការមិនគោរពវិធានបញ្ញត្តិ.....................................៤១
**មាត្រា ១១០.-** អំណាចធ្វើមូលវិចារណ៍របស់ចៅក្រម.......................................៤៣
**មាតិកាទី ៣ ការស៊ើបអង្កេតបឋម**.....................................................................៤៣

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL



6/240

ជំពូកទោល ការស៊ើបអង្កេតបឋម.......................................................៤៣
មាត្រា ១១១.– ការបើកការស៊ើបអង្កេតបឋម.........................................................៤៣
មាត្រា ១១២.– វិធានដែលអនុវត្តចំពោះការស៊ើបអង្កេតបឋម.......................................៤៣
មាត្រា ១១៣.– ការឆែកឆេរ.................................................................................៤៤
មាត្រា ១១៤.– ការបញ្ជាឱ្យចូលខ្លួន ការស៊ើបអង្កេតបឋម.........................................៤៤
មាត្រា ១១៥.– កំណត់ហេតុស្រង់ចម្លើយ ការស៊ើបអង្កេតបឋម.....................................៤៥
មាត្រា ១១៦.– ការឃាត់ខ្លួនជនជាប់សង្ស័យ...........................................................៤៥
មាត្រា ១១៧.– មោឃភាពនៃការមិនគោរពវិធានបញ្ញត្តិ..............................................៤៥
មាត្រា ១១៨.– អំណាចផ្ញើមូលវិចារណ៍របស់ចៅក្រម................................................៤៥
មាតិកាទី ៤ ការប្រគល់ឱ្យម្ចាស់ដើមវិញនូវវត្ថុដែលចាប់យកក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេត..៤៦
ជំពូកទោល ការប្រគល់ឱ្យម្ចាស់ដើមវិញនូវវត្ថុដែលចាប់យកក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេត.៤៦
មាត្រា ១១៩.– អាជ្ញាធរមានសមត្ថកិច្ចបង្គាប់ឱ្យប្រគល់វត្ថុជូនម្ចាស់ដើមវិញ..........៤៦
មាត្រា ១២០.– ការប្រគល់វត្ថុដែលរឹបអូសជូនម្ចាស់ដើមវិញ.......................................៤៦
គន្ថីទី ៤ ការស៊ើបសួរ.......................................................................................៤៧
មាតិកាទី ១ ចៅក្រមស៊ើបសួរ.............................................................................៤៧
ជំពូកទី ១ បទប្បញ្ញត្តិទូទៅ...............................................................................៤៧
មាត្រា ១២១.– ការសម្ងាត់នៃការស៊ើបសួរ..............................................................៤៧
មាត្រា ១២២.– ការបើកការស៊ើបសួរ......................................................................៤៧
មាត្រា ១២៣.– សមត្ថកិច្ចដែនដី............................................................................៤៧
មាត្រា ១២៤.– ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ.................................................៤៨
មាត្រា ១២៥.– វិសាលភាពនៃការប្ដឹង.....................................................................៤៨
មាត្រា ១២៦.– ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ...................................................៤៩
មាត្រា ១២៧.– ការស៊ើបសួរដាក់បន្ទុកនិងដោះបន្ទុក.................................................៤៩
មាត្រា ១២៨.– ជំនួយរបស់ក្រឡាបញ្ជី.....................................................................៤៩
មាត្រា ១២៩.– មុខងាររបស់ក្រឡាបញ្ជី...................................................................៤៩
មាត្រា ១៣០.– ការចុះដល់ទីកន្លែងដោយចៅក្រមស៊ើបសួរនិងក្រឡាបញ្ជី.........៥០

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

**មាត្រា ១៣១.-** ដីកាចាត់ឱ្យស៊ើបសួរជំនួស................................៥០

**មាត្រា ១៣២.-** ការស្នើសុំឱ្យបំពេញកិច្ចដោយព្រះរាជអាជ្ញា........................៥០

**មាត្រា ១៣៣.-** ការស្នើសុំឱ្យបំពេញកិច្ចដោយជនត្រូវចោទ........................៥១

**មាត្រា ១៣៤.-** ការស្នើសុំឱ្យបំពេញកិច្ចដោយដើមបណ្តឹងរដ្ឋប្បវេណី..............៥១

**មាត្រា ១៣៥.-** ការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា..............................៥១

**មាត្រា ១៣៦.-** វត្តមានរបស់ព្រះរាជអាជ្ញាចំពោះកិច្ចស៊ើបសួរ......................៥២

**មាត្រា ១៣៧.-** ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍..........៥២

**មាត្រា ១៣៨.-** បណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី...........៥២

**មាត្រា ១៣៩.-** ការបញ្ជូនបណ្តឹងទៅព្រះរាជអាជ្ញា..................................៥២

**មាត្រា ១៤០.-** ការបង់ប្រាក់តម្កល់ទុក...............................................៥៣

**មាត្រា ១៤១.-** បណ្តឹងដោយបំពាន ឬ បណ្តឹងដោយអូសបន្លាយពេលវេលា.......៥៣

**មាត្រា ១៤២.-** បណ្តឹងឱ្យជួសជុលការខូចខាត.......................................៥៤

**ជំពូកទី ២ ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ**........................................៥៤

**ផ្នែកទី ១ ការជូនដំណឹងអំពីការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ**........................៥៤

**មាត្រា ១៤៣.-** ការជូនដំណឹងអំពីការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ.............៥៤

**មាត្រា ១៤៤.-** ជំនួយរបស់អ្នកបកប្រែ................................................៥៥

**ផ្នែកទី ២ ការសួរចម្លើយជនត្រូវចោទ**...............................................៥៥

**មាត្រា ១៤៥.-** វត្តមានរបស់មេធាវីក្នុងពេលសួរចម្លើយ............................៥៥

**មាត្រា ១៤៦.-** សំណួរដោយមានការអនុញ្ញាតរបស់ចៅក្រមស៊ើបសួរ..............៥៦

**មាត្រា ១៤៧.-** ការពិភាក្សាដេញដោល...............................................៥៦

**មាត្រា ១៤៨.-** រយៈពេលអប្បបរមាសម្រាប់ការសួរចម្លើយ.........................៥៦

**មាត្រា ១៤៩.-** សិទ្ធិការពារខ្លួនរបស់ជនត្រូវចោទ..................................៥៦

**ផ្នែកទី ៣ ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី**.....................................៥៧

**មាត្រា ១៥០.-** ការស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី.......................៥៧

**មាត្រា ១៥១.-** សំណួរដោយមានការអនុញ្ញាតរបស់ចៅក្រមស៊ើបសួរ.............៥៧

**មាត្រា ១៥២.-** ការពិភាក្សាដេញដោល ឬ ការសួរតទល់............................៥៨


ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL



8/240

**ផ្នែកទី ៤ ការស្តាប់ចម្លើយសាក្សី**..................................................៥៨
**មាត្រា ១៥៣.-** ការស្តាប់ចម្លើយសាក្សី..................................................៥៨
**មាត្រា ១៥៤.-** សម្បថរបស់សាក្សី..................................................៥៨
**មាត្រា ១៥៥.-** ជំនួយរបស់អ្នកបកប្រែ..................................................៥៨
**មាត្រា ១៥៦.-** សាក្សីដែលអនុញ្ញាតឱ្យរួចពីសម្បថ..................................................៥៩
**មាត្រា ១៥៧.-** ភាពគ្មានលទ្ធភាពស្តាប់ចម្លើយរបស់សាក្សីមួយចំនួន..............៥៩
**មាត្រា ១៥៨.-** ការចុះទៅដល់លំនៅឋានរបស់សាក្សី..................................................៥៩
**ផ្នែកទី ៥ ការឆែកឆេរនិងការចាប់យកវត្ថុតាង**..................................................៥៩
**មាត្រា ១៥៩.-** វិធានអនុវត្តចំពោះការឆែកឆេរ..................................................៥៩
**មាត្រា ១៦០.-** ការបិទស្លាកបោះត្រាលើវត្ថុតាង..................................................៦០
**មាត្រា ១៦១.-** ការប្រគល់វត្ថុដែលចាប់យកឱ្យទៅម្ចាស់ដើមវិញដោយចៅក្រមស៊ើបសួរ..៦០
**ផ្នែកទី ៦ កោសលវិច័យ**..................................................៦១
**មាត្រា ១៦២.-** ភាពចាំបាច់នៃការធ្វើកោសលវិច័យ..................................................៦១
**មាត្រា ១៦៣.-** បញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ..................................................៦១
**មាត្រា ១៦៤.-** ការចាត់តាំងអ្នកជំនាញដែលមិនស្ថិតក្នុងបញ្ជីថ្នាក់ជាតិ............៦១
**មាត្រា ១៦៥.-** ដីកាចាត់តាំងអ្នកជំនាញ..................................................៦២
**មាត្រា ១៦៦.-** ការត្រួតពិនិត្យបេសកកម្មរបស់អ្នកជំនាញដោយចៅក្រមស៊ើបសួរ.៦២
**មាត្រា ១៦៧.-** កិច្ចដែលចាំបាច់សម្រាប់ការបំពេញបេសកកម្មរបស់អ្នកជំនាញ....៦២
**មាត្រា ១៦៨.-** របាយការណ៍របស់អ្នកជំនាញ..................................................៦៣
**មាត្រា ១៦៩.-** ការចាត់តាំងអ្នកជំនាញច្រើនរូប..................................................៦៣
**មាត្រា ១៧០.-** ការជូនដំណឹងអំពីសេចក្តីសន្និដ្ឋាននៃកោសលវិច័យ..............៦៣
**មាត្រា ១៧១.-** សោហ៊ុយសម្រាប់ធ្វើកោសលវិច័យ..................................................៦៤
**ផ្នែកទី ៧ ការស្តាប់ទូរស័ព្ទ**..................................................៦៥
**មាត្រា ១៧២.-** ការស្តាប់ទូរស័ព្ទជាអាទិ៍ដែលបង្គាប់ដោយចៅក្រមស៊ើបសួរ........៦៥
**ផ្នែកទី ៨ ដីកាចាត់ឱ្យស៊ើបសួរជំនួស**..................................................៦៥
**មាត្រា ១៧៣.-** ដីកាចាត់ឱ្យស៊ើបសួរជំនួស..................................................៦៥

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង



9/240

**មាត្រា ១៧៤.–** អត្ថន័យនៃដីកាចាត់ឱ្យស៊ើបសួរជំនួស........................៦៦
**មាត្រា ១៧៥.–** ដីកាចាត់ឱ្យស៊ើបសួរជំនួសដែលចេញឱ្យចៅក្រមម្នាក់ទៀត.........៦៦
**មាត្រា ១៧៦.–** ដីកាចាត់ឱ្យស៊ើបសួរជំនួសចេញឱ្យមន្ត្រីនគរបាលយុត្តិធម៌.........៦៦
**មាត្រា ១៧៧.–** ការប្រតិបត្តិដីកាចាត់ឱ្យស៊ើបសួរជំនួសដោយមន្ត្រីនគរបាលយុត្តិធម៌..៦៦
**មាត្រា ១៧៨.–** កំណត់ហេតុស្ដីពីការស្រាវជ្រាវ និងការពិនិត្យ.......................៦៦
**មាត្រា ១៧៩.–** វិធានទាក់ទងនឹងការស្ដាប់ចម្លើយដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌..........................................................៦៧
**មាត្រា ១៨០.–** ការស្ដាប់ចម្លើយដែលពុំអាចធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌..៦៧
**មាត្រា ១៨១.–** ការឆែកឆេរ និងការចាប់យកដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌..៦៧
**មាត្រា ១៨២.–** ការឃាត់ខ្លួននៅក្នុងក្របខ័ណ្ឌនៃដីកាចាត់ឱ្យស៊ើបសួរជំនួស.......៦៨
**មាត្រា ១៨៣.–** ការស្ដាប់ទូរស័ព្ទជាអាទិ៍នៅក្នុងក្របខ័ណ្ឌនៃដីកាចាត់ឱ្យស៊ើបសួរជំនួស..៦៨
**មាត្រា ១៨៤.–** កំណត់ហេតុកសាងដោយមន្ត្រីនគរបាលយុត្តិធម៌..................៦៨
**ជំពូកទី ៣ វិធានការនីតិវិធីរាយ**..................................................៦៨
**ផ្នែកទី ១ ដីកា**...................................................................៦៨
**មាត្រា ១៨៥.–** ការចេញដីកា..........................................................៦៨
**ផ្នែកទី ២ ដីកាបង្គាប់ឱ្យចូលខ្លួន**.............................................៦៩
**មាត្រា ១៨៦.–** ដីកាបង្គាប់ឱ្យចូលខ្លួន...............................................៦៩
**មាត្រា ១៨៧.–** និទ្ទេសដែលត្រូវចុះលើដីកាបង្គាប់ឱ្យចូលខ្លួន.......................៦៩
**មាត្រា ១៨៨.–** ការជូនដំណឹងអំពីដីកាបង្គាប់ឱ្យចូលខ្លួន..........................៦៩
**ផ្នែកទី ៣ ដីកាបង្គាប់ឱ្យនាំខ្លួន**..............................................៧០
**មាត្រា ១៨៩.–** ការចេញដីកាបង្គាប់ឱ្យនាំខ្លួនដោយចៅក្រមស៊ើបសួរ..............៧០
**មាត្រា ១៩០.–** ដីកាបង្គាប់ឱ្យនាំខ្លួន.................................................៧០
**មាត្រា ១៩១.–** និទ្ទេសដែលត្រូវចុះលើដីកាបង្គាប់ឱ្យនាំខ្លួន.........................៧០
**មាត្រា ១៩២.–** ការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន.....................................៧០
**មាត្រា ១៩៣.–** ការបង្ហាញខ្លួនតាមដីកាបង្គាប់ឱ្យនាំខ្លួន............................៧១
**មាត្រា ១៩៤.–** ការគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន...............៧១

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង



10/240 W

**ផ្នែកទី ៤ ដីកាបង្គាប់ឱ្យចាប់ខ្លួន**.....................................................៧១
**មាត្រា ១៩៥.-** ការចេញដីកាបង្គាប់ឱ្យចាប់ខ្លួនដោយចៅក្រមស៊ើបសួរ............៧១
**មាត្រា ១៩៦.-** ដីកាបង្គាប់ឱ្យចាប់ខ្លួន...........................................៧១
**មាត្រា ១៩៧.-** ដីកាបង្គាប់ឱ្យចាប់ខ្លួន និងយោបល់របស់ព្រះរាជអាជ្ញា............៧២
**មាត្រា ១៩៨.-** និទ្ទេសដែលត្រូវចុះលើដីកាបង្គាប់ឱ្យចាប់ខ្លួន......................៧២
**មាត្រា ១៩៩.-** ការអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួន...................................៧២
**មាត្រា ២០០.-** ការផ្សព្វផ្សាយជាអន្តរជាតិនូវដីកាបង្គាប់ឱ្យចាប់ខ្លួន...............៧២
**មាត្រា ២០១.-** ការបង្ហាញខ្លួនតាមដីកាបង្គាប់ឱ្យចាប់ខ្លួន.........................៧៣
**មាត្រា ២០២.-** ការគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន.............៧៣
**ផ្នែកទី ៥ ការឃុំខ្លួនបណ្ដោះអាសន្ន**...............................................៧៣
**មាត្រា ២០៣.-** គោលការណ៍នៃការឃុំខ្លួនបណ្ដោះអាសន្ន.........................៧៣
**មាត្រា ២០៤.-** ករណីនៃការឃុំខ្លួនបណ្ដោះអាសន្ន...............................៧៣
**មាត្រា ២០៥.-** មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន...........................៧៤
**មាត្រា ២០៦.-** កំណត់សម្គាល់របស់ជនត្រូវចោទ និងការប្រាប់ហេតុផលនៃដីកា..៧៤
**មាត្រា ២០៧.-** ដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន..........................៧៤
**មាត្រា ២០៨.-** ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋ...............៧៥
**មាត្រា ២០៩.-** ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទមជ្ឈិម...............៧៥
**មាត្រា ២១០.-** ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ននៅក្នុងករណីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិជាអាទិ៍..........................................៧៥
**មាត្រា ២១១.-** ការពន្យាពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន.........................៧៦
**មាត្រា ២១២.-** សេចក្ដីសម្រេចទាក់ទងនឹងអនីតិជនមានអាយុតិចជាង ១៤ (ដប់បួន) ឆ្នាំ..........................................................៧៦
**មាត្រា ២១៣.-** ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋទាក់ទងនឹងអនីតិជនមានអាយុចាប់ពី ១៤(ដប់បួន)ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី)ឆ្នាំ...៧៦
**មាត្រា ២១៤.-** ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទមជ្ឈិមទាក់ទងនឹងអនីតិជនមានអាយុចាប់ពី ១៤(ដប់បួន)ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី)ឆ្នាំ..៧៦

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

។



11/240

**មាត្រា ២១៥.–** ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំដោយចៅក្រមស៊ើបសួរ...៧៧
**មាត្រា ២១៦.–** ការដោះលែងឱ្យនៅក្រៅឃុំតាមបណ្ដឹងរបស់ព្រះរាជអាជ្ញា.........៧៧
**មាត្រា ២១៧.–** ការដោះលែងឱ្យនៅក្រៅឃុំតាមបណ្ដឹងរបស់ជនត្រូវចោទ..........៧៧
**មាត្រា ២១៨.–** ការជូនដំណឹងអំពីដីកាដោះលែងឱ្យនៅក្រៅឃុំ......................៧៨
**ផ្នែកទី ៦ ដីកាបង្គាប់ឱ្យឃុំខ្លួន**..................................................៧៨
**មាត្រា ២១៩.–** ការចេញដីកាបង្គាប់ឱ្យឃុំខ្លួនដោយចៅក្រមស៊ើបសួរ..............៧៨
**មាត្រា ២២០.–** និយមន័យដីកាបង្គាប់ឱ្យឃុំខ្លួន........................................៧៨
**មាត្រា ២២១.–** និទ្ទេសដែលត្រូវចុះលើដីកាបង្គាប់ឱ្យឃុំខ្លួន.........................៧៩
**មាត្រា ២២២.–** ការអនុវត្តដីកាបង្គាប់ឱ្យឃុំខ្លួន.........................................៧៩
**ផ្នែកទី ៧ ការត្រួតពិនិត្យតាមផ្លូវតុលាការ**...........................................៧៩
**មាត្រា ២២៣.–** កាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ..........................៧៩
**មាត្រា ២២៤.–** ការមិនអនុវត្តការត្រួតពិនិត្យតាមផ្លូវតុលាការ ចំពោះអនីតិជនមាន អាយុក្រោម ១៤(ដប់បួន)ឆ្នាំ..................................៨០
**មាត្រា ២២៥.–** ការប្រគល់បង្កាន់ដៃ..................................................៨០
**មាត្រា ២២៦.–** ដីកាបង្គាប់ឱ្យដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ..........៨១
**មាត្រា ២២៧.–** ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយឯកឯងដោយចៅក្រម ស៊ើបសួរ..........................................................៨១
**មាត្រា ២២៨.–** បណ្ដឹងសុំកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយព្រះរាជអាជ្ញា...៨១
**មាត្រា ២២៩.–** បណ្ដឹងសុំកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយជនត្រូវចោទ..៨២
**មាត្រា ២៣០.–** ការគេចវេះរបស់ជនត្រូវចោទពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវ តុលាការ.........................................................៨២
**ជំពូកទី ៤ ការកោះហៅ និងការជូនដំណឹង**.............................................៨៣
**ផ្នែកទី ១ បទប្បញ្ញត្តិទូទៅ**...........................................................៨៣
**មាត្រា ២៣១.–** រយៈពេលរួម..........................................................៨៣
**មាត្រា ២៣២.–** របៀបកោះហៅ........................................................៨៣
**មាត្រា ២៣៣.–** ការកោះហៅជនត្រូវចោទដែលត្រូវបានឃុំខ្លួន.........................៨៤

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

12/249

**មាត្រា ២៣៤.-** ការកោះហៅមេធាវី..................................................៨៤

**មាត្រា ២៣៥.-** និទ្ទេសនៃការកោះហៅនៅក្នុងសំណុំរឿង..........................៨៤

**មាត្រា ២៣៦.-** ការជូនដំណឹងអំពីដីកាសម្រេចដល់មេធាវី..........................៨៤

**មាត្រា ២៣៧.-** ការជូនដំណឹងអំពីដីកាសម្រេចដល់ព្រះរាជអាជ្ញា....................៨៤

**មាត្រា ២៣៨.-** ការជូនដំណឹងអំពីដីកាសម្រេចដល់ជនត្រូវចោទ......................៨៤

**មាត្រា ២៣៩.-** ការប្រគល់ដីកាកោះហៅ ឬ ដីកាផ្សេងៗទៀត........................៨៥

**ផ្នែកទី ២ វិធានដោយឡែក**........................................................៨៥

**មាត្រា ២៤០.-** និទ្ទេសដែលត្រូវចុះជាកាតព្វកិច្ចនៅក្នុងកំណត់ហេតុរបស់ចៅក្រមស៊ើបសួរ..................................................៨៥

**មាត្រា ២៤១.-** ហត្ថលេខាលើកំណត់ហេតុនៃការចូលខ្លួនជាលើកដំបូង............៨៦

